ជីវិតថ្លៃថ្នូរ
LIFE WITH DIGNITY

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
*The NGO Forum on Cambodia*
ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង
*Working Together for Positive Change*

# ការសិក្សាស្តីពីវិវាទដីធ្លីនៅក្នុងខេត្តចំនួន ៤ នៃ ប្រទេសកម្ពុជា៖ ការដៅលើផែនទី ផលប៉ះពាល់ និង ដំណោះស្រាយដែលអាចធ្វើទៅបាន









ភ្នំពេញ ប្រទេសកម្ពុជា
ខែវិច្ឆិកា ឆ្នាំ ២០១៥

**ការសិក្សាស្តីពីវិវាទដីធ្លីនៅក្នុងខេត្តចំនួន ៤ នៃប្រទេសកម្ពុជា៖**
**ការផ្តោតលើផែនទី ផលប៉ះពាល់ និងដំណោះស្រាយដែលអាចធ្វើទៅបាន**

កាលបរិច្ឆេទបោះពុម្ពផ្សាយ៖ ខែវិច្ឆិកា ឆ្នាំ ២០១៥
បោះពុម្ពផ្សាយដោយ៖ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
គម្រោងសុវត្ថិភាពដីធ្លី

ស្រាវជ្រាវដោយ៖ ហ៊ាន សុខុម

**សេចក្តីបញ្ជាក់៖**
ទស្សនៈបង្ហាញក្នុងរបាយការណ៍នេះសុទ្ធតែជាទស្សនៈរបស់អ្នកនិពន្ធ ហើយមិនបង្ហាញពីទស្សនៈរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាទេ។ នៅពេលខ្លឹមសារនៃរបាយការណ៍នេះត្រូវគេដកស្រង់ ឬផលិតសារជាថ្មី ការទទួលស្គាល់ និងការសុំអនុញ្ញាតសិទ្ធិរបស់អ្នកនិពន្ធ និងអ្នកបោះពុម្ពផ្សាយនឹងត្រូវគេអោយតម្លៃ។

© **វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា, ខែវិច្ឆិកា ឆ្នាំ ២០១៥**

# មាតិកា


**សេចក្ដីសង្ខេប**........................................................................................iii
**សេចក្ដីថ្លែងអំណរគុណ**..............................................................................ix
**ពាក្យកាត់** ......................................................................................................x
**១.សេចក្ដីផ្ដើម**............................................................................................ ១
១.១ សាវតារ.................................................................................................. ១
១.២ លំនាំបញ្ហា ............................................................................................. ២
១.៣ គោលដៅ និងគោលបំណង........................................................................... ៣
១.៤ សំណួរសម្រាប់ការវាយតម្លៃ........................................................................... ៤
**២. វិធីសាស្ត្រក្នុងការជ្រើសរើសសំណាកគំរូ** ...................................................... ៤
២.១ វិធីជ្រើសរើសសំណាកគំរូទីតាំងស្រាវជ្រាវ ....................................................... ៥
២.២ វិធីជ្រើសរើសសំណាកគំរូ ............................................................................ ៥
២.៣ វិធីសាស្ត្រប្រមូលទិន្នន័យ............................................................................ ៨
២.៣.១ វិធីសាស្ត្រប្រមូលទិន្នន័យបឋមតាមបែបគុណវិស័យ ....................................... ៨
២.៣.២ វិធីសាស្ត្រប្រមូលទិន្នន័យបឋមតាមបែបបរិមាណវិស័យ ................................... ៨
២.៣.៣ វិធីសាស្ត្រប្រមូលទិន្នន័យដែលមានស្រាប់តាមបែបបរិមាណវិស័យនិងគុណវិស័យ.. ៩
២.៤ វិធីសាស្ត្រវិភាគទិន្នន័យ............................................................................... ៩
២.៤.១ វិធីសាស្ត្រវិភាគទិន្នន័យតាមបែបគុណវិស័យ................................................ ៩
២.៤.២ វិធីសាស្ត្រវិភាគទិន្នន័យតាមបែបបរិមាណវិស័យ ........................................... ៩
**៣. ពិនិត្យឯកសារដែលមានស្រាប់ឡើងវិញ** ......................................................... ១៧
៣.១ ប្រវត្តិនៃកម្មសិទ្ធិដីធ្លីនៅកម្ពុជា..................................................................... ១៧
៣.២ ក្របខ័ណ្ឌច្បាប់ស្ដីពីដីធ្លី ............................................................................. ១៧
៣.៣ បញ្ហាវិវាទដីធ្លី............................................................................................ ២១
៣.៤ យន្តការដោះស្រាយវិវាទដីធ្លី......................................................................... ២៣
៣.៥ ផលប៉ះពាល់................................................................................................ ២៩
**៤. ប្រជាសាស្ត្រ** ............................................................................................... ៣២
**៥. ទីតាំងភូមិសាស្ត្រ និងស្ថានភាពសង្គម** ............................................................ ៣៣
**៦. ស្ថានភាពដីធ្លីនៅក្នុងខេត្តដែលបានសិក្សា**........................................................ ៣៥
**៧. ដើមហេតុចំបងនៃវិវាទ**................................................................................ ៣៩
៧.១ ការយល់ដឹងពីរខុសគ្នាអំពីតថភាពតែមួយ៖ ការទាមទារដីអនុលោមតាមច្បាប់ភូមិបាល ឆ្នាំ២០០១ ជំទាស់នឹងទម្លាប់ជាប្រពៃណីទាក់ទងនឹងការកាន់កាប់ដីធ្លី.............................. ៣៩
៧.២ សេចក្ដីសម្រេចរបស់ស្ថាប័នកម្រិតផ្សេងៗមិនស៊ីសង្វាក់គ្នា .................................. ៤៤
៧.៣ ដំណើរការយឺតនៃការចុះបញ្ជីដីធ្លី ប៉ុន្តែសម្បទានដីមានល្បឿនលឿន........................ ៤៦
**៨. យុទ្ធសាស្ត្រយកដី/កាន់កាប់ដី** ....................................................................... ៤៨
៨.១ យុទ្ធសាស្ត្ររបស់ក្រុមហ៊ុន ............................................................................. ៤៨
៨.២ យុទ្ធសាស្ត្ររបស់អ្នកភូមិ ............................................................................... ៥០

**៩. ដំណើរការដោះស្រាយដីធ្លី** ....................................................... ៥១
៩.១ យន្តការដោះស្រាយវិវាទដីធ្លី ....................................................... ៥១
៩.២ សកម្មភាពរបស់អ្នកភូមិ ....................................................... ៥៥
៩.៣ កិច្ចចរចា ....................................................... ៦០
៩.៤ កិច្ចសម្រុះសម្រួល ....................................................... ៦១
**១០. មូលហេតុ និងបរាជ័យក្នុងការដោះស្រាយវិវាទ** ....................................................... ៦៦
**១១. យេនឌ័រ និង ទិដ្ឋភាពនៃកម្មសិទ្ធិដីធ្លី** ....................................................... ៧២
**១២. ផលប៉ះពាល់វិវាទដីធ្លី** ....................................................... ៨០
**១៣. សេចក្តីសន្និដ្ឋាន** ....................................................... ៨៨
**១៤. ការស្នើសុំឲ្យមានដំណោះស្រាយបានប្រសើរ តាមទស្សនៈសហគមន៍** ....................................................... ៩១
**ឯកសារយោង** ....................................................... ៩៤
**ឧបសម្ព័ន្ធ** ....................................................... ៩៩
ឧបសម្ព័ន្ធ១: បញ្ជីសំណួរ ....................................................... ៩៩
ឧបសម្ព័ន្ធ២: គោលការណ៍ណែនាំ ....................................................... ១២៥

## បញ្ជីតារាង

តារាងទី១: តំបន់គោលដៅរបស់អង្គការ LWD នៅក្នុង៤ខេត្តដែលបានជ្រើសសម្រាប់ការស្រាវជ្រាវ ...៦
តារាងទី២: សំណាកគំរូភូមិ ....................................................... ៦
តារាងទី៣: ទិន្នន័យមួយចំនួនស្តីពីសម្បទានដី ....................................................... ១៩
តារាងទី៤ : អ្នកផ្តល់ចម្លើយតាមភេទ និងកម្រិតវប្បធម៌ ....................................................... ៣២
តារាងទី៥: ចំណូលនិងចំណាយ ....................................................... ៣៣
តារាងទី៦: សម្បទានដីសេដ្ឋកិច្ចនៅក្នុងខេត្តទាំងបួន (ប្រភពរបស់អង្គការលីកាដូ) ....................................................... ៤០
តារាងទី៧: ស្ថានភាពវិវាទដីធ្លីទាក់ទងនឹងឯកសារបញ្ជាក់ (%) ....................................................... ៤៧
តារាងទី៨: របៀបដែលភាគីទីពីរទាមទារដីវិវាទ ....................................................... ៤៨
តារាងទី៩: ជំហាននានានៃបណ្តឹងតវ៉ារបស់អ្នកភូមិ ....................................................... ៥៨
តារាងទី១០: យេនឌ័រនៅក្នុងកម្មសិទ្ធិដីធ្លី ទី១ (ចំនួនក្បាលដី) ....................................................... ៧៧
តារាងទី១១: យេនឌ័រនៅក្នុងកម្មសិទ្ធិដីធ្លី ទី២ (ទំហំដី) ....................................................... ៧៧
តារាងទី១២: ផលប៉ះពាល់នៃវិវាទដីធ្លីមកលើកិច្ចការរបស់ស្ត្រីនៅក្នុងគ្រួសារនិងសហគមន៍ ....................................................... ៧៨
តារាងទី១៣: ផលប៉ះពាល់មកពីការបាត់បង់ដីធ្លី ....................................................... ៨៣

## បញ្ជីរូបភាព

រូបទី១: ស្ថានភាពដីធ្លីរបស់ប្រជាពលរដ្ឋ ....................................................... ៣៦
រូបទី២: ស្ថានភាពនៃប្រជាពលរដ្ឋដែលបានសិក្សាទាក់ទងនឹងវិវាទដីធ្លី ....................................................... ៣៨
រូបទី៣: មូលហេតុបង្កវិវាទ ....................................................... ៤១
រូបទី៤: ផែនការដោះស្រាយវិវាទនៅពេលខាងមុខ ....................................................... ៦៧
រូបទី៥: ចាប់ពីពេលចាប់ផ្តើមមានវិវាទ តើអ្នកភូមិអាចដាំដំណាំលើដីវិវាទបានឬទេ? ....................................................... ៨១
រូបទី៦: ប្រាក់ចំណូលប្រែប្រួល ក្រោយពេលចាប់ផ្តើមវិវាទ ....................................................... ៨២

# សេចក្តីសង្ខេប


ដើម្បីរួមចំណែកដំណោះស្រាយវិវាទដីធ្លី អង្គការជីវិតថ្លៃថ្នូរ (LWD) និងអង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF) បានធ្វើការសិក្សាមួយស្តីពីវិវាទដីធ្លី នៅក្នុងតំបន់ប្រតិបត្តិ ដែលបានជ្រើសរើស របស់អង្គការជីវិតថ្លៃថ្នូរ ដើម្បីស្វែងយល់ឲ្យបានស៊ីជម្រៅអំពីក្របខណ្ឌច្បាប់ និងបទបញ្ញត្តិនានាដែលមានទាក់ទងនឹងសិទ្ធិកាន់កាប់ដីធ្លី ការទទួលបានដីធ្លី និងដំណោះស្រាយវិវាទដីធ្លី ជាពិសេសនៅទីជនបទ។

ការសិក្សាត្រូវបានធ្វើឡើងនៅក្នុង ១១ឃុំ និង២៦ភូមិ ដែលត្រូវបានជ្រើសរើសចេញពី ២៣ឃុំ និង៨៥ភូមិ ដែលជាតំបន់គោលដៅរបស់អង្គការជីវិតថ្លៃថ្នូរ។ សំណាកគ្រួសារសរុបក្នុងភូមិទាំងអស់មានចំនួន ៣៨២គ្រួសារ ដោយប្រើវិធីជ្រើសរើសសំណាកងាយ និងដោយចៃដន្យ (Simple Random Sample) និងសមាមាត្រតាមទំហំដែលយកចេញពីបញ្ជីគ្រួសាររងគ្រោះ។ ការសិក្សានេះក៏មានការសម្ភាសន៍អ្នកផ្តល់ចម្លើយសំខាន់ៗមិនរៀបរយព្រមទាំងការពិភាក្សាក្រុមគោលដៅ។ លទ្ធផលរកឃើញពីការសិក្សាសំខាន់មានដូចខាងក្រោម៖

- អ្នកផ្តល់ចម្លើយទាំងអស់សុទ្ធតែជាកសិករខ្មែរក្រីក្រ ហើយ ៦៧% នៃអ្នកទាំងនោះចាប់ផ្តើមរស់នៅក្នុងភូមិមុនឆ្នាំ២០០១។ ភាគច្រើននៃអ្នកផ្តល់ចម្លើយមានកម្រិតវប្បធម៌ទាប៖ ៧១.៦%នៃអ្នកផ្តល់ចម្លើយជាបុរស និង ៨៧.២%នៃអ្នកផ្តល់ចម្លើយជាស្ត្រី មិនដែលចូលសាលារៀន ឬមិនបានបញ្ចប់កម្រិតបឋមសិក្សាឡើយ។

- វិវាទភាគច្រើនកើតឡើងទាក់ទងនឹងដីកសិកម្ម ឬដីព្រៃដែលបានកាន់កាប់ដោយអ្នកភូមិ និង ដីព្រៃសហគមន៍របស់ពួកគេ។

- ក្នុងបណ្តាភូមិសំណាកទាំង២៦ យើងសង្កេតឃើញមានករណីវិវាទដីធ្លីចំនួន ២៨រវាងអ្នកភូមិ និងភាគីទីពីរ។ នៅខេត្តកំពង់ស្ពឺ ពោធិ៍សាត់ និងកំពង់ឆ្នាំង ភាគីទីពីរជាក្រុមហ៊ុនឯកជន(៦៥.២%) និងរដ្ឋ(៧.៦%) ត្រូវបានបញ្ជាក់ថាជាភាគីទីពីរ ចំណែកនៅខេត្តបាត់ដំបង ភាគីទីពីរជាប្រជាពលរដ្ឋមកពីភូមិផ្សេងទៀត (១៨.៨%) និងឈ្មួញ(៤.២%)។

- ច្រើនជាង៤០% នៃប្រជាពលរដ្ឋដែលបានសិក្សាបានរាយការណ៍ថា ពួកគាត់មានក្បាលដីស្រែ ឬដីព្រៃដែលកំពុងមានវិវាទ ចំណែកឯ ១០.២% និង១២.៨% នៃអ្នកផ្តល់ចម្លើយបានប្រាប់ថា ដីចំការ និងដីព្រៃសហគមន៍របស់ពួកគាត់កំពុងមានវិវាទ ។

- វិវាទចំនួន ១៩ក្នុងចំណោមវិវាទដីធ្លីចំនួន ២៨នៅក្នុងភូមិសំណាកនៃខេត្តទាំងបួនដែលបានសិក្សាត្រូវបានដោះស្រាយរួចហើយ តាមរយៈការទទួលយកសំណងមិនសមរម្យ និងវិវាទដីធ្លីចំនួន៩ទៀត មិនទាន់មានដំណោះស្រាយនៅឡើយ។
- ដើមហេតុចម្បងចំនួន បី ដែលបណ្តាលឲ្យមានវិវាទដីធ្លីគឺៈ ការទាមទារដីដោយយោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ ដែលផ្ទុយទៅនឹង វិធានច្បាប់តាមបែបប្រពៃណីនៃការកាន់កាប់ដីភាពមិនស៊ីសង្វាក់នៃការធ្វើសេចក្តីសម្រេចនៅកម្រិតផ្សេងៗ ដោយមិនបានពិគ្រោះយោបល់គ្នាដែលអាចបង្កឲ្យមានវិវាទ ហើយដំណើរការដ៏យឺតយ៉ាវក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ប៉ុន្តែសម្បទាន ដីមានល្បឿនលឿនក៏ជាកត្តា បង្កលក្ខណៈឲ្យមានវិវាទដីធ្លីផងដែរ។

- ចំនួនតិចជាងពាក់កណ្តាលនៃអ្នកភូមិ(៤៨.១%) ដែលមានស្រែ និង៥៧.១% ដែលមានដីលំនៅដ្ឋានដែលកំពុងមានវិវាទ មិនមានឯកសារណាមួយ សម្រាប់បញ្ជាក់កម្មសិទ្ធិរបស់ខ្លួនទេ ហើយ ៧៦.៩%នៃម្ចាស់ដីចំការ ៧២.១%នៃម្ចាស់ ដីព្រៃ និង ៦៧.៣%នៃអ្នកតំណាងដី សហគមន៍ ក៏មិនមានឯកសារ ណាបញ្ជាក់កម្មសិទ្ធិរបស់ខ្លួនដែរ។ ភាគច្រើននៃឯកសារបញ្ជាក់កម្មសិទ្ធិសម្រាប់ដីចំការ ដីព្រៃ និងដីព្រៃសហគមន៍មានលិខិតបញ្ជាក់ដីធ្លីដែលចេញដោយមេភូមិ លិខិតផ្ទេរសិទ្ធិការកាន់កាប់ដីដែលចេញដោយមេឃុំ ឬក្រុមប្រឹក្សាឃុំ និងពាក្យស្នើសុំកាន់កាប់ និងប្រើប្រាស់ដី ដែលចេញដោយមេឃុំ ឬក្រុមប្រឹក្សាឃុំ។

- ប្រជាពលរដ្ឋបានគូសបញ្ជាក់ថា សម្បទានដីសេដ្ឋកិច្ច(៧៣.២%) និងសម្បទានដីសង្គមកិច្ច(២៦.៨%) គឺជាមូលហេតុចម្បងដែលនាំឲ្យដីរបស់ពួកគាត់កើតមានវិវាទ។ មួយចំណែកតូចនៃអ្នកផ្តល់ចម្លើយ(៧.១%)បានបញ្ជាក់ថា មានមូលហេតុផ្សេងៗទៀតដូចជា ការរុករករ៉ែ/ អាជីវកម្មរ៉ែ និងរដ្ឋមានតម្រូវការធ្វើជាតំបន់អភិវឌ្ឍន៍ជាដើម។

- មានសកម្មភាពមួយចំនួនដែលអ្នកភូមិបានប្រាប់ អំពីរបៀបដែលភាគីទីពីរបានទាមទារកាន់កាប់ដីវិវាទ។ អ្នកផ្តល់ចម្លើយចំនួន ២៨.៦% បាននិយាយអំពីការគំរាមមកលើអ្នកកាន់កាប់ដីដំបូង ក្នុងខណៈដែលច្រើនជាងមួយភាគបី (៣៦.៣%) មិនបានដឹងអំពីសកម្មភាពដែលភាគីទីពីរទាមទារកាន់កាប់ដីឡើយ។

- អ្នកភូមិអាចទៅរកអាជ្ញាធរមូលដ្ឋានភូមិ ឃុំ ៨៩% ដើម្បីឱ្យជួយដោះស្រាយបញ្ហាវិវាទដីធ្លី ទិន្នន័យបានបង្ហាញថា អាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ (ពីថ្នាក់ភូមិរហូតដល់ថ្នាក់ស្រុក) បានចូលរួមដោះស្រាយវិវាទជូនប្រជាពលរដ្ឋរួមទាំងវិវាទដីធ្លីផងដែរ។

- តួអង្គដែលសកម្មជាងគេបំផុតនៅក្នុងការដោះស្រាយវិវាទដីធ្លី គឺជាក្រុមប្រឹក្សាឃុំ និងអាជ្ញាធរស្រុក។ មានវិវាទចំនួន ៦ ក្នុងចំណោមវិវាទទាំង២៨ពាក់ព័ន្ធនឹងក្រុមហ៊ុន ដែលបានដោះស្រាយនៅថ្នាក់ឃុំ។ មានវិវាទធ្លីចំនួន៥ទៀតក្នុងចំណោមវិវាទទាំង២៨ត្រូវបានដោះស្រាយដោយគណៈកម្មាការរដ្ឋបាល នៅថ្នាក់ស្រុក និងខេត្តនៅក្នុងខេត្តកំពង់ឆ្នាំង សូម្បីតែមានអ្នកភូមិមួយចំនួនតូចមិនមានការពេញចិត្តនឹងដំណោះស្រាយនេះក្តី។ មានតែវិវាទចំនួនមួយគត់នៅភូមិត្រពាំងក្រើញ (វិវាទទី៩) ក្នុងស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដែលអាជ្ញាធរខេត្តបានធ្វើអន្តរាគមន៍។

- យើងសង្កេតឃើញថា មានកត្តាចំនួនបីដែលអាចជួយឲ្យដំណើរការដោះស្រាយវិវាទអាចធ្វើទៅបាន ដែលអាចធ្វើអោយមានយុត្តិធម៌តិច ឬច្រើន ឬ អាចទទួលយកបាន។ ១) ភាគីវិវាទទាំងសងខាងគប្បីមានសុឆន្ទៈ និងមានការយោគយល់គ្នា និងមិនមានកិច្ចកល និងទាញយកផលប្រយោជន៍នៅក្នុងកិច្ចចរចានេះឡើយ។ ២) វាហាក់ដូចជាមានលំនាំនៃប្រព័ន្ធអំណាចបែបខ្សែ-ខ្នង ដែលនៅតែមានអត្ថិភាពនៅក្នុងយន្តការដោះស្រាយវិវាទនៅឡើយ។ វាហាក់ដូចជាថាដំណើរការដោះស្រាយវិវាទអាចទទួលបានជោគជ័យបាន បើសិនជាស្ថាប័នដោះស្រាយវិវាទដីធ្លីគ្រប់ជាន់ថ្នាក់ មានអំណាចក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួន ដោយអនុលោមតាមក្របខណ្ឌច្បាប់ដែលមានស្រាប់។ ៣) ការស្រុះស្រួលគ្នាយ៉ាងរឹងមាំក្នុងចំណោមអ្នកភូមិនៅក្នុងរង្វង់សហគមន៍ អាចជាកម្លាំងមួយយ៉ាងរឹងប៉ឹងសម្រាប់ការពារសិទ្ធិលើដីធ្លីរបស់ខ្លួន។

- «*ដីជាជីវិតយើង*» មានលក្ខណៈទូទៅសម្រាប់អ្នកភូមិដែលដីរបស់ពួកគេកំពុងមានវិវាទ។ នៅក្នុងគ្រប់ករណីវិវាទ ដែលយើងបានសិក្សាក្នុងខេត្តគោលដៅ អ្នកភូមិមានចេតនារួមកម្លាំងគ្នាដើម្បីតវ៉ាជាចំហ សូម្បីជំទាស់នឹងអ្នកមានអំណាចយ៉ាងណាក៏ដោយពីព្រោះពួកគាត់មានអារម្មណ៍ថា គេបានដកហូតដីពីពួកគាត់ដោយអយុត្តិធម៌។ ភស្តុតាងបង្ហាញថា ៧៣.៨% ពួកគាត់បានធ្វើអ្វីៗជាការតវ៉ា ជំទាស់នឹងការដកហូតដីពីពួកគាត់។

- វាមានសំខាន់ដែលត្រូវកត់សម្គាល់ថា ច្រើនជាងពាក់កណ្តាលបន្តិចនៃអ្នកផ្តល់ចម្លើយ (៥២.១%) បានយល់ដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការមានមិត្ត មេធាវី ឬអ្នកតំណាងពីអង្គការ

មូលដ្ឋាន/អង្គការមិនមែនរដ្ឋាភិបាល ដើម្បីជួយខ្លួននៅក្នុងដំណើរការសម្រុះសម្រួល។ អ្នកផ្តលចម្លើយ ៥៦.២% បាននិយាយថា ពួកគេមានអ្នកជួយនៅក្នុងអំឡុងពេលនៃដំណើរការផ្សះផ្សារ។ ច្រើនជាង ៦០% នៃអ្នកផ្តល់ចម្លើយបានប្រាប់ថា ពួកគាត់បានទទួលព័ត៌មាន និងមានការយល់ដឹង តាមរយៈអាជ្ញាធរមូលដ្ឋាន និងអង្គការមូលដ្ឋាន / អង្គការមិនមែនរដ្ឋាភិបាល។ អ្នកដឹកនាំភូមិ និងសមាជិកសហគមន៍ (៣៨.៧%) និងប្រព័ន្ធផ្សព្វផ្សាយ (២២.៦%) បានដើរតួនាទីផងដែរក្នុងការផ្សព្វផ្សាយអំពីសិទ្ធិក្នុងការមានអ្នកណាម្នាក់ ដើម្បីជួយអ្នកភូមិនៅក្នុងដំណើរការសម្រុះសម្រួល។

- អ្នកភូមិបានមើលឃើញថា មានតែក្រុមមួយចំនួនតូចប៉ុណ្ណោះដែលសកម្មខ្លាំងជាងគេ គឺមានក្រុមជួយខ្លួនឯង ក្រុមជីឆ្លី ក្រុមស្រ្តី ក្រុមយុវវ័យ និងក្រុមព្រៃសហគមន៍។ ទោះជាយ៉ាងណាក៏ដោយ ពាក់កណ្តាលនៃអ្នកភូមិ (៥០%) គិតថា សមត្ថភាពរបស់ក្រុមទាំងនេះមានកម្រិតមធ្យម ក្នុងខណៈដែល៤២%ផ្សេងទៀតគិតថា ក្រុមមានសមត្ថភាពទាប។ គួរសម្គាល់ថា ៤០.៦% មិនបានដឹងថា នៅក្នុងសហគមន៍របស់ខ្លួនមានក្រុមទាំងនោះឡើយ។

- ៨០.៦% នៃអ្នកផ្តល់ចម្លើយបានបញ្ជាក់ថា ភាគីទីពីរកំពុងកាន់កាប់ដីវិវាទមកទល់ពេលនេះ។ ៨២.៥% ទៀតបានប្រាប់ថាលទ្ធផលនៃដំណោះស្រាយវិវាទមិនយុត្តិធម៌ទេ។ ច្រើនជាងពាក់កណ្តាលនៃអ្នកផ្តល់ចម្លើយ(៥៧.៧%) កំពុងបន្តរង់ចាំដំណោះស្រាយ ក្នុងខណៈដែល ២៥.៨%ទៀតចង់ដាក់បណ្តឹងនៅស្ថាប័នផ្សេងទៀត។ អ្នកផ្តល់ចម្លើយ ៩.៧% អស់សង្ឃឹម និងបានសម្រេចថានឹងបោះបង់បណ្តឹង។ អ្នកផ្តល់ចម្លើយមួយចំនួនតូចបានប្រាប់ថា ពួគេនឹងចេញទៅធ្វើកូដកម្ម ឬក៏វិលត្រឡប់មកកាន់កាប់ដីរបស់ខ្លួនវិញ។
- ជាបឋម ការបរាជ័យ មានទំនាក់ទំនងទៅនឹងការផ្តល់សំណងគ្មានស្តង់ដារច្បាស់លាស់ដល់អ្នកភូមិដែលដីរបស់ពួកគេ ត្រូវបានរឹបអូសយកតាមរយៈការផ្តល់សម្បទានដីសេដ្ឋកិច្ច និងសង្គមកិច្ច ។

- បើតាមទស្សនៈរបស់អ្នកសម្របសម្រួល អ្នកភូមិត្រូវបានគេសង្ស័យថា មានខ្នងជាគណបក្សនយោបាយ ឬសាច់ញាតិ ដែលមានអំណាចធ្វើឱ្យបរាជ័យក្នុងការការសម្របសម្រួលដោយភ្លេចខ្លួនថាពួកគេខ្លួនឯងខ្វះការប្តេជ្ញាចិត្តក្នុងការដោះស្រាយវិវាទទាំងនោះ។

- ទោះបីជាមានការចូលរួមរបស់ស្ត្រីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅក្នុងមុខតំណែងដែលអាចធ្វើការសម្រេចចិត្ត បានមានការកើនឡើងជាលំដាប់នៅក្នុងវិស័យជាច្រើនក៏

ដោយ ប៉ុន្តែចំនួនស្ត្រីចូលរួមនៅក្នុងការដោះស្រាយវិវាទដី ធ្លីនៅក្នុងខេត្តគោលដៅទាំងបួននៅមានកម្រិតនៅឡើយ។ នៅគ្រប់កម្រិតទាំងអស់នៃអាជ្ញាធរមូលដ្ឋានពីថ្នាក់ស្រុករហូតដល់ថ្នាក់ភូមិ សមាមាត្រនៃអ្នកដឹកនាំជាស្ត្រីមានចំនួនតិចនៅឡើយបើប្រៀបធៀបទៅនឹងបុរស។ ចំនួនតិចរបស់ស្ត្រី និងតួនាទីរបស់ពួកគេបានរឹតត្បិតនៅក្នុងការដោះស្រាយបញ្ហាវិវាទដីធ្លី ។

- គោលបំណងជាក់លាក់នៃសម្បទានដីសេដ្ឋកិច្ច គឺដើម្បីអភិវឌ្ឍសកម្មភាពកសិកម្ម និងកសិឧស្សាហកម្ម ឱ្យបានខ្លាំងក្លា។ គោលបំណងសម្បទាន គឺដើម្បីបង្កើតប្រាក់ចំណូលរបស់រដ្ឋ ឬខេត្តតាមរយៈពន្ធដីសម្បទានសេដ្ឋកិច្ច និងបង្កើនការងារនៅតំបន់ជនបទសម្រាប់ការកាត់បន្ថយភាពក្រីក្រ។ វាគឺជាការពិតដែលថា ក្រុមហ៊ុនបានផ្តល់នូវឱកាសការងារសម្រាប់អ្នកភូមិ។ ប៉ុន្តែការងារដែលផ្តល់ឱ្យនោះគឺមានលក្ខណៈម្តងម្កាលតាមរដូវកាលប៉ុណ្ណោះ មិនមែនការងាររយៈពេលវែងដោយមានការចុះកិច្ចសន្យានោះទេ។

- ជាលទ្ធផលនៃការបាត់បង់នៃដីកសិកម្ម ដីសម្រាប់ឃ្វាលសត្វពាហនៈ ការបាត់បង់ដំណាំ និងការមិនអាចប្រើប្រាស់ធនធានព្រៃឈើ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់បានជួបនឹងអស្ថេរភាព និងប្រឈមនឹងអសុវត្ថិភាពស្បៀងអាហារ។ អ្នកផ្តល់ចម្លើយ៨២% បាននិយាយថា ចាប់តាំងពីមានវិវាទដីធ្លីមក ពួកគាត់មិនអាចធ្វើសកម្មភាពដាំដុះបានទេ។ រីឯ ៧៣,៣% ទៀតនិយាយថា ពួកគាត់មិនអាចប្រើប្រាស់ធនធានធម្មជាតិនៅលើដីទំនាស់នោះបានទេ។

- វិវាទដីធ្លីដែលបានធ្វើឱ្យប៉ះពាល់ដល់ប្រាក់ចំណូលរបស់អ្នកភូមិ។ អ្នកឆ្លើយ៥៥,៨% បានឱ្យដឹងថា ប្រាក់ចំណូលគ្រួសាររបស់ពួកគេបានធ្លាក់ចុះជាងមុន។ ៧៥,៧% បាននិយាយថា ក្រុមគ្រួសាររបស់ពួកគេមិនមានប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់ទ្រទ្រង់សេចក្តីត្រូវការជាមូលដ្ឋានសម្រាប់ការចិញ្ចឹមជីវិតពេញមួយឆ្នាំនោះទេ។ ចំណែកឯ ៧៤,៦% និយាយថា ពួកគេខ្វះប្រាក់ដើមទុនសម្រាប់យកទៅរកស៊ីចិញ្ចឹមជីវិត។ ប្រការដែលអ្នកភូមិមិនអាចប្រើប្រាស់ដីកសិកម្ម ៦៣.៨% និងមិនអាចប្រើប្រាស់ធនធានធម្មជាតិ ៣៣.៨% គឺជាមូលហេតុចម្បងនៃប្រាក់ចំណូលគ្រួសាររបស់អ្នកភូមិបានថយចុះ។ ៤៥% នៃអ្នកភូមិបាននិយាយថា ពួកគេមិនអាចដើរកាត់ដីមានជម្លោះ ដោយសារតែរបងរបស់ក្រុមហ៊ុនសាងសង់ព័ទ្ធជុំវិញ។ ដូចគ្នាផងដែរ អ្នកភូមិក៏មិនអាចលែងគោក្របីរបស់គេដោយសេរីដូចពីមុនបានឡើយ។

- អ្នកផ្តល់ចម្លើយ ៧៣,៣%បាននិយាយថា ពួកគេមិនអាចប្រើប្រាស់ធនធានធម្មជាតិបានទៀតទេ បន្ទាប់ពីដីរបស់ពួកគេមានវិវាទ។ ជម្លោះដីធ្លីក៏បានប៉ះពាល់ដល់ការអប់រំរបស់កុមារ។ អ្នកភូមិ១៩,១% បានរៀបរាប់ថា កុមារមិនបានទៅសាលារៀនទេព្រោះថា ពួកគេត្រូវជួយឪពុកម្តាយដើម្បីរកប្រាក់ ឬនៅផ្ទះជួយមើលប្អូនរបស់ពួកគេ។

- ករណីវិវាទទាំងអស់នៅក្នុងខេត្តចំនួនបួនបង្ហាញពីបញ្ហា នៃអតុល្យភាពអំណាចដែលមានជាទូទៅនៅក្នុងជម្លោះដីធ្លី។ ស្ទើរតែគ្រប់ករណីទាំងអស់បានគូសបញ្ជាក់អំពីការបរាជ័យនៃយន្តការដោះស្រាយវិវាទ ដែលមានស្រាប់ក្នុងការផ្តល់ជាដំណោះស្រាយដល់សហគមន៍ ដែលបាត់ដីធ្លីតាមរយៈសម្បទានដីសង្គមកិច្ច និងសេដ្ឋកិច្ចដល់ក្រុមហ៊ុន ឬបុគ្គលមានអំណាច។

# សេចក្ដីថ្លែងអំណរគុណ

ការសិក្សាស្រាវជ្រាវនេះអាចធ្វើទៅបានអាស្រ័យដោយមានការគាំទ្រពីបុគ្គល ស្ថាប័ន និងអង្គការជាច្រើនដែលបានចូលរួមចំណែកផ្ដល់នូវព័ត៌មាន ការណែនាំ និងការជួយឧបត្ថម្ភដ៏មានតម្លៃ។ ។

ជាបឋម យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា អង្គការជីវិតថ្លៃថ្នូរ និងFinn Church Aid (FCA) ដែលបានជួយផ្ដល់នូវការឧបត្ថម្ភគាំទ្រ និងណែនាំ។

យើងខ្ញុំក៏សូមសំដែងនូវការដឹងគុណជាពន្លឹក ចំពោះតំណាងអង្គការមិនមែនរដ្ឋាភិបាល និងអង្គការនានានៅថ្នាក់មូលដ្ឋាន ដូចជាអង្គការជីវិតថ្លៃថ្នូរ អាដហុក និងលីកាដូ ដែលបានរួមសហការផ្ដល់នូវព័ត៌មាន និងចំណាយពេលវេលារបស់ខ្លួន។

យើងខ្ញុំក៏សូមថ្លែងនូវអំណរគុណជាអនេក ចំពោះតំណាងអាជ្ញាធរមូលដ្ឋាន គណៈកម្មការសុរិយោដី រដ្ឋបាលព្រៃឈើ និងបរិស្ថាននៅគ្រប់កំរិត នៅក្នុងខេត្តគោលដៅ រួមមានកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ និងបាត់ដំបង ដែលបានចំណាយពេលវេលាផ្ដល់នូវគំនិតយ៉ាងស៊ីជម្រៅ។

យើងខ្ញុំក៏សូមសំដែងនូវការដឹងគុណដែរ ចំពោះតំណាងអ្នកភូមិ ចាស់ព្រឹទ្ធាចារ្យ ហើយនឹងប្រជាពលរដ្ឋរងគ្រោះទាំងឡាយនៅក្នុងតំបន់គោលដៅដែលបានចំណាយពេលវេលាផ្ដល់នូវព័ត៌មាន នៅអំឡុងពេលដែលយើងខ្ញុំចុះ សិក្សានៅមូលដ្ឋាន។

ជាចុងក្រោយតែក៏សំខាន់ដែរ យើងខ្ញុំសូមថ្លែងនូវអំណរគុណជាពិសេស ចំពោះក្រុមសិក្សាស្រាវជ្រាវ ទាំងផ្នែកគុណវិស័យ ក៏ដូចជាបរិមាណវិស័យរបស់មជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ ដែលបានចូលរួមចំណែកយ៉ាងសកម្មនៅក្នុងការសិក្សានេះ។

# ពាក្យកាត់

| | |
|---|---|
| AC | គណៈកម្មការរដ្ឋបាល |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ADHOC | អង្គការអាដហុក |
| CAS | មជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ |
| CBO | អង្គការមូលដ្ឋាន |
| CCHR | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| DKCC | គណៈកម្មការសុរិយោដីថ្នាក់ស្រុក/ខណ្ឌ |
| ELC | សម្បទានដីសេដ្ឋកិច្ច |
| FGD | ក្រុមពិភាក្សា |
| FUNCINPEC | គណបក្សហ៊្វុនស៊ិនប៉ិច |
| GIZ | អង្គការ GIZ |
| INGO | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ |
| KSS | ក្រុមហ៊ុនកំពង់ស្ពឺស្ហ្គរ័ |
| LASSP | កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី |
| LICADHO | អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) |
| LMAP | គម្រោងរៀបចំដែនដី និង រដ្ឋបាលដីធ្លី |
| LNGO | អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក |
| LWD | អង្គការជីវិតថ្លៃថ្នូរ |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| NARLD | អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី |
| NCC | គណៈកម្មការសុរិយោដីថ្នាក់ជាតិ |
| NGOF | វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា |
| NTFP | អនុផលព្រៃឈើ |
| ODC | អង្គការទិន្នន័យអំពីការអភិវឌ្ឍ កម្ពុជា (Open Development Cambodia) |
| PMCC | គណៈកម្មការសុរិយោដីថ្នាក់ខេត្ត/ក្រុង |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SLC | សម្បទានដីសង្គមកិច្ច |
| SNEC | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| WB | ធនាគារពិភពលោក |

# ការសិក្សាស្តីពីវិវាទដីធ្លីនៅក្នុងខេត្តចំនួនបួននៅកម្ពុជា៖ ការដៅលើផែនទី ផលប៉ះពាល់ និងដំណោះស្រាយដែលអាចធ្វើបាន

## ១.សេចក្តីផ្តើម

### ១.១ សាវតារ

ប្រទេសកម្ពុជាគឺជាសង្គមកសិកម្ម ដោយផ្អែកលើព្រៃឈើ ដីកសិកម្ម និងប្រភពធនធានទឹកច្រើនក្រៃលែង។ ដីគឺជាទ្រព្យដ៏សំខាន់សម្រាប់ប្រជាជនកម្ពុជា ៧០% ដែលប្រកបការងារកសិកម្មដើម្បីចិញ្ចឹមជីវិត។ ផលិតផលកសិកម្មចម្បងគឺស្រូវដែលគេដាំដុះសម្រាប់ការប្រើប្រាស់ក្នុងប្រទេសនិងការនាំចេញ។ ផលិតផលផ្សេងទៀតរួមមានកៅស៊ូ ដំឡូងមី ពោត សាច់ និងទឹកដោះ បន្លែ និងអំពៅ។ សម្ពាធចំនួនប្រជាជនបានបណ្តាលឱ្យមានកំណើន តំរូវការដីកសិកម្ម និងផលិតកម្មស្បៀងអាហារ។ ទោះបីកសិករបានទទួលយកនិងអនុវត្តការបង្កើនបច្ចេកទេសកសិកម្ម ដើម្បីបង្កើនផលិតភាពកសិកម្មក៏ដោយ ប៉ុន្តែជាលទ្ធផលផលិតភាពមិនបានប្រសើរឡើងច្រើនឡើយ។ ពួកកសិករ ជាពិសេសអ្នកគ្មានដីធ្លីបានទៅចាប់យកដីព្រៃ (USAID, 2011).។

កំណើនសេដ្ឋកិច្ចដ៏លឿនរាប់ចាប់តាំងពីឆ្នាំ1990 បានបង្កឱ្យមានកំណើនតម្លៃ និងទាក់ទាញការវិនិយោគឯកជនទៅ តាមតំបន់ជនបទ។ ប្រការនេះនាំឱ្យមានការបង្កើតប្រព័ន្ធច្បាប់សម័យទំនើបមួយ ដែលបណ្តាលឱ្យមានការភាន់ច្រឡំ និងមានការយល់ខុសអំពីភាពជាម្ចាស់ដីស្របច្បាប់ ដែលនាំឱ្យកើតមានជម្លោះដីធ្លីជាច្រើន (Sekiguchi និង Hatsukano, 2013) ។ ដូចគ្នានេះដែរ សិទ្ធិដីធ្លី និងអចលនវត្ថុគឺជាសិទ្ធិមនុស្សជាមូលដ្ឋានក្នុងការការពារផលប្រយោជន៍សេដ្ឋកិច្ចរបស់សហគមន៍។ ការយល់ច្រឡំអំពីគោលនយោបាយដីធ្លី ភាពខ្សោយនៃការអនុវត្តច្បាប់ កង្វះឆន្ទៈនយោបាយដ៏ពិតប្រាកដបានជំរុញការកើនឡើងនៃជម្លោះរវាងក្រុមហ៊ុន និងសហគមន៍មូលដ្ឋាន (CCHR, 2012)។

គេមើលឃើញថា ជម្លោះដីធ្លី គឺជាបញ្ហាប្រឈមដ៏ធំមួយសម្រាប់ប្រទេសកម្ពុជា។ មានករណីវិវាទដីធ្លីមួយចំនួននាំឱ្យមានការបាត់បង់ការប្រើប្រាស់ដីនិងធនធានធម្មជាតិ។ យោងតាមរបាយការណ៍របស់វេទិកានៃអង្គការ មិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាក្នុងឆ្នាំ2014 ចំនួននៃជម្លោះដីធ្លីថ្មីនៅក្នុងឆ្នាំ2012បានកើនខ្ពស់បើប្រៀបធៀបទៅនឹងឆ្នាំមុនៗ តែចំនួនវិវាទបានធ្លាក់ចុះក្នុងអំឡុងពេលឆ្នាំ2013។ ចំនួនសរុបនៃជម្លោះដីធ្លីនៅក្នុងឆ្នាំ2013 គឺមាន 311 ករណីដែលក្នុងនោះមាន 80 ដែលបង្កឡើងដោយសម្បទានដីសេដ្ឋកិច្ច។ គួរកត់សម្គាល់ផងដែរថា ករណីវិវាទដីធ្លីទាំងអស់បានធ្វើឱ្យមានផលប៉ះពាល់ដល់ 65867គ្រួសារ ដែលពាក់ព័ន្ធទៅនឹងដីកសិកម្ម លំនៅដ្ឋាន និង

ព្រៃឈើ ហើយចំនួនខ្ពស់បំផុតបានកើតឡើងនៅក្នុងរាជធានីភ្នំពេញ ខេត្តរតនគីរី និងខេត្តកំពង់ស្ពឺ។ នៅឆ្នាំ2014 អង្គការ លីកាដូបានប្រកាសឱ្យដឹងថា វិវាទដីធ្លី នៅក្នុងប្រទេសកម្ពុជាមានកន្លះលានករណីបានកើតឡើង ដោយរាប់ចាប់ពីពេលដែលពួកគេបានចាប់ផ្តើមការប្រមូលទិន្នន័យ (អង្គការលីកាដូ ឆ្នាំ2014)។ បើយោងតាមសមាគមអាដហុក មានប្រជាពលរដ្ឋជាង 770.000នាក់ (ស្ទើរតែស្មើនឹង 6% នៃប្រជាជនសរុប) ត្រូវបានរងផលប៉ះពាល់ដោយការរំលោភដីធ្លីពីឆ្នាំ2000 ដល់ឆ្នាំ2013 (អាដហុក 2013)។ ៧៧%ភាគរយនៃវិវាទដីធ្លី ដែលបានកត់ត្រាទុកមិនទាន់បានដោះស្រាយ នៅឡើយក្នុងឆ្នាំ2013។ ដើមចមនៃជម្លោះដីធ្លីរួមមានគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ សម្បទានដីសេដ្ឋកិច្ច/សម្បទានដីដទៃទៀត និងការរំលោភយកដី ដែលមាន លក្ខណៈជាបុគ្គល(NGOF, 2014) ។

ស្រដៀងគ្នានេះដែរ នៅក្នុងការវាយតម្លៃបឋម និងឆាប់រហ័សមួយ លើជម្លោះដីធ្លីនៅតំបន់គោលដៅអង្គការជីវិតថ្លៃថ្នូរ(LWD)បានរកឃើញថាជម្លោះនេះបានកើតមាន ដោយសមាជិកសហគមន៍ ក្រុមហ៊ុនឯកជនក្នុងស្រុកនិងបរទេស អាជ្ញាធរមូលដ្ឋាន ទាហាន និងកងរាជអាវុធហត្ថ។ គួរកត់សម្គាល់ផងដែរថាជម្លោះដីធ្លី និងការរំលោភយកដីធ្លីត្រូវបានកើតឡើងភាគច្រើននៅភាគឦសាននៃប្រទេសកម្ពុជា គឺសម្បទានដីសេដ្ឋកិច្ច និងរ៉ែ។ ផលប៉ះពាល់នេះមិនគ្រាន់តែកើត មានទៅលើប្រព័ន្ធអេកូឡូស៊ីប៉ុណ្ណោះទេ ប៉ុន្តែក៏ប៉ះពាល់វប្បធម៌ប្រពៃណី និងជីវភាពរស់នៅរបស់ក្រុមជនជាតិដើមភាគតិចដែរ (Men, 2011) ។

មានភាគីជាច្រើនដែលបានជាប់ទាក់ទងក្នុងជម្លោះដីធ្លី។ ទោះជាយ៉ាងណាក៏ដោយ ជម្លោះដីគឺជាបញ្ហាប្រឈមមួយសម្រាប់ក្រុមគ្រួសារក្រីក្រ ដោយសារតែពួកគាត់មានការលំបាកក្នុងការដាក់ពាក្យបណ្តឹង តវ៉ាជាផ្លូវការទៅតុលាការ។ ជាញឹកញាប់គ្រួសារក្រីក្រមិនអាចធ្វើពាក្យបណ្តឹងទៅតុលាការបានទេ ដោយសារថ្លៃសេវាប្រព័ន្ធតុលាការ គឺហួសពីលទ្ធភាពរបស់ពួកគាត់។ ជាលទ្ធផលភាពទន់ខ្សោយរបស់ក្របខណ្ឌស្ថាប័នសម្រាប់ដោះស្រាយជម្លោះដីធ្លីគឺជាគ្រោះថ្នាក់បន្ថែមមួយទៀតសម្រាប់ក្រុមគ្រួសារនីមួយៗ ដើម្បីចូលរួមក្នុងការដាក់ពាក្យបណ្តឹងជាផ្លូវការ (SNEC 2007) ។

## ១.២ លំនាំបញ្ហា

ស្ថានភាពបច្ចុប្បន្ននៃជម្លោះដីធ្លីនៅក្នុងប្រទេសកម្ពុជាមានសារៈសំខាន់ខ្លាំងណាស់។ មានកត្តាជាច្រើនដែលបានបណ្តាលឱ្យមានជម្លោះដែលរួមមានទីកន្លែងជម្លោះ ប្រវត្តិដីធ្លី និងស្ថានភាពនយោបាយដែលធ្វើឱ្យវាពិបាកខ្លាំងក្នុងការដោះស្រាយ។ លើសពីនេះទៅទៀត ជម្លោះដីធ្លីមានការរីក

រាលដាល និងត្រូវបានគេមើលឃើញ ថាជាបញ្ហាដ៏ធ្ងន់ធ្ងរសម្រាប់ស្ថេរភាព និងសុខុមាលភាពរបស់ប្រទេស ដោយសារតែមានកត្តា និងផលប្រយោជន៍ពាក់ព័ន្ធជាច្រើន ដែលគេមិនអាចដោះស្រាយបានយ៉ាងងាយស្រួលនោះទេ។ ការព្រួយបារម្ភអំពីជម្លោះដីធ្លីសម្រាប់ប្រទេសនេះ ត្រូវបានបណ្តាញផ្សព្វផ្សាយជាតិនិងអន្តរជាតិលើកឡើងទូទៅ។ ទោះបីបញ្ហាដីធ្លីជាបញ្ហាបន្ទាន់មួយដែលត្រូវជំនះអោយបានក៏ដោយ ក៏គេត្រូវ ការពេលវេលា និងការខំប្រឹងប្រែងជាច្រើន ដើម្បីដោះស្រាយជាបណ្តើរ ក្នុងបេសកម្ម ដើម្បីស្វែងរកវិធានការ និងវិធីសាស្ត្រនានា សម្រាប់ដោះស្រាយ (Schwedersky, 2010)។ មានតួលេខខុសៗគ្នាអំពីចំនួននៃជម្លោះដីធ្លីនៅក្នុងប្រទេសកម្ពុជា ដោយហេតុថា ស្ថាប័ន/អង្គការក្រៅរដ្ឋាភិបាលផ្សេងគ្នាបានអះអាងថា តួលេខខុសគ្នាដោយសារការប្រើវិធីសាស្ត្រផ្សេងគ្នា។ មានជម្លោះជាច្រើនមិនដែលឈានដល់តុលាការ ដោយសារជម្លោះទាំងនោះត្រូវបានអាជ្ញាធរមូលដ្ឋាន ឬគណៈកម្មការសុរិយោដីបានដោះស្រាយ ឬដោយសារហេតុផលថា គ្រួសារដែលពាក់ព័ន្ធក្នុងជម្លោះខ្វះចំណេះដឹង និងធនធានក្នុងការដាក់ពាក្យបណ្តឹងទៅតុលាការ (SNEC 2007)។

ដើម្បីចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាទំនាស់ដីធ្លី អង្គការ LWD និង NGOF បានធ្វើការសិក្សាលើបញ្ហាជម្លោះដីធ្លីនៅក្នុងតំបន់ប្រតិបត្តិការដែលបានជ្រើសរើសរបស់អង្គការ LWD ដើម្បីទទួលបាននូវការយល់ដឹងក្នុងក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់ទៅលើកម្មសិទ្ធិដីធ្លី ការទិញយកដីធ្លី និងការដោះស្រាយវិវាទដីធ្លី ជាពិសេសនៅទីជនបទ។ អង្គការមិនមែនរដ្ឋាភិបាលទាំងនេះ រួមជាមួយសមាជិកបណ្តាញរបស់ពួកគេនឹងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហានេះ និងជួយដល់ប្រជាជន ដើម្បីទាមទារសិទ្ធិដីធ្លីរបស់ពួកគេព្រមទាំងធ្វើអោយប្រសើរឡើងនូវសមត្ថភាពសម្រាប់ទាំងសហគមន៍ និងអាជ្ញាធរ បន្ទាប់ពីរបាយការណ៍ត្រូវបាន ធ្វើឡើង។ ទោះជាយ៉ាងណាក៏ដោយ វាអាចនឹងមានតម្រូវការកើនឡើងរួមបញ្ចូលគ្នានឹងការខិតខំប្រឹងប្រែងនិងវិធីសាស្ត្រពីសំណាក់អង្គការសិទ្ធិមនុស្សនិងអង្គការមិនមែនរដ្ឋាភិបាលផ្នែកអភិវឌ្ឍនានា ក្នុងគោលបំណងដើម្បីសម្រេចបាននូវការសម្របសម្រួល និងលទ្ធផលនៃគម្រោងល្អប្រសើរជាងមុន ។

## ១.៣ គោលដៅ និងគោលបំណង

គោលដៅរួមនៃការស្រាវជ្រាវនេះ គឺដើម្បីរៀបចំផែនការលំអិតអំពីជម្លោះដីធ្លី ដែលបានកើតឡើងនៅក្នុងតំបន់ គោលដៅរបស់អង្គការ LWD និងកំណត់ការអនុវត្តយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាកាដែលមានស្រាប់។ លើសពីនេះទៀត ការស្រាវជ្រាវនេះ ផ្តល់នូវការយល់ដឹងអំពីផលប៉ះពាល់នៃបញ្ហាជម្លោះដីធ្លីទៅលើជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានជាពិសេសលើស្ត្រី។

## គោលបំណងជាក់លាក់

ការស្រាវជ្រាវនេះមានបំណងដោះស្រាយគោលបំណងដូចខាងក្រោមៈ

- ដើម្បីធ្វើផែនទីវិវាទដីធ្លីនៅក្នុងតំបន់គោលដៅរបស់អង្គការ LWD (ខេត្តបាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងកំពង់ស្ពឺ) ។
- ដើម្បីយល់ពីដំណោះស្រាយដែលបានផ្តល់ឱ្យ ដើម្បីដោះស្រាយវិវាទដីធ្លី និងស្ថានភាពរបស់វិវាទដីធ្លី។
- ដើម្បីយល់ពីផលប៉ះពាល់នៃវិវាទដីធ្លីទៅលើជីវភាពរស់នៅរបស់សហគមន៍នៅមូលដ្ឋាន ជាពិសេសលើស្រ្តី។
- ដើម្បីចងក្រងឯកសារករណីសិក្សាអំពីករណីវិវាទ ដែលទទួលបានជោគជ័យដោយសារការតស៊ូមតិក្នុងវិវាទដីធ្លី។

## ១.៤ សំណួរសម្រាប់ការវាយតម្លៃ

ការស្រាវជ្រាវនេះធ្វើឡើង ដើម្បីឆ្លើយសំណួរដូចខាងក្រោមៈ

- តើអ្វីខ្លះជាកត្តាដ៏សំខាន់ដែលនាំឱ្យមានវិវាទដីធ្លី?
- តើយន្តការដោះស្រាយវិវាទដីធ្លីក្នុងតំបន់គោលដៅមានអ្វីខ្លះ? តើយន្តការមួយណាដែលមានប្រសិទ្ធភាពជាង និងមានការពេញចិត្តជាងពីសំណាក់សហគមន៍ ?
- តើភាគីណាខ្លះ ដែលពាក់ព័ន្ធនៅក្នុងវិវាទទាំងនេះ និងថា តើវិវាទទាំងនោះត្រូវបានគេដោះស្រាយយ៉ាងដូចម្តេច?
- តើការចូលរួមរបស់ភាគីពាក់ព័ន្ធ និងតួនាទីរបស់ស្រ្តីក្នុងការដោះស្រាយបញ្ហាវិវាទដីធ្លីមានអ្វីខ្លះ?
- តើផលប៉ះពាល់ដែលបានកើតឡើងដោយសារវិវាទដីធ្លីលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានអ្វីខ្លះ?
- តើអ្វីខ្លះជាកត្តាដែលបណ្តាលឱ្យដំណោះស្រាយវិវាទដីធ្លីនេះបរាជ័យ ?
- តើមានអនុសាសន៍អ្វីខ្លះសម្រាប់ភាគីពាក់ព័ន្ធដែលបានចូលរួមនៅក្នុងដំណើរការដំណោះស្រាយ ថាតើត្រូវ ពន្លឿន បង្កើន និងដាក់ចេញនូវដំណោះស្រាយទំនាស់ដីធ្លីអោយទទួលបានជោគជ័យយ៉ាងដូចម្តេច។

# ២. វិធីសាស្ត្រក្នុងការជ្រើសរើសសំណាកគំរូ

អង្គការ NGOF និង LWD បានស្នើវិធីសាស្ត្រចំនួនបួនដើម្បីអនុវត្តការស្រាវជ្រាវនេះរួមមានៈ ការពិនិត្យឯកសារដែលមានស្រាប់ ការសម្ភាសន៍ទាំងរៀបរយ និងមិនរៀបរយ ករណីសិក្សា និងការ

សង្កេតក្រៅផ្លូវការ។ ដូច្នេះមជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់(CAS) ទទួលយកនូវវិធីសាស្រ្តទាំងនេះ ដោយសារវាមានលក្ខណៈច្បាស់លាស់ជាងដែលជាឧបករណ៍ចំរុះនៃគុណភាពនៃការសិក្សាដើម្បីផ្ទៀងផ្ទាត់ ការសម្ភាសន៍ តាមបែបបរិមាណវិស័យដែលបានធ្វើឡើងជាលើកដំបូង។ លើសពីនេះទៀត វិធីទាំងនេះនឹងផ្តល់ជាមធ្យោបាយកាន់តែច្រើនសម្រាប់ការធ្វើផែនទីជម្លោះដីធ្លីនៅតំបន់គោលដៅរបស់អង្គការ LWD ។ការស្រាវជ្រាវនេះនឹងពឹងផ្អែកទាំងទិន្នន័យ ដែលប្រមូលបានដល់ទីកន្លែង និងទិន្នន័យដែលមានស្រាប់។ ការផ្តោតសំខាន់នៃការសិក្សានេះ គឺផ្អែកលើការស្រាវជ្រាវជាក់ស្តែងដល់ទីកន្លែង ដោយប្រើវិធីសាស្រ្តគុណវិស័យ និងបរិមាណវិស័យ ដើម្បីសម្រេចគោលបំណងទាំងអស់នេះ។

## ២.១ វិធីជ្រើសរើសសំណាកគំរូទីតាំងស្រាវជ្រាវ

ការសិក្សានេះ បានគ្របដណ្តប់តែបួនខេត្តគោលដៅរបស់អង្គការ LWD ប៉ុណ្ណោះគឺ ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំងពោធិសាត់ និងបាត់ដំបង ដែលវិវាទដីធ្លីពាក់ព័ន្ធភាគីចំនួនពីរនាក់ឡើងទៅ និងមិនទាន់បានដោះស្រាយនៅឡើយ។ តំបន់គោលដៅនៃការសិក្សានេះ ត្រូវបានជ្រើសរើសនៅក្នុងទីតាំងជាក់លាក់ ដោយយោងតាមលទ្ធផលនៃការវាយតម្លៃយ៉ាងឆាប់រហ័សដែលបានធ្វើឡើងដោយអង្គការ LWD នៅក្នុងពេលកន្លងមកថ្មីៗនេះ នៅក្នុងភូមិចំនួន 85 និង 23 ឃុំនៃខេត្តទាំងបួនខាងលើ។ ការសិក្សានេះគូសផែនទីនៃវិវាទដីធ្លី ហើយវាមានផលប៉ះពាល់លើកជីវភាពរស់នៅថ្នាក់មូលដ្ឋាននៅក្នុងខេត្តដែលបានជ្រើសរើសទោះបីមានជម្លោះថ្មី ឬចាស់ក៏ដោយ។ ជាមួយនឹងបណ្តាខេត្តដែលបានជ្រើសរើស ទិន្នន័យ និងព័ត៌មានដែលប្រមូលបានមិនតំណាងវិវាទដីធ្លីនៅទូទាំងប្រទេសកម្ពុជានោះទេ។ ទោះជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវនេះក៏បានបង្ហាញអំពីព័ត៌មានសំខាន់ៗទុកជាមូលដ្ឋានសម្រាប់ការពិនិត្យពិចារណា ដើម្បីឆ្លុះបញ្ចាំងដល់ករណីដ៏ទៃទៀតសំរាប់ដំណោះស្រាយនាពេលអនាគត និងរៀបចំធ្វើផែនការករណីវិវាទដីធ្លី និងជីវភាពរស់នៅថ្នាក់មូលដ្ឋាន។

## ២.២ វិធីជ្រើសរើសសំណាកគំរូ

ទំហំនៃសំណាកគំរូនៃគ្រួសារដែលទទួលរងផលប៉ះពាល់ចំនួន 382 គឺជាសំណាកគំរូតំណាងឱ្យគ្រួសារទាំងអស់ចំនួន 8896 ដែលរងផលប៉ះពាល់ពីវិវាទដីធ្លីនៅក្នុងខេត្តគោលដៅទាំង៤។ ក្នុងចំណោម 23ឃុំ និង ៨៥ភូមិ មានតែ 50% នៃឃុំ និង 30% នៃភូមិ(11 ឃុំនិង 26 ភូមិ)ទេ ដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សានេះ។ ដូច្នេះហើយនៅក្នុងខេត្តកំពង់ស្ពឺមានភូមិចំនួន 16 នៅក្នុងឃុំចំនួន 5 ដែលនៅក្រៅតំបន់គោលដៅ ។ នៅក្នុងខេត្តកំពង់ឆ្នាំងមានភូមិចំនួន 4 ក្នុងឃុំ

ចំនួន 3 ចំនែកឯនៅខេត្តពោធិសាត់មានភូមិចំនួន 3 ក្នុងឃុំចំនួន2 និងខេត្តបាត់ដំបងមានភូមិចំនួន 3នៅក្នុងឃុំចំនួន 1 (មើលតារាងទី 1) ។

## តារាងទី ១: តំបន់គោលដៅរបស់អង្គការ LWD នៅក្នុង ៤ ខេត្តដែលបានជ្រើសសម្រាប់ការស្រាវជ្រាវ

| ខេត្ត | ឃុំ | | ភូមិ | |
|---|---|---|---|---|
| 1-កំពង់ស្ពឺ | គោលដៅ | ជ្រើសរើស | គោលដៅ | ជ្រើសរើស |
| ស្រុកភ្នំស្រួច | 2 | 1 | 4 | 1 |
| ស្រុកឱរ៉ាល់ | 5 | 2 | 27 | 8 |
| ស្រុកថ្ពង | 4 | 2 | 21 | 7 |
| សរុប | 11 | 5 | 52 | 16 |
| 2-កំពង់ឆ្នាំង | | | | |
| ស្រុកសាមគ្គីមានជ័យ | 6 | 3 | 14 | 4 |
| 3-ខេត្តពោធិ៍សាត់ | | | | |
| ស្រុកភ្នំក្រវាញ | 5 | 2 | 11 | 3 |
| 4- បាត់ដំបង | | | | |
| ស្រុកបវេល | 1 | 1 | 8 | 3 |
| សរុប | 23 | 11 | 85 | 26 |

ភូមិសំណាកគំរូចំនួន 26 ដែលបានជ្រើសត្រូវបានគេចាត់ទុកជាឯកតាសំណាកគំរូបឋម (PSU) ។ យើងប្រើវិធី សាស្ត្រចៃដន្យសម្រាប់ការជ្រើសរើសភូមិសំណាកគំរូទាំងនេះ ដើម្បីឱ្យមានលក្ខណៈវិទ្យាសាស្ត្រ។ ភូមិដែលបានជ្រើសរើសមានដូចខាងក្រោម៖

## តារាងទី ២: សំណាកគំរូភូមិ

| ល.រ | ទំហំសំណាក | ភូមិ | ឃុំ | ស្រុក | ខេត្ត |
|---|---|---|---|---|---|
| 1 | 33 | Ou Russey | Boeng Pram | Bavel | Battambang |
| 2 | 39 | Yuti Thor | | | |
| 3 | 18 | Kropéu Sésep | | | |
| 4 | 5 | Chrok Kov | Peam | Sameakki Mean Chey | Kampong Chhnang |
| 5 | 2 | Taing Krous keut*** | Krang Lvea | | |
| 6 | 5 | Srésa | Tbaeng Khpos | | |
| 7 | 2 | Mean Nork Lech | | | |

| | | | | | |
|---|---|---|---|---|---|
| 8 | 2 | Taing Sroeung | Sangkae Satob | Aoral | Kampong Speu |
| 9 | 14 | Taming | | | |
| 10 | 5 | Trapaing Kong | | | |
| 11 | 2 | Kouk | | | |
| 12 | 7 | Chumneap | | | |
| 13 | 10 | Dambang Vinh | | | |
| 14 | 1 | Kess | Ta Sal | | |
| 15 | 2 | Kriel Pong | | | |
| 16 | 13 | Kraing Boeng | Tang Samraong | Phnom Sruoch | |
| 17 | 24 | Krovak | Yea Angk | Thporng | |
| 18 | 5 | Sya | | | |
| 19 | 14 | Prich Khposs | | | |
| 20 | 1 | Rumchek | | | |
| 21 | 67 | Tropeang Kreunh | Prambei Mom | | |
| 22 | 24 | Thnal Kéng | | | |
| 23 | 6 | Thbeng Prachaop | | | |
| 24 | 21 | Sré Popeay | Santreae | Phnom Kravanh | Pursat |
| 25 | 43 | Kset Borey | | | |
| 26 | 17 | Say | Prongil | | |

**** ភូមិនេះត្រូវបានជំនួសដោយសារតែអាជ្ញាធរមូលដ្ឋានមិនអនុញ្ញាតឱ្យចូលធ្វើការសិក្សា*

តាមធម្មតាចំនួននៃក្រុមគ្រួសារសំណាកគំរូនៅក្នុងភូមិនីមួយៗត្រូវបានគណនាតាមរយៈរូបមន្ត ni = n(Ni/N); ni = ចំនួននៃសំណាកគំរូនៃភូមិនីមួយ; Ni = ចំនួនគ្រួសារដែលរងផលប៉ះពាល់នៅក្នុងភូមិនីមួយៗ; N = ចំនួននៃគ្រួសារដែលរងផលប៉ះពាល់នៅក្នុងភូមិទាំងអស់; ហើយ n = ចំនួននៃសំណាកគំរូសរុប។ សំណាកគំរូគ្រួសារសរុបក្នុងភូមិទាំងអស់មានចំនួន 382។ ចំនួននៃសំណាកគំរូនៅក្នុងភូមិនីមួយៗគឺសមាមាត្រទៅនឹងទំហំនៃគ្រួសារសរុប ដែលរងផលប៉ះពាល់ដោយជម្លោះ។ ចំនួននៃសំណាកគំរូនៅក្នុងភូមិនីមួយៗអាចត្រូវបានគណនា បន្ទាប់ពីដំណើរការចុះស្រង់ធ្វើបញ្ជីគ្រួសារ។ សំណាកគំរូគ្រួសារនៃភូមិនីមួយត្រូវបានជ្រើសរើសដោយប្រើវិធីចៃដន្យទាញចេញពីបញ្ជីគ្រួសារ ដែលរងផលប៉ះពាល់ ។

ក្រុមស្រាវជ្រាវ បានធ្វើការសំភាសន៍មិនរៀបរយជាមួយនឹងអ្នកផ្តល់ព័ត៌មានសំខាន់ដែលបានជ្រើសរើសចំនួន 92 នាក់ ក្នុងនោះរួមមានអាជ្ញាធរមូលដ្ឋាន តំណាងអ្នកភូមិ គណៈកម្មការសុរិយោដី តំណាងនៃអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក/អង្គការសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិដែលពាក់ព័ន្ធនៅក្នុងតំបន់គោលដៅ។ គុណតម្លៃនៃការសម្ភាសន៍បែបរចនាសម្ព័ន្ធត្រូវបានប្រើដើម្បីផ្ទៀងផ្ទាត់របកគំហើញ ដែលបានមកពីពីការសម្ភាសន៍តាមបែបរចនាសម្ព័ន្ធ។

ក្រុមស្រាវជ្រាវបានធ្វើការពិភាក្សាក្រុមគោលដៅចំនួនមួយនៅក្នុងខេត្តនីមួយៗ ដោយមានអ្នកចូលរួម៥០%ជាស្រី និង៥០%ទៀតជាប្រុសក្នុងចំណោមគ្រួសារដែលរងផលប៉ះពាល់ និងជាអ្នកដែលសកម្មក្នុងការតវ៉ានិង/ឬក្នុងការដោះស្រាយវិវាទដីធ្លី។

## ២.៣ វិធីសាស្ត្រប្រមូលទិន្នន័យ

### ២.៣.១ វិធីសាស្ត្រប្រមូលទិន្នន័យបឋមតាមបែបគុណវិស័យ

បញ្ជីសំណួរមិនរៀបរយតាមបែបគុណវិស័យចំនួន៥ ត្រូវបានរៀបចំឡើងសម្រាប់ការសម្ភាសន៍អ្នកផ្តល់ចម្លើយសំខាន់ៗម្នាក់ទល់ម្នាក់។ លើសពីនេះទៀត បញ្ជីសំណួរសម្រាប់ការពិភាក្សាក្រុមគោលដៅ ត្រូវបានរៀបចំឡើងសម្រាប់អ្នកដែលដឹងច្រើនអំពីបញ្ហាជាក់លាក់និងកម្មវត្ថុនៅតាមប្រធានបទ ឬតាមគោលបំណង។ ចំណែកឯករណីសិក្សាដែលជាការអនុវត្តល្អៗត្រូវបានធ្វើឡើងសំរាប់ ការប្រមូលព័ត៌មានស៊ីជម្រៅនៅក្នុងស្ថានភាពជាក់លាក់មួយ។ លើសពីនេះទៀត ការសង្កេតមិនផ្លូវការនៅតាមគោលដៅនឹងត្រូវបានរួមបញ្ចូលក្នុងការសិក្សានេះដែរ ដោយហេតុថាវិធីនេះគឺជាឧបករណ៍ដ៏សំខាន់មួយសម្រាប់អ្នកស្រាវជ្រាវ ដើម្បីទទួលបានការយល់ដឹងកាន់តែច្បាស់អំពីស្ថានភាពជាក់ស្តែងនៅតាមភូមិ។

### ២.៣.២ វិធីសាស្ត្រប្រមូលទិន្នន័យបឋមតាមបែបបរិមាណវិស័យ

តារាងសំណួរស្រាវជ្រាវរៀបរយតាមបែបបរិមាណវិស័យមួយ ត្រូវបានរៀបចំឡើងសម្រាប់ការសម្ភាសន៍គ្រួសារ។ ដំណាក់កាលដំបូងនៃការស្រាវជ្រាវតាមបែបបរិមាណវិស័យ ក្រុមស្រាវជ្រាវបានធ្វើបញ្ជីគ្រួសារដែលរងផលប៉ះពាល់នៅក្នុងភូមិគោលដៅទាំង២៦ នៅក្នុងខេត្តទាំង៤។ នៅពេលដែលការធ្វើបញ្ជីគ្រួសារបានចប់សព្វគ្រប់ហើយ ក្រុមស្រាវជ្រាវបានធ្វើការសម្ភាសន៍ម្នាក់ទល់ម្នាក់ជាមួយនឹងគ្រួសាររងគ្រោះ ដែលបានធ្វើការជ្រើសរើសនៅក្នុងភូមិតាមបែបចៃដន្យចេញពីបញ្ជីគ្រួសារ ។

### ២.៣.៣ វិធីសាស្ត្រប្រមូលទិន្នន័យដែលមានស្រាប់តាមបែបបរិមាណវិស័យ និងគុណវិស័យ

សកម្មភាពនេះគឺជាការពិនិត្យឯកសារសិក្សា និងរបាយការណ៍ដែលទាក់ទងទៅនឹងប្រធានបទនេះ ដែលមានស្រាប់ដែលបានសរសេរឡើងដោយរាជរដ្ឋាភិបាលកម្ពុជា និងទីភ្នាក់ងារនានារបស់រដ្ឋាភិបាល រួមទាំងអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។ ឯកសារដែលពាក់ព័ន្ធត្រូវបានប្រមូល និងពិនិត្យឡើងវិញ ដើម្បីបង្ហាញពីព័ត៌មានពាក់ព័ន្ធដើម្បីអាចជួយឱ្យក្រុមអ្នកស្រាវជ្រាវដៅទីតាំងស្រាវជ្រាវ។

## ២.៤ វិធីសាស្ត្រវិភាគទិន្នន័យ

### ២.៤.១ វិធីសាស្ត្រវិភាគទិន្នន័យតាមបែបគុណវិស័យ

បទសម្ភាសន៍ជាមួយនឹងអ្នកផ្តល់ចម្លើយសំខាន់ៗនិងក្រុមពិភាក្សាត្រូវបានថតទុក ដោយម៉ាស៊ីនថតសម្លេងឌីជីថល និងសរសេរឡើងវិញដូចដែលគេបាននិយាយ។ បទសម្ភាសន៍ដែលសរសេរឡើងវិញត្រូវបានយកទៅចំរាញ់ និងវិភាគព័ត៌មានដែលចំបាច់សំរាប់ឆ្លើយសំណួរស្រាវជ្រាវ។

ចម្លើយមួយចំនួនដែលបានពីអ្នកផ្តល់ចម្លើយសំខាន់ៗនិងក្រុមពិភាក្សាត្រូវបានយកទៅប្រើប្រាស់សំរាប់បង្ហាញនៅក្នុងរបាយការណ៍។

### ២.៤.២ វិធីសាស្ត្រវិភាគទិន្នន័យតាមបែបបរិមាណវិស័យ

ការវិភាគទិន្នន័យតាមបែបបរិមាណវិស័យត្រូវបានធ្វើតាមប្រព័ន្ធកុំព្យូទ័រ។ កម្មវិធី SPSS ត្រូវបានប្រើប្រាស់សម្រាប់គណនាភាគរយ និងសម្រាប់គណនាខ្វែងក្នុងការផ្ទៀងផ្ទាត់ទិន្នន័យឱ្យបានត្រឹមត្រូវ។ រីឯកម្មវិធី Excel ត្រូវបានប្រើប្រាស់សម្រាប់បង្កើតតួលេខ។

# សេចក្តីសង្ខេបនៃករណីវិវាទ

ក្នុងចំណោមភូមិសំណាកគំរូចំនួន២៦ យើងសង្កេតឃើញមានវិវាទដីធ្លីចំនួន២៨ករណីរវាងអ្នកភូមិ និងភាគីទី២។ នៅក្នុងខេត្តកំពង់ស្ពឺ ខេត្តពោធិ៍សាត់ និងកំពង់ឆ្នាំង ភាគីទី២ត្រូវបានគេលើកឡើងថាមាន ក្រុមហ៊ុនឯកជន (៦៥.២%) និងរដ្ឋ (៧.៦%)។ ចំណែកឯនៅខេត្តបាត់ដំបង ភាគីទី២គឺជាអ្នកភូមិមកពីភូមិផ្សេងទៀត (១៨.៨%) និងឈ្មួញ (៤.២%)។ ខាងក្រោមនេះគឺជាករណីវិវាទដីធ្លីនៅក្នុងខេត្តទាំងបួន៖

| លរ | ស្រុក = ១<br>ឃុំ = ២<br>ភូមិ= ៣ | ប្រភេទនៃការសិក្សា | ស្ថានភាពសង្គមនៃភាគីវិវាទ<br>1=ភាគីទីមួយ<br>2=ភាគីទីពីរ | ប្រភេទដីវិវាទ | មូលហេតុនៃវិវាទ | លទ្ធផល |
|---|---|---|---|---|---|---|
| **១-ខេត្តកំពង់ស្ពឺ** | | | | | | |
| 1 | ១-ឱរ៉ាល់<br>២-សង្កែសាទប<br>៣-គោក | បរិមាណនិងគុណភាព | 1-អ្នកភូមិ<br>2-កំពង់ស្ពឺស្ហ្វូហ្គ័រ | ដីព្រៃ/ដីដាំ ដំណាំ (៧០ហិកតា) | នៅឆ្នាំ២០១០ក្រុមហ៊ុនបានរានដីដែលអ្នកភូមិប្រហែល២០គ្រួសារបានទាមទារថាជារបស់ពួកគាត់។ | នៅឆ្នាំ២០១១ ក្រុមហ៊ុនបានផ្តល់ប្រាក់សំណងពី ៣៧.៥០ទៅ ៥០.០០ដុល្លារក្នុងមួយគ្រួសារ។ មានតែគ្រួសាររងគ្រោះខ្លះបានទទួលប្រាក់១០០០ដុល្លារក្នុងមួយគ្រួសារនៅពេលចុងក្រោយ។ |
| 2 | ១-ឱរ៉ាល់<br>២-សង្កែសាទប<br>៣-ត្រពាំងគង | បរិមាណនិងគុណភាព | 1-អ្នកភូមិ<br>2-កំពង់ស្ពឺស្ហ្វូហ្គ័រ | ដីព្រៃរបស់ភូមិ (៨០ហិកតា) និងដីដាំ ដំណាំ (៧៥ហិកតា) | នៅដើមឆ្នាំ២០១២ក្រុមហ៊ុនបានយកដី ព្រៃសហគមន៍និងដីឯកជនដែលអ្នកភូមិបានទាមទារថាជារបស់ខ្លួន។ | ក្រៅពី៧០គ្រួសារ គ្រួសារនីមួយៗ ទទួលប្រាក់សំណងចំនួន២៥០.០០ដុល្លារ សម្រាប់ដីព្រៃ។ តែ ជាង១០គ្រួសារទៀតនៅមិនទាន់បានទទួលអ្វីទេសម្រាប់ក្បាលដីរបស់ខ្លួន។ |
| 3 | ១-ឱរ៉ាល់ | បរិមាណនិង | 1-អ្នកភូមិ | ដីព្រៃរបស់ភូមិ | ក្រុមហ៊ុនបានកាន់កាប់ដី | នៅឆ្នាំ២០១៤ ក្រុមហ៊ុនបានផ្តល់ |

| | | | | | | |
|---|---|---|---|---|---|---|
| | ២-សង្កែសាទប<br>៣-តាម៉ិញ | គុណភាព | 2-កំពង់ស្ពឺស្វ៊ូហ្គ័រ | /ដីដាំដំណាំ<br>(៧៣ហិកតា) | សហគមន៍នៅឆ្នាំ២០១២ | ប្រាក់ដល់គ្រួសាររងគ្រោះគ្រោះចំនួន៧៥.០០ដុល្លារ ក្រៅពី៧៣គ្រួសារ។ |
| 4 | ១-ឱរ៉ាល់<br>២-សង្កែសាទប<br>៣-តាំងស្រឹង | បរិមាណ | 1-អ្នកភូមិ<br>2-អេកអិលអេក | ដីកសិកម្ម<br>(១៦ហិកតា) | នៅឆ្នាំ២០០៦ ក្រុមហ៊ុនបានយកដីដែលអ្នកភូមិ៩គ្រួសារបានទាមទារថាជារបស់ខ្លួន។ | គ្រួសាររងគ្រោះបានបដិសេធសំណងរបស់ក្រុមហ៊ុនដែលពួកគាត់បានគិតថាមានចំនួនតិចតួចពេក។ |
| 5 | ១-ឱរ៉ាល់<br>២-សង្កែសាទប<br>៣-ជំនាប់ | បរិមាណ | 1-អ្នកភូមិ<br>2-អេកអិលអេក | ដីព្រៃ/កសិកម្ម<br>(២៣៥ហិកតា) | នៅឆ្នាំ២០១១ក្រុមហ៊ុនបានយកដីដែលអ្នកភូមិ៣២គ្រួសារកំពុងកាន់កាប់។ | វិវាទកំពុងបន្ត។ |
| 6 | ១-ឱរ៉ាល់<br>២-សង្កែសាទប<br>៣-ដំបងវេញ | បរិមាណ | 1-អ្នកភូមិ<br>2-អេកអិលអេក | ដីព្រៃ/កសិកម្ម<br>(២៩៣ហិកតា) | នៅឆ្នាំ២០១១ក្រុមហ៊ុនបានយកដីដែលអ្នកភូមិ៥០គ្រួសារបានទាមទារថាជា របស់ពួកគាត់។ | វិវាទកំពុងបន្ត។ |
| 7 | ១-ឱរ៉ាល់<br>២-តាសាល<br>៣-កេះ | បរិមាណ | 1-អ្នកភូមិ<br>2-ក្រុមហ៊ុនចិន | ដីព្រៃ/កសិកម្ម<br>(២៤ហិកតា) | នៅឆ្នាំ២០១៣ក្រុមហ៊ុនបានយកដី ដែលអ្នកភូមិ៨គ្រួសារកំពុងកាន់កាប់។ | នៅឆ្នាំ២០១៤ គ្រួសាររងគ្រោះបានទទួលដីរបស់ខ្លួនមកវិញលើកលែងមួយគ្រួសារ។ |
| 8 | ១-ឱរ៉ាល់<br>២-តាសាល<br>៣-ក្រៀលពង | បរិមាណ | 1-អ្នកភូមិ<br>2-ក្រុមហ៊ុនចិន | ដីរបស់ភូមិ<br>(១៣០ហិកតា) | នៅឆ្នាំ២០១១ក្រុមហ៊ុនបានរំលោភដីរបស់ភូមិ ដែលជំទាស់នឹងអ្នកភូមិ១១ គ្រួសារ។ | ក្រុមហ៊ុនអាចកាន់កាប់ដីបានតែមួយផ្នែកតូច។ វិវាទត្រូវបានបញ្ចប់។ |
| 9 | ១-ថ្ពង<br>២-ប្រាំបីមុម<br>៣-ត្រពាំងគ្រើញនិង | បរិមាណនិងគុណភាព | 1-អ្នកភូមិ<br>2-ស៊ីធីម៉ាត | ដីព្រៃ/កសិកម្ម<br>(២៩៥ហិកតា) | នៅឆ្នាំ២០០៦ក្រុមហ៊ុនបានយកដីដែលអ្នកភូមិ៥៥គ្រួសារកំពុងកាន់កាប់។ | នៅឆ្នាំ២០១២ដីត្រូវបានបែងចែកឲ្យភាគីទាំងសង ខាង។ដីទំហំ១៥០០ហិកតាដែលជាចំណែករបស់អ្នកភូមិរងគ្រោះ ត្រូវបាន |

| | | | | | | |
|---|---|---|---|---|---|---|
| | ថ្នល់កែង | | | | | លក់ឲ្យក្រុមហ៊ុនភ្នំពេញស្ទ័ហ្គ័រ។ សំណងជាមធ្យមមានចំនួន ៣០០.០០ ដុល្លារ លើកលែងតំណាងអ្នកភូមិនិងសាច់ញាត់ជិតស្និទ្ធរបស់គាត់ខ្លះដែលមានវិញ្ញាបនបត្រកាន់កាប់ដីបានលក់ដីចុងក្រោយក្នុងតម្លៃខ្ពស់។ |
| 10 | ១-ថ្កូង<br>២-ប្រាំបីមុម<br>៣-ត្បែងប្រជាប់ | បរិមាណនិងគុណភាព | 1-អ្នកភូមិ<br>2-សាលាកសិកម្មព្រែកលាប | ដីព្រៃ/កសិកម្ម (៣០០ហិកតា) | សាលាព្រែកលាបនៅភ្នំពេញបានទទួលការអនុញ្ញាតឲ្យអភិវឌ្ឍន៍តំបន់ នេះក្នុងឆ្នាំ២០០៧ ដែលបង្កឲ្យមាន កង្វល់ក្នុងចំណោមអ្នកភូមិជាង៣០ គ្រួសារដែលកំពុងដាំដំណាំនៅទីនោះ។ | អ្នកភូមិនៅតែមានការបារម្ភចំពោះក្បាលដីរបស់ខ្លួននៅថ្ងៃអនាគត។ |
| 11 | ១-ថ្កូង<br>២-យាអង្គ<br>៣-ក្រវៀក | បរិមាណ | 1-អ្នកភូមិ<br>2-ស៊ីធីម៉ាត | ដីព្រៃ/កសិកម្ម (ជាង១០០ហិកតា) | នៅឆ្នាំ២០០៦ក្រុមហ៊ុនបានយកដីរបស់ភូមិនាំឲ្យអ្នកភូមិជាង ១២០គ្រួសារបានទាមទារ។ | ក្រុមហ៊ុនបានផ្តល់សំណងចំនួន ២៦២.៥០ដុល្លារដល់គ្រួសារនីមួយៗ។ |
| 12 | ១-ថ្កូង<br>២-យាអង្គ<br>៣-ស្យា | បរិមាណ | 1-អ្នកភូមិ<br>2-ស៊ីធីម៉ាត | ដីព្រៃ/កសិកម្ម (៩៦ហិកតា) | នៅឆ្នាំ២០០៥ក្រុមហ៊ុនបានយកដីដែលអ្នកភូមិ២៨គ្រួសារទាមទារថាជារបស់ ខ្លួន។ | អ្នកភូមិខ្លះបានទទួលសំណងជាប្រាក់ចំណែកអ្នកដទៃទៀតមិនបានទទួលអ្វីសោះ។ |
| 13 | ១-ថ្កូង<br>២-ប្រាំបីមុម<br>៣-ព្រៃចខ្ពស់ | បរិមាណ | 1-អ្នកភូមិ<br>2-ស៊ីធីម៉ាត | ដីព្រៃ/កសិកម្ម (៤២១ហិកតា) | ក្រុមហ៊ុនបានយកដីរបស់ភូមិនៅឆ្នាំ ២០០៧ ដែលជំទាស់នឹងអ្នកភូមិចំនួន ១២៣គ្រួសារ។ | អ្នកភូមិខ្លះបានទទួលសំណងជាប្រាក់ ប៉ុន្តែគ្រួសារដែលនៅសល់បានទាមទារចំណែករបស់ខ្លួនពីព្រោះក្រុមហ៊ុនបានប្រគល់ ទឹកប្រាក់ជាសំណងទៅឲ្យតំណាង |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | អ្នកភូមិ។ |
| 14 | ១-ថ្កូង<br>២-ប្រាំបីមុម<br>៣-រំចេក | បរិមាណ | 1-អ្នកភូមិ<br>2-ស៊ីធីម៉ាត | ដីព្រៃ/កសិកម្ម (២៣ហិកតា) | នៅឆ្នាំ២០០៥ ក្រុមហ៊ុនបានយកដី ដែលអ្នកភូមិ១០គ្រួសារបានទាមទារ ថាជារបស់ខ្លួន។ | ក្រុមហ៊ុនបានផ្តល់សំណងជាប្រាក់ស្ទើរតែគ្រប់គ្រួសាររងគ្រោះ។ |
| 15 | ១-ភ្នំស្រូច<br>២-តាំងសំរោង<br>៣-ក្រាំងបឹង | បរិមាណ | 1-អ្នកភូមិ<br>2-ម៉ាស៊្វ័រ អាំងទៃរណាស្យូណាល់ | ដីស្រែ (៣៧៥ ហិកតានៃសម្បទានដីសេដ្ឋកិច្ច៩៥០ ហិកតា) | នៅឆ្នាំ២០១០ក្រុមហ៊ុនបានយកដីដែល អ្នកភូមិ៧៩គ្រួសារបានទាមទារថាជាដីស្រែរបស់ខ្លួន។ | មិនមានដំណោះស្រាយត្រូវបានសម្រេច។ |
| **២-ខេត្តកំពង់ឆ្នាំង** | | | | | | |
| 16 | ១-សាមគ្គីមានជ័យ<br>២-ត្បែងខ្ពស់<br>៣-ស្រែសា | បរិមាណនិងគុណភាព | 1-អ្នកភូមិ<br>2-សម្បទានដីសង្គមកិច្ច | ដីព្រៃ/កសិកម្ម (៧០ហិកតា នៃសម្បទានដីសង្គមកិច្ច២៧២៧ហិកតា) | នៅឆ្នាំ២០១៣ សម្បទានដីសង្គមកិច្ច បានប៉ះពាល់អ្នកភូមិ ៣០គ្រួសារដែលមានក្បាលដីនៅតំបន់នេះ។ | មិនមានដំណោះស្រាយត្រូវបានសម្រេច។ |
| 17 | ១-សាមគ្គីមានជ័យ<br>២-ត្បែងខ្ពស់<br>៣-ស្រែសានិងមានកលិច | បរិមាណនិងគុណភាព | 1-អ្នកភូមិ<br>2-កងរាជអាវុធហត្ថ | ដីកសិកម្ម (៣០ហិកតា) | ដើម្បីប្រែក្លាយជាមជ្ឈមណ្ឌលបណ្តុះ បណ្តាលនៅឆ្នាំ២០១៣ កងរាជអាវុធ ហត្ថបានយកដីនៅតំបន់ភ្នំមួយដែលអ្នកភូមិជាង១០គ្រួសារទាមទារថាជារបស់ខ្លួន។ | អ្នកខ្លះបានទទួលសំណងជាប្រាក់ ឬដោះដូរជា ក្បាលដីនៅកន្លែងផ្សេង រីឯអ្នកខ្លះទៀត មិនបានទទួលអ្វីសោះ។ |
| 18 | ១-សាមគ្គីមានជ័យ<br>២-ពាម<br>៣-ច្រកក្ងួរ | បរិមាណនិងគុណភាព | 1-អ្នកភូមិ<br>2-សម្បទានដីសង្គមកិច្ច | ដីកសិកម្ម(៥០ហិកតានៃសម្បទានដីសង្គមកិច្ច៤៨០ ហិកតា) | នៅឆ្នាំ២០១១ សម្បទានដីសង្គមកិច្ច បាន ប៉ះពាល់អ្នកភូមិ ១២គ្រួសារ ដែល មានក្បាលដីនៅតំបន់នេះ។ | ករណីវិវាទនេះនៅកំពុងរងចាំនៅឡើយ ។ |

| | | | | | | |
|---|---|---|---|---|---|---|
| 19 | ១-សាមគ្គីមានជ័យ<br>២-ពាម<br>៣-ច្រកក្វូរ | បរិមាណនិងគុណភាព | 1-អ្នកភូមិ<br>2-អាជ្ញាធរមូលដ្ឋាន | ដីកសិកម្ម (២៥ ហិកតានៅក្នុងព្រៃសហគមន៍ ៦៨២ ហិកតា) | នៅឆ្នាំ២០០៨ព្រៃសហគមន៍បានប៉ះ ពាល់ដល់ អ្នកភូមិ១៤ គ្រួសារដែលមាន ក្បាលដីនៅទីនោះ។ | ក្បាលដីខ្លះត្រូវបានគេឆៀលចេញ ហើយនៅសល់ ៦គ្រួសារកំពុងនៅមានវិវាទនៅឡើយ។ |
| 20 | ១-សាមគ្គីមានជ័យ<br>២-ក្រាំងល្វា<br>៣-តាំងគ្រួសកើត | បរិមាណ | 1-អ្នកភូមិ<br>2-អូជ្រៃ | ដីស្រែ (៧ហិកតា) | នៅឆ្នាំ២០១២ ក្រុមហ៊ុនបានកំណត់ ព្រំដីសម្បទានសេដ្ឋកិច្ចត្រួតស៊ីគ្នាទៅលើ ដីស្រែដែលជាកម្មសិទ្ធិរបស់អ្នកភូមិ ជាង ១០គ្រួសារ។ | អ្នកភូមិមានកង្វល់អំពីដីរបស់ខ្លួន។ |
| **៣-ខេត្តពោធិ៍សាត់** | | | | | | |
| 21 | ១-ភ្នំក្រវាញ<br>២-សន្ទ្រែ<br>៣-ស្រែពពាយ | បរិមាណនិងគុណភាព | 1-អ្នកភូមិ<br>2-ភាពីម៉ិច | ដីព្រៃ/ដាំដំណាំ (៧៥ហិកតា) | នៅឆ្នាំ២០១១ ក្រុមហ៊ុនបានរានដីដែល អ្នកភូមិ២៥គ្រួសារបានទាមទារថាជា របស់ខ្លួន។ | វិវាទមិនទាន់ចប់ទេ លើកលែងអ្នកខ្លះដែលមាន ក្បាលដីត្រូវបានវាស់វែងនិងឆៀលចេញពីសម្ប ទានដីសេដ្ឋកិច្ចក្នុងអំឡុងយុទ្ធនាការរបស់ យុវជនស្ម័គ្រចិត្តឆ្នាំ២០១២។ |
| 22 | ១-ភ្នំក្រវាញ<br>២-សន្ទ្រែ<br>៣-ស្រែពពាយ | បរិមាណនិងគុណភាព | 1-អ្នកភូមិ<br>2-សម្បទានដីសង្គមកិច្ច | ដីព្រៃសហគមន៍ (២០៦ហិកតា នៃដីសម្បទានសង្គមកិច្ចជិត ៦០០ហិកតា) | ការអនុម័តសម្បទានដីសង្គមកិច្ចនៅ ឆ្នាំ២០១០ បានប្រឈមនឹងអ្នកភូមិ ១១៣ គ្រួសារដែលជាសមាជិករបស់ សហគមន៍ព្រៃឈើដែលត្រូវបានបង្កើតក្នុងឆ្នាំ២០០៣ និងគ្រួសារខ្លះ ដែលកាន់កាប់ដីនៅក្បែរនោះ ហើយវិវាទក៏បានចាប់ផ្តើមនៅឆ្នាំ | មិនមានកិច្ចព្រមព្រៀងត្រូវបានសម្រេច។ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | ២០១២។ | |
| 23 | ១-ភ្នំក្រវាញ<br>២-សន្ទ្រែ<br>៣-ក្សេត្របុរី | បរិមាណនិង<br>គុណភាព | 1-អ្នកភូមិ<br>2-ភាពីម៉ិច | ដីព្រៃ/ដាំ ដំណាំ<br>(ជាង១០០ហិកតា) | ក្រុមហ៊ុនបានរានក្បាលដីដែលអ្នក ភូមិជាង២០គ្រួសារបានទាមទារថាជារបស់ខ្លួន។ | ក្បាលដីមួយចំនួនត្រូវបានឆ្វៀលចេញពីសម្បទានដីសេដ្ឋកិច្ច ហើយត្រូវបានវាស់វែងដោយ យុវជនស្ម័គ្រចិត្ត។ប៉ុន្តែគ្រួសាររងគ្រោះខ្លះ អាច ការពារ ចំណែកដីខ្លះដែលខ្លួន កាន់កាប់ ឬក៏បាត់បង់ក្បាលដីទាំងអស់។ |
| 24 | ១-ភ្នំក្រវាញ<br>១-សន្ទ្រែ<br>២-ក្សេត្របុរី | បរិមាណនិង<br>គុណភាព | 1-អ្នកភូមិ<br>2-ភាពីម៉ិច | ដីព្រៃសហគមន៍<br>(២៣០ហិកតា) | នៅឆ្នាំ២០១២ ក្រុមហ៊ុនបានឈូស ឆាយចំណែកដីនៃព្រៃសហគមន៍ដែលត្រូវបានបង្កើតនៅឆ្នាំ២០០៦ជាហេតុនាំឲ្យមានវិវាទជាមួយអ្នកភូមិ ១១១ គ្រួសារដែលជាសមាជិកសហគមន៍។ | សកម្មភាពរបស់ក្រុមហ៊ុនត្រូវបានបញ្ឈប់ដោយអាជ្ញាធរមូលដ្ឋាន។ |
| 25 | ១-ភ្នំក្រវាញ<br>២-ព្រងិល<br>៣-សាយ | បរិមាណ | 1-អ្នកភូមិ<br>2-ភាពីម៉ិច | ដីព្រៃ/កសិកម្ម<br>(៦០ហិកតា) | នៅឆ្នាំ២០១២ ក្រុមហ៊ុនបានយកដី ដែលអ្នកភូមិ ៩២គ្រួសារទាមទារថា ជារបស់ខ្លួន។ | អ្នកខ្លះបានទទួលដីរបស់ខ្លួនមកវិញ ប៉ុន្តែអ្នកខ្លះទៀតបានបាត់បង់ដីទាំងអស់ ឬដីមួយផ្នែករបស់ខ្លួន។ |
| **៤-ខេត្តបាត់ដំបង** | | | | | | |
| 26 | ១-បវេល<br>២-អំពិលប្រាំដើម<br>៣-បឹងប្រាំ | បរិមាណនិង<br>គុណភាព | 1-អ្នកភូមិ<br>2-ឈ្មួញនិងអាជ្ញាធរមូលដ្ឋាន | ដីព្រៃ/កសិកម្ម<br>(ជាង៣០០០ ហិកតា) | អ្នកភូមិជាង៣០០០គ្រួសារនៅតំបន់បឹងប្រាំដែលជាអ្នកចំណូល ថ្មីមកពីខេត្ត ផ្សេងៗបានប្រឈមនឹងក្រុមឈ្មួញ (ដែលបានទិញដីពីនាយ | លទ្ធផលត្រូវបានកត់សម្គាល់ដោយការដោះលែង អ្នកដឹកនាំសហគមន៍នៅឆ្នាំ២០០៧ ហើយក្រុម ឈ្មួញត្រូវបានចាកចេញពីតំបន់នេះ។ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | ទាហានជាន់ ខ្ពស់ខ្មែរក្រហម នៅឆ្នាំ១៩៩៦)និងអាជ្ញាធរមូលដ្ឋាន ក្នុងអំឡុងឆ្នាំ២០០៥-២០០៧។ នៅពាក់កណ្តាលឆ្នាំ ២០០៦ អ្នកដឹកនាំសហគមន៍ត្រូវបានចាប់ខ្លួននិងជាប់ឃុំឃាំងអស់រយៈពេល១៤ខែ។ | |
| 27 | ១-បវេល<br>២-បឹងប្រាំ<br>៣-យុត្តិធម៌ និង អូរបួស្សី | បរិមាណនិង គុណភាព | 1-សម្បទានដីសង្គមកិច្ច<br>2-អ្នកភូមិមកពីឃុំផ្សេង | ដីកសិកម្ម/ព្រៃនៅក្នុងឃុំបឹងប្រាំ (៨០០ហិកតា) | ក្នុងអំឡុងឆ្នាំ២០១១-២០១២ យុទ្ធនាការរបស់យុវជនស្ម័គ្រចិត្ត អ្នកភូមបឹងប្រាំ(ជាង១៧០០គ្រួសារ) បានទទួលប័ណ្ណកម្មសិទ្ធិដីធ្លី ប៉ុន្តែមិនអាចយកដីពីក្រុម ១៩២គ្រួសារដែលភាគច្រើនមកពី ឃុំ/ ស្រុកជិតខាងបានមកតាំងទីលំនៅឬធ្វើកសិកម្មអស់រយៈពេលយ៉ាងយូរនៅលើដីវិវាទ។ | ក្រុម១៩២គ្រួសារបានស្វែងរកការគាំទ្រនៅស្ថាប័នជាតិ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការអន្តរជាតិ។ វិវាទកំពុងស្ថិតនៅក្នុងការស៊ើបអង្កេត។ |
| 28 | ១-បវេល<br>២-បឹងប្រាំ<br>៣-ក្រពើ សែសិប | បរិមាណនិង គុណភាព | 1-អ្នកភូមិ<br>2-ឈ្មួញ | ដីកសិកម្ម/ព្រៃ (ជាង៥០០ហិកតា) | អ្នកភូមិជាង៩០គ្រួសារបាន និង កំពុង កាន់កាប់ដីវិវាទអស់ពេលជាយូរមក ហើយ។ នៅឆ្នាំ២០០៤ វិវាទបានចាប់ ផ្តើមនៅពេលដែលឈ្មួញមួយរូបបាន ទាមទារដីនេះថាជាតំបន់អភិវឌ្ឍន៍ របស់ខ្លួន។ | អ្នកភូមិបន្តធ្វើកសិកម្មនៅកន្លែងដីវិវាទ ចំណែកឯឈ្មួញបានដាក់បណ្តឹងនៅតុលាការ។ |

# ៣. ការពិនិត្យមើលឯកសារស្រាវជ្រាវកន្លងមក

## ៣.១ ប្រវត្តិនៃកម្មសិទ្ធិដីធ្លីនៅកម្ពុជា

នៅក្រោមច្បាប់ប្រពៃណីបុរាណ, ដីធ្លីទាំងអស់នៅក្នុងប្រទេសកម្ពុជាត្រូវបានគេទទួលស្គាល់ថាជាកម្មសិទ្ធិរបស់ព្រះមហាក្សត្រ។ ប្រជាពលរដ្ឋទទួលបានសិទ្ធិក្នុងការកាន់កាប់ គឺមានន័យថាពួកគេអាចដាំដុះលើដីដោយសេរី។ ប្រសិនបើពួកគេបានដាំដុះជាបន្តបន្ទាប់លើដីនោះ សិទ្ធិកាន់កាប់របស់ពួកគេត្រូវបានគេទទួលស្គាល់។ ប្រសិនបើដីនោះមិនត្រូវបានដាំដុះអស់រយៈពេលបីឆ្នាំនោះភោគីត្រូវបានបាត់បង់សិទ្ធិកាន់កាប់។ ច្បាប់នេះអនុវត្តអស់ជាច្រើន សតវត្សរហូតដល់បារាំងបានដាក់អាណានិគមនៅសតវត្សទី២០ (Rendall et al, 2003; Pel et al, 2005) ។

កម្មសិទ្ធិឯកជនលើដីធ្លីត្រូវបានគេទទួលស្គាល់ជាលើកដំបូងនៅក្នុងច្បាប់ នៅអំឡុងពេលអាណានិគមបារាំងដោយអនុម័តយកតាមក្រមរដ្ឋប្បវេណីបារាំង។ ប្រព័ន្ធកម្មសិទ្ធិលើទ្រព្យសម្បត្តិពីប្រទេសលោកខាងលិចបានបន្តរហូតដល់ក្រោយពេលដែលទទួលបានឯករាជ្យពីប្រទេសបារាំងនៅឆ្នាំ1953។ នៅពេលជាមួយគ្នានេះដែរក៏មានតំបន់ដែលជាកន្លែងដែលច្បាប់ប្រពៃណីនៅតែត្រូវបានគេអនុវត្តនៅឡើយ។ លំនាំនេះនាំឱ្យមានសហអត្ថិភាពទាំងភាពជាម្ចាស់ដីបែបទំនើប និងសិទ្ធិនៃការកាន់កាប់ដែលមានតាំងពីពេលនោះមក។

របបខ្មែរក្រហមពីខែមេសាឆ្នាំ1975 ដល់ខែមករាឆ្នាំ1979 បានលុបចោលកម្មសិទ្ធិឯកជនទាំងអស់។ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម របបដែលដឹកនាំបន្តបានបង្កើតសេដ្ឋកិច្ចតាមបែបសង្គមនិយម គឺថាទឹកដីទាំងអស់ជាកម្មសិទ្ធិរបស់រដ្ឋ ហើយបន្តដល់ទសវត្សឆ្នាំ1980។ នៅក្រោមប្រព័ន្ធចែកចាយដីដែលគេហៅថា ក្រុមសាមគ្គី គឺថាកសិករត្រូវបានគេបែងចែកជាក្រុម ដើម្បីចែករំលែកដីធ្លី កម្លាំងពលកម្ម និងសត្វពាហណៈ ហើយដីដែលត្រូវបានបែងចែកដល់ក្រុមទាំងនោះដោយមិនគិតពីកម្មសិទ្ធិឬការកាន់កាប់មុនឆ្នាំ1979 ទេ (Amakawa, 2001a, 2001b) ។

## ៣.២ ក្របខ័ណ្ឌច្បាប់ស្តីពីដីធ្លី

រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាបានចែងថាជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិទទួលបានកម្មសិទ្ធិ ដរាបណាមិនមានទំនាស់ផលប្រយោជន៍សាធារណៈ។ នីតិបុគ្គលខ្មែរ និងពលរដ្ឋដែលមានសញ្ជាតិជាខ្មែរទាំងអស់ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។ ជនបរទេសមិនត្រូវបានអនុញ្ញាតជាម្ចាស់កម្មសិទ្ធិលើដីធ្លីនៅកម្ពុជាឡើយ ប៉ុន្តែអាចជាម្ចាស់នៃលំនៅដ្ឋានមួយចំនួនក្នុងអគារសហកម្មសិទ្ធិមួយ ដែលនៅពីលើជាន់ផ្ទាល់ដី ហើយអគារនេះមិនត្រូវសាងសង់លើដីដែលមានចម្ងាយ 30គីឡូម៉ែត្រ ពីព្រំដែនឡើយ។ ជនបរទេសអាចកាន់កាប់បាន

រហូតដល់ទៅ 49% នៃផលចំណេញក្នុងការសាជីវកម្មកម្ពុជា(RGC, 1993; RGC, 2010; RGC Land Law, 2001a)។

ក្នុងឆ្នាំ1989 រដ្ឋាភិបាលថ្មីមួយបានចាប់ផ្តើមសេដ្ឋកិច្ចទីផ្សារ ដែលស្ថិតក្រោមរដ្ឋធម្មនុញ្ញថ្មី និងកម្មវិធីកំណែទម្រង់ដីធ្លី។ នៅឆ្នាំ1989 សេចក្តីណែនាំស្តីពីការអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ត្រូវបានអនុម័ត ហើយកម្មសិទ្ធិលើដីលំនៅដ្ឋានត្រូវបានគេទទួលស្គាល់។ សេចក្តីណែនាំនេះក៏បានទទួលស្គាល់កម្មសិទ្ធិលើដីដែលបានដាំដុះផងដែរ។ ច្បាប់ភូមិបាលឆ្នាំ1992 បានឈានមួយជំហានទៅមុខទៀត ដោយទទួលស្គាល់កម្មសិទ្ធិលើដីលំនៅដ្ឋាន។ នៅខែសីហា ឆ្នាំ2001 រដ្ឋសភាបានអនុម័តច្បាប់ភូមិបាលឆ្នាំ2001 ។

ច្បាប់ភូមិបាលឆ្នាំ2001 កំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុ និងបង្កើតក្របខ័ណ្ឌសម្រាប់ផ្តល់កម្មសិទ្ធិដីធ្លី។ ច្បាប់ នេះទទួលស្គាល់ដីប្រាំប្រភេទសំខាន់ៗ: i)ដីឯកជន; (ii)ដីសាធារណៈរបស់រដ្ឋ (ដែលបម្រើផលប្រយោជន៍សាធារណៈ); (iii) ដីឯកជនរបស់រដ្ឋ; (iv) ដីសមូហភាព; និង (v) ដីរបស់សហគមន៍ជនជាតិដើមភាគតិច(មាត្រា 4-28, ច្បាប់ភូមិបាលឆ្នាំ2001)។ នៅក្រោមច្បាប់ភូមិបាលឆ្នាំ2001 បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈ ដោយសន្តិវិធី និងមិនមានការជំទាស់ - លើកលែងតែដីសាធារណៈរបស់រដ្ឋ-ចាប់ពី ៥(ប្រាំ)ឆ្នាំយ៉ាងតិច គិតមកដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់នេះលើអចលនវត្ថុ ដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុងការកាន់កាប់ជាឯកជនមានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ(មាត្រា 30 ច្បាប់ភូមិបាល 2001)។ ច្បាប់ភូមិបាលឆ្នាំ2001បានពង្រីកកម្ម សិទ្ធិឯកជនលើដីធ្លីលំនៅដ្ឋាន និងកសិកម្ម និងបានបង្កើតប្រព័ន្ធសម្រាប់ការផ្តល់កម្មសិទ្ធិជាលក្ខណៈប្រព័ន្ធលើដីធ្លី និងបង្កើតប្រព័ន្ធដោះស្រាយជម្លោះដ៏ទូលំទូលាយមួយ។ ច្បាប់នេះក៏បានគ្រប់គ្រងលើសិទ្ធិជួលដែរ (RGC, 2001a) ។

ច្បាប់ភូមិបាលឆ្នាំ2001 បានទទួលស្គាល់សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចលើកម្មសិទ្ធិសមូហភាពលើដីរបស់ពួកគាត់ និងសិទ្ធិក្នុងការទាមទារ និងពង្រឹងផលប្រយោជន៍របស់ពួកគេប្រឆាំងនឹងភាគីទីបី។ ដីសហគមន៍ជនជាតិដើមភាគតិចមានរួមបញ្ចូលទាំងដីលំនៅដ្ឋាននិងកសិកម្ម និងរួមបញ្ចូលទាំងដីបម្រុងទុកសម្រាប់ការដាំដុះបែបវិលជុំ។ នៅក្រោមច្បាប់នេះសហគមន៍ជនជាតិដើមភាគតិចអាចនឹងបន្តការគ្រប់គ្រងដីសហគមន៍របស់ខ្លួនតាមប្រពៃណីរបស់ខ្លួន។

នៅឆ្នាំ2003 នេះរាជរដ្ឋាភិបាលបានបង្កើតអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (SLC) ស្របពេលនឹងដំណើរការអនុវត្តការបែងចែកដីធ្លីដែលដឹកនាំដោយធនាគារពិភពលោក សម្រាប់គម្រោងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម(LASED)។ សម្បទានដីសង្គមកិច្ច គឺជាយន្តការមួយក្នុងការផ្តល់ដី

ឯកជនរបស់រដ្ឋទៅដល់ក្រុមគ្រួសារក្រីក្រគ្មានដីធ្លីសម្រាប់លំនៅដ្ឋាន និងកសិកម្ម (Thiel 2009; UNHCR 2007; GTZ 2009)។

បើយោងតាមសមាគមអាដហុក ក្នុងឆ្នាំ2013 តួលេខនៃសម្បទានដីសង្គមកិច្ច ត្រូវបានបង្កើនរហូតដល់ទៅ 485 ដែលបានផ្តល់ជាដីសរុបចំនួន 626,823.26ហិកតា ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រតាមរយៈការផ្ទេរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋសម្រាប់គោលបំណងសង្គមផ្តល់ដល់ជនក្រីក្រដែលខ្វះដីធ្លីលំនៅដ្ឋានឬ/ និងដីកសិកម្មគ្រួសារ ។

ការប៉ាន់ប្រមាណរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក គឺខ្ពស់ជាងការប៉ាន់ប្រមាណដែលបានចេញផ្សាយដោយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ។ អង្គការទិន្នន័យអំពីការអភិវឌ្ឍដែលជាគេហទំព័រ "ទិន្នន័យបើកចំហ" ដែលជួយប្រមែលប្រមូលការទទួលបានព័ត៌មានទាន់ហេតុការអំពីប្រទេសកម្ពុជា បានរាយការណ៍ថា នៅក្នុងខែកញ្ញា ឆ្នាំ2012 មានដីសម្បទានសេដ្ឋកិច្ចចំនួន 337 សម្បទានរុករករ៉ែ 87 និងតំបន់សេដ្ឋកិច្ចពិសេសចំនួន 23 ។ នៅចុងខែធ្នូ ឆ្នាំ2012 រដ្ឋាភិបាលបានបម្រុងទុក ឬផ្តល់ទៅឱ្យក្រុមហ៊ុនឯកជនយ៉ាងហោចណាស់ 2,657,470 ហិកតា (អាដហុក 2013) ។ បើយោងតាមអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ), ទំហំនៃតំបន់សម្បទានដីសេដ្ឋកិច្ចគឺមាន 2.119.082 ហិកតា សម្រាប់ដីសម្បទានចំនួន 272។ (http://www.licadho- cambodia.org/topic/land) ។

## តារាងទី ៣: ទិន្នន័យមួយចំនួនស្តីពីសម្បទានដី

| ប្រភព | ទិន្នន័យក្រសួងកសិកម្មផ្លូវការ | | | ធនាគារពិភពលោក | អង្គការអាដហុក | អង្គការអាដហុក | អង្គការលីកាដូ | អង្គការលីកាដូ |
|---|---|---|---|---|---|---|---|---|
| ខែ/ឆ្នាំ | 04/2010 | 02/2012 | 06/2012 | 2004-2009 | 12/2011 | 12/2012 | 03/2012 | 03/2015 |
| ទំហំដីសរុប | 956,690 ហិកតា | 1,190,000 ហិកតា | 1,181,522 ហិកតា | 958,000 ហិកតា | 2,276,349 ហិកតា | 2,657,470 ហិកតា | 2,036,170 ហិកតា | 2,119,082 ហិកតា |
| ចំនួនក្រុមហ៊ុន | 85 | 118 | 117 | 61 | 225 | ? | 227 | 272 |

ក្រោយមកទៀត នៅក្នុងឆ្នាំ2005 អនុក្រឹត្យលេខ 146 ស្តីពីសម្បទានដីសេដ្ឋកិច្ចបានបង្កើតក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិសម្រាប់ផ្តល់ និងគ្រប់គ្រងសម្បទានដីទ្រង់ទ្រាយធំ ការអភិវឌ្ឍដែលផ្តោតទៅរកទីផ្សារ រួមបញ្ចូលទាំងតម្រូវការ ដើម្បីធ្វើការពិគ្រោះយោបល់ជាសាធារណៈ ព្រមទាំងការវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន (Grimditch et al, 2009; RGC, 2005b)។

នៅឆ្នាំដដែលនេះដែរ អនុក្រឹត្យលេខ118ស្តីពីការគ្រប់គ្រងដីរដ្ឋត្រូវបានបង្កើតឡើងសំដៅការរឹតបន្តឹងសម្បទាន ដីសេដ្ឋកិច្ចមកត្រឹមដីឯកជនរបស់រដ្ឋ។ ប្រសិនបើដីនោះត្រូវបានចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ, រដ្ឋត្រូវតែចាត់ថ្នាក់ឡើងវិញ ថាជាដីឯកជនរបស់រដ្ឋមុនពេលផ្តល់ដីសម្បទានណាមួយ។ អនុក្រឹត្យលេខ 118 បង្កើតអាជ្ញាធរ និងស្ថាប័នជាក់លាក់ ដែលទទួលខុសត្រូវចំពោះការកំណត់អត្តសញ្ញាណ ការធ្វើចំណាត់ថ្នាក់ ការបម្លែង និងការចុះបញ្ជីដីរដ្ឋ ផ្តល់នូវមូលដ្ឋានសម្រាប់ការសហប្រតិបត្តិការអន្តរក្រសួងស្តីពី ការកំណត់ការប្រើប្រាស់ និងគ្រប់គ្រងដីរបស់រដ្ឋ និងរួមបញ្ចូលទាំងនីតិវិធីមួយចំនួនសម្រាប់សុំការអត្ថាធិប្បាយពីសាធារណជន (RGC, 2001a; RGC, 2005a)។

នៅខែឧសភាឆ្នាំ2012 សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចេញសារាចរលេខ ០០១ (ឬបទបញ្ជា ០១ បប) ស្តីពី "វិធានការដើម្បីពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច (ELCs)" ដែលបានប្រកាសពីការផ្អាកបណ្តោះអាសន្នលើការផ្តល់ដីសម្បទានសេដ្ឋកិច្ចថ្មីៗ ពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់និងការអនុវត្តគោលនយោបាយមួយដែលគេហៅថា "ស្បែកខ្លា" ក្នុងគោលបំណងអនុញ្ញាតឱ្យសហគមន៍រស់នៅបានក្នុងរង្វង់ដីសម្បទានទាំងនោះ។ នៅក្នុងក្របខណ្ឌនៃការអនុវត្តបទបញ្ជា 001 មានយុទ្ធនាការចុះបញ្ជីដីធ្លីថ្មីមួយ (គោលនយោបាយចាស់សកម្មភាពថ្មី) ត្រូវបានអនុវត្តដោយយុវជនស្ម័គ្រចិត្ត ដើម្បីបង្កើនល្បឿនដំណើរការនៃការចុះបញ្ជីដី ដែលត្រូវបានធ្វើកាលពីពេលមុនតាមរយៈប្រព័ន្ធចុះបញ្ជីជាលក្ខណៈដាច់ដោយដុំ ឬជាលក្ខណៈប្រព័ន្ធ។ យុទ្ធនាការនេះត្រូវបានរៀបចំ និងផ្តល់ហិរញ្ញប្បទានទាំងស្រុង ដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយគ្មានម្ចាស់ជំនួយពីខាងក្រៅចូលរួមនៅក្នុងការអនុវត្តឡើយ (ADHOC, 2014)។

បន្ទាប់ពីមានការចេញបទបញ្ជា 001 ចំនួនសម្បទានដីសេដ្ឋកិច្ចថ្មីបានធ្លាក់ចុះយ៉ាងខ្លាំង។ បើយោងទៅតាមរាជកិច្ច មានដីសម្បទានសេដ្ឋកិច្ចថ្មីតែ 15 ប៉ុណ្ណោះ ត្រូវបានផ្តល់ពីខែឧសភាដល់ខែធ្នូឆ្នាំ2012 និងមិនមានចាប់តាំងពីខែធ្នូ។ បើតាមព័ត៌មានរបស់អាដហុកឆ្នាំ 2012 បានបង្ហាញថាយ៉ាងហោចណាស់សម្បទានដីសេដ្ឋកិច្ចចំនួន 33 ត្រូវបានផ្តល់ បន្ទាប់ពីការប្រកាសសារាចរលេខ 001 ហើយតួលេខឡើងកាន់តែខ្ពស់ជាងមុន នេះបើយោងតាមប្រភពផ្សេងទៀតដូចជាអង្គការទិន្នន័យអំពីការអភិវឌ្ឍន៍ (ODC) ដែលបានចេញផ្សាយទិន្នន័យដែលទាក់ទងទៅនឹងដីសម្បទានសេដ្ឋកិច្ចដែលទើបតែផ្តល់ចំនួន 38 ក្នុងនោះមានពីរដែលបានផ្តល់នៅឆ្នាំ2013។ ប្រព័ន្ធផ្សព្វផ្សាយបានរាយការណ៍ផងដែរ ស្តីពីសម្បទាន "មិនផ្លូវការ" កន្លងមកថ្មីៗនេះ នៅក្នុងដែនជម្រកសត្វព្រៃលំផាត់ខេត្តរតនគិរី (ADHOC, 2014)។

## ៣.៣ បញ្ហាវិវាទដីធ្លី

មជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ បានចាត់ចំណាត់ថ្នាក់ប្រភេទសំខាន់បីនៃជម្លោះដីធ្លីនៅក្នុងប្រទេសកម្ពុជា ដោយប្រើចំណាត់ថ្នាក់វិវាទដីធ្លីរបស់លោក Ashley ផ្អែកទៅលើបទពិសោធន៍របស់គាត់ក្នុងបញ្ហា ដីធ្លី ក្នុងនាមលោកជាទីប្រឹក្សារបស់គណៈកម្មការសិទ្ធិមនុស្សរបស់រដ្ឋសភានៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ1990 (Ashley, 1999)។ លោកAshley បានពិពណ៌នាអំពីជម្លោះដីធ្លីប្រាំមួយប្រភេទដែលយកមកផ្គុំឱ្យទៅជាបីប្រភេទធំៗ៖

**១. វិវាទរវាងរដ្ឋ និងពលរដ្ឋធម្មតា:** វិវាទប្រភេទនេះត្រូវបានពិពណ៌នាថា មានពីរប្រភេទតូចៗទៀត។ ទី១ មាន "វិវាទដែលអ្នកភូមិកាន់កាប់ដីដែលជាគោលការណ៍គឺជាដីរបស់រដ្ឋ-ដែលរួមទាំងព្រៃ...ដីសម្បទាន ឬដីដែលត្រូវបានប្រើប្រាស់ ឬលៃទុកសម្រាប់ប្រើប្រាស់ជាសាធារណៈ ដូចជា ផ្លូវថ្នល់ ឬសាលារៀនជាដើម។ ការបណ្ដេញប្រជាជនចេញពីដីប្រភេទនេះត្រូវបានគេពិពណ៌នាថាកើតមានឡើង បើសូម្បីអ្នកភូមិបានទទួលដីនោះដោយ សុចរិត និង/ឬបាននឹងកំពុងប្រើប្រាស់ដីនោះអស់រយៈពេលជាច្រើនឆ្នាំក៏ដោយ។ ទី២ ករណីដែលរដ្ឋដកហូតយកដីសម្រាប់ការប្រើប្រាស់ជាសាធារណៈ។ក្នុងករណីនេះ វិវាទកើតឡើងដោយសារអ្នកកំពុងកាន់កាប់ដី នោះបដិសេធមិនព្រមលះបង់ដីរបស់គេទៅឱ្យរដ្ឋ ឬដោយសារតែពួកគេមានការមិនពេញចិត្តនឹងសំណងដែល រដ្ឋបានផ្ដល់ឱ្យ។

**២. វិវាទរវាងប្រជាពលរដ្ឋ និងអ្នកតំណាងរបស់រដ្ឋ ដែលធ្វើសំរាប់ផលប្រយោជន៍ផ្ទាល់ខ្លួនជាអន្តរ ការីឱ្យវិស័យឯកជន:** លោក Ashley បានកត់សម្គាល់ថា ពាក្យបណ្ដឹងជាច្រើនដាក់ទៅសភាជាតិពាក់ព័ន្ធនឹងបុគ្គលដែលជាយោធា ឬកងប្រដាប់អាវុធផ្សេងៗទៀត របស់រដ្ឋាភិបាលដែលបានដកហូតដីដោយបង្ខំសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន។ ក្នុងករណីបែបនោះ ភាពខុសគ្នារវាងផ្នែកឯកជន និងរដ្ឋមិនមានភាពច្បាស់លាស់ទេ ដោយសារមន្ត្រីរបស់រដ្ឋាភិបាលបានចូលរួមដោយផ្ទាល់នៅក្នុងសកម្មភាពរបស់វិស័យឯកជន ឬដើរតួក្នុងរូបភាពសហការយ៉ាងជិតស្និទ្ធជាមួយវិនិយោគិន (CAS/WB, 2006)។ ប្រភេទវិវាទទាំងពីរខាងដើមនេះ ហាក់មានភាពត្រួតស៊ីគ្នាច្រើនព្រោះថាវិវាទដែលបានពណ៌នាក្នុងប្រភេទទី១ នឹងកើតឡើងដោយសារផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុបានទៅដល់មន្ត្រីរដ្ឋាភិបាលតាមរយៈដំណើរការដែលពាក់ព័ន្ធ។ នៅក្នុងប្រភេទទី១ និងទី២ លោក Ashley បានពិពណ៌នាអំពីករណីជាច្រើន រួមមានទាំងករណីដែលបណ្ដឹងស្រប

ច្បាប់របស់អ្នកភូមិមានភាពច្បាស់លាស់ជាងបណ្តឹងដទៃទៀត រហូតដល់ករណី ដែលច្របូកច្របល់ដោយសារសង្គ្រាមនិងភាពក្រីក្រ។

**៣. វិវាទពាក់ព័ន្ធនឹងភាគីឯកជន**: លោក Ashley ពណ៌នាអំពីវិវាទធំៗពីរ ដែលពាក់ព័ន្ធនឹងភាគីឯកជន។ ប្រភេទទី១ គឺទាក់ទិនទៅនឹងការប៉ុនប៉ងទាមទារយកវិញនូវទ្រព្យសម្បត្តិ ដែលធ្លាប់មានពីមុនសម័យរបបខ្មែរក្រហម ជាក់ស្តែងណាស់ វិវាទទាំងនេះគឺមានលក្ខណៈទូទៅនៅដើមទសវត្សរ៍ឆ្នាំ1990 ប៉ុន្តែមានភាពស្ងប់ស្ងៀមរួចហើយនៅក្នុងពេលវេលារបស់លោក។ វិវាទប្រភេទទីពីរ អាចហៅបានថាជា "វិវាទតូចតាចផ្សេងទៀត" ដែលក្នុងប្រភេទនេះមានវិវាទតូចៗ ជាច្រើនអំពីបញ្ហាព្រំដី កេរ្តិ៍មរតក, និងការកាន់កាប់ដីជាដើម។

នៅក្នុងឆ្នាំ២០១៣ សមាគមអាដហុកបានដោះស្រាយករណីទំនាស់ដីធ្លីសរុបចំនួន ១៣៥ ដែលប៉ះពាល់លើដីសរុបចំនួន៣៦៨៦៥ហិកតា និង ៦៥៨៨គ្រួសារ។ វិវាទទាំងនេះប្រមូលផ្តុំនៅក្នុងភាគខាងជើង និងភាគឦសាននៃប្រទេសរួមមាន ខេត្តរតនគិរី ព្រះវិហារ និងខេត្តសៀមរាប ដែលរងផលប៉ះពាល់ច្រើនបំផុត។ ក្នុងចំណោម ១៣៥ករណីមាន ៩៧ករណីជាករណីរំលោភយកដីធ្លី និង២៩ករណីទាក់ទងទៅនឹងសម្បទានដីសេដ្ឋកិច្ច ២ករណីទាក់ទងនឹងសម្បទានដីសង្គមកិច្ច ៦ករណីទាក់ទងទៅនឹងការបណ្តេញចេញដោយបង្ខំ និងមានមួយករណីដែលទាក់ទងទៅនឹងការនេសាទ។ សមាគមអាដហុកបានកត់សំគាល់ឃើញមានការកើនឡើង ៥៨ភាគរយ បើធៀបទៅនឹងជម្លោះដីធ្លីនៅឆ្នាំ២០១២ (នៅពេលដែលអាដហុកបានដោះស្រាយ ៧០ ករណីជម្លោះដីធ្លី ដែលប៉ះពាល់លើផ្ទៃដីចំនួនសរុប ១០១៥០៨ហិកតា និង១០៦៨៩គ្រួសារ)។ នៅក្នុងបីខែដំបូងនៃឆ្នាំ ២០១៤ នេះសមាគមអាដហុកបានកត់ត្រាជម្លោះដីធ្លីថ្មីចំនួន ៣៧ ដែលប៉ះពាល់ដល់ ២៦១៧គ្រួសារស្មើនឹងយ៉ាងហោចណាស់ 6.470នាក់ លើទំហំដីសរុបចំនួន ៥,៩៥១.៥១៦ ហិកតា (ADHOC, 2014)។

យោងតាមការស្រាវជ្រាវរបស់មជ្ឈមណ្ឌលព័ត៌មានរបស់ NGOF ករណីវិវាទដីថ្មីចំនួន ២៨ ត្រូវបានកត់ត្រានៅដើមឆ្នាំ២០១៣។ ចំនួននេះមានកម្រិតទាបបើប្រៀបធៀបទៅនឹងករណីដែលមានក្នុងអំឡុងពេលឆ្នាំ២០១០មាន៣៩ករណីឆ្នាំ២០១១ មាន៣៩ករណីនិងឆ្នាំ២០១២មាន៤៦ករណី។ ចំនួនសរុបនៃជម្លោះដីធ្លីនៅឆ្នាំ២០១៣ មាន ៤០៥ ករណី ដោយរាប់ទាំងករណីសេសសល់ក្នុងអំឡុងពេលប៉ុន្មានឆ្នាំមុននេះ។ ក្នុងនោះមាន ៨១ករណីត្រូវបានដោះស្រាយនៅក្នុងឆ្នាំ២០១៣

និង១៣ ករណីទំនាស់ដីធ្លីត្រូវបានគេបោះបង់ចោល។ ជាលទ្ធផលក្នុងចំណោម ៤០៥ ករណីនៃជម្លោះដីសរុបនេះបានកត់ត្រាមាន ៧៧ភាគរយ ស្មើនឹង ៣១១ករណីមិនត្រូវបានគេដោះស្រាយយ៉ាងពេញ លេញនៅឆ្នាំ ២០១៣ ទេ (NGO Forum 2014) ។

## ៣.៤ យន្តការដោះស្រាយវិវាទដីធ្លី

កាលពីខែកក្កដា ឆ្នាំ2009 រាជរដ្ឋាភិបាលកម្ពុជាបានចេញ "សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយធ្លី"។ ចក្ខុវិស័យនៃគោលនយោបាយដីធ្លីនៅក្នុងប្រទេសកម្ពុជាគឺ "ដើម្បីគ្រប់គ្រង ប្រើប្រាស់និងបែងចែកដីប្រកបដោយសមធម៌ មានតម្លាភាព មានប្រសិទ្ធិភាព និងប្រកបដោយនិរន្តរភាព នៅក្នុងគោលបំណងរួមចំណែកក្នុងការសម្រេចបានគោលដៅនៃការកាត់បន្ថយភាពក្រីក្រថ្នាក់ជាតិ ក្នុងការធានាសន្តិសុខស្បៀង ធនធានធម្មជាតិ និងការពារបរិស្ថានការពារជាតិ និងអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមក្នុងបរិបទសេដ្ឋកិច្ចទីផ្សារ »។

ក្រុមប្រឹក្សាសម្រាប់គោលនយោបាយដីធ្លី មានកាតព្វកិច្ចលើកកម្ពស់ និងត្រួតពិនិត្យការអនុវត្តគោល នយោបាយដីធ្លីដោយអនុលោមតាមទិសដៅនៃឧត្តមក្រុមប្រឹក្សា កំណែទម្រង់របស់រដ្ឋក៏ដូចជា ការសម្របសម្រួលក្នុងចំណោមអនុគណៈកម្មការទាំងបី (រដ្ឋបាលដីធ្លី, ការគ្រប់គ្រងដីធ្លី និងការចែកចាយដី) ដើម្បីពង្រឹងការអនុវត្តច្បាប់ដីធ្លី និងច្បាប់ផ្សេងទៀតដែលទាក់ទងទៅនឹងបរិស្ថាន ព្រៃឈើ ជលផល ធនធានទឹក ក្រមរដ្ឋប្បវេណី វិមជ្ឈការ និងសហវិមជ្ឈការ(RGC, 2009)។

យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី 3 របស់រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានសង្កត់ធ្ងន់លើការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការបន្តកម្មវិធីកំណែទម្រង់ដីធ្លី ក្នុងគោលបំណងពង្រឹងប្រព័ន្ធនៃការគ្រប់គ្រងដីធ្លី ការចែកចែក និងការប្រើប្រាស់ដី, ការធានាបាននូវសុវត្ថិភាពក្នុងការផ្តល់កម្មសិទ្ធិ ការលុបបំបាត់ការទន្ទ្រានយកដីដោយខុសច្បាប់និងអនាធិបតេយ្យ និងការទប់ស្កាត់ការប្រើប្រាស់មិនត្រឹមត្រូវនៃការកាន់កាប់ ការកាន់កាប់ដីសម្បទានសម្រាប់គោលបំណងទុកលក់ដូរដើម្បីផលចំណេញ ឬគ្មានគោលបំណងផលិតភាពណាមួយច្បាស់លាស់។ យុទ្ធសាស្រ្តនេះក៏ផ្តល់នូវសកម្មភាពនានាសម្រាប់ការសម្រេចបាននូវគោលបំណងដែលបានរៀបរាប់ខាងលើនេះ។

## «យុទ្ធសាស្ត្រចតុកោណ» ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅកម្ពុជាដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា

### មុំទី៣. ការកែទម្រង់ដីធ្លី ការបោសសម្អាត មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

៦២- គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺការបន្តធ្វើកំណែទម្រង់ដីធ្លី ដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រង, បែងចែក និងប្រើប្រាស់ដីធ្លី, ធានាសុវត្ថិភាពនៃកម្មសិទ្ធិដី, លុបបំបាត់ភាពអនាធិបតេយ្យ ក្នុងការកាន់កាប់ដីដោយខុសច្បាប់ និងទប់ស្កាត់ ការប្រមូលដីទុកដោយមិនបានប្រើប្រាស់ និងមិនផលិតព្រមទាំងបន្តបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ដែលត្រូវបានកំណត់ជាគោលដៅទី៩ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។

៦៣-ក្នុងនីតិកាលកន្លងទៅរាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលធំៗ ជាច្រើនគួរឲ្យកត់សម្គាល់ មានជាអាទិ៍៖ ការអនុម័តច្បាប់ស្តីពី អស្សាមិករណ៍ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗពាក់ព័ន្ធនឹងវិស័យនគរូបនីយកម្មសំណង់ និងវិស័យដីធ្លី, ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីចំនួនជាង ៣ លានប័ណ្ណ តាមរយៈការចុះបញ្ជីនៅក្នុងក្របខណ្ឌផែនការទូទៅ និងការអនុវត្ត «គោលនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី» ការបែងចែកដីក្រោមរូបភាពសម្បទានដីសង្គមកិច្ច និងការធ្វើប្រទានកម្ម ដែលមានចំនួនសរុបជាង ៥៣ពាន់គ្រួសារ, ការចុះបញ្ជីរដ្ឋទំហំធំៗ, ការចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ច, ការចុះបញ្ជីសិទ្ធិជួលរយៈពេលវែង និងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ និងកាត់បន្ថយវិវាទដីធ្លីតាមរយៈយន្តការដែលមានស្រាប់ និងក្នុងក្របខណ្ឌ «គោលនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី»។ ដោយឡែកលទ្ធផលក្នុងការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ដើម្បីគោលដៅនៃការបង្កើនផ្ទៃដីសម្រាប់ការអភិវឌ្ឍត្រូវបានរំលេចតាមរយៈការកើនឡើងគួរឲ្យកត់សម្គាល់នៃទំហំផ្ទៃដី ដែលត្រូវបានបោសសម្អាតរួចពីមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមសម្រាប់គម្រោងវិនិយោគសាធារណៈលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគម្រោងវិនិយោគពាក់ព័ន្ធផ្សេងទៀត។

៦៤- ទន្ទឹមនឹងការសម្រេចបានសមិទ្ធផល ដូចខាងលើកម្ពុជានៅមានភាពចាំបាច់ក្នុងការបន្តដោះស្រាយបញ្ហាប្រឈមមួយចំនួនជាអាទិ៍ភាព មិនទាន់ស៊ីសង្វាក់គ្នាលើការធ្វើបច្ចុប្បន្នកម្មប្រព័ន្ធព័ត៌មានដីធ្លី, ការសម្របសម្រួលខាងស្ថាប័ន, ការដោះស្រាយវិវាទដីធ្លី, សេចក្តីត្រូវការក្នុងការបង្កើនមធ្យោបាយ និងធនធានមនុស្សសម្រាប់ការវាស់វែងដីធ្លីព្រមទាំងសេចក្តីត្រូវការក្នុងការបន្តបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម។

៦៥- លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនីតិកាលទី៥ និងបន្តអនុវត្តកាន់តែសកម្ម និងស៊ីជម្រៅថែមទៀតនូវការកែទម្រង់ដីធ្លី ដោយផ្តោតលើការពង្រឹងការគ្រប់គ្រង, ការរៀបចំ, ការប្រើប្រាស់ និងការបែងចែកដីធ្លី ដើម្បីរួមចំណែកធ្វើឲ្យសម្រេចគោលដៅជាតិ ក្នុងការកាត់បន្ថយភាពក្រីក្រ, ការធានាសន្តិសុខស្បៀង, ការការពារបរិស្ថាន និងធនធានធម្មជាតិ និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចក្នុងបរិការណ៍នៃសេដ្ឋកិច្ចទីផ្សារ។

៦៦-ដើម្បីសម្រេចគោលដៅនេះ រាជ រដ្ឋាភិបាលនឹងផ្តោតអាទិភាពទៅលើ៖

ទី១- ការជំរុញរៀបចំគោលនយោបាយដី ធ្លីទូលំទូលាយ «សៀវភៅសដីធ្លី»។

ទី២- ការជំរុញរៀបចំច្បាប់ស្តីពីការរៀបចំដែនដី និងនគរូបនីយកម្ម និងច្បាប់ស្តីពីដីកសិកម្ម។

ទី៣-ការបន្តជំរុញល្បឿននៃការចុះបញ្ជី និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ទាំងដីរដ្ឋ ដីឯកជន និងដីសហគមន៍ជនជាតិដើមភាគតិច តាមរយៈការចុះបញ្ជីនៅក្នុងក្របខណ្ឌផែនការទូទៅ និងការបន្តអនុវត្ត «គោលនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី» ដោយផ្តល់អាទិភាពលើតំបន់ដែលគ្មានវិវាទ ដើម្បីធានា សុវត្ថិភាព និងទំនុកចិត្តក្នុងការកាន់កាប់ដីធ្លី។

ទី៤-ការបន្តជំរុញកសាងទិន្នន័យអំពីការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដើម្បីជាមូលដ្ឋានច្បាស់លាស់ក្នុងការរៀបចំផែនការប្រើប្រាស់ និងបែងចែកដីធ្លីឲ្យបានត្រឹមត្រូវជាអាទិ៍ដីសម្រាប់កសិកម្ម, ឧស្សាហកម្ម, ទេសចរណ៍, ជនបទ, ទីក្រុង, លំនៅឋាន និងតំបន់អភិរក្ស សំដៅធ្វើវិចារណកម្មនៃការប្រើប្រាស់ដី, ចៀសវាងការប្រើប្រាស់ដី និងការបំប្លែង ការប្រើប្រាស់ដីមិនចំសក្តានុពល។ ការយកចិត្តទុកដាក់នឹងត្រូវផ្តោតទៅលើការបន្តជំរុញកិច្ចស្រាវជ្រាវ និងការរៀបចំចំណាត់ថ្នាក់ដីទៅតាមប្រភេទមានសក្តានុពលអំណោយផលដល់ផលិតកម្មកសិកម្មតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ទី៥-ការបន្តធានាការគ្រប់គ្រង, ការការពារ និងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិប្រកបដោយតម្លាភាព និងប្រសិទ្ធភាព ដើម្បីរក្សាចីរភាពបរិស្ថាន និងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ព្រមទាំងការទប់ស្កាត់រាល់ការកាប់ទន្ទ្រានដីព្រៃ និងការចាត់វិធានការតឹងរឹង ចំពោះបុគ្គលដែលរំលោភកាន់កាប់ដីគ្រប់ប្រភេទដោយខុសច្បាប់ និងប្រមូលដីទុកមិនផលិត រួមទាំងការបន្តដកហូតមកវិញនូវសម្បទានដីសេដ្ឋកិច្ចដែលក្រុមហ៊ុនមិនគោរពតាមកិច្ចសន្យា និងបទដ្ឋានគតិយុត្តជាធរមានទន្ទឹមនឹងការឈប់ផ្តល់ថែមទៀតនូវសម្បទានដីសេដ្ឋកិច្ច។

ទី៦-ការបន្តបែងចែកនិងប្រើប្រាស់ដីរដ្ឋ ជាពិសេសដីសម្បទានសេដ្ឋកិច្ចដែលត្រូវបានដកហូតមកវិញ និងផ្ទៃដីដែលត្រូវបានបោសសម្អាតរួចពីមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ដើម្បីបម្រើប្រយោជន៍នៃការអភិវឌ្ឍប្រកបដោយតម្លាភាព និងសមធម៌ ឆ្លើយតបទៅនឹងសេចក្តីត្រូវ

ការរបស់ប្រជាជនក្រីក្រ, យោធិនពិការ, គ្រួសារយោធាពលី និងមរណៈ និងអតីតកងកម្លាំងប្រដាប់អាវុធ ដែលគ្មាន ឬខ្វះដីពិតប្រាកដ តាមរយៈការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច និងការធ្វើប្រទានកម្ម។

ទី៧- ការបន្តអនុវត្តគោលនយោបាយមិនយកពន្ធលើដីកសិកម្មជាលក្ខណៈគ្រួសារ និងការបន្តជួយប្រជាកសិករ ក្នុងការលើកកម្ពស់ផលិតភាពនៃការប្រើប្រាស់ដី តាមរយៈការសាងសង់ប្រព័ន្ធគមនាគមន៍ផ្លូវថ្នល់, ធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ផ្សេងទៀត។

ទី៨- ការបន្តដោះស្រាយវិវាទដីធ្លីប្រកបដោយប្រសិទ្ធភាព, តម្លាភាព និងយុត្តិធម៌ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន តាមរយៈយន្តការដោះស្រាយវិវាទដីធ្លីទាំងក្នុង និងក្រៅប្រព័ន្ធតុលាការ។

ទី៩- ការបន្តជំរុញអនុវត្ត « ផែនការយុទ្ធសាស្ត្រ ជាតិសកម្មភាពមីន២០១០-២០១៩» ជាពិសេសការបន្តបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ដើម្បីបង្កើនផ្ទៃដីដាំដុះធានាសុវត្ថិភាពក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងកាត់បន្ថយបន្ថែមទៀតនូវអត្រាគ្រោះថ្នាក់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម។

ចាប់តាំងពីឆ្នាំ1985 រដ្ឋាភិបាលនៃប្រទេសកម្ពុជាបានប្រឹងប្រែងអនុវត្តវិស័យអាទិភាពចំនួនបីសំខាន់សម្រាប់ការធ្វើកំណែទម្រង់ដីធ្លីៈ ការងាររដ្ឋបាលដីធ្លី, ការគ្រប់គ្រងដីធ្លី និងការបែងចែកដីធ្លី។ នៅខែមិថុនាឆ្នាំ2002 ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) បានបង្កើតគម្រោងរៀបចំដែនដីនិងរដ្ឋបាលដីធ្លី (LMAP) បច្ចុប្បន្នហៅថា កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី (LASSP) ដោយមានគោលដៅនៃការធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពកម្មសិទ្ធិដីធ្លី និង ជំរុញការអភិវឌ្ឍទីផ្សារដីធ្លីប្រកបដោយប្រសិទ្ធិផល។ LMAP ចែកចេញជាប្រាំផ្នែក។ ក្នុងចំណោមនេះមានផ្នែកទី៤ ដែលស្តីពី "ការពង្រឹងយន្តការសម្រាប់ដោះស្រាយវិវាទ" ត្រូវបានបង្កើតឡើងជាការឆ្លើយតបដោយផ្ទាល់ទៅនឹងបញ្ហា នៃដំណោះស្រាយវិវាទដីធ្លីដែលបានពណ៌នាខាងដើម។ គោលបំណងដ៏សំខាន់របស់ផ្នែកនេះ គឺដើម្បីធានាថាវិវាទដីធ្លី "ត្រូវបានដោះស្រាយយ៉ាងឆាប់រហ័ស និងមានការពេញចិត្តរបស់ភាគីពាក់ព័ន្ធ"។ ដើម្បីសម្រេចគោលបំណងនេះ ឯកសារនៃគម្រោង LMAP គ្រោងរៀបចំសកម្មភាពដែលផ្តោតសំខាន់លើការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី (Adler et al, 2006) ។

អង្គការ NGO Forum បានគូសបញ្ជាក់ពីយន្តការដោះស្រាយវិវាទដីធ្លីជាផ្លូវការចំនួនប្រាំមាននៅក្នុងប្រទេសកម្ពុជារួមមាន៖ ក្រុមប្រឹក្សាឃុំ/សង្កាត់ គណៈកម្មការសុរិយោដី គណៈកម្មការរដ្ឋបាល អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងតុលាការ។ អាណត្តិរបស់**ក្រុមប្រឹក្សាឃុំ/សង្កាត់** គឺដើម្បីផ្សះផ្សានូវគំនិតដែលផ្ទុយនៅក្នុងចំណោមប្រជាពលរដ្ឋនៅក្នុងឃុំ ប៉ុន្តែពុំមានអំណាចធ្វើសេចក្តីសម្រេចចិត្តណាមួយទេ។ (Art. 6, No 47 ANK.BK /May 31, 2002 អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។ **គណៈកម្មការសុរិយោដី** មានបេសកម្មដោះស្រាយវិវាទលើដីដែលមិនបានចុះបញ្ជី។ គណៈកម្មការសុរិយោដីមាននៅកម្រិតថ្នាក់ស្រុក/ខណ្ឌ "គណៈកម្មការសុរិយោដីស្រុក"(DKCC)", នៅកម្រិតខេត្ត/ក្រុង "គណៈកម្មការសុរិយោដីខេត្ត/ក្រុង "(PMCC)" និងនៅកម្រិតថ្នាក់ជាតិ "គណៈកម្មការសុរិយោដីថ្នាក់ជាតិ" (NCC) ។ **គណៈកម្មការរដ្ឋបាល** មិនមែនជាយន្តការដោះស្រាយជម្លោះ អចិន្ត្រៃយ៍នោះទេ។

ការបង្កើតគណៈកម្មការរដ្ឋបាលនេះ គឺមានលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះក្នុងអំឡុងពេលដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ ចំនួននៃគណៈកម្មការរដ្ឋបាល នេះឆ្លើយតបគ្នាទៅនឹងចំនួននៃឃុំដែលជាកន្លែងដែលចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធត្រូវបានអនុវត្ត។ **អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី** (NALDR) មានយុត្តាធិការលើករណីទាំងឡាយដែល«ស្ថិតនៅក្រៅយុត្តាធិការ» របស់គណៈកម្មការសុរិយោដី ឬតុលាការ។ **តុលាការ** មានអាណត្តិដោះស្រាយវិវាទលើដីដែលមានប័ណ្ណកម្មសិទ្ធិ។ មានយុត្តាធិការបើកម្រិតនៃការដោះស្រាយតាមប្រព័ន្ធតុលាការពោលគឺសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល (NGO Forum, 2014)។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពី កម្ពុជាបានកត់សម្គាល់ថា ជាក់ស្តែងពាក្យបណ្តឹងត្រូវបានដាក់ជូនទៅអាជ្ញាធរជាច្រើន ដែលនៅក្នុងទ្រឹស្តីពុំមានដែនយុត្តាធិការក្នុងការដោះស្រាយវិវាទដីធ្លី។ ក្នុងករណីជាច្រើនពាក្យបណ្តឹងត្រូវបានបញ្ជូនព្រមៗគ្នាទៅឱ្យអាជ្ញាធរខុសៗគ្នា។

យោងតាមរបាយការណ៍មួយពីខែកញ្ញា ឆ្នាំ2013 របស់អង្គការ GIZ កម្ពុជា គណៈកម្មការសុរិយោដីបានទទួលបណ្តឹងជិត 5,000 ករណី និងបានដោះស្រាយបានច្រើនជាង 2.500ករណី។ ក្នុងចំណោមករណីទាំងនេះ មានជិត 400 ករណីជាប់ពាក់ព័ន្ធនឹងភាគីជម្លោះដែលជាញឹកញាប់ គឺរវាងក្រុមអ្នកភូមិដែលប្រឆាំងនឹងអ្នកមានអំណាច។ ដោយសារវិវាទដីធ្លីមានការកើនឡើង ហើយ

ករណីដែលដំណោះស្រាយបានរាយការណ៍មានប្រហែល 50ភាគរយ ។ ដូចនេះកំណត់ត្រារបស់គណៈកម្មការសុរិយោដីបង្ហាញពីការរីកចម្រើន (GIZ, 2013)។

ការសិក្សាដែលធ្វើដោយធនាគារពិភពលោក មជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ និងអង្គការ GTZ បានរកឃើញថា គណៈកម្មការសុរិយោដីមានកំណត់ត្រាល្អប្រសើរជាងមុនក្នុងការការដោះស្រាយជម្លោះដីតូចៗ តែក៏ខំពុះពារដើម្បីដោះស្រាយករណីស្មុគស្មាញ ជាពិសេសករណីដែលពាក់ព័ន្ធនឹងពហុភាគីវិវាទនឹងភាគីដែលមានខ្សែជាមន្ត្រីរដ្ឋាភិបាល ឬយោធា។ របាយការណ៍ដដែលបញ្ជាក់ថា ខណៈពេលដែលករណីវិវាទអាចនឹងធ្លាក់ចុះទៅក្រោមយុត្តាធិការនៃគណៈកម្មការសុរិយោដី ភាគីទន់ខ្សោយមិនអាចដាក់ពាក្យប្តឹងដោយសារតែកង្វះការជឿជាក់នៅក្នុងដំណើរការ និងលទ្ធផលដោះស្រាយ (CAS and WB, 2006)។ ការសិក្សាមួយទៀតរបស់ធនាគារពិភពលោកបានរកឃើញថា មនុស្សដែលពាក់ព័ន្ធនៅក្នុងវិវាទដីធ្លីជៀសវាងពីការដាក់ពាក្យបណ្តឹងដោយសារតែ «ស្ថាប័នយុត្តិធម៌ផ្លូវការនានាដូចជាគណៈកម្មការសុរិយោដីឬតុលាការនេះត្រូវបានគេយល់ថា មានតម្លៃថ្លៃចំណាយពេលវេលាច្រើន និងលំអៀងទៅខាងអ្នកមាន "(CAS / WB 2006a) ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានសន្និដ្ឋានថា ប្រជាជនកម្ពុជាដែលបានផ្លាស់ទីលំនៅ ឬមានហានិភ័យក្នុងការផ្លាស់ទីលំនៅដោយសារការផ្តល់ដីសម្បទានសេដ្ឋកិច្ច និងការរឹបអូសដីធ្លីមិនបានប្រើប្រាស់ និងទទួលផលប្រយោជន៍ពីយន្តការដោះស្រាយវិវាទទេ។ បរាជ័យក្នុងការការពារ និងផ្តល់ឱ្យភាគីវិវាទទទួលបាននូវការដោះស្រាយតាមផ្លូវច្បាប់ ជាពិសេសសម្រាប់សហគមន៍ក្រីក្រ និងចាញ់ប្រៀបគេគឺជាការរំលោភយ៉ាងច្បាស់នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជា។ អវត្តមាននៃយន្តការសម្រាប់ដោះស្រាយជម្លោះដីធ្លី ដែលប្រកបដោយប្រសិទ្ធភាពឯករាជ្យ និងអាចពឹងពាក់បានសហគមន៍ក្រីក្របំផុត និងដែលងាយរងគ្រោះបំផុតនឹងនៅតែប្រឈមហានិភ័យនឹងការលែងមានកម្មសិទ្ធិលើដីរបស់ពួកគាត់ ហើយត្រូវគេប្តូរទីលំនៅចេញដោយនិទណ្ឌភាព (CCHR,2014)។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) គឺជាស្ថាប័នសម្រាប់ទំនាក់ទំនងរវាងរាជរដ្ឋាភិបាល និងបណ្តាប្រទេសម្ចាស់ជំនួយ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងជាស្ថាប័នសម្រាប់ជួយសំរួលការទំនាក់ទំនងរវាងក្រសួង និងស្ថាប័នរដ្ឋាភិបាលផ្សេងទៀត នៅក្នុងការសម្របសម្រួល

នៃជំនួយអភិវឌ្ឍន៍។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក៏ទទួលខុសត្រូវចំពោះគម្រោងវិនិយោគទាំងអស់នៅក្នុងប្រទេសកម្ពុជារួមមានវិស័យកសិកម្ម និងកសិឧស្សាហកម្ម (GTZ, 2009) ។

## ៣.៥ ផលប៉ះពាល់

ទោះបីជារដ្ឋាភិបាលបានព្យាយាម ដើម្បីកសាងឡើងវិញ និងការកែលម្អការគ្រប់គ្រងដីធ្លីគិតចាប់តាំងពីឆ្នាំ1989 ក៏ដោយ តែកម្មសិទ្ធិដីធ្លីនៅតែជាបញ្ហាចម្រូងចម្រាស់យ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងពេលជាមួយគ្នានោះដែរ កំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សនាំឱ្យមានកំណើនតម្រូវការដីធ្លី។ ចំណែកឯនៅក្នុងប្រទេសកម្ពុជាចំនួននៅតំបន់ជនបទប្រជាជនជាង80% ប្រកបរបរកសិកម្មដើម្បីចិញ្ចឹមជីវិត ដែលនាំឱ្យអសន្តិសុខក្នុងការកាន់កាប់ដីធ្លីនេះបានកើនឡើង។

លើសពីនេះទៅទៀត បើយោងតាមរាជរដ្ឋាភិបាលកម្ពុជារហូតមកដល់ខែកញ្ញាឆ្នាំ2013 កម្មវិធីចុះបញ្ជីដីធ្លីបានចេញប័ណ្ណកម្មសិទ្ធិដីធ្លីច្រើនជាងបីលាន (សុន្ទរកថារបស់សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជាណាចក្រកម្ពុជាស្តីពី "យុទ្ធសាស្ត្រចតុកោណ" ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា(25 កញ្ញា 2013), http://bit.ly/HxsV9U) ។ ទោះយ៉ាងណា មានក្បាលដីជាច្រើនត្រូវបានដកចេញ ពីកម្មវិធីចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធនៅក្រោមហេតុផល "មានភាពស្មុគស្មាញពេក" ឬ "ស្ថានភាពមិនច្បាស់លាស់" (ឧទាហរណ៍ក្បាលដីជាប់នឹងដីរដ្ឋដែលមិនទាន់បានកំណត់ព្រំដែននៅឡើយ ឬមានច្រើននាក់ទាមទារកម្មសិទ្ធិលើដីនេះ)។ មិនមានបញ្ញត្តិក្នុងច្បាប់ដែលចាត់ទុកទីកដីមួយថា: ″ស្មុគ្រស្មាញពេក″ ឬ ″ស្ថានភាពមិនច្បាស់លាស់″ នោះទេ។ ជាលទ្ធផលគ្រួសារងាយរងគ្រោះដោយ ការបណ្តេញចេញពាក់ព័ន្ធវិវាទដីធ្លីត្រូវបានផាត់ចេញពីកម្មវិធីផ្តល់កម្មសិទ្ធិ (CCHR, 2013) ។

បញ្ហាវិវាទដីធ្លីបណ្តាលឱយមានភាពគ្មានដីធ្លី។ មិនមានទិន្នន័យថ្នាក់ជាតិ ដែលអាចជឿទុកចិត្តបានអំពីចំនួនប្រជាជនដែលគ្មានដីនៅក្នុងប្រទេសកម្ពុជាទេ ប៉ុន្តែគេប៉ាន់ប្រមាណថាភាពគ្មានដីធ្លីបានកើនឡើងពី 20% ទៅ 40% នៃគ្រួសារជនបទដែលគ្មានដីនៅក្នុងឆ្នាំ 2009 (GTZ, 2009)។

ភាពគ្មានដីធ្លីដោយអចេតនា និងភាពសឹងតែគ្មានដីធ្លីត្រូវបានចាត់ទុកថា ជាដើមហេតុបឋមបណ្តាលឱ្យមានភាពក្រីក្រ និងការអភិវឌ្ឍន៍ធនធានមនុស្សខ្សោយនៅក្នុងប្រទេសកម្ពុជា។ ក្រុមគ្រួសារវ័យក្មេង និងស្ត្រីមេគ្រួសារភាគច្រើនជាអ្នកគ្មានដី ឬ សឹងតែគ្មានដី(USAID, 2011) ។ ក្នុងសំណាកគំរូនៃការស្ទង់មតិមួយរបស់អង្គការ Oxfam, ក្នុងចំណោម ៨ គ្រួសារ មានមួយគ្រួសារ

ដែលគ្មានដី។ ចំណែកឯ 21% ឬស្ត្រីមេគ្រួសារម្នាក់ក្នុងចំណោម៥នាក់ គឺគ្មានដីធ្លី (GTZ, 2009; ADB, 2004) ។

ទីភ្នាក់ងារ USAID បានមើលឃើញពីមូលហេតុសំខាន់ពីរ នៃការកើនឡើងនៃភាពគ្មានដីធ្លី។ ទី១ កំណើនចំនួនប្រជាជន(ពីប្រាំបីលាននាក់នៅចុងឆ្នាំ1980 ទៅ 14លាននាក់នាពេលបច្ចុប្បន្ននេះ) នាំឱ្យមានការកើនឡើងនូវតម្រូវ ការខាងដីធ្លីដែរ។ គ្រួសារមួយចំនួនបានទាយយកប្រយោជន៍ការកើនឡើងនៃតម្លៃ និងការលក់ដីរបស់ពួកគេដើម្បីធ្វើការវិនិយោគកម្លាំងពលកម្ម និងដើមទុនរបស់ខ្លួនទៅក្នុងសកម្មភាពផលិតប្រាក់ចំណូលផ្សេងទៀត។ ទីពីរ មាន ករណីជាច្រើន ភាពគ្មានដីធ្លីគឺជាលទ្ធផលនៃអសុវត្ថិភាពក្នុងការកាន់កាប់ដី។ ជនក្រីក្រជាញឹកញាប់មិនមានឯកសារផ្លូវច្បាប់ ដើម្បីគាំទ្រការអះអាងក្នុងការតវ៉ារឿងដីធ្លីរបស់ពួកគេ និងការខ្វះជំនឿលើប្រព័ន្ធតុលាការ។ គ្រួសារក្រីក្រមួយចំនួនតូចបានបញ្ចប់នីតិវិធីចុះឈ្មោះធ្វើអោយពួកគេកាន់តែងាយរងគ្រោះបន្ថែមទៀតពីការទន្ទ្រាន យកដីធ្លីនិងការបណ្តេញចេញដោយបង្ខំ។ លើសពីនេះទៀត នៅក្នុងតំបន់មួយចំនួនកម្មវិធីបែងចែកដីធ្លីមិនត្រូវបានគេអនុវត្តទេ។

ការគ្មានសុវត្ថិភាពលើដីធ្លីនេះ មានការទាក់ទងទៅនឹងប្រវត្តិនៃការកាន់កាប់ដីធ្លីនៅកម្ពុជា។ ចាប់តាំងពីរបបខ្មែរក្រហមបានរំលាយកម្មសិទ្ធិឯកជនទាំងអស់រហូតមកដល់ពេលនេះ នៅទីជនបទភាគច្រើននៃប្រទេសកម្ពុជា នៅតែបន្តពឹងផ្អែកលើវិធីមួយគឺប្រើប្រាស់ដីដើម្បីសម្គាល់ខ្លួនថាជាម្ចាស់ ដោយសំអាងលើការទទួលស្គាល់រួមគ្នារវាងអ្នកជិតខាង ហើយអ្នកភូមិជឿថាវាគ្រប់គ្រាន់នៅក្នុងការកំណត់ព្រំដី។ ជាលទ្ធផលមនុស្សរាប់លាននាក់នៅកម្ពុជានៅខ្វះឯកសារ និងមានការទទួលស្គាល់សិទ្ធិរបស់ពួកគាត់ពេញលេញដោយមានប័ណ្ណកម្មសិទ្ធិដីធ្លីត្រឹមត្រូវ (Surya, 2012)។ ការខ្វះខាតវិញ្ញាបនបត្រនៃភាពជាម្ចាស់លើដីបង្កើតអសុវត្ថិភាព និងភាពងាយរងគ្រោះទៅនឹងការរំលោភដីធ្លី និងការបណ្តេញចេញដោយបង្ខំ។ ដោយគ្មានប័ណ្ណកម្មសិទ្ធិដីធ្លី ប្រជាជនគ្មានអ្វីអះអាង ដើម្បីសំគាល់ថាជាដីរបស់ពួកគេនៅពេលដែលអាជ្ញាធរ ឬក្រុមហ៊ុនមកយកដីនោះ។ សម្បទានដីសេដ្ឋកិច្ចមានផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមាន ។ រាជរដ្ឋាភិបាលកម្ពុជាបានអះអាងថា សម្បទានដីសេដ្ឋកិច្ចមានផលប៉ះពាល់ជាវិជ្ជមានមកលើប្រទេសកម្ពុជា ដោយបានរួមចំណែកដល់ការអភិវឌ្ឍដ៏សំខាន់មួយរបស់ប្រទេសកម្ពុជា ទោះបីជាមិនមានភស្តុតាង ឬទិន្នន័យជាក់ស្តែងដែលត្រូវបានបោះពុម្ពផ្សាយជាផ្លូវការអំពីអត្ថប្រយោជន៍នៃសម្បទានដីសេដ្ឋកិច្ចក៏ដោយ។ ផ្ទុយទៅវិញផលប៉ះពាល់ជាអវិជ្ជមាននៃការបណ្តេញចេញដែលជាញឹកញាប់បំផុត បណ្តាលមកពីសម្បទានដីសេដ្ឋកិច្ចត្រូវបានគេចងក្រងជាឯកសារនៅទូទាំងប្រទេស(CCHR 2013)។

ផលប៉ះពាល់នៃការបណ្តេញចេញនេះ មិនត្រូវបានកម្រិតត្រឹមការបាត់បង់ផ្ទះសម្បែងរបស់នរណាម្នាក់នោះទេ។ ជាញឹកញាប់ការបណ្តេញចេញបណ្តាលឱ្យមានកំណើនភាពក្រីក្រ ការទទួលបានប្រាក់ចំណូលតិចជាងមុន ការជំពាក់បំណុល ការខ្វះលទ្ធភាពទទួលបានទឹកស្អាត អនាម័យ និងការចិញ្ចឹមជីវិត បញ្ហាផ្លូវកាយ និងសុខភាពផ្លូវចិត្ត បែកបាក់ក្រុមគ្រួសារស្លាកស្នាមទុយិសសង្គមប៉ះពាល់ដល់សាមគ្គីភាពក្នុងសហគមន៍ និងការដាក់ឱ្យនៅឆ្ងាយពីសង្គមដទៃទៀត។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានផ្តល់នូវឧទាហរណ៍មួយពីភូមិឈូក ឃុំជីខលើស្រុកស្រែអំបិល ខេត្តកោះកុងថា ប្រាក់ចំណូលប្រចាំឆ្នាំជាមធ្យមរបស់ជនរងគ្រោះ ពីការបណ្តេញចេញដោយបង្ខំបានធ្លាក់ចុះពី $1,083 .82 ទៅ $484,92 នៅក្នុងភូមិព្រែកជីក ឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង ប្រាក់ចំណូលមធ្យមប្រចាំឆ្នាំរបស់អ្នកភូមិដែលគេបណ្តេញចេញនេះបានធ្លាក់ចុះពី $2,070.31 ទៅ $315,89។ ដូចគ្នានេះដែរ ចំពោះអ្នកដែលគេបណ្តេញចេញនៅភូមិអណ្តូងក្នុងសហគមន៍នេះ មានការថយចុះប្រាក់ចំណូលយ៉ាងច្រើន មានការប៉ះពាល់យ៉ាងខ្លាំងដល់ការថែទាំសុខភាព ដែលអាចបណ្តាលឱ្យមានកង្វះអាហារូបត្ថម្ភ និងបញ្ហាផ្សេងទៀតជាច្រើន (CCHR 2013) ។

ទោះបីជាដីធ្លីមានសារៈសំខាន់ដែលមិនអាចវាស់បានសម្រាប់ទាំងបុរស និងស្ត្រីនៅក្នុងប្រទេសកម្ពុជា ស្ត្រីដែលជាអ្នកថែទាំដ៏សំខាន់នៃគ្រួសារ គឺជាផ្នែកមួយនៃក្រុមដែលងាយរងគ្រោះបំផុតនៅក្នុងបរិបទនៃសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន និងរងផលប៉ះពាល់យ៉ាងខ្លាំងបំផុត ដោយការឆ្លងរីករាលដាលនៃការរំលោភយកដីធ្លីនៅប្រទេសកម្ពុជា។ នៅក្នុងឆ្នាំ2013 ការស្រាវជ្រាវដែលធ្វើឡើងដោយអង្គការស្ត្រីខ្មែរបានរកឃើញថា ស្ត្រីមានជីវភាពកាន់តែអាក្រក់ឡើងៗដោយសារការបណ្តេញចេញពីដីរបស់ខ្លួន (Strey Khmer Organization 2013)។

ការបណ្តេញចេញដោយបង្ខំនេះក៏មានផលប៉ះពាល់យ៉ាងខ្លាំងលើកុមារដែរ។ នៅពេលដែលគ្រួសារត្រូវបានផ្លាស់ប្តូរទៅកាន់តំបន់តាំងទីលំនៅថ្មី។ កុមារជាញឹកញាប់ត្រូវបានគេបង្ខំឱ្យចាកចោលសាលារៀន ឬក្រុមគ្រួសារដែលចាំបាច់ត្រូវ នៅបែកគ្នានៅក្នុងគោលបំណង ដើម្បីរក្សាទុកកុមារឱ្យនៅក្បែរកន្លែងបណ្តេញចេញ ដូច្នេះ ពួកគេអាចបញ្ចប់ឆ្នាំសិក្សា។ នៅក្នុងករណីមួយចំនួនក្រុមគ្រួសារត្រូវចំណាយលុយ ដើម្បីអាចផ្ទេរកូនទៅសាលារៀនផ្សេងទៀត ដែល បណ្តាលឱ្យមានផលប៉ះពាល់បន្ថែមទៀតដល់ស្ថានភាពសេដ្ឋកិច្ចគ្រួសារ( Surya, 2012)។ ពលកម្មកុមារក៏ជាក្តីបារម្ភដ៏ធំមួយ។ កុមារត្រូវបានចាកចេញពីសាលារៀន មានពេលខ្លះដោយសារតែដើម្បីធ្វើការ និងរកប្រាក់សម្រាប់គ្រួសាររបស់ពួកគេ បន្ទាប់ពីការបណ្តេញចេញ ព្រោះថាក្រុមគ្រួសារជាញឹកញាប់មិនអាចដោះបំណុលរបស់ខ្លួនបាន (Aprodev, 2011)។

សម្បទានដី ជម្លោះដីធ្លី និងការបណ្តេញចេញគំរាមកំហែងដល់អត្តិភាព នៃសហគមន៍ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា ធ្វើឱ្យប៉ះពាល់ដល់ជីវិតរស់នៅតាមបែបប្រពៃណីរបស់ពួកគេច្រើនបែបច្រើនយ៉ាង។ បើយោងតាមអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិមានករណីជាច្រើនដែលសម្បទានកំពុងត្រូវបានអភិវឌ្ឍដោយផ្ទាល់នៅលើដីរបស់ជនជាតិដើមភាគតិចជាហេតុធ្វើឱ្យសហគមន៍ព្យាយាមចុះបញ្ជីដីរបស់ខ្លួនរួចទៅហើយ, វាមានតិចតួចឬគ្មាននរណាម្នាក់បានចាកចេញ។ ឧទាហរណ៍នៅដើមឆ្នាំ2013 កាសែតភ្នំពេញប៉ុស្តិ៍បានរាយការណ៍ថា សហគមន៍ចារ៉ាយនៅខេត្តរតនគីរី ប្រមាណ 100 គ្រួសារបានបដិសេធការប៉ុនប៉ងរបស់អាជ្ញាធរមូលដ្ឋានដើម្បីវាស់ដីធ្លីរបស់ពួកគេ: «នៅក្នុងភូមិរបស់យើងមិនមានព្រៃឈើទៀតទេ សម្រាប់ព្រលឹងបុព្វបុរសរបស់យើង ដូច្នេះយើងចង់រក្សាវាទុកសម្រាប់បុព្វបុរស និងសម្រាប់កំណត់អត្តសញ្ញាណជនជាតិភាគតិចរបស់យើង»។ (Phak Seangly, 2013)

## ៤. ប្រជាសាស្ត្រ

អ្នកផ្តល់ចម្លើយទាំងអស់ជាជនជាតិខ្មែរ ហើយ ៦៧% នៃអ្នកផ្តល់ចម្លើយទាំងនេះបានចាប់ផ្តើមរស់នៅក្នុងភូមិមុនឆ្នាំ២០០១។ ក្នុងចំណោមអ្នកផ្តល់ចម្លើយទាំងអស់ ដែលយើងបានសម្ភាសម្នាក់ទល់ម្នាក់គឺ ៤០.៦% ជាបុរស និង៥៩.៤% ជាស្ត្រី។ ភាគច្រើននៃអ្នកផ្តល់ចម្លើយមានកម្រិតវប្បធម៌ទាប: ៧១.៦% នៃអ្នកផ្តល់ចម្លើយប្រុស និង ៨៧.២% នៃអ្នកផ្តល់ចម្លើយជាស្ត្រី មិនដែលបានទៅរៀននៅសាលា ឬក៏មិនបានរៀនចប់សាលាបឋមសិក្សាទេ។អ្នកផ្តល់ចម្លើយជាស្ត្រីបាត់បង់អត្ថប្រយោជន៍ខាងសិក្សាជាងបុរស។ ក្នុងចំណោមអ្នកផ្តល់ចម្លើយជាស្ត្រីទាំងអស់ មានតែ៧.៥%ប៉ុណ្ណោះ ទល់នឹង១៩.៤%នៃបុរស ដែលអាចរៀនដល់អនុវិទ្យាល័យ។ មិនមានអ្នកផ្តល់ចម្លើយជាស្ត្រីណាដែលបានទៅរៀននៅវិទ្យាល័យ ឬនៅស្ថាប័នកម្រិតឧត្តមសិក្សាទេ រីឯដែលបុរសយ៉ាងហោចណាស់មួយចំនួនតូចបានសិក្សាដល់កម្រិតទាំងនេះ (គឺ១.៨% និង១.៣% តាមលំដាប់)។

**តារាងទី ៤ : អ្នកផ្តល់ចម្លើយតាមភេទ និងកម្រិតវប្បធម៌**

| កម្រិតវប្បធម៌ | ភេទ | | | | | |
|---|---|---|---|---|---|---|
| | 1: ប្រុស | | 2: ស្រី | | សរុប | |
| | ចំនួន | % | ចំនួន | % | ចំនួន | % |
| មិនបានរៀន/មិនបញ្ចប់បឋមសិក្សា | 111 | 71.6% | 198 | 87.2% | 309 | 80.9% |
| បញ្ចប់បឋមសិក្សា | 8 | 5.2% | 12 | 5.3% | 20 | 5.2% |
| អនុវិទ្យាល័យ | 30 | 19.4% | 17 | 7.5% | 47 | 12.3% |

| | | | | | | |
|---|---|---|---|---|---|---|
| វិទ្យាល័យ | 3 | 1.9% | 0 | 0.0% | 3 | .8% |
| សកលវិទ្យាល័យ | 2 | 1.3% | 0 | 0.0% | 2 | .5% |
| មិនដឹង | 1 | .6% | 0 | 0.0% | 1 | .3% |
| សរុប | 155 | 100.0% | 227 | 100.0% | 382 | 100.0% |

### តារាងទី ៥: ចំណូលនិងចំណាយ

| | ចំណូលមធ្យម | | ចំណាយមធ្យម | |
|---|---|---|---|---|
| | ចំនួន | % | ចំនួន | % |
| តិចជាង100,000 រៀល | 11 | 2.9 | 9 | 2.4 |
| 100,000 - 199,000 រៀល | 40 | 10.5 | 42 | 11.0 |
| 200,000 - 399,000 រៀល | 120 | 31.4 | 132 | 34.6 |
| 400,000 - 599,000 រៀល | 97 | 25.4 | 133 | 34.8 |
| 600,000 - 799,000រៀល | 52 | 13.6 | 47 | 12.3 |
| 800,000 - 999.000 រៀល | 26 | 6.8 | 9 | 2.4 |
| 1 លាន - 1.2 លានរៀល | 10 | 2.6 | 4 | 1.0 |
| លើសពី 1.2 លានរៀល | 26 | 6.8 | 6 | 1.6 |
| សរុប | 382 | 100.0 | 382 | 100.0 |

ជាសរុបអ្នកចូលរួមនៅក្នុងការស្ទង់មតិនេះ ជាជនក្រីក្រ។ ភាគច្រើនជាកសិករ (៧៦.៤%) ហើយមួយចំនួនតូចជា អ្នកស៊ីឈ្នួលធ្វើកសិកម្ម (៦.៣%)។ ប្រហែល ៧០%មានចំណូលទាបជាង៤០០ ០០០រៀល (១៥០ដុល្លារ)ក្នុង១ខែ គឺមានន័យថា សមាជិកម្នាក់ៗក្នុងគ្រួសារអាចរកចំណូលបានត្រឹមតែ ៣០ដុល្លារក្នុង១ខែ ឬ១ដុល្លារក្នុង១ថ្ងៃ ដោយគិតថាក្នុង១គ្រួសារមានសមាជិក៥នាក់ជាមធ្យមនៅក្នុងខេត្តសំណាកគំរូ ហើយប្រៀបធៀបចំណូលនេះនឹងចំណូលរបស់មនុស្សម្នាក់ៗចំនួន២.៧ដុល្លារក្នុង១ថ្ងៃនៅថ្នាក់ជាតិ (http://www.nis.gov.kh/nis/NA/NA2012.html)។ ក្នុងចំណោមអ្នកផ្តល់ចម្លើយ ដែលមានចំណាយច្រើនជាងចំណូលក្នុងគ្រួសារ គឺ៩០.៤% ត្រូវការខ្ចីលុយ ពីអ្នកដទៃ។ អ្នកផ្តល់ចម្លើយផ្សេងទៀត (៩.៦%) ត្រូវការទិញស្រូវ/អង្ករ ដើម្បីបម្រុងទុកប្រើប្រាស់ ដោយប្រើប្រាក់ដែលសន្សំបាន ឬក៏ដោយការលក់សត្វចិញ្ចឹម។

## ៥. ទីតាំងភូមិសាស្ត្រ និងស្ថានភាពសង្គម

ជាទូទៅវិវាទដីធ្លីបានកើតឡើងនៅក្នុងតំបន់ដែលគេស្គាល់ថា ជាទីកន្លែងនៃការប្រឈមមុខដាក់គ្នារវាង កម្លាំងរបស់រដ្ឋាភិបាល និងភាគីប្រយុទ្ធខ្មែរក្រហម ដែលតែងតែកើតឡើងជាញឹកញាប់ឬស្ទើរតែទាំងស្រុងនៃតំបន់ប្រយុទ្ធគ្នាទាំងនេះត្រូវបានគ្រប់គ្រងដោយខ្មែរក្រហម។

ឧទាហរណ៍នៅស្រុកឱរ៉ាល់ដែលទើបនឹងបង្កើតថ្មី ផ្ទៃដីទាំងមូលស្ទើរតែគ្រប់គ្រងដោយភាគីខ្មែរក្រហម។ គឺទើបតែនៅក្រោយពេលធ្វើសមាហរណកម្មរបស់ភាគីខ្មែរក្រហមនៅក្នុងឆ្នាំ១៩៩៦នេះទេ ដែលសន្តិភាពបានវិលត្រឡប់មករកប្រជាពលរដ្ឋមូលដ្ឋានវិញ។ ចាប់តាំងពីពេលនោះមក អ្នកភូមិចាស់ដែលភាគច្រើនត្រូវបានជម្លៀសចេញពីការប្រឈមមុខដាក់គ្នារវាងភាគីប្រយុទ្ធទាំងពីរក្រុម ហើយបានចេញទៅរស់នៅអស់រយៈពេលជាច្រើនឆ្នាំនៅក្នុងឃុំអូរគគីរនៃស្រុកសំពៅទង បានវិលត្រឡប់មកទឹកដីកំណើតរបស់ខ្លួនវិញ។ គួរកត់សម្គាល់ដែរថា មានប្រជាពលរដ្ឋដែលមកពីតំបន់ផ្សេងៗនៃប្រទេសក៏បានមកតាំងទីលំនៅក្នុងតំបន់នេះ ដើម្បីកសាងជីវភាពថ្មីរបស់ខ្លួនផងដែរ ជាពិសេសអតីតទាហានមកពីភាគីទាំងពីរ។ អ្នកភូមិចាស់ប្រកបមុខរបរចិញ្ចឹមជីវិតអាស្រ័យនឹងក្បាលដីដែលជាកេរមរតករបស់ខ្លួន ហើយបើសិនជាដីនេះមិនសមល្មមនឹងការទ្រទ្រង់ជីវភាពទេ ពួកគាត់ត្រូវរានព្រៃដែលនៅជិតៗនេះ។ ពួកគាត់ត្រូវខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីស្វះស្វែងរកក្បាលដីសម្រាប់ដាំស្រូវឬដំណាំរួមផ្សំដទៃទៀត មានដូចជាពោត ដំឡូងសណ្តែក ចេក និងស្វាយជាដើម។ ទោះជាយ៉ាងណាក៏ដោយ ជាទូទៅ ជីវភាពពួកគាត់បានពឹងអាស្រ័យលើអនុផលព្រៃឈើ មានដូចជាវល្លិ ផ្លែឈើ ស្លឹកនិងឫសរុក្ខជាតិ បន្លែ រុក្ខជាតិផ្សំថ្នាំ ជ័រឈើ ឬឈើមូល និងសត្វព្រៃថែមទៀត។ ទន្ទឹមនឹងនេះ ពួកគាត់ក៏យកគោ ក្របី មកឃ្វាលនៅលើដីដែលសម្បូរដោយស្មៅនេះផងដែរ។ ខុសប្លែកពីអ្នកភូមិចាស់ អ្នកចំណូលថ្មីដែលចេញមកពីតំបន់ដទៃទៀតនៃប្រទេសបានចូលមកកាន់ទឹកដីនេះ ដើម្បីទ្រទ្រង់ជីវភាពរស់នៅឲ្យល្អប្រសើរតាមការស្វែងរកឱកាសប្រកបមុខរបរជួញដូរ ឬតាមការស្វះស្វែងរកដីដោយការរានព្រៃ ឬមួយទិញដីពីអ្នកភូមិចាស់។ នៅខេត្តពោធិ៍សាត់ អ្នកចំណូលថ្មីមានឱកាសច្រើន ដើម្បីរកចំណូលតាមរយៈការជួញដូរឈើមានតម្លៃ ឬក៏រានដី និង/ឬទិញដីមានទំហំធំៗ។

នៅស្រុកថ្ពង អ្នកចំណូលស្រុកមានចំនួនតិចជាង។ តាមធម្មតាអ្នកភូមិចាស់ដាំដំណាំស្រូវតាមដីស្រែនានា ដែលពួកគាត់បានកាន់កាប់ក្នុងអំឡុងឆ្នាំដំបូងៗ ក្រោយពេលដួលរលំនៃរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩ ។ ប៉ុន្តែនៅឃុំអមលាំង ពួកខ្មែរក្រហមបានបង្ហាញខ្លួនញឹកញាប់ណាស់។ ដើម្បីការរស់រានរបស់ខ្លួនប្រជាពលរដ្ឋមូលដ្ឋានបានវិលត្រឡប់ទៅរកដីដែលជាកេរមត៌កពីដូនតា ឬមួយរានព្រៃនៅក្បែរខាងសម្រាប់ធ្វើជាស្រែចំការព្រមទាំងស្វះស្វែងរកដី ដែលមានស្មៅសម្រាប់ចិញ្ចឹមគោ ក្របីផងដែរ។

នៅក្នុងខេត្តកំពង់ឆ្នាំង ស្រុកសាមគ្គីមានជ័យដែលជាស្រុកទើបនឹងបង្កើតថ្មីផងដែរនោះ គឺជាទឹកដីដែលគ្របដណ្តប់ដោយព្រៃពាក់កណ្តាលស្រោង នៅឆ្នាំដំបូងៗបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ ហើយក៏ជាតំបន់មួយក្នុងចំណោមតំបន់ដែលមានការប្រឈមមុខដាក់គ្នាផ្នែកអាវុធ។ ទោះជាយ៉ាងណាក៏ដោយ ក្រោយ ការបោះឆ្នោតទូទៅដែលរៀបចំដោយអ៊ុនតាក់ក្នុង

ឆ្នាំ១៩៩៣ និន្នាការមួយដែលមានលក្ខណៈជាចលនាមហាជន បានទាមទារយកដីដែលគេហៅថា ដីកេរ្តិ៍ពីដូនតា ឬដីកេរ្តិ៍មរតកមកជារបស់ខ្លួនវិញ ដែលជាដីដែលពួកគាត់ធ្លាប់បានប្រើប្រាស់កាលពីរបបមុនៗ។ ហេតុការណ៍នេះ គឺវាមានការទាក់ទិនយ៉ាងស្អិតរមួតទៅនឹងគណបក្សហ៊្វុនស៊ិនប៉ិច ដែលសន្យាថា នឹងប្រគល់កម្មសិទ្ធិដីធ្លីទាំងអស់ទៅឲ្យអ្នកកាន់កាប់ដីនៅក្នុងរបបដែលកន្លងទៅ បើសិនជាគណបក្សនេះឈ្នះឆ្នោត។ ដោយសារចំនួនប្រជាពលរដ្ឋចេះតែកើនឡើង គឺមិនអាចទប់ស្កាត់ពួកគាត់មិនឲ្យពង្រីកដីកសិកម្មនៅក្នុងតំបន់ព្រៃបានឡើយ ហើយនៅពេលខ្លះពួកគាត់បានធ្វើហួសពីព្រំប្រទល់នៃភូមិ/ឃុំរបស់ខ្លួនទៅទៀត។

នៅខេត្តបាត់ដំបង តំបន់បឹងប្រាំជាក់ស្តែងគឺជាព្រៃស្បាត ដែលភាគច្រើនដុះដោយដើមឫស្សី និងប្រភេទឈើដ៏មានតម្លៃមួយចំនួន ហើយក៏ជាទីជម្រកនៃពពួកសត្វព្រៃផងដែរ។ មិនមានប្រជាពលរដ្ឋណាដែលមានក្បាលដីដាំដំណាំនៅទីនោះទេ ពីព្រោះក្រោយពេលរំដោះចេញពីរបបប៉ុលពត ទឹកដីនេះនៅតែបន្តកាន់កាប់ដោយកម្លាំងខ្មែរក្រហមដដែល រហូតមកទល់នឹងសមាហរណកម្មក្នុងឆ្នាំ១៩៩៦។ ទោះជាយ៉ាងណាក៏ដោយ ការបំផ្លិចបំផ្លាញគម្របព្រៃឈើនៅក្នុងតំបន់នេះ ដើម្បីប្រែក្លាយវាទៅជាតំបន់អភិវឌ្ឍន៍កសិកម្ម មិនអាចបន្ទុចបង្អាក់វាបានឡើយ។

ក្នុងក្របខណ្ឌនៃគោលនយោបាយឈ្នះ-ឈ្នះដែលមិនបានចែងជាលាយលក្ខណ៍អក្សរ នាយទាហានជាន់ខ្ពស់របស់ខ្មែរក្រហមខ្លះបានលក់ស្ទើរតែទាំងអស់នៃទឹកដី ដែលខ្លួនបានកាន់កាប់កន្លងមកទៅឲ្យក្រុមឈ្មួញ គឺប្រការនេះហើយនាំឲ្យមានការប្រឈមមុខនឹងទាហានខ្មែរក្រហមមួយចំនួន ដែលមិនបានទទួលចំណែកដី។ ម្យ៉ាងវិញទៀត ទំនាស់ក៏កើតមានផងដែររវាងអ្នកចំណូលថ្មីដែលត្រូវបានទាក់ទាញចិត្ត ដោយអ្នកដឹកនាំសហគមន៍បឹងប្រាំ ជាមួយនឹងអ្នកភូមិចាស់ដែលមកពីឃុំនានានៅជិតខាងពាក់ព័ន្ធនឹងការរានដីព្រៃសម្រាប់ដាំដំណាំ។

## ៦. ស្ថានភាពដីធ្លីនៅក្នុងខេត្តដែលបានសិក្សា

ជាដំបូង វាមានសារៈសំខាន់ ដែលត្រូវរំឭកថា ភូមិសំណាកគំរូទាំង២៦មានទីតាំងនៅក្នុងតំបន់ជនបទ ហើយម្យ៉ាងវិញទៀត ភូមិស្ទើរតែទាំងអស់ស្ថិតនៅតំបន់ដាច់ស្រយាលគ្របដណ្តប់ទៅដោយព្រៃ។ ភាគច្រើននៃភូមិសំណាកគំរូទាំងនេះធ្លាប់បានស្ថិតនៅក្រោមការគ្រប់គ្រង ឬក៏ឆ្លងកាត់ដោយកងទ័ពខ្មែរក្រហម មុននឹងធ្វើសមាហរណកម្មតាមរយៈគោលនយោបាយឈ្នះ-ឈ្នះរបស់រាជរដ្ឋាភិបាលកម្ពុជា។

ដើម្បីគោលបំណងជាក់លាក់នៅក្នុងរបាយការណ៍នេះ ដីនឹងត្រូវបានបែងចែកជាប្រាំប្រភេទ ដោយអនុលោមតាម ការប្រើប្រាស់របស់ប្រជាពលរដ្ឋ គឺមានដីលំនៅដ្ឋាន ស្រែ ចំការ ដីព្រៃ និង ដីព្រៃសហគមន៍។ ដីលំនៅដ្ឋានសំដៅលើដីដែលអ្នកប្រើប្រាស់សម្រាប់ជាទីលំនៅរបស់ខ្លួន។ ស្រែសំដៅលើដីដែលប្រើសម្រាប់ដាំស្រូវ។ ចំការសំដៅលើ ដីដែលប្រើប្រាស់ក្នុងគោលបំណង ច្រើនយ៉ាងសម្រាប់ដាំដំណាំផ្សេងៗ ជួនកាលក៏មានទាំងដំណាំស្រូវដែរ។ ដីព្រៃនៅទីនេះសំដៅ លើក្បាលដីដែលមិនទាន់រានព្រៃ ហើយត្រូវបានកាន់កាប់ដោយអ្នកភូមិ សម្រាប់ទុកធ្វើកសិកម្ម ឬជាលំនៅដ្ឋាននៅពេលអនាគត។ ដីព្រៃសហគមន៍សំដៅលើដីព្រៃរួម ដែលសមាជិកសហគមន៍ ទាំងឡាយអាចប្រើប្រាស់សម្រាប់ការប្រមូលអនុផលព្រៃឈើឬអុស។ ដីនេះអាចត្រូវបែងចែកទៅ ឲ្យអ្នកភូមិក្រីក្រ ដែលខ្វះខាតដី ឬក៏អាចចែកទៅឲ្យសមាជិកទាំងអស់របស់សហគមន៍ សម្រាប់ ជាដីបម្រុងទុកនៅពេលអនាគត។

### រូបទី ១: ស្ថានភាពដីធ្លីរបស់ប្រជាពលរដ្ឋ




ចំពោះការសិក្សាទាំងមូល ប្រជាពលរដ្ឋទទួលយ៉ាងហោចណាស់បានដីមួយក្បាលក្នុងចំណោមដី ទាំងប្រាំប្រភេទខាងលើ។ មិនមានអ្នកណាដែលមិនមានដីនោះទេ។ ប្រជាពលរដ្ឋស្ទើរតែទាំង អស់មានដី សម្រាប់លំនៅដ្ឋាន (៩៨.៧%)។ ទោះជាយ៉ាងណាក៏ដោយ គេសង្កេតឃើញថា មាន តែប្រជាពលរដ្ឋតិចតួច(១.៣%)ទេ ដែលមិនមានដីលំនៅដ្ឋាន។ ក្នុងចំណោមអ្នកទាំងនេះ គឺមាន អ្នកចំណូលថ្មីដែលមកតាំងផ្ទះសម្បែងលើដីអ្នកភូមិដែលមានចិត្តសប្បុរស ហើយអ្នកខ្លះក៏បាន សង់ផ្ទះលើដីឪពុកម្តាយ ហើយស្ទើរតែទាំងអស់ជាគ្រួសារក្រីក្រដែលមានស្ត្រីជាមេគ្រួសារ។

បើតាមបរិបទនៃជនបទកម្ពុជា ដែលប្រជាពលរដ្ឋភាគច្រើនពឹងអាស្រ័យលើផលិតកម្មស្រូវ ដើម្បី គ្រាន់តែចិញ្ចឹមជីវិត ដូច្នេះវាពិតហើយដែលថា ភាគច្រើននៃប្រជាពលរដ្ឋដែលបានសិក្សា (៩៤.៨%)មានដីស្រែ។ ក្នុងចំណោមអ្នកទាំងនេះ ច្រើនជាងពីរភាគបី (៦៧.៥%) មានដីស្រែមួយ

ក្បាល ឬពីរក្បាលនៅក្នុងខេត្តគោលដៅទាំងបួន។ ជាមធ្យមអ្នក ផ្តល់ចម្លើយក្នុងការស្ទង់មតិនេះ មានដីស្រែចំនួនពីរក្បាល។ ទោះជាយ៉ាងណាក៏ដោយ ២៣.៦% នៃអ្នកផ្តល់ចម្លើយ ដែលភាគច្រើនមកពីខេត្តកំពង់ស្ពឺនិងពោធិ៍សាត់ ដែលមានផ្ទៃដីព្រៃអាចពង្រីកបានជាដីស្រែបាននិយាយប្រាប់ថា បានទទួលដីស្រែចំនួន៣ក្បាល ឬលើសពីនេះ។ ជាមធ្យមគ្រួសារនីមួយៗ នៅក្នុងការស្ទង់មតិទទួលបានដីស្រែ ប្រហែល២ហិកតា។ នេះមានន័យថាទិន្នផលស្រូវក្នុង១ឆ្នាំ ដែលផលិតដោយគ្រួសារដែលមានសមាជិកជាមធ្យម ចំនួនប្រាំនាក់ មានចំនួនបីតោន ដែលអាចគ្រាន់តែបម្រើជាតម្រូវការមូលដ្ឋានរបស់ពួកគាត់តែប៉ុណ្ណោះ។ មានតែ ២៩%នៃប្រជាពលរដ្ឋដែលបានសិក្សា ដែលភាគច្រើនមកពីខេត្តកំពង់ស្ពឺ និងពោធិ៍សាត់ មានដីចំការជាមធ្យមចំនួន ២ហិកតា។ ប្រជាពលរដ្ឋប្រើប្រាស់ដីចំការ សម្រាប់ដាំដំណាំរួមផ្សំក្រៅពីស្រូវ មានដូចជាស្វាយ ចេក សណ្តែក និង បន្លែបង្ការសម្រាប់ជាប្រាក់ចំណូលបន្ថែមទៅលើការផលិតស្រូវ។

វាមានសារៈសំខាន់គួរកត់សម្គាល់ថា បើតាមការសង្កេតពេលចុះសិក្សាតាមមូលដ្ឋាន និងសម្ភាសន៍ជាមួយនឹងអ្នកផ្តល់ព័ត៌មានសំខាន់ៗ ទំហំដីស្រែ និងចំការដែលអ្នកភូមិបាននិយាយប្រាប់ គឺស្មើនឹងទំហំដីសរុបដែលពួកគាត់មាន ក្នុងនោះមានផ្នែកនៃដីដែលពួកគាត់បានរាន ដោយប្រើកម្លាំងពលកម្មរបស់ខ្លួនឯងផ្ទាល់ ដើម្បីដាំដំណាំផ្សេងៗ ហើយដីព្រៃដែលនៅសល់មិនទាន់បានដាំដំណាំនៅឡើយទេ។ នេះមានន័យថា អ្នកភូមិបានដាំដំណាំតែនៅលើដីមួយផ្នែកដែលពួកគាត់បានប្រកាសថា ជាស្រែឬចំការរបស់ខ្លួន។

ក្រៅពីដីស្រែ ឬចំការ អ្នកភូមិក៏មានដីព្រៃដែលពួកគាត់បានកាន់កាប់ សម្រាប់បម្រុងទុកដាំដំណាំនៅពេលអនាគត។ ដីព្រៃត្រូវបានកាន់កាប់តាមរយៈការបែងចែក ការរានដីការទាមទារដីមិនទាន់កាន់កាប់ កេរ្តិ៍មរតក និងការទិញ។ ស្ទើរពាក់កណ្តាលនៃប្រជាពលរដ្ឋដែលបានសិក្សា (៤៦.៣%) បាននិយាយប្រាប់ថា ពួកគាត់មានដីយ៉ាងហោចណាស់១កន្លែងនៅក្នុងដីព្រៃ ចំណែកឯអ្នកដទៃទៀត (១៣.១%) បានប្រាប់ថា ពួកគេក៏ជាម្ចាស់ដីមួយក្បាលនៃព្រៃ សហគមន៍ដែលបានបែងចែកជាលក្ខណៈបុគ្គលទៅឲ្យសមាជិកសហគមន៍ ឬក្នុងរូបភាពជាសហកម្មសិទ្ធិ។ ចំណែក ដីព្រៃមានទំហំជាមធ្យម ៣.៨ហិកតា។ វាមានសារសំខាន់នឹងកត់សម្គាល់ថា អ្នកភូមិជាច្រើន (១៦.៨%) មិនអាចបង្ហាញប្រាប់អំពីទំហំនៃដីព្រៃរបស់ខ្លួនបានទេ ហើយវាក៏ពិបាកនឹងបង្ហាញពីដីក្នុងព្រៃសហគមន៍ ដែលអ្នកភូមិទាមទារថាជាកម្មសិទ្ធិរបស់ខ្លួនបានទំហំប៉ុណ្ណាពីព្រោះនៅព្រៃសហគមន៍ខ្លះ ដីត្រូវបានបែងចែកទៅអោយសមាជិក គ្រប់គ្នាហើយ ចំណែកឯនៅសហគមន៍ផ្សេងទៀត ដីព្រៃនៅជាកម្មសិទ្ធិរួមនៅឡើយ។

ឯកជនភាវូបនីយកម្មដីក្នុងឆ្នាំ១៩៨៩ មិនបានប្រព្រឹត្តទៅឲ្យទន្ទឹមនឹងការធ្វើផែនទី និងការចុះបញ្ជីកម្មសិទ្ធិដីធ្លីយ៉ាងល្អិតល្អន់របស់សុរិយោដីនោះឡើយ រួមផ្សំនឹងកំណើនប្រជាពលរដ្ឋយ៉ាងឆាប់រហ័ស និងតម្រូវការដីយ៉ាងខ្ពស់សម្រាប់កសិកម្មបែបពាណិជ្ជកម្ម អាជីវកម្មឈើមូល និងសកម្មភាពនានាដែលមិនមែនបម្រើផ្នែកកសិកម្ម ក៏ដូចជាប្រព្រឹត្តទៅនៅក្នុងគោលបំណងកេងចំណេញ ដែលនាំឲ្យកើតជាកម្លាំងជំរុញឲ្យមានវិវាទដីធ្លីនៅតំបន់ជនបទ ក្នុងនោះរួមទាំងខេត្តគោលដៅរបស់អង្គការជីវិតថ្លៃថ្នូរផងដែរ។ វិវាទបានលេចឡើងភាគច្រើនទាក់ទងនឹងដីកសិកម្ម ឬជាដីព្រៃដែលបានកាន់កាប់ដោយអ្នកភូមិ ក៏ដូចជាដីព្រៃសហគមន៍របស់ពួកគាត់ផងដែរ។ ច្រើនជាង ៤០% នៃប្រជាពលរដ្ឋដែលត្រូវបានសិក្សា បាននិយាយប្រាប់ថា ពួកគាត់មានក្បាលដីស្រែឬដីនៅក្នុងព្រៃដែលមានវិវាទ រីឯអ្នកផ្តល់ចម្លើយចំនួន ១០.២% និង១២.៨% បានប្រាប់ថាដីចំការ និងដីសហគមន៍របស់ខ្លួននៅមានវិវាទ។

ទំហំដីវិវាទមានលក្ខណៈខុសៗគ្នា ទៅតាមប្រភេទនៃដីដែលប្រជាពលរដ្ឋប្រើប្រាស់។ មួយចំនួនធំនៃប្រជាពលរដ្ឋមានដីលំនៅដ្ឋាន ដីស្រែនិងដីចំការមានវិវាទ ក្នុងទំហំអតិបរមាចំនួន៥ហិកតា។ ទោះជាយ៉ាងណាក៏ដោយ វាមានការពិបាកដឹងអំពីទំហំដីព្រៃដែលមានវិវាទដោយមកពីប្រជាពលរដ្ឋមិនអាចបង្ហាញប្រាប់ថាដីនោះមានទំហំប៉ុណ្ណា។

**រូបទី ២: ស្ថានភាពនៃប្រជាពលរដ្ឋដែលបានសិក្សាទាក់ទងនឹងវិវាទដីធ្លី**




វិវាទចំនួន១៩ ក្នុងចំណោមវិវាទដីទាំង ២៨នៅក្នុងភូមិសំណាកគំរូនានានៃខេត្តដែលមានសិក្សាចំនួនបួនបានដោះស្រាយរួចរាល់ហើយ តាមរយៈការផ្តល់សំណងមិនយុត្តិធម៌ ហើយវិវាទខ្លះទៀតកំពុងរង់ចាំដំណោះស្រាយ។ មានវិវាទចំនួន ៩ ក្នុងវិវាទទាំង២៨នៅព្យួរនៅកំពុងរង់ចាំដំណោះស្រាយ។ ដោយអនុលោមតាមការគណនាតំបន់ដីដែលមានវិវាទ និងអ្វីដែលពួកគាត់មានយើងអាចនិយាយបានថា ក្នុងករណីប្រជាពលរដ្ឋដែលបានសិក្សាមានដីកសិកម្មមានវិវាទ

ពួកគាត់មិនអាចទាមទារដីនោះមកវិញបានទេ។ ៨០គ្រួសារ ស្មើនឹង៥១.៩% ជាអ្នកគ្មានដីស្រែ និង១៤គ្រួសារទៀត ឬ៩.១% នឹងទៅជា អ្នកស្ទើរតែគ្មានដី ហើយនៅទីបញ្ចប់ ៩២.១% នឹងបាត់បង់ដីព្រៃដែលខ្លួនបានកាន់កាប់។

# ៧. ដើមហេតុចំបងនៃវិវាទ

## ៧.១ ការយល់ដឹងពីរខុសគ្នាអំពីតថភាពតែមួយៈ ការទាមទារដីអនុលោមតាមច្បាប់ភូមិបាលឆ្នាំ ២០០១ ផ្ទុយនឹងទម្លាប់ជាប្រពៃណីទាក់ទងនឹងការកាន់កាប់ដីធ្លី

នៅពេលដែលរដ្ឋាភិបាលកម្ពុជាថ្មីមួយត្រូវបានបង្កើតនៅក្នុងឆ្នាំ១៩៨៩ សេដ្ឋកិច្ចទីផ្សារត្រូវបានរៀបចំឡើងនៅក្រោមរដ្ឋធម្មនុញ្ញថ្មី និងកម្មវិធីកម្មវិធីកំណែទម្រង់ដីធ្លី។ នៅឆ្នាំ១៩៨៩ សេចក្តីណែនាំស្តីអំពីការអនុវត្តការប្រើប្រាស់ និងគោលនយោបាយគ្រប់គ្រងដីធ្លីត្រូវបានអនុម័ត ហើយកម្មសិទ្ធិដីលំនៅដ្ឋានក៏ត្រូវបានទទួលស្គាល់។ សេចក្តីណែនាំនេះ ក៏បានទទួលស្គាល់សិទ្ធិនៃការកាន់កាប់ដីដាំដំណាំផងដែរ។ ច្បាប់ភូមិបាលឆ្នាំ១៩៩២ ក៏បានបញ្ជាក់បន្ថែមអំពីការអនុញ្ញាតឲ្យមានកម្មសិទ្ធិដីលំនៅដ្ឋានផងដែរ។ ដោយគិតដល់ដំណើរការនេះ នៅក្នុងខេត្តដែលបានសិក្សាទាំងបួន យើងអាចសង្កេតឃើញថា ដំណើរការពង្រីកដីធ្លីក្នុងចំណោមប្រជាពលរដ្ឋមូលដ្ឋាន ហើយនឹងដំណើរការស្វែងរកឱកាសទទួលបានដីថ្មីរបស់អ្នកចំណូលថ្មីបានកើតមានជាញឹកញាប់។ ម្យ៉ាងចំនួនដ៏ច្រើននៃប្រជាពលរដ្ឋក៏ជាសម្ពាធនាំឲ្យមានលំហូរមនុស្សចេញពីបណ្តាខេត្ត ដែលមានដង់ស៊ីតេប្រជាជនខ្ពស់ឲ្យចេញទៅកាន់ខេត្តដែលមានដង់ស៊ីតេទាបផងដែរ។ ជាឧទាហរណ៍ ចាប់តាំងពីឆ្នាំ១៩៩៦នោះមក អ្នកចំណូលថ្មីបានប្តូរទីលំនៅមកឃុំបឹងប្រាំក្នុងខេត្តបាត់ដំបង ទៅនៅស្រុកភ្នំក្រវាញនៃខេត្តពោធិ៍សាត់ ឬក៏ទៅរស់នៅក្នុងស្រុកឱរ៉ាល់នៃ ខេត្តកំពង់ស្ពឺ ដើម្បីស្វះស្វែងរកដីកសិកម្មថ្មីតាមការរុករានដី ឬមួយតាមការអះអាងដីដែលមិនបានកាន់កាប់ថាជារបស់ខ្លួន ភាគច្រើនកើតមាននៅក្នុងតំបន់ដែលធ្លាប់បានគ្រប់គ្រងដោយភាគីខ្មែរក្រហម។

ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកឱរ៉ាល់បាននិយាយប្រាប់អំពីរបៀបដែលអ្នកចំណូលថ្មីមកកាន់កាប់ដីៈ

*«ពីមុនមកមិនជាពិបាកទេ មករកដីនៅទីនេះ។ ពួកគាត់ខ្លះមកសុំឃុំ ជួនកាលខ្លះទៀតមិនទាំងសុំផង។ ពួកគាត់ មកធ្វើតែតូប ដុតតែធ្យូង ដល់នៅយូរៗទៅ គាត់ថាដីគាត់ឯណេះៗ។ ខាងអាជ្ញាធរគិតថា មិនបោះបង់ឬដេញ គាត់ចេញទេ មកពីយោគយល់ថា គាត់ទើបនឹងឆ្លងកាត់សង្គ្រាម ហើយត្រូវការដីដើម្បីចិញ្ចឹមជីវិតតទៅទៀត។»*

ម្យ៉ាងវិញទៀត ប្រជាពលរដ្ឋមូលដ្ឋានក៏បានពង្រីកដីកសិកម្មរបស់ខ្លួនតាមការកាន់កាប់ដីព្រៃទំនេរ ដែលពួកគាត់ប្រើប្រាស់សម្រាប់ដុតធ្យូង ឬធ្វើជាកន្លែងឃ្វាលគោក្របី។ ពួកគាត់បានបែងចែកដីទាំងនេះជាមួយគ្នាគាត់។ ព្រំដីត្រូវបានទទួលស្គាល់បានតែជាមួយគ្នាគាត់ដែលជាអ្នករស់នៅក្នុងភូមិជាមួយ ឬនៅភូមិផ្សេងទៀតជិតគ្នា។ ក្រោយមកទើបពួកគាត់អះអាងថា ជាកម្មសិទ្ធិរបស់ខ្លួនបន្ទាប់ពីក្បាលដីខ្លះត្រូវបានប្រើប្រាស់សម្រាប់ដាំដំណាំ ហើយជួនកាលបានទុកវាឲ្យនៅដីព្រៃដដែល។

អ្នកមកពីខាងក្រៅដែលជាអ្នកមាន ក៏បានទិញដីពីប្រជាពលរដ្ឋមូលដ្ឋានសម្រាប់ការកេងចំណេញផងដែរ ជាឧទាហរណ៍នៅស្រុកសាមគ្គីមានជ័យក្នុងខេត្តកំពង់ឆ្នាំង។

ស្ទើរតែក្នុងពេលជាមួយគ្នានេះ រដ្ឋាភិបាលក៏បានចាប់ផ្តើមប្រគល់ដីសម្រាប់សម្បទានដីសង្គមកិច្ចឲ្យក្រុមហ៊ុនឯកជន ហើយនៅក្នុងការសិក្សាទាំងបួនខេត្តនេះ វាក៏មិនត្រូវបានដកចេញផងដែរ។

**តារាងទី៦: សម្បទានដីសេដ្ឋកិច្ចនៅក្នុងខេត្តទាំងបួន** (**ប្រភពរបស់អង្គការលីកាដូ**)

| ឈ្មោះក្រុមហ៊ុន | ខេត្ត | កាលបរិច្ឆេទ | ទំហំជាហិកតា | កម្មសិទ្ធិ | ដំណាំ | ប្រភេទ |
|---|---|---|---|---|---|---|
| Leang Hour Hong | បាត់ដំបង | 2000-06-07 | 8000.00 | ខ្មែរ | អំពៅ | elc |
| Rath Sambath | បាត់ដំបង | 2009-04-03 | 5200.00 | ខ្មែរ | កៅស៊ូ | elc |
| Suon Mean Sambath | បាត់ដំបង | 2011-04-06 | 4095.00 | ខ្មែរ | មិនដឹង | elc |
| OJI | កំពង់ឆ្នាំង | | 10000.00 | ជប៉ុន | ផ្លែឈើ | elc |
| CJ Cambodia 2 | កំពង់ស្ពឺ | 1999-11-15 | 3000.00 | កូរ៉េ | ដំឡូងមី | elc |
| CJ Cambodia 1 | កំពង់ស្ពឺ | 1999-11-15 | 5000.00 | កូរ៉េ | ដំឡូងមី | elc |
| Uk Khun | កំពង់ស្ពឺ | 2001-05-25 | 12506.00 | ខ្មែរ | ដំណាំចម្រុះ | elc |
| Golden Land | កំពង់ស្ពឺ | 2004-03-05 | 4900.00 | ចិន | ដំឡូងមី | elc |
| City Mart | កំពង់ស្ពឺ | 2006-02-28 | 9853.00 | ស្រីលង្កា | មិនដឹង | elc |
| HLH | កំពង់ស្ពឺ | 2009-03-30 | 10492.00 | សិង្ហបុរី | ពោត | elc |
| Fortuna Plantation | កំពង់ស្ពឺ | 2009-10-12 | 7100.00 | ម៉ាឡេស៊ី | ដំឡូងមី | elc |
| Fortuna Plantation | កំពង់ស្ពឺ | 2009-10-12 | 855.00 | ម៉ាឡេស៊ី | ដំឡូងមី | elc |
| Grandis Timber | កំពង់ស្ពឺ | 2009-12-31 | 9820.00 | អាមេរិក | ផ្លែឈើ | elc |

| | | | | | | |
|---|---|---|---|---|---|---|
| Great Field | កំពង់ស្ពឺ | 2010-01-29 | 9059.00 | ចិន | អំពៅ | ELC |
| Yellow Field | កំពង់ស្ពឺ | 2010-01-29 | 8591.00 | ចិន | អំពៅ | ELC |
| Phnom Penh Sugar | កំពង់ស្ពឺ | 2010-02-04 | 8506.00 | ខ្មែរ | អំពៅ | ELC |
| Kampong Speu Sugar | កំពង់ស្ពឺ | 2010-02-04 | 8245.00 | ខ្មែរ | អំពៅ | ELC |
| Yun Khean Minerals | កំពង់ស្ពឺ | 2010-12-07 | 290.00 | ចិន | មិនដឹង | ELC |
| Kampong Speu Sugar | កំពង់ស្ពឺ | 2011-03-21 | 4700.00 | ខ្មែរ | អំពៅ | ELC |
| Reththy Kiri Sakor | កំពង់ស្ពឺ | 2011-04-06 | 1400.00 | ខ្មែរ | អំពៅ | ELC |
| Forestry Investment | កំពង់ស្ពឺ | 2011-11-27 | 839.00 | ស្រីលង្កា | ផ្លែឈើ | ELC |
| Master International | កំពង់ស្ពឺ | | 889.00 | ចិន | ដំឡូងមី | ELC |
| Ratanak Visal | ពោធិ៍សាត់ | 1999-10-15 | 3000.00 | ខ្មែរ | ដំឡូងមី | ELC |
| MDS Import Export | ពោធិ៍សាត់ | 2010-07-09 | 1950.00 | ខ្មែរ | កៅស៊ូ | ELC |
| MDS Import Export | ពោធិ៍សាត់ | 2010-12-30 | 4402.00 | ខ្មែរ | កៅស៊ូ | ELC |
| MDS SEZ | ពោធិ៍សាត់ | | 2667.00 | ខ្មែរ | គ្មាន | SEZ |

**រូបទី៣: មូលហេតុបង្កវិវាទ**



ពេលសួរប្រជាពលរដ្ឋអំពីមូលហេតុដែលដីរបស់គាត់មានវិវាទ ពួកគាត់បានបង្ហាញប្រាប់ថា សម្បទានដីសេដ្ឋកិច្ច (៧៣.២%) និងសម្បទានដីសង្គមកិច្ច (២៦.៨%) ជាមូលហេតុសំខាន់ដែលនាំឲ្យដីរបស់ពួកគាត់កើតមានវិវាទ។ សម្បទានដីសេដ្ឋកិច្ច ដែលរដ្ឋាភិបាលបានប្រគល់ឲ្យក្រុមហ៊ុនភ្នំពេញស្ហ្វហ្គ័រ (PPS) កំពង់ស្ពឺស្ហ្វហ្គ័រ (KSS) អេកអិលអេក ស៊ីធីម៉ាត និងម៉ាស្វ័រអ៊ិនធ័រណាស្យូណាល់នៅខេត្តកំពង់ស្ពឺ និងក្រុមហ៊ុនភាពីម៉ិចនៅខេត្តពោធិ៍សាត់ រួមទាំងសម្បទានដីសង្គមកិច្ចនៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងបាត់ដំបង ហើយនិងព្រៃសហគមន៍នៅខេត្តកំពង់ឆ្នាំង និងពោធិ៍សាត់។ មួយចំណែកតូចនៃអ្នកផ្តល់ចម្លើយ (៧.១%) បានបញ្ជាក់ថា មានមូលហេតុផ្សេងទៀតដូចជាការរុករក រ៉ែ/អាជីវកម្មរ៉ែ ហើយនឹងតម្រូវការតំបន់អភិវឌ្ឍន៍របស់រដ្ឋ។ វាពិតហើយដែលថា រដ្ឋាភិបាលផ្តល់ដីទៅឲ្យក្រុមហ៊ុន សម្រាប់ដាំដំណាំ ដូចជាអំពៅ ដំឡូងមី ពោត ដើមអាកាស្យា ដំណាំផ្លែឈើ កៅស៊ូ និងដំណាំដទៃទៀត (សូមអាន តារាងទី៦)។ វិវាទដីធ្លីដែលបង្កដោយសម្បទានដីសេដ្ឋកិច្ចភាគច្រើនកើតមាននៅខេត្តកំពង់ស្ពឺ និងខេត្តពោធិ៍សាត់។ នៅខេត្តកំពង់ស្ពឺ វិវាទចំនួន៨ក្នុងចំណោមករណីវិវាទដីធ្លីទាំង១៥ បណ្តាលមកពីសម្បទានដីរបស់ក្រុមហ៊ុនចំនួន៥ ហើយនៅខេត្តពោធិ៍សាត់ វិវាទចំនួន៤នៃវិវាទដីទាំងប្រាំបានកើតមានជាមួយក្រុមហ៊ុនមួយ។ សម្បទានដីសង្គមកិច្ច ភាគច្រើនមាននៅខេត្តកំពង់ឆ្នាំង ដែលរដ្ឋាភិបាលបានបម្រុងទុកដីខ្លះធ្វើជាសម្បទានដីសង្គមកិច្ចសម្រាប់យោធិន ពិការ និងមន្ត្រីរាជការចូលនិវត្តន៍ ចំណែកឯរដ្ឋបាលព្រៃឈើក៏មានបំណងការពារបរិស្ថាន តាមរយៈការបង្កើតព្រៃ សហគមន៍ ក៏ដូចជារក្សាតំបន់គម្របព្រៃបៃតងផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ក៏ផ្ទៃដីទាំងនេះមានការជាន់លើ លើដីដែលកាន់កាប់ដោយអ្នកភូមិទៀតផង។ ករណីវិវាទមួយទៀត បានកើតឡើងនៅពេលដែលរដ្ឋាភិបាលត្រូវការទំហំដីសម្រាប់កសាងមជ្ឈមណ្ឌលហ្វឹកហ្វឺនសម្រាប់កងរាជអាវុធហត្ថ ហើយបានត្រួតលើដីរបស់អ្នកភូមិផងដែរ។ យើងបានសង្កេតឃើញថា បួនករណីក្នុងចំណោមករណីវិវាទចំនួនប្រាំត្រូវបានបង្កដោយសម្បទានដីសង្គមកិច្ច និងតម្រូវការរបស់រដ្ឋាភិបាលធ្វើជាព្រៃសហគមន៍ និងការកសាងមជ្ឈមណ្ឌលហ្វឹកហ្វឺនរបស់រដ្ឋាភិបាល។ ចំពោះករណី វិវាទនៅខេត្តបាត់ដំបង រដ្ឋាភិបាលបានយកដីដែលកំពុងកាន់កាប់ដោយអ្នកភូមិមួយក្រុមមកធ្វើជាសម្បទានដី សង្គមកិច្ចសម្រាប់អ្នកភូមិមួយក្រុមទៀត ដូច្នោះហើយបានជាវិវាទនៅតែបន្តទៀតនៅទីនោះ។

តាមទស្សនៈរបស់អ្នកភូមិ ដោយមកពីពួកគាត់មានការខ្វះចំណេះដឹងផ្នែកច្បាប់ភូមិបាលនិងបទបញ្ញត្តិនានាទាក់ទងនឹងដីធ្លី និងធនធានធម្មជាតិ ទើបបានជាពួកគាត់តែងតែមានចិត្តប្រកាន់យកវិធានច្បាប់កាន់កាប់ដីធ្លីតាមបែបប្រពៃណី ដើម្បីអះអាងកម្មសិទ្ធិលើដីរបស់ខ្លួន។ ការយល់ដឹងអំពីកម្មសិទ្ធិតាមរយៈកេរ្តិ៍មរតកដែលត្រូវបានបញ្ជូនពី មួយជំនាន់ទៅមួយជំនាន់នៅតែអនុវត្តនៅឡើយ។ បើសូម្បីតែខ្មែរក្រហមបានរំលាយកម្មសិទ្ធិឯកជនលើដីធ្លីយ៉ាង ណាក្តី ក្រោយការទទួលស្គាល់នូវកម្មសិទ្ធិលើដីលំនៅដ្ឋាន និងដីកសិកម្ម ភស្តុតាងបានបង្ហាញឲ្យឃើញថា នៅក្នុងសហគមន៍ខ្លះនៃខេត្តចំនួនបី (កំពង់ស្ពឺ កំពង់ឆ្នាំង និង ពោធិ៍សាត់) ក្នុងបណ្តាខេត្តទាំងបួនអ្នកភូមិបានខំព្យាយាមយ៉ាងលំបាក ដើម្បីធ្វើជាម្ចាស់លើដីដែលជាកេរ្តិ៍តំណែលពីដូនតា។ ចំពោះទស្សនៈនេះ ពួកគាត់ជាអ្នកងាយរងគ្រោះដោយសារវិវាទដីធ្លី។

ស្ត្រីមួយរូបនៅភូមិស្រែសា បាននិយាយថា៖
*«នៅភូមិស្រែសាឆ្នាំ១៩៨២ អាជ្ញាធរបានចែកដីគ្រប់ៗគ្រួសារ។ ក្រោយឆ្នាំ១៩៩៣ អ្នកភូមិទាំងអស់នាំគ្នាទៅយកដីកេរ្តិ៍ពីដូនតា។ អ្នកខ្លះមានដីត្រូវម្ចាស់ដើមយកដីគេវិញ ទើបរដ្ឋអំណាចមូលដ្ឋានឲ្យដីទំនេរមួយកន្លែងទៅគាត់។ អ្នកខ្លះទៀតបង្ខំចិត្តទៅយកដីកេរ្តិ៍ដូនតានៅតំបន់ដំណាក់ត្រយឹង ដែលខ្មែរក្រហមធ្លាប់កាន់កាប់ពីមុន។ ខ្ញុំវិញមានដីកេរ្តិ៍ដែរ អញ្ចឹងខ្ញុំក៏ចាប់កាន់កាប់ដីនៅតំបន់នោះទៅ។»*

អ្នកភូមិម្នាក់មកពីភូមិក្បេត្របុរី ឃុំសន្ទ្រែ នៃខេត្តពោធិ៍សាត់បានត្អូញត្អែរថា៖
*«គេ(ភាគីទីពីរ) មកនេះមិនមែនចិត្តឯងទេ សុទ្ធមានច្បាប់មានទម្លាប់ត្រឹមត្រូវ យើងមិនខ្លាចគេ?។ គេមានច្បាប់ បានគេហ៊ានធ្វើ យើងហ៊ានថាគេ?។ តែយើងស្របច្បាប់ដែរហើយ ពីព្រោះកេរ្តិ៍គល់តាំងពីដើមមករបស់យាយតា តាំងពីដើមមក មិនមែនទៅចាប់ដីថ្មីឯណា។»*

នៅក្នុងសង្គមខ្មែរ ពាក្យ «កេរ្តិ៍» នេះមានអត្ថន័យរបស់វា។ បើសិនអ្នកណាម្នាក់មិនបានការពារកេរ្តិ៍មរតកពីដូនតាទេ គាត់នឹងត្រូវគេចាត់ទុកថា មនុស្សមិនបានជោគជ័យ។ ច្បាប់កេរ្តិ៍កាលបានពោលថា៖ *«កូនអើយកេរ្តិ៍មេបា ចូររក្សាគន់គិតគ្រង ថែទាំចាំរួសរង ប្រុងប្រយ័ត្ន ប្រយោជន៍យូរ»*។ ឃ្លានេះមានន័យថា មនុស្សជំនាន់ក្រោយគប្បីគិតគូរអំពីកេរ្តិ៍មរតកដូនតា ហើយត្រូវចេះការពារកេរនេះឲ្យបានហ្មត់ចត់សម្រាប់ទុកជាប្រយោជន៍យូរអង្វែង។

ម្យ៉ាងវិញទៀត អ្នកភូមិខ្លះបានត្អូញត្អែរអំពីភាពស្របច្បាប់នៃដីរបស់ខ្លួន ដោយផ្អែកលើពេលវេលាដែលពួកគាត់បានកាន់កាប់និងប្រើប្រាស់ដីនេះ គឺអ្នកភូមិបានកាន់កាប់និងប្រើប្រាស់ដីមុនពេលចេញអនុក្រិត្យអំពីសម្បទានដី។

អ្នកភូមិម្នាក់មកពីភូមិស្រែពពាយ ក្នុងខេត្តពោធិ៍សាត់បានត្អូញត្អែរថា៖

*«យើងមានដីនេះមិនស្របច្បាប់ មកតែពីអ្នកកាន់ច្បាប់មិនដែលស៊ីញ៉េឯកសារឲ្យយើងទេ បានចោទយើងថា ដាំដំណាំលើដីរដ្ឋ។ តែតាមពិតរដ្ឋទេ ដែលដោះយករួចខ្លួន តែយើងមិនថា។ យើងធ្វើលើដីនោះតាំងពីដំបូងមក ទើបរដ្ឋមកតាមក្រោយ គឺរដ្ឋទេដែលរំលោភយើង។»*

អ្នកភូមិម្នាក់ទៀតបានប្រាប់ថា៖

*«យើងមិនបានរំលោភច្បាប់ទេ ផ្ទុយទៅវិញច្បាប់ទេដែលរំលោភយើង ព្រោះយើងបានដាំដំណាំហើយ ទើបគេមកហាមយើងតាមក្រោយ។ គេគួរតែហាមយើងតាំងពីដំបូងមក។»*

បើតាមទស្សនវិស័យរបស់អាជ្ញាធរ ច្បាប់ និងបទបញ្ញត្តិនានាអំពីដីធ្លី និងធនធានធម្មជាតិត្រូវរៀបចំឡើងឲ្យមានកម្មសិទ្ធិដីធ្លី។ ដីសម្រាប់សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ចក្នុងខេត្តគោលដៅទាំងបួនភាគច្រើនស្ថិតក្នុងតំបន់ព្រៃ ដែលអនុលោមតាមច្បាប់ថាជាដីរបស់រដ្ឋ។ ទោះជាយ៉ាងនេះក្តី នៅក្នុងសម្បទានដីទាំងនេះប្រជាពលរដ្ឋបាន និងកំពុងកាន់កាប់ដី ដើម្បីគោលបំណងកសិកម្ម។ នៅពេលដែលក្រុមហ៊ុន ឬអាជ្ញាធរអនុវត្តសកម្មភាពទាក់ទង នឹងសម្បទានដី អ្នកភូមិចូលមកទាមទារដីទាំងនេះថាជាដីរបស់ខ្លួន។

មន្ត្រីមួយរូបក្នុងស្រុកភ្នំក្រវាញបានបានប្រសាសន៍ថា៖

*«អ្នកភូមិនៅក្បែរគ្រប់រីនេះ ធ្លាប់បានប្តឹងថា ក្រុមហ៊ុនរំលោភយកដីគាត់។តាមពិតដីនេះជាដីព្រៃទេ ពួកគាត់គ្រាន់តែប្រាប់ថា កន្លែងនេះជាដីរបស់គាត់។ យ៉ាងណាក៏ដោយ ដីនេះខាងអាជ្ញាធរបានជួលឲ្យក្រុមហ៊ុនរួចហើយ តែពួកគាត់នៅតែអះអាងថា ជាដីនេះស្ថិតនៅក្នុងភូមិចាស់ពីដូនតាគាត់។»*

## ៧.២ សេចក្តីសម្រេចមិនស៊ីសង្វាក់គ្នារបស់ស្ថាប័ននៃកម្រិតផ្សេងៗ

ការធ្វើសេចក្តីសម្រេចមិនស៊ីសង្វាក់គ្នារបស់ស្ថាប័នក្នុងកម្រិតផ្សេងៗ ដោយមិនបានពិគ្រោះយោបល់គ្នាអាចបណ្តាលឲ្យមានវិវាទ។ ក្នុងខេត្តគោលដៅដែលបានសិក្សា យើងសង្កេតឃើញមានការធ្វើសេចក្តីសម្រេចដោយអាជ្ញាធរថ្នាក់ក្រោម និងអាជ្ញាធរថ្នាក់លើអំពីការបែងចែងដីនិងបទបញ្ញត្តិទាក់ទងដីធ្លី គឺមិនស៊ីសង្វាក់គ្នាទេ។ គេសង្កេតឃើញមានលំនាំនេះនៅគ្រប់ទីកន្លែងក្នុងតំបន់ដីមានវិវាទ។ ការបែងចែកដីត្រូវបានធ្វើរួចហើយ ឬក៏អាជ្ញាធរថ្នាក់ភូមិនិងឃុំបានអនុញ្ញាតឲ្យអ្នកភូមិប្រើប្រាស់ដីនេះ សម្រាប់ការចិញ្ចឹមជីវិតរបស់ខ្លួន។ តែទោះជាយ៉ាងនេះក្តី សេចក្តីសម្រេចរបស់រដ្ឋបាលថ្នាក់លើ ដូចជាថ្នាក់ជាតិ និងថ្នាក់ខេត្តជាដើម បានលប់លើសេចក្តីសម្រេច

របស់ថ្នាក់ក្រោម ដូច្នោះហើយបានជាវិវាទផ្ទុះឡើង។ សម្រាប់ជាឧទាហរណ៍ យើងយកករណីវិវាទដីធ្លីចំនួនបួននៅខេត្តពោធិ៍សាត់ កំពង់ឆ្នាំង និងបាត់ដំបង។

វិវាទដីដែលបណ្តាលមកពីសម្បទានដីសង្គមកិច្ចនៅភូមិស្រែសា ឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ ក្នុងខេត្តកំពង់ឆ្នាំង។ អ្នកភូមិស្រែសាដែលបានចាប់ផ្តើមមករស់នៅចាប់ពីចុងទសវត្សរ៍ ១៩៨០មក បានក្លាយជាអ្នកគ្មានដីធ្លី ដោយសារប្រជាពលរដ្ឋមកពីភូមិដទៃៗទៀតក្នុងឆ្នាំ១៩៩៣ បានស្នើសុំដីដែលជាកេរ្តិ៍មរតកពីជំនាន់មុនយកធ្វើជាកម្មសិទ្ធិរបស់គេវិញ។ អ្នកភូមិដែលគ្មានដីទាំងនេះក៏តម្រូវកាន់កាប់ដីព្រៃថ្មី ដែលអាជ្ញាធរមូលដ្ឋានបានដឹងឮដែរ។ ក្រោយមកក្នុងអំឡុងឆ្នាំ ២០០៨-២០០៩ គណៈកម្មការចម្រុះថ្នាក់ស្រុក និងខេត្តបានសម្រេចធ្វើអត្តសញ្ញាណកម្មដី ដែលអ្នកភូមិទាំងនេះរស់នៅ និងធ្វើកសិកម្ម។ ការធ្វើអត្តសញ្ញាណកម្មដីនេះ គឺក្នុងគោលបំណងផ្តល់ដីដល់មន្ត្រីរាជការចូលនិវត្តន៍ យុទ្ធជនកាត់រំសាយ និងពលីពិការក្នុងក្របខណ្ឌសម្បទានដីសង្គមកិច្ច។

ករណីវិវាទនៅបឹងប្រាំ(វិវាទទី២៧)អាចទុកជាឧទាហរណ៍មួយទៀត ដែលឆ្លុះបង្ហាញនូវភាពមិនស៊ីសង្វាក់គ្នានៃសេចក្តីសម្រេចរបស់ថ្នាក់ដឹកនាំកម្រិតផ្សេងៗគ្នា។ ប្រជាពលរដ្ឋ១៩២គ្រួសារមកពីឃុំអំពិលប្រាំដើមនៅជិតខាងបានចូលមករស់នៅ ឬអាស្រ័យផលក្នុងតំបន់បឹងប្រាំ ចាប់តាំងពីពេលសមាហរណកម្មខ្មែរក្រហម ដោយមានការដឹងឮពីអាជ្ញាធរមូលដ្ឋាន។ ទោះជាយ៉ាងនេះក្តី នៅក្នុងឆ្នាំ២០១១ អនុក្រឹត្យលេខ ២០២ ចេញដោយរាជរដ្ឋាភិបាលបានសម្រេចធ្វើអនុបយោគតំបន់គ្របដណ្តប់ដោយព្រៃនេះ ជាដីឯកជនរបស់រដ្ឋ នៅក្នុងគោលបំណងប្រែក្លាយតំបន់ នេះទៅជាសម្បទានដីសង្គមកិច្ចសម្រាប់ប្រជាពលរដ្ឋនៅឃុំបឹងប្រាំ ជាហេតុនាំឲ្យជាន់ទៅលើដីដែលក្រុម ១៩២ គ្រួសាររស់នៅ ឬអាស្រ័យផល។ គណៈកម្មការសុរិយោដីបានចេញប័ណ្ណកម្មសិទ្ធិប្រជាពលរដ្ឋឃុំបឹងប្រាំ ទោះជាយ៉ាងនេះក្តី ក្រុម១៩២គ្រួសារមកពីឃុំអំពិលប្រាំដើមមិនព្រមចាកចេញពីតំបន់នេះទេ។ ម្ល៉ោះហើយជាលទ្ធផល ប្រជាពលរដ្ឋឃុំបឹងប្រាំមានប័ណ្ណកម្មសិទ្ធិដី ប៉ុន្តែមិនអាចទទួលបានដីឡើយ។ ចំណែកឯក្រុម១៩២គ្រួសារមានប័ណ្ណក៏ពិតមែន ក៏ប៉ុន្តែបានកាន់កាប់ដីនេះ និងអះអាងថា ពួកគាត់បានចូលកាន់កាប់ដីនេះអស់រយៈពេលជាយូរមកហើយ ដូច្នោះប្រជាពលរដ្ឋនៅទីនោះតែងនាំគ្នានិយាយលេងថា «*មានប្លង់អត់ដី មានដីអត់ប្លង់*»។

ព្រៃសហគមន៍ភូមិស្រែពពាយ (វិវាទទី២២) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៣ តាមគំនិតផ្តួចផ្តើមរបស់អ្នកភូមិ និងមានការទទួលស្គាល់ពីសំណាក់រដ្ឋបាលព្រៃឈើថ្នាក់ខេត្ត។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងឆ្នាំ២០១០ អាជ្ញាធរស្រុកភ្នំក្រវាញបានប្រកាសអំពីការដាក់បញ្ចូលព្រៃសហ

គមន៍នេះ ទៅក្នុងសម្បទានដីសង្គមកិច្ច ព្រមទាំងមានការ ឯកភាពយល់ព្រមពីសម្តេចនាយករដ្ឋមន្ត្រីផង។ (*ប្រធានភូមិស្រែពពាយ*)

ដូច្នេះគ្រប់ករណីវិវាទទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ច បានកើតឡើងមកពីសេចក្តីសម្រេចរបស់រដ្ឋបាលថ្នាក់ជាតិ ដែលជំទាស់នឹងសេចក្តីសម្រេចដំបូងរបស់ថ្នាក់ភូមិនិងឃុំ ដែលអនុញ្ញាតឲ្យប្រជាពលរដ្ឋមករស់នៅតំបន់វិវាទនោះ ដោយមិនបានពិគ្រោះយោបល់ជាមួយគ្នា។

## ៧.៣ ដំណើរការយឺតនៃការចុះបញ្ជីដីធ្លី ប៉ុន្តែសម្បទានដីមានល្បឿនលឿន

ចាប់តាំងពីឆ្នាំ១៩៨៥ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំអនុវត្តវិស័យបីជាអាទិភាពដើម្បីកំណែទម្រង់ដីធ្លី៖ រដ្ឋបាលដីធ្លី ការគ្រប់គ្រងដីធ្លី និងការបែងចែកដីធ្លី។ នៅខែមិថុនាឆ្នាំ២០០២ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានបង្កើតគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ដែលបច្ចុប្បន្ននេះមានឈ្មោះថាកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី នៅក្នុងគោលដៅលើកកំពស់សន្តិសុខទាក់ទងសិទ្ធិកាន់កាប់ដីធ្លី និងជំរុញការអភិវឌ្ឍទីផ្សារដីធ្លី ប្រកបដោយប្រសិទ្ធភាព។ បើតាមរបាយការណ៍ក្នុងខែមិថុនា ឆ្នាំ២០១៣ គឺមួយខែមុនការបោះឆ្នោតថ្នាក់ជាតិនៅដំណាក់កាលទីមួយនៃកម្មវិធីចុះបញ្ជីដីធ្លី មានដីចំនួន ៦៦០ ០០០ក្បាល ត្រូវបានវាស់វែង និងបានចេញប័ណ្ណកម្មសិទ្ធិចំនួន ៣៨០.០០០ប័ណ្ណ។ រាជរដ្ឋាភិបាលបានជូនដំណឹងថា ក្នុងដំណាក់កាលទីពីរ ដែលចាប់ផ្តើមអនុវត្តសកម្មភាពបន្តក្នុងខែវិច្ឆិកា ឆ្នាំ២០១៣ ក្រុមយុវជនស្ម័គ្រចិត្តនឹងចុះវាស់វែងដីទំហំ ៥០ ០០០ហិកតា(អាដហុក ឆ្នាំ២០១៣)។ បើយោងតាមព័ត៌មានរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មកទល់នឹងថ្ងៃទី២៩ខែវិច្ឆិកាឆ្នាំ២០១៤ ជាលទ្ធផលនៃការអនុវត្តបទបញ្ជា ០០១ ក្រសួងបានផ្តល់ប័ណ្ណកម្មសិទ្ធិដីចំនួន ៦១០.០០០ប័ណ្ណ ជូនប្រជាពលរដ្ឋ។ ជាលទ្ធផលសរុបមានប័ណ្ណកម្មសិទ្ធិដីចំនួន ៣ ៨០០.០០០ ប័ណ្ណ ដែលត្រូវបានប្រគល់ជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស(http://mlmupc.gov.kh/)។

ទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋដែលមានវិវាទក្នុងភូមិសំណាកគំរូក្នុងខេត្តដែលយើងបានសិក្សាមិនមែនសុទ្ធតែគ្រប់គ្នាបានទទួលប័ណ្ណកម្មសិទ្ធិដីនោះទេ។ ម្ល៉ោះហើយអ្នកភូមិទាំងនេះមិនមានឯកសារដែលមានសុពលភាព សម្រាប់ជាភស្តុតាងតទល់នឹងការអនុវត្តសម្បទានដីសេដ្ឋកិច្ច ឬសង្គមកិច្ចឡើយ។

## តារាងទី៧: ស្ថានភាពវិវាទដីធ្លីទាក់ទងនឹងឯកសារបញ្ជាក់ (%)

| ដីលំនៅដ្ឋាន (ចំនួន =7) | | ស្រែ (ចំនួន =154) | | ចំការ (ចំនួន =39) | | ដីព្រៃ (ចំនួន =165) | | | ដីព្រៃសហគមន៍ (ចំនួន =49) | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ពិតមែន | ទេ | ពិតមែន | ទេ | ពិតមែន | ទេ | ពិតមែន | ទេ | មិនដឹង | ពិតមែន | ទេ | មិនដឹង |
| 42.9 | 57.1 | 51.9 | 48.1 | 23.1 | 76.9 | 17 | 72.1 | 10.9 | 10.2 | 67.3 | 22.5 |

អ្នកភូមិចំនួនតិចជាងពាក់កណ្តាល (៤៨.១%) មានស្រែ និង៥៧.១% ទៀត ដែលមានដីលំនៅដ្ឋានមានវិវាទមិនមានឯកសារអ្វីសម្រាប់បញ្ជាក់ពីកម្មសិទ្ធិរបស់ខ្លួនទេ។ ចំណែកឯ ៧៦.៩%នៃអ្នកដែលមានចំការ ៧២.១% នៃអ្នកដែលមានដីព្រៃ និង៦៧.៣% នៃអ្នកមានដីក្នុងព្រៃសហគមន៍ក៏មិនមានឯកសារបញ្ជាក់កម្មសិទ្ធិដែរ។ ភាគច្រើននៃឯកសារបញ្ជាក់កម្មសិទ្ធិលើដីចំការ ដីព្រៃ និងដីព្រៃសហគមន៍ ជាលិខិតបញ្ជាក់ដីធ្លីដែលចេញដោយមេភូមិ លិខិតផ្ទេរកម្មសិទ្ធិ និងពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លីដែលចេញដោយមេឃុំឬក្រុមប្រឹក្សាឃុំ។ ឯកសារទាំងនេះមិនរឹងមាំទេ បើប្រៀបធៀបនឹងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត។ មានតែ២៥%នៃឯកសារសម្រាប់ដីព្រៃនិង២០%នៃដីព្រៃសហគមន៍ប៉ុណ្ណោះ ដែលបានផ្តល់ដោយស្ថាប័នថ្នាក់ខេត្តនេះ។ ចំពោះករណីវិវាទនៅឃុំបឹងប្រាំ អ្នកភូមិមួយចំនួនបានទទួលប័ណ្ណកម្មសិទ្ធិដីធ្លី ប៉ុន្តែមិនអាចយកដីបាន ពីព្រោះភាគីវិវាទម្ខាងទៀតមិនព្រមឲ្យ ដោយអះអាងថា ពួកគេបានកាន់កាប់ដីនេះយូរមកហើយ។ *«អ្នកឯងដាំដំណាំនឹងប័ណ្ណហ្នឹងទៅតែខ្ញុំដាំដំណាំលើដីខ្ញុំ»* (អ្នករស់នៅភូមិយុត្តិធម៌ម្នាក់ ឃុំបឹងប្រាំបានដកស្រង់សំដីរបស់ភាគីទីពីរ)។

# ៨. យុទ្ធសាស្ត្រយកដី/កាន់កាប់ដី

## ៨.១ យុទ្ធសាស្ត្ររបស់ក្រុមហ៊ុន

ដើម្បីអនុវត្តសម្បទានដីសេដ្ឋកិច្ចបាន ក្រុមហ៊ុនឯកជនត្រូវទទួលបាននូវកិច្ចសន្យាមួយស្ដីពីសម្បទានដីសេដ្ឋកិច្ចពីរាជរដ្ឋាភិបាល។ មុននឹងចាប់ផ្ដើមសកម្មភាពក្រុមហ៊ុនត្រូវផ្ដល់ព័ត៌មានជូនអាជ្ញាធរមូលដ្ឋាន។ តែវាមិនមិនច្បាស់ថា តើក្រុមហ៊ុនបានផ្ដល់ព័ត៌មានដល់អ្នកភូមិអំពីពេលវេលាដែលក្រុមហ៊ុនចាប់ផ្ដើមរានព្រៃ ដើម្បីដាំដំណាំដែរឬទេ។ អ្នកភូមិភាគច្រើនត្អូញត្អែរថា ពួកគាត់មិនបានទទួលព័ត៌មានទាក់ទងនឹងពេលវេលាដែលក្រុមហ៊ុនចាប់ផ្ដើមរានព្រៃនោះទេ។ ក្នុងករណីវិវាទខ្លះ អាជ្ញាធរមូលដ្ឋាននៅថ្នាក់ទាបជាងក៏មិនបានទទួលព័ត៌មានអំពីបញ្ហាហ្នឹងដែរ។

នៅពេលសួរមេឃុំមួយរូបថា តើគាត់បានទទួលព័ត៌មានពីក្រុមហ៊ុនស៊ីធីម៉ាត ឬពីអាជ្ញាធរមូលដ្ឋានថ្នាក់លើដែរឬទេ គាត់ក៏បានបញ្ជាក់៖ *«ខ្ញុំអត់បានព័ត៌មានអីទេ។លោកអាចសាកសួរព័ត៌មាននេះទៅខាងលោកអភិបាលស្រុក។»*

អ្នកភូមិបានបញ្ជាក់ប្រាប់ពីសកម្មភាពមួយចំនួនទាក់ទងនឹងរបៀប ដែលភាគីទីពីរបានទាមទារដីវិវាទថា ជារបស់ខ្លួន។ ២៨.៦%នៃអ្នកផ្ដល់ចម្លើយបានប្រាប់ថា មានការគំរាមចំពោះអ្នកកាន់កាប់ដីដំបូង ចំណែកឯអ្នក ផ្ដល់ចម្លើយច្រើនជាងមួយភាគបី (៣៦.៣%) មិនបានដឹងអំពីសកម្មភាពទាមទារដីរបស់ភាគីទីពីរទេ។

### តារាងទី៨: របៀបដែលភាគីទីពីរទាមទារដីវិវាទ

| ការទាមទាររបស់ភាគីទីពីរ | ចំនួន | ភាគរយ |
|---|---|---|
| មិនដឹង | 139 | 36.2% |
| ការគំរាមចំពោះអ្នកកាន់កាប់ដីដំបូង | 110 | 28.6% |
| ការរំលោភអំណាចរបស់មន្ត្រីរដ្ឋាភិបាលនិងឈ្មួញដែលមានទំនាក់ទំនងល្អ | 37 | 9.6% |
| ការរានដីដោយមិនបានបង្ហាញឯកសារ | 33 | 8.6% |
| មានឯកសារគាំទ្រ/លិខិតអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន | 21 | 5.5% |
| អ្នកភូមិបានលក់ដី | 13 | 3.4% |
| ភាគីទីពីរប្រាប់ថាបានទិញដីរដ្ឋ (ពីរដ្ឋាភិបាល) | 12 | 3.1% |
| អំពើហិង្សាលើអ្នកកាន់កាប់ដីដំបូង | 8 | 2.1% |
| ផ្សេងទៀត | 11 | 2.9% |

យុទ្ធសាស្ត្រក្រុមហ៊ុនគឺ *«ត្រូវរានព្រៃជាមុនសិន ទើបដោះស្រាយបញ្ហាតាមក្រោយ»*។ ស្ទើរគ្រប់ករណីវិវាទជាមួយសម្បទានដីសេដ្ឋកិច្ច ក្រុមហ៊ុនចាប់ផ្តើមរានដីព្រៃ ដើម្បីកំណត់ព្រំដីសម្បទានតាមការប្រើផែនទីរបស់ខ្លួន ដោយ មិនបានប្រាប់អ្នកភូមិឲ្យបានដឹងជាមុន ពីព្រោះគេបានអះអាងថា បានផ្តល់ព័ត៌មានដល់អាជ្ញាធរមូលដ្ឋានរួចហើយ។ នៅពេលដែលដំណើរការកំណត់ព្រំដីសម្បទានបានហួសចូលដល់ដីអ្នកភូមិ ទើបតំណាងក្រុមហ៊ុនចេញមកចរចា។ កិច្ចចរចាជាមួយអ្នកភូមិ និងដំណើរការកំណត់ព្រំដីសម្បទានបានប្រព្រឹត្តទៅពេលក្នុងពេលជាមួយគ្នា។ យុទ្ធសាស្ត្រនេះនាំឲ្យអ្នកភូមិដែលមានដីវិវាទងាយនឹងរងគ្រោះ។

តំណាងប្រជាពលរដ្ឋនៅភូមិគោកម្នាក់និយាយប្រាប់អំពីរបៀប ដែលពួកគាត់បានបាត់បង់ដីកសិកម្មរបស់ខ្លួន ដោយសារដំណើរការរកំណត់ព្រំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន៖
*«ដំបូងគេយកគ្រឿងចក្រមកឈូសឆាយដីនៅទំនេរ (ដើម្បីកំណត់ព្រំដីក្រុមហ៊ុន)។ យើងទៅតវ៉ាឲ្យគេបញ្ឈប់ រួចគេឲ្យគ្រឿងចក្រផ្អាកសិន។ គេឲ្យយើងទៅតវ៉ាគ្នា ដោះស្រាយនៅសាលាឃុំ។ តែល្ងាចមកពីសាលាឃុំ គេឈូសអស់រលីង មើលលែងស្គាល់ដី ណាជាដីណា ព្រំប្រទល់ពីណាទល់ណាទេ។ម្នាក់ៗបាត់បង់អស់រលីង មិនដឹងរបស់អ្នកណានៅត្រង់ណាទេ។ ហ្នឹងជាយុទ្ធសាស្ត្ររបស់គេ។»*

តំណាងម្នាក់ទៀតមកពីភូមិគោកដែរបាននិយាយថា៖ *«យើងប្រាប់កុំឲ្យគេឈូស ចាំដោះស្រាយសិន។ ប្រាប់ហើយបីបួនថ្ងៃមកគេនៅតែឈូស។ គេមកនេះដូចជាមកយកដីយើងតែម្តង។»*

បន្ទាប់ពីរានដីរួចហើយ តំណាងក្រុមហ៊ុនបានបន្តចរចាជាមួយអ្នកភូមិទៀត។ ដោយបានទទួលកិច្ចសន្យាពីរាជរដ្ឋាភិបាលក្នុងដំណើរការនៃកិច្ចចរចានេះ ក្រុមហ៊ុនបានទាញយកប្រយោជន៍ពីអ្នកភូមិដែលភាគច្រើនមិនមានឯកសាររឹងមាំជាភស្តុតាងថាជាដីរបស់ពួកគាត់មែន។

យុទ្ធសាស្ត្រ មួយទៀតគឺ ក្រុមហ៊ុនបានប្រើអ្នកគួរជេរ ឬអាជ្ញាធរមូលដ្ឋានសម្រាប់បញ្ចុះបញ្ចូលអ្នកភូមិពីម្នាក់ទៅម្នាក់ឲ្យទទួលយកសំណងដ៏តិចតួចមិនសមស្របនឹងមិនគួរទទួលយក៖
*«បើយកឬមិនយក (សំណងជាលុយ) គេនៅតែយកដី។ អញ្ចឹងយកទៅ គ្រាន់បើជាងអត់។ បើព្រមយក ឬមិនព្រមយក ក៏គេនៅតែឈូសដី។»* (តំណាងអ្នកភូមិម្នាក់នៅភូមិគោក)។

ក្រុមហ៊ុនបានបំភិតបំភ័យអ្នកភូមិ ដោយប្រើច្បាប់ទាក់ទងនឹងដីធ្លី និងធនធានធម្មជាតិដែលអ្នកភូមិបានកាន់កាប់មិនស្របច្បាប់ ពីព្រោះដីព្រៃទាំងអស់ជាដីរដ្ឋ។ ផលចំណេញបានពីយុទ្ធសាស្ត្រនេះគឺ អ្នកភូមិស្លូតត្រង់ច្រើននាក់មុខជាបានទទួលសំណង ពីព្រោះពួកគាត់ខ្លាចបាត់បង់ដីដោយ

មិនបានអ្វីសោះ ម្ល៉ោះហើយក៏ផ្ចិតមេដៃប្រគល់ដីទៅឲ្យក្រុមហ៊ុនទៅ។ វាក៏ងាយស្រួលផងដែរសម្រាប់ក្រុមហ៊ុននៅក្នុងការទាក់ទងជាមួយ«អ្នកភូមិរឹងរូស»មួយចំនួនតូច ដែលជំទាស់នឹងសកម្មភាពរបស់ក្រុមហ៊ុន ឬក៏តថ្លៃឲ្យបានតម្លៃដីសមស្របច្រើន ឬតិចទៅ តាមទីផ្សារដីធ្លី។

ជាការពិតដែលថា យុទ្ធសាស្ត្ររបស់សមាជិកសហគមន៍ក្នុងស្ថានភាពឯកោបានទទួលជោគជ័យ។ អ្នកភូមិគ្រប់គ្នាបានយល់ព្រមទទួលសំណងជាបន្តបន្ទាប់។ ទោះជាយ៉ាងនេះក្តី សំណងពីគ្រួសារមួយទៅគ្រួសារមួយមានចំនួនខុសៗគ្នា អាស្រ័យទៅតាមកម្រិតនៃការស៊ូទ្រាំទាមទាររបស់គ្រួសារនីមួយៗនៅក្នុងការចរចាតម្លៃសំណង។ អ្នកភូមិ ដែលព្រមទទួលសំណងជាប្រាក់ នៅពេលដែលក្រុមហ៊ុនបានស្នើតម្លៃដំបូងបានទទួលសំណងតិចតួចណាស់ បើ ប្រៀបធៀបនឹងអ្នកដែលខិតខំទាមទារយ៉ាងមុតមាំ។ ជាឧទាហរណ៍ នៅភូមិគោក អ្នកភូមិមួយចំនួនបានទទួល សំណងត្រឹមតែ ១៥ម៉ឺនរៀលទៅ ២០ម៉ឺនរៀល ឬ ៣៦ ទៅ ៥០ដុល្លារប៉ុណ្ណោះ សម្រាប់ដីមួយហិកតាដែលបាត់បង់ នៅពេលកោះហៅប្រជុំមកចរចាលើកដំបូង ហើយមានតែបី ឬបួនគ្រួសារជាចំនួនយ៉ាងតិចតួចណាស់ ដែលបាន សុខចិត្តទទួលសំណង ក្នុងចំនួនទឹកប្រាក់ចំនួនពី ៩០០ ទៅ ១០០០ ដុល្លារក្នុងដីមួយហិកតា នៅពេលកោះប្រជុំ លើកទីប្រាំដែលជាលើកចុងក្រោយ។

## ៤.២ យុទ្ធសាស្ត្ររបស់អ្នកភូមិ

អ្នកភូមិជាអ្នកងាយរងគ្រោះ និងស្ថិតក្នុងស្ថានភាពទន់ខ្សោយជាង បើប្រៀបធៀបនឹងក្រុមហ៊ុន។ ក្នុងខេត្តបួនដែលបានសិក្សា មានអ្នកភូមិតិចតួចបំផុតដែលបានទទួលវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិដីដែលមានសុពលភាពលើកលែងតែខេត្តបាត់ដំបង ដែលអ្នកភូមិភាគច្រើនមានឯកសារសម្រាប់បញ្ជាក់ថាជាដីស្រែរបស់ខ្លួន។ កង្វះខាតឯកសារបញ្ជាក់ សូម្បីតែដីស្រែដែលជាប្រភេទដីយ៉ាងសំខាន់សម្រាប់ការផ្គត់ផ្គង់ការចិញ្ចឹមជីវិតក៏កើតមានដែរ ជាពិសេសនៅខេត្តកំពង់ស្ពឺ។ ឯកសារដែលពួកគាត់មាន ជាឯកសារដែលបានចេញដោយអាជ្ញាធរមូលដ្ឋានថ្នាក់ក្រោម ឬមួយ ជាលិខិតទិញលក់ដែលទទួលស្គាល់ដោយមេភូមិ ឬមេឃុំ។

បែបផែនជាប្រពៃណីនៃការផ្ទេរដីពីមួយជំនាន់ទៅមួយជំនាន់ ដោយមានសាក្សីទទួលស្គាល់ព្រំដីគឺជាយុទ្ធសាស្ត្ររួមសម្រាប់អ្នកភូមិនៅក្នុងភូមិសំណាកគំរូនៃខេត្តទាំងបី (កំពង់ស្ពឺ កំពង់ឆ្នាំង និង ពោធិ៍សាត់)។ ក្នុងករណីវិវាទខ្លះ ពួកគេបានអះអាងថាអាជ្ញាធរមូលដ្ឋានបានផ្តល់ដីទៅឲ្យពួកគាត់តាមពាក្យសុំដី។ អ្នកភូមិមានការខ្វះខាតចំណេះដឹងអំពីទិដ្ឋភាពច្បាប់ ដូចជាពួកគាត់មិនបានដឹងថាច្បាប់ភូមិបាលឆ្នាំ២០០១ ដែលមិនទទួលស្គាល់កម្មសិទ្ធិចាស់មុនឆ្នាំ១៩៧៩ជាដើម ក៏ដូចជាមាត្រា ៣០ ក្នុងច្បាប់ភូមិបាលស្តីពីភោគៈមិនមានការជំទាស់ជាដើម។ ឥរិយាបថបែបនេះធ្វើឲ្យពួកគាត់មិនយកចិត្តទុកដាក់ឲ្យបានច្រើន ដើម្បីនឹងទទួលបានឯកសារបញ្ជាក់អចលនវត្ថុរបស់

ខ្លួន។ វាជាការពិតនៅពេលសួរពួកគាត់ថា តើមានអ្នកសម្រុះសម្រួលណាបានពន្យល់ពួកគាត់ ឬសហគមន៍អំពីអ្វីទាក់ទងនឹងច្បាប់ភូមិបាល ឬឯកសារដទៃទៀតស្តីពីដីធ្លីដែរឬទេ គឺមានតែ ៣៦.៩%ទេ ដែលផ្តល់ចម្លើយវិជ្ជមាន។ ទោះជាយ៉ាងណាក៏ដោយ ក្នុងចំណោមអ្នកផ្តល់ចម្លើយទាំងនេះ៦២.៩%បានបញ្ជាក់ថា ការពន្យល់មិនសូវច្បាស់ ឬមួយមិនច្បាស់សោះ។

«មាត្រា ៣០: បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈ ដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ឆ្នាំ យ៉ាងតិចគិតមកដល់កាលបរិច្ឆេទនៃការប្រកាសឲ្យប្រើប្រាស់ច្បាប់នេះ លើអចលនវត្ថុដែលមានលក្ខណៈត្រឹមត្រូវ តាមច្បាប់ក្នុងការកាន់កាប់ជាឯកជនមានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិបាន។ ក្នុងករណីមានការជំទាស់ដល់ការផ្តល់កម្មសិទ្ធិស្ថាពរនេះ អ្នកតវ៉ាត្រូវយកភស្តុតាងមកបញ្ជាក់ថា ខ្លួនឯងផ្ទាល់បានបំពេញលក្ខខណ្ឌនៃភោគៈ ដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ឆ្នាំនៅលើអចលនវត្ថុ ដែលមានជំទាស់ ឬយកភស្តុតាងដែលថា ខ្លួនបានទិញអចលនវត្ថុនេះពីភោគីដើម ឬសិទ្ធិវន្តស្របច្បាប់ ឬអ្នកទទួលផ្ទេរកម្មសិទ្ធិ ឬពីសន្តិជនរបស់ខ្លួន។»(RGC 2001a)

ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកមួយរូបបានមានប្រសាសន៍ថា៖
*«កន្លែងនេះ ប្រជាពលរដ្ឋបានវិលត្រឡប់មកវិញ ក្រោយសមាហរណកម្មខ្មែរក្រហម ហើយគាត់មករស់នៅតាមរបៀបកេរ្តិ៍អាករពីបរមបុរាណ(...) ប្រជាពលរដ្ឋមិនសូវចាប់អារម្មណ៍ប័ណ្ណកម្មសិទ្ធិហ្នឹងទេ ពីព្រោះនៅស្រុកនេះប្រជាពលរដ្ឋអត់សូវយល់ដឹងពីទិដ្ឋភាពច្បាប់ពាក់ព័ន្ធនឹងកម្មសិទ្ធិដី។»*

កង្វះចំណេះដឹងអំពីទិដ្ឋភាពផ្លូវច្បាប់ទាក់ទងនឹងកម្មសិទ្ធិដីធ្លី ហើយការមិនមានឯកសារសម្រាប់បញ្ជាក់អចលនវត្ថុ ធ្វើឲ្យអ្នកភូមិមានងាយរងគ្រោះ។ ពួកគាត់មិនមានអ្វីជាសំអាង ដើម្បីតវ៉ាជំទាស់នឹងក្រុមហ៊ុននោះទេ និងបើតាមទស្សនវិស័យស្តីពីទិដ្ឋភាពច្បាប់ដែលភាគីទីពីរនៃវិវាទ ឬអ្នកសម្រុះសម្រួលបានពន្យល់ គឺត្រូវតម្រូវឲ្យពួកគាត់ទទួលយកសំណងដែលអាចទទួលយកបានពីក្រុមហ៊ុនជាថ្នូរនឹងដីដែលបាត់បង់។

# ៩. ដំណើរការដោះស្រាយដីធ្លី

## ៩.១ យន្តការដោះស្រាយវិវាទដីធ្លី

ដូចដែលបានបញ្ជាក់នៅខាងលើ នៅប្រទេសកម្ពុជាមានយន្តការដោះស្រាយវិវាទចំនួនប្រាំ៖ ក្រុមប្រឹក្សាឃុំ/សង្កាត់ គណៈកម្មការសុរិយោដី គណៈកម្មការរដ្ឋបាល អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងតុលាការ។ទោះជាយ៉ាងណាក៏ដោយ ស្ថាប័នដែលសកម្មជាងគេក្នុងការដោះ

ស្រាយវិវាទគឺ ក្រុមប្រឹក្សាឃុំ/សង្កាត់ និងអាជ្ញាធរស្រុក។ ក្នុងខេត្តគោលដៅទាំងបួន មានវិវាទតែពីរប៉ុណ្ណោះ គឺនៅភូមិកេះ និងភូមិក្រៀលពង ក្នុងឃុំតាសាល ស្រុកឱរ៉ាល់នៃខេត្តកំពង់ស្ពឺ ក្នុងចំណោមវិវាទទាំង២៨ (វិវាទទី៧ និងទី៨) ដែលបានដោះស្រាយនៅត្រឹមថ្នាក់ភូមិ។ មេភូមិ និងអនុប្រធានភូមិបានចាត់ចែងការប្រមូលផ្តុំអ្នកភូមិទៅជួបចរចាជាមួយក្រុមហ៊ុន ហើយក៏បានសម្រេចកិច្ចព្រមព្រៀង ដោយមិនមានអំពីហិង្សា។

មានវិវាទចំនួន៦ទៀតជាមួយក្រុមហ៊ុន វិវាទពីរនៅឃុំសង្កែសាទប (វិវាទទី២ និងទី៣) និង៤វិវាទនៅឃុំយាអង្គ (វិវាទទី១១ ១២ ១៣ និង១៤) ក្នុងខេត្តកំពង់ស្ពឺ ក្នុងចំណោមវិវាទទាំង២៨ ដែលបានដោះស្រាយនៅថ្នាក់ឃុំ។ ក្រុមប្រឹក្សាឃុំបានចាត់ចែងការកោះអញ្ជើញភាគីវិវាទទាំងសងខាង(តំណាងក្រុមហ៊ុននិងអ្នកភូមិ) ដើម្បីជួបចរចាគ្នានៅសាលាឃុំ។ កិច្ចព្រមព្រៀងអាចសម្រេចទៅបានតាមការផ្តល់សំណងបន្តិចបន្តួច ដោយមានអ្នកផ្សេងទៀត ដែលជាអ្នកគួរជេរ ឬជាអ្នករៀបដី ដែលបានជួបជជែកជាមួយអ្នកភូមិ ដោយប្រើយុទ្ធសាស្ត្រគំរាមថា បើអ្នកភូមិព្រមយក ឬក៏មិនព្រមយកសំណង ក៏ក្រុមហ៊ុននៅតែយកដីជាដដែលទេ។

មានករណីវិវាទចំនួន៥ទៀតក្នុងចំណោមវិវាទ២៨ ដែលបានដោះស្រាយនៅថ្នាក់ស្រុក ក្នុងនោះករណីវិវាទបួននៅឃុំសង្កែសាទប (វិវាទទី១ ទី៤ ទី៥ និងទី៦) ក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដែលអាជ្ញាធរថ្នាក់ស្រុកបានចូលរួមក្នុងការដោះស្រាយវិវាទ តាមវិធីសម្រុះសម្រួលបន្តពីថ្នាក់ឃុំ ដែលអ្នកភូមិនៅសេសសល់ពីរបីនាក់មិនសុខចិត្តទទួលយកសំណងតិចតួចពីក្រុមហ៊ុន។ ចំពោះករណីវិវាទមួយនៅខេត្តពោធិ៍សាត់ (វិវាទទី២៤) ដែលក្រុមហ៊ុនបានរានព្រៃ ហើយត្រួតលើដីអ្នកភូមិក្នុងមួយគ្រួសារៗចំនួន ២-៣ហិកតា។ អន្តរាគមន៍របស់ថ្នាក់ស្រុកអាចបញ្ចប់បានតាមរយៈការវាស់វែងដីក្រុមហ៊ុនឡើងវិញ និងកាត់ដីជូនអ្នកភូមិវិញ។

សូម្បីអ្នកភូមិមួយចំនួនក៏មិនបានសប្បាយចិត្តនឹងការដោះស្រាយវិវាទដីធ្លីរបស់ខ្លួនដែរ បើទោះបីជាគណៈកម្មការចម្រុះថ្នាក់ស្រុកនិងខេត្ត បានដោះស្រាយបញ្ចប់វិវាទនៅខេត្តកំពង់ឆ្នាំង (វិវាទទី១៧ និង ទី២០) នៅខេត្តបាត់ដំបង (វិវាទទី២៦) និងនៅខេត្តពោធិ៍សាត់ (វិវាទទី២៤ និងទី២៥)។ ទោះជាយ៉ាងណានេះក្តី ករណីវិវាទរវាងប្រជាពលរដ្ឋនៅភូមិស្រែសា និងភូមិមានកលិច (វិវាទទី១៧) និងកងរាជអាវុធហត្ថ ដែលគណៈកម្មការចម្រុះថ្នាក់ស្រុកនិងខេត្តបានដោះស្រាយវិវាទជាថ្នូរនឹងដីនៅតំបន់ផ្សេងទៀតជូនអ្នកភូមិ ហើយក៏មានអ្នកដែលបានទទួលសំណងជាប្រាក់សមរម្យផងដែរ។ ចំពោះករណីវិវាទនៅភូមិក្បេគ្រុបុរី (វិវាទទី២៨) ដោយអនុវត្តតាមបទបញ្ជា០០១របស់សម្តេចនាយករដ្ឋមន្ត្រី គណៈកម្មការរដ្ឋបាលថ្នាក់ខេត្តបានដោះស្រាយវិវាទ តាមការចុះវាស់វែងដីអាស្រ័យផលជូនប្រជាពលរដ្ឋ។ ករណីវិវាទរវាងប្រជាពលរដ្ឋនៅភូមិតាំងគ្រួសកើត (វិវាទទី២០)

ក្នុងខេត្តកំពង់ឆ្នាំងជាមួយនឹងក្រុមហ៊ុនជប៉ុនមួយ មន្ត្រីរដ្ឋបាលព្រៃឈើ និងអាជ្ញាធរស្រុកបានធ្វើអន្តរាគមន៍ ហើយអ្នកភូមិក៏នៅបន្តប្រើប្រាស់ដីរបស់ខ្លួនតទៅទៀត។

មានតែវិវាទមួយគត់នៅភូមិត្រពាំងក្រើញ (វិវាទទី៩) ក្នុងស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដែលអាជ្ញាធរខេត្តបានធ្វើអន្តរាគមន៍ ដោយមានជំនួយពីអ្នករៀបដីនិងក្រុមហ៊ុនបានព្រមព្រៀងប្រគល់ដីចំនួន ១៥០០ហិកតាជូនអ្នកភូមិវិញ ហើយបន្ទាប់មកអ្នកភូមិបានលក់ដីនេះទៅឲ្យក្រុមហ៊ុនមួយទៀត។

មានករណីវិវាទចំនួន៩ (វិវាទទី១០ ទី១៥ ទី១៦ ទី១៨ ទី១៩ ទី២១ ទី២២ ទី២៧ និងទី២៨) ក្នុងចំណោមវិវាទទាំង២៨ កំពុងព្យួរនៅឡើយ។ ចំពោះករណីវិវាទមួយនៅភូមិត្បែងប្រជាប់ (វិវាទទី ១០) អាជ្ញាធរស្រុកបានព្រមានអ្នកភូមិឲ្យ ផ្អាកការប្រើប្រាស់ដីមានវិវាទនេះសិន ប៉ុន្តែអ្នកភូមិមួយចំនួននៅតែបន្តធ្វើកសិកម្ម នៅក្នុងក្តីបារម្ភចំពោះការដោះស្រាយវិវាទនៅពេលខាងមុខ។ ករណីវិវាទមួយទៀតនៅភូមិតាំងសំរោង ក្នុងស្រុកភ្នំស្រួច(វិវាទទី១៥) ប្រជាពលរដ្ឋ បានធ្វើដំណើរទៅស្នើសុំការដោះស្រាយនៅក្រសួងមហាផ្ទៃ ទីស្តីការគណៈរដ្ឋមន្ត្រី និងតុលាការខេត្ត។ វិវាទទាក់ទងនឹងសម្បទានដីសង្គមកិច្ចរបស់អាជ្ញាធរស្រុក និងមានការចូលរួមពីសំណាក់អង្គការជីវិតថ្លៃថ្នូរកំពុងនៅព្យួរ ប៉ុន្តែអ្នកភូមិនៅកាន់កាប់ដីរបស់ខ្លួនដដែល។ ករណីវិវាទមួយនៅឃុំពាម (វិវាទទី១៨) នៅព្យួរនៅឡើយ ពីព្រោះបណ្តឹងរបស់អ្នកភូមិបានចាប់ធ្វើតាំងពីអាជ្ញាធរថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ជាតិ រួមទាំងព្រះបរមរាជវាំងផង។ ករណីវិវាទមួយទៀត ក្នុងទីកន្លែងដដែល (វិវាទទី១៩) ទាក់ទងនឹងព្រៃសហគមន៍ក៏នៅព្យួរត្រឹមថ្នាក់ឃុំផងដែរ។ ហើយករណីវិវាទមួយទៀតនៅភូមិក្បែត្របុរីពាក់ព័ន្ធនឹងសម្បទានដីសង្គមកិច្ច (វិវាទទី២៣) ក៏កំពុងព្យួរនៅថ្នាក់ខេត្ត។

ករណីវិវាទចំនួនបីនៅឃុំបឹងប្រាំមានភាពស្មុគស្មាញខ្លាំងណាស់។ យន្តការដោះស្រាយវិវាទទាំងអស់បានចូលពាក់ព័ន្ធ រួមទាំងស្ថាប័នថ្នាក់ជាតិផងដែរ។ មានតែករណីវិវាទរវាងសហគមន៍បឹងប្រាំនិងក្រុមឈ្មួញនិងអាជ្ញាធរមូលដ្ឋានទេ ដែលបានដោះស្រាយរួចហើយ។ ករណីវិវាទពីរទៀតកំពុងព្យួរនៅឡើយ។

ជាសរុបករណីវិវាទចំនួន ១៩ក្នុងចំណោម ២៨ ត្រូវបានដោះស្រាយដោយអ្នកសម្រុះសម្រួលវិវាទខុសៗគ្នា។ ទោះជាយ៉ាងនេះក្តី ក្នុងបណ្តាករណីវិវាទដែលបានដោះស្រាយទាំង១៩នេះ មានតែករណីវិវាទមួយគត់ ដែលបានដោះស្រាយរួច ហើយអ្នកភូមិក៏មានការពេញចិត្តទៀតផង ពីព្រោះអាជ្ញាធរមូលដ្ឋានបានដោះស្រាយយ៉ាងសកម្មនូវកង្វល់របស់អ្នកភូមិ។ ម្យ៉ាងវិញទៀត ចំពោះករណីវិវាទមួយនេះ ក៏មានការពិគ្រោះយោបល់ជាមួយអ្នកភូមិ និងតំណាងអ្នកភូមិមុននឹងធ្វើសេចក្តីសម្រេចណាមួយផងដែរ។ ករណីវិវាទដទៃទៀត ត្រូវបានដោះស្រាយរួចក៏ពិតមែន

តែមិនមានការពេញចិត្តពីសំណាក់អ្នកភូមិទេ ពីព្រោះជាកិច្ចព្រមព្រៀងដោយបង្ខំ និងផ្តល់សំណងជាប្រាក់មិនសមស្រប។ អ្នកភូមិមួយចំនួននៅក្នុងវិវាទជាច្រើនបណ្តាវិវាទទាំងនេះដែលបានដោះស្រាយហើយមិនទាន់បានទទួលសំណងនៅឡើយ ពីព្រោះមកពីអំពើពុករលួយ ឬក៏អ្នកភូមិខ្លះមិនព្រមទទួលយកសំណង។

យើងសង្កេតឃើញមានកត្តាចំនួនបី ដែលអាចជួយឲ្យការដោះស្រាយវិវាទអាចដំណើរការទៅក្នុងលទ្ធផលថា មានយុត្តិធម៌តិច ឬច្រើន ឬក៏ត្រឹមអាចទទួលយកបាន។ ជាបឋមភាគីទាំងសងខាងគប្បីមានសុឆន្ទៈ និងការយោគយល់គ្នា ប៉ុន្តែមិនមែនគួរមានកិច្ចកល និងទាញយកប្រយោជន៍នៅក្នុងកិច្ចចរចានោះទេ។ ស្ទើរគ្រប់ករណីវិវាទក្រុមហ៊ុនមានគោលជំហររឹងមាំ និងទាញយកផលប្រយោជន៍ពីអ្នកភូមិ ដោយសារបានទទួលកិច្ចសន្យាស្តីពីសម្បទានពីរាជរដ្ឋាភិបាល។ អាស្រ័យហេតុនេះ ហើយអ្នកភូមិក៏ស្ថិតនៅក្នុងស្ថានភាពទន់ខ្សោយតម្រូវឲ្យទទួលយកសំណង ដែលបានស្នើដោយក្រុមហ៊ុន សូម្បីតែជាចំនួនដ៏តិចតួច និងមិនសមល្មមនឹងតម្លៃដីរបស់អ្នកភូមិយ៉ាងណាក្តី។ ក៏ប៉ុន្តែវាហាក់ដូចជាអាចធ្វើកិច្ចព្រមព្រៀងរវាងភាគីទាំងសងខាងបាន សូម្បីតែកិច្ចព្រមព្រៀងនេះលំអៀងជាប្រយោជន៍ទៅឲ្យខាងក្រុមហ៊ុនយ៉ាងណាក្តី ហើយក៏ប៉ុន្តែវានឹងអាចឲ្យវិវាទទាំងនេះងើបឡើងវិញនៅពេលអនាគត ពីព្រោះអ្នកភូមិគិតថាកិច្ចព្រមព្រៀងនេះមិនយុត្តិធម៌។ នៅស្ទើរគ្រប់វិវាទដែលមិនត្រូវបានដោះស្រាយគេអាចឃើញមានភស្តុតាងបញ្ជាក់ថា ក្រុមហ៊ុនបានបង្ហាញនូវឥរិយាបថយ៉ាងតឹងតែង ដោយសំអាងថា ពួកគេមានកិច្ចសន្យាស្តីពីសម្បទានដីសេដ្ឋកិច្ច និងមានបំណងដកហូតយកដីពីអ្នកភូមិទទេ ដោយមិនចាំបាច់ផ្តល់នូវសំណងសមស្របដោយអនុលោមតាមច្បាប់ភូមិបាលនោះឡើយ។

ហេតុការណ៍មួយទៀតគឺថាការដោះស្រាយវិវាទដីធ្លីមានក៏ពិតមែន ប៉ុន្តែមិនដំណើរការទៅបានល្អទេ។ វាហាក់ដូចជាមានលំនាំអំណាចបែបខ្សែ-ខ្នងកំពុងតែប្រព្រឹត្តទៅនៅក្នុងយន្តការដោះស្រាយវិវាទ។ ដោយក្រឡេកមើលដំណើរការដោះស្រាយវិវាទ ចំពោះវិវាទដែលដោះស្រាយមិនបានក្នុងខេត្តគោលដៅនានា អ្នកសម្រុះសម្រួលវិវាទនៅថ្នាក់ក្រោម ដែលបានបញ្ជូនសំណុំរឿងវិវាទទៅឲ្យថ្នាក់លើតាមឋានានុក្រមបានលើកហេតុផលថា ករណីវិវាទនេះ *«ហួសដែនសមត្ថកិច្ចរបស់ខ្លួន»* ។ ដើម្បីបំភ្លឺអំពីបញ្ហានេះ យើងយកករណីវិវាទ(វិវាទទី៩)នៅភូមិ ត្រពាំងក្រើញ និងភូមិថ្មល់កែង។ បណ្តឹងរបស់អ្នកភូមិបានឆ្លងកាត់ការដោះស្រាយនៅថ្នាក់ឃុំរហូតដល់ថ្នាក់ខេត្តតែទោះជាយ៉ាងនេះក្តី ការដោះស្រាយដូចជាស្ទាត់ឈឹង។ អ្នកភូមិក៏បានចេញដំណើរទៅជួបរដ្ឋសភា ហើយដោយទទួលបានភ្លើងបៃតងពីរដ្ឋសភា អាជ្ញាធរខេត្តក៏បានចាត់វិធានការ ទើបវិវាទត្រូវបានបញ្ចប់ដោយឲ្យក្រុមហ៊ុនប្រគល់ដីជាងពាក់កណ្តាលមកឲ្យអ្នកភូមិវិញ។ ដំណើរការដោះស្រាយវិវាទហាក់ដូចជាអាចបានជោគជ័យបាន បើសិនជាស្ថាប័នដោះស្រាយវិវាទតាមថ្នាក់

ផ្សេងៗមានអំណាចក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដោយអនុលោមតាមក្របខណ្ឌច្បាប់បច្ចុប្បន្ន នេះ។

ថ្វីត្បិតបង្ហាញនៅចុងក្រោយ តែវាក៏សំខាន់ដែរថា គឺការស្រុះស្រួលគ្នាយ៉ាងរឹងមាំក្នុងចំណោមប្រជាពលរដ្ឋក្នុងសហគមន៍អាចជាកម្លាំងមួយយ៉ាងរឹងប៉ឹង សម្រាប់ការពារសិទ្ធិលើដីធ្លីរបស់ខ្លួន។ ការស្រុះស្រួលគ្នាដ៏រឹងមាំរបស់ប្រជាពលរដ្ឋក្នុងភូមិត្រពាំងក្រើញ និងថ្នល់កែងអាចការពារដីរបស់ខ្លួនបាន ហើយគេអាចឃើញមានលំនាំនេះដែរនៅក្នុងករណីវិវាទដទៃៗទៀត ដែលមិនត្រូវបានដោះស្រាយក្នុងខេត្តគោលដៅសម្រាប់សិក្សាស្រាវជ្រាវ។ ភាពទន់ខ្សោយ ផ្នែកធនធានសង្គមក្នុងបណ្តាសហគមន៍ជាច្រើននៅក្នុងខេត្តកំពង់ស្ពឺ បាននាំទៅរកការបាត់បង់ដីធ្លី។

## ៩.២ សកម្មភាពរបស់អ្នកភូមិ

«*ដីជាជីវិត*» ជាពាក្យមួយឃ្លាដែលអ្នកភូមិ ដែលមានវិវាទដីធ្លីតែងនិយមប្រើគ្រប់ៗគ្នា។ ក្នុងករណីវិវាទទាំងអស់ក្នុងខេត្តដែលយើងបានសិក្សា អ្នកភូមិមានចេតនារួមគ្នា ដើម្បីទាមទារដោយចំហ សូម្បីប្រឆាំងនឹងអ្នកមានអំណាចយ៉ាងណាក្តី ពីព្រោះពួកគាត់មានអារម្មណ៍ថា ការដកហូតដីធ្លីពីពួកគាត់មិនយុត្តិធម៌ទេ។ជាភស្តុតាងគឺ ៧៣.៨% នៃអ្នកផ្តល់ចម្លើយបានប្រាប់ថា ពួកគាត់ធ្វើអ្វីៗដើម្បីជំទាស់នឹងការដកហូតដីពីពួកគាត់។ ទោះជាយ៉ាងនេះក្តី ក្នុងករណីវិវាទខ្លះ មន្ត្រីរាជការដែលមានអារម្មណ៍ថា ដីរបស់ខ្លួនត្រូវបានគេដកហូតដោយអយុត្តិធម៌មានការរារែកចិត្ត ក្នុងការតវ៉ា ពីព្រោះពួកគាត់មិនចង់ «មានបញ្ហា» ឬក៏មិនចង់ «បង្កឲ្យមានរឿង» ។

នៅស្រុកឱរ៉ាល់ អ្នកភូមិរងគ្រោះមានស្ថានភាពសង្គមខុសៗគ្នា គឺមានអ្នកភូមិចាស់ និងអ្នកចំណូលថ្មីដែលមកពីកន្លែងផ្សេងៗគ្នានៃប្រទេស រួមទាំងអ្នកដែលជាអតីតយោធិនទាំងនៅក្នុងជួររដ្ឋាភិបាល ក៏ដូចជាកងកម្លាំងរបស់ខ្មែរក្រហម។ ករណីវិវាទនៅភូមិគោកដែលមានការទាក់ទិននឹងអ្នកភូមិចាស់ដែលមានក្បាលដីច្រើន (ភាគច្រើនសម្រាប់ដំណាំស្រូវ) និងអ្នកចំណូលថ្មីដែលទើបនឹងកាន់កាប់ដី ដែលបានមកពីការចែកដីឲ្យពីសំណាក់នាយទាហានជាន់ខ្ពស់របស់ភាគីខ្មែរក្រហមមួយរូប។ ម្ល៉ោះហើយ ការចងក្រងជាក្រុមរបស់អ្នកភូមិរងគ្រោះហាក់ដូចជាមិនរឹងមាំទេ។ ក្នុងចំណោមតំណាងអ្នកភូមិ មានពីរក្រុមតូចៗដែលបានចូលរួមយ៉ាងសកម្មក្នុងការតវ៉ាទាមទារជាចំហ (ក្រុមទី១ មានអតីតនាយទាហានជាន់ទាបម្នាក់ក្នុងជួររដ្ឋាភិបាលរួមគ្នាជាមួយសាច់ញាតិជិតស្និទ្ធរបស់ខ្លួន ហើយក្រុមទី២ជាក្រុមដែលដឹកនាំដោយអតីតអ្នករស់នៅជំរំជាយដែន និងជាបុគ្គលិកចូលនិវត្តន៍ពីមណ្ឌលសុខភាពស្រុក។ ចំណែកឯអ្នកភូមិខ្លះទៀត ដែលជាអ្នកភូមិចាស់បង្ហាញថាមិនសូវសកម្មក្នុងការចូលរួមតវ៉ាទេ។ រូបភាពនេះបានបង្ហាញឲ្យឃើញនូវការស្រុះ

ស្រួលគ្នាក្នុងសង្គមនៅក្នុងភូមិនេះមានកម្រិតទាបទេ មិនទាន់គិតដល់ទំនាក់ទំនងរបស់ពួកគាត់ជាមួយនឹងអាជ្ញាធរមូលដ្ឋានផង។ ចំណែកឯមន្ត្រីមូលដ្ឋានមួយចំនួនដែលរងគ្រោះ (ថ្នាក់ ឃុំ និង ស្រុក) ពួកគាត់បានកាន់កាប់ក្បាលដីនៅក្នុងតំបន់នេះ ដែលអាជ្ញាធរមូលដ្ឋានបានបែងចែកឲ្យនៅឆ្នាំដំបូងៗ បន្ទាប់ពីការធ្វើសមាហរណកម្មរបស់ខ្មែរក្រហម។ ប៉ុន្តែពួកគាត់មិនអាចទាមទារយកដីនេះបានមកវិញ ដោយសារពួកគាត់មានការបារម្ភចំពោះមន្ត្រីដែលមានឋានៈខ្ពស់ជាង។ ពាក់ព័ន្ធនឹងករណីវិវាទនៅភូមិត្រពាំងគង សាមគ្គីភាពក្នុងចំណោមអ្នកភូមិរងគ្រោះមិនអាចប្រព្រឹត្តទៅបានទេ លើកលែងតែករណីវិវាទទាក់ទងនឹងដីព្រៃសហគមន៍របស់ភូមិ ដែលអ្នកភូមិបានទទួលសំណងជាប្រាក់គ្រប់ៗគ្នា។ ប៉ុន្តែអ្នកភូមិខ្លះ (រួមទាំងមេភូមិផង) ដែលមានក្បាលដីដាំដំណាំមិនបានទទួលសំណងអ្វីសោះ រីឯអ្នកភូមិខ្លះទៀតបានទទួលសំណងជាប្រាក់ បើសូម្បីសំណងនោះមិនសមល្មមយ៉ាងណាក្តី ជាពិសេសអ្នកភូមិដែលមានមន្ត្រីមូលដ្ឋាន (ប្រធានប៉ុស្តិ៍នគរបាលឃុំ) ជាអ្នកដឹកនាំ។ ម្យ៉ាងវិញទៀត នៅភូមិតាម៉ិញចំពោះដីរបស់ភូមិវាជាការងាយស្រួលទេ ដែលប្រជាពលរដ្ឋមូលដ្ឋានព្រមទទួលយកសំណងដែលស្នើដោយក្រុមហ៊ុន ប៉ុន្តែមានតែអ្នកតវ៉ាជំទាស់ម្នាក់គត់ ដែលជាអតីតមេឃុំដែលបានរងសម្ពាធ ហើយត្រូវបានចាប់ដាក់ពន្ធនាគារដោយសារមានការតវ៉ាជំទាស់ពីគាត់ខ្លាំងពេក។

នៅខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ ការទាមទារនិងការតវ៉ាជំទាស់របស់ប្រជាពលរដ្ឋមូលដ្ឋានមានលក្ខណៈស្រដៀងគ្នា និងស្ទើរតែដូចគ្នា ដូចបានបង្ហាញនៅខាងលើរួចហើយ។ នៅខេត្តកំពង់ឆ្នាំង តំណាងអ្នកភូមិស្រែសា(ដែលត្រូវបានចោទប្រកាន់ដោយអាជ្ញាធរមូលដ្ឋាន និង តំណាងក្រុមអង្គការសិទ្ធិមនុស្សមួយរូបថា បានកាន់កាប់ដីដោយខុសច្បាប់) ដែលជានាយទាហានមួយរូប មិនអាចប្រមែប្រមូលប្រជាពលរដ្ឋរងគ្រោះដើម្បីទាមទារដីរបស់ខ្លួនឲ្យបានខ្លាំងក្លានោះឡើយ។ ជួនកាលគាត់បានចូលរួមជាមួយអ្នកដទៃទៀត ដើម្បីដាក់បណ្តឹងនៅកន្លែងដោះស្រាយវិវាទខាងក្រៅ ដូចជានៅទីស្នាក់ការអាដហុកប្រចាំខេត្តកំពង់ឆ្នាំង។ ម្យ៉ាងវិញទៀត វិវាទដែលមានទំហំតូចៗ (អ្នកភូមិរងគ្រោះមានចំនួនតិចតួច) អាចជាមូលហេតុមួយក្នុងចំណោមមូលហេតុដែលអាចធ្វើឲ្យសម្លេងទាមទាររបស់ពួកគាត់បានគេដឹងឮ។ នៅខេត្តពោធិ៍សាត់ គេបានរកឃើញថា មានតំណាងខ្លះ ដែលជាអតីតមន្ត្រីមូលដ្ឋាន(មេភូមិ ឬមេឃុំ)បានចេញតវ៉ាជំទាស់ដាច់ដោយឡែកៗពីគ្នា។ នេះបង្ហាញថា គ្រួសារនីមួយៗបានព្យាយាមការពារដីរបស់ខ្លួនមិនមែនតាមរូបភាពជាក្រុមនោះទេ តែជាលក្ខណៈគ្រួសារ។ មូលហេតុនៃការតវ៉ាជំទាស់បែបនេះអាចពាក់ព័ន្ធនឹងទំនុកចិត្តក្នុងរវាងគ្នានឹងគ្នា កម្រិតវប្បធម៌ និងស្ថានភាពសង្គមរបស់ពួកគាត់។

ការចូលរួមរបស់អ្នកភូមិយ៉ាងសកម្មត្រូវបានបង្ហាញឲ្យឃើញ នៅក្នុងករណីវិវាទនៅភូមិត្រពាំងក្រើញ (វិវាទទី៩) ក្នុងស្រុកថ្គូងដែលពាក់ព័ន្ធនឹងប្រជាពលរដ្ឋចំនួនជាង ៥០០គ្រួសារ និងករណីវិវាទមួយទៀតនៅតំបន់បឹងប្រាំក្នុងស្រុកបវេល។ ករណីវិវាទទីមួយមានពីរដំណាក់កាល គឺដំណាក់កាលដំបូងបានចាប់ផ្តើមក្នុងឆ្នាំ២០០៦ ហើយដំណាក់កាលទីពីរក្នុងឆ្នាំ២០១២។ នៅពេលដំបូងអ្នកភូមិបានចេញតវ៉ាជំទាស់នៅតំបន់វិវាទ ដើម្បីឲ្យអ្នកបញ្ជាម៉ាស៊ីនរបស់ ក្រុមហ៊ុនស៊ីធីម៉ាតបញ្ឈប់សកម្មភាពរបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ និងសូម្បីពួកគាត់បានទៅជួបមេឃុំ និង អភិបាលស្រុក ដើម្បីស្វែងរកការដោះស្រាយយ៉ាងណាក្តី ក៏មិនបានសម្រេចលទ្ធផលអ្វីដែរ ហើយនៅអាជ្ញាធរថ្នាក់ខេត្ត លទ្ធផលមិនបានសម្រេចដូចគ្នា។ ម្ល៉ោះហើយតាមរយៈអង្គការអាដហុកប្រចាំខេត្ត ពួកគាត់បានចេញទៅជួបសមាជិករដ្ឋសភាប្រចាំខេត្ត ដើម្បីនឹងជូនដំណើរតំណាងអ្នកភូមិមួយចំនួនតាមរថយន្តឆ្ពោះទៅកាន់រដ្ឋសភានៅភ្នំពេញ។ ក្រោយមកទើបអនុប្រធានរដ្ឋសភាបានប្រគល់ជូនតំណាងអ្នកភូមិនូវលិខិតមួយច្បាប់ដែលបានបញ្ជាក់ថា អាជ្ញាធរមូលដ្ឋានត្រូវប្រគល់ដីវិវាទជូនប្រជាពលរដ្ឋមូលដ្ឋានវិញ។ ទោះជាយ៉ាងនេះក្តី មិនមានសេចក្តីសម្រេចណាត្រូវបានធ្វើនោះទេ។ ទើបតែនៅក្នុងឆ្នាំ២០១២ ប្រជាពលរដ្ឋដែលមានកំហឹងបានធ្វើការតវ៉ាជំទាស់ជាថ្មី ពីព្រោះក្រុមហ៊ុនបានចាប់ផ្តើមធ្វើសកម្មភាពមកលើដីដាំដំណាំរបស់ពួកគាត់ឡើងវិញ។ ដើម្បីបញ្ចប់វិវាទយ៉ាងយូរមួយ កិច្ចព្រមព្រៀងត្រូវបានសម្រេចនៅសាលាខេត្ត ដោយបែងចែកដីវិវាទឲ្យភាគីទាំងសងខាង។ នៅតំបន់បឹងប្រាំវិញ អតីតនាយទាហានខ្មែរក្រហមមួយរូបបានប្រមែប្រមូលប្រជាពលរដ្ឋ ដែលបាត់បង់ផលប្រយោជន៍មកពីខេត្តផ្សេងៗនៃប្រទេស ដើម្បីទទួលបានចំណែកដីនៅតំបន់បឹងប្រាំ ដែលអតីតនាយទាហានជាន់ខ្ពស់ខ្មែរក្រហមពីរបីរូបបានលក់ទៅឲ្យក្រុមឈ្មួញក្នុងស្រុក។ អាស្រ័យហេតុនេះ ហើយទើបបានជាធ្វើឲ្យមានកំណើនប្រជាពលរដ្ឋរហូតដល់ជាង ៣០០០ គ្រួសារក្នុងឆ្នាំ២០០៦ ហើយវាក៏បង្កឲ្យមានការប្រឈមមុខជាមួយនឹងអ្នកកាន់កាប់ដីដំបូងមកពីភូមិឃុំជិតខាង និងជាពិសេសជាមួយនឹងអ្នកបម្រើការឲ្យក្រុមហ៊ុន (របស់ឈ្មួញ)។

ជាលទ្ធផលអ្នកដឹកនាំសហគមន៍បឹងប្រាំត្រូវបានចាប់ខ្លួនដាក់ពន្ធនាគារនៅពាក់កណ្តាលឆ្នាំ ២០០៦ ហើយអ្នកដឹកនាំមួយចំនួនទៀតក្នុងមូលដ្ឋានក៏ត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ផងដែរ។ ប្រជាពលរដ្ឋមូលដ្ឋានមិនអាចនៅស្ងៀមបានទេ ចំពោះការចាប់ខ្លួនអ្នកដឹកនាំរបស់ខ្លួននោះ។ ពួកគាត់បានប្រមែប្រមូលគ្នីគ្នាមកជួបជុំនៅមុខតុលាការខេត្ត ហើយក៏បន្តនាំគ្នាមកតវ៉ាជំទាស់នៅឯភ្នំពេញទៀត ក្នុងពេលដែលអ្នកដឹកនាំសហគមន៍ត្រូវបានបញ្ជូនមកពន្ធនាគារព្រៃស។ សាមគ្គីភាពក្នុងចំណោមអ្នកភូមិទាំងនេះ អាចធ្វើឲ្យសម្លេងនៃការទាមទារតវ៉ារបស់ពួកគាត់បានលេចឮឡើង។ ក្រុមអង្គការសិទ្ធិមនុស្សទាំង២៣អង្គការ ក្នុងនោះមានអាដហុក លីកាដូ វីជីឡែន អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិពាក់ព័ន្ធដទៃទៀត ក៏បានផ្តល់នូវការគាំទ្រឲ្យមានដោះលែង

អ្នកដឹកនាំរបស់អ្នកភូមិទាំងនោះ។ ដោយឡែកដំណើការអនុវត្តសម្បទាដីសង្គមកិច្ចក្នុងអំឡុងឆ្នាំ ២០១១-២០១៣ បានធ្វើឲ្យប៉ះពាល់ដល់ប្រជាពលរដ្ឋ ចំនួន១៩២គ្រួសារដែលបានតាំងទីលំនៅ ឬអាស្រ័យផលនៅអស់រយៈពេលជាច្រើនឆ្នាំ នៅលើផ្ទៃដីទំហំ ៨០០ ហិកតាដែលបច្ចុប្បន្នជាផ្នែកមួយនៃឃុំបឹងប្រាំ។ មកទល់ពេលនេះ មិនទាន់មានសេចក្ដីសម្រេចណាត្រូវបានធ្វើនៅឡើយទេ។

## តារាងទី៩: ជំហាននានានៃបណ្ដឹងតវ៉ារបស់អ្នកភូមិ

| ជំហាននៃបណ្ដឹង | អ្នកទទួលបណ្ដឹង | ភាគរយ |
|---|---|---|
| ជំហានទីមួយ | អាជ្ញាធរមូលដ្ឋាន (ថ្នាក់ភូមិនិងឃុំ) | 89.0% |
| ជំហានទីពីរ | សាលាស្រុក | 75.8% |
| ជំហានទីបី | សាលាខេត្ត | 71.6% |
| ជំហានទីបួន | សមាជិកសភា/គណបក្សនយោបាយ | 34.0% |
| ជំហានទីប្រាំ | អង្គការមូលដ្ឋាន/អង្គការមិនមែនរដ្ឋាភិបាល ឬនាយករដ្ឋមន្ត្រី | 18.2% |

នៅពេលសួរថា តើពួកគាត់ ឬសហគមន៍បានធ្វើអ្វីមុនពេលចូលទៅដល់គណៈកម្មការសុរិយោដីថ្នាក់ស្រុក អ្នកភូមិទំនងជាទៅរកអាជ្ញាធរមូលដ្ឋានថ្នាក់ភូមិ ឬថ្នាក់ឃុំ ដើម្បីឲ្យដោះស្រាយបញ្ហាដីធ្លីរបស់ខ្លួន (៨៩%)។ គេបានរកឃើញថា អាជ្ញាធរមូលដ្ឋានគ្រប់ថ្នាក់(ចាប់ពីថ្នាក់ភូមិដល់ថ្នាក់ស្រុក)បានចូលរួមក្នុងការដោះស្រាយវិវាទ ជាពិសេស ភាគច្រើនជាករណីវិវាទដីធ្លី។ ដោយឡែកប្រជាពលរដ្ឋមូលដ្ឋាន បានស្វះស្វែងរកការដោះស្រាយវិវាទរបស់ខ្លួននៅថ្នាក់ភូមិភាគច្រើនទាក់ទងនឹងករណីវិវាទមានទំហំតូចៗ ដូចជាអំពើហិង្សា ការលែងលះ ការបំផ្លាញដំណាំ ហើយបើសិនជាទាក់ទងនឹងបញ្ហាដីធ្លី មានដូចជាការបិទផ្លូវ ឬបញ្ហាព្រំដីជាដើម។ មូលហេតុគឺ មកពីមេភូមិជាទូទៅ (ប៉ុន្តែមិនមែនជាអនុប្រធានភូមិឬជំនួយការភូមិទេ) ហាក់ដូចជាមានការរាប់អានជិតស្និទ្ធជាមួយអ្នកភូមិ ហើយមេភូមិភាគច្រើនមានកំណើតនៅក្នុងភូមិនេះ ឬក៏មកពីភូមិឬឃុំជិតខាង ប៉ុន្តែអ្នកភូមិមិនទុកចិត្តមេភូមិចំពោះការដោះស្រាយវិវាទដែលមានទំហំធំៗ ដូចជាករណីសម្បទានដីសេដ្ឋកិច្ច សម្បទានដីសង្គមកិច្ច និងវិវាទពាក់ព័ន្ធនឹងអ្នកមានអំណាច(ឈ្មួញនិងមន្ត្រីជាន់ខ្ពស់)នោះទេ។ ម្ល៉ោះហើយអ្នកភូមិបានទៅក្រុមប្រឹក្សាឃុំ ដោយមានទំនុកចិត្តច្រើនថា អាចដោះស្រាយវិវាទដីធ្លីរបស់ខ្លួនពាក់ព័ន្ធនឹងភាគីទីពីរដែលបានលើកឡើងនៅខាងលើ។ ជាទូទៅបើសិនជាបញ្ហានៅតែមិនអាចដោះស្រាយបាន ពួកគាត់នឹងទៅថ្នាក់ស្រុកដើម្បីឲ្យដោះស្រាយ (៧៥.៨%) និង/ឬទៅថ្នាក់ខេត្ត (៧១.៦%) ដោយរំពឹងថា ថ្នាក់នេះដែលទុកដូចជាជា «ឪពុកម្ដាយ» មុខជានឹងជួយពួកគាត់ក្នុងការដោះស្រាយបញ្ហាដ៏សំខាន់បំផុតនៅក្នុងឆាកជីវិតរបស់ពួកគាត់ជា

មិនខាន។ក្នុងករណីដែលការដោះស្រាយបញ្ហានេះនៅតែស្ងាត់ ពួកគាត់នឹងទៅរកគណបក្សនយោបាយ ឬសមាជិករដ្ឋសភាឲ្យដោះស្រាយ (៣៩.០%)។ ពួកគាត់ក៏អាចទៅរកអង្គការមូលដ្ឋាន/អង្គការមិនមែនរដ្ឋាភិបាល (១៨.២%) ដើម្បីជួយពួកគាត់ក្នុងការបំពេញកិច្ចការផ្សេងៗសម្រាប់បន្តបណ្តឹងទាក់ទងនឹងដីធ្លី។ សេចក្តីសង្ឃឹមចុងក្រោយសម្រាប់ការដោះស្រាយវិវាទរបស់ពួកគាត់ ក៏ផ្តោតទៅលើខុទ្ទកាល័យនាយករដ្ឋមន្ត្រីផងដែរ(១៨.២%)។ នៅក្នុងករណីវិវាទខ្លះប្រជាពលរដ្ឋដូចជានៅក្នុងឃុំពាមនៃខេត្តកំពង់ឆ្នាំង និងឃុំប្រាំបីមុមនិងឃុំសង្កែសាទបក្នុងខេត្តកំពង់ស្ពឺ ក៏ដូចជានៅក្នុងឃុំបឹងប្រាំក្នុងខេត្តបាត់ដំបងបានដាក់ញត្តិរបស់ខ្លួននៅស្ថាប័នជាន់ខ្ពស់នានា ដូចជានៅរដ្ឋសភា ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាជាដើម ពីព្រោះពួកគាត់មានការព្រួយបារម្ភពីបញ្ហាដីធ្លីរបស់ខ្លួន។ បើសូម្បីតែគណៈកម្មការសុរិយោដីមានសិទ្ធិអំណាចក្នុងការដោះស្រាយវិវាទដីធ្លីដែលភាគីវិវាទទាំងសងខាងមិនមានប័ណ្ណកម្មសិទ្ធិដីក៏ពិតមែន ក៏ប៉ុន្តែអ្នកផ្តល់ចម្លើយខ្លះ(២៤.៩%) ដឹងថាបណ្តឹងរបស់ពួកគាត់បានទៅដល់គណៈកម្មការសុរិយោដី។ នៅស្រុកភ្នំស្រួចក្នុងខេត្តកំពង់ស្ពឺ ភាគីវិវាទទាំងពីរបានដាក់បណ្តឹងនៅតុលាការខេត្តដូចគ្នា។ អ្នកភូមិបានប្រើមធ្យោបាយផ្សេងៗក្នុងកិច្ចប្រឹងប្រែងជាយុទ្ធសាស្ត្រមួយគឺធ្វើយ៉ាងដូចម្តេចឲ្យអ្នកធ្វើសេចក្តីសម្រេច ដែលមានអំណាចមកអន្តរាគមន៍ជំនួសឲ្យពួកគាត់ (WB, 2006a)។

វាមានសារសំខាន់នឹងកត់សម្គាល់ថា មានតែអ្នកផ្តល់ចម្លើយលើសពាក់កណ្តាលបន្តិច (៥២.១%) ដែលដឹងថា ពួក គាត់មានសិទ្ធិមានមិត្តភក្តិ ឬមេធាវី ឬតំណាងអង្គការមូលដ្ឋាន/អង្គការមិនមែនរដ្ឋាភិបាលណាម្នាក់ ដើម្បីជួយពួកគាត់នៅក្នុងដំណើរការសម្រុះសម្រួល។ ច្រើនជាង៦០% នៃអ្នកផ្តល់ចម្លើយបានប្រាប់ថា ពួកគាត់បានទទួលព័ត៌មាន នេះតាមរយៈអាជ្ញាធរមូលដ្ឋាន ឬអង្គការមូលដ្ឋាន/អង្គការមិនមែនរដ្ឋាភិបាល ក្នុងពេលផ្សព្វផ្សាយចំណេះដឹង។ អ្នកដឹកនាំភូមិ និងសមាជិកសហគមន៍ (៣៨.៧%) ក៏ដូចជាប្រព័ន្ធផ្សព្វផ្សាយ (២២.៦%) បាន ដើរតួនាទីផងដែរក្នុងការផ្សព្វផ្សាយអំពីសិទ្ធិ ដែលអ្នកភូមិអាចមានអ្នកណាម្នាក់សម្រាប់ជួយពួកគាត់នៅក្នុងអំឡុងដំណើរការសម្រុះសម្រួល។

អ្នកភូមិបានរាយការណ៍ថា ក្រុមរបស់ប្រជាពលរដ្ឋខ្លះ ដូចជាក្រុមជួយខ្លួនឯង ក្រុមបញ្ហាដីធ្លី ក្រុមស្ត្រី ក្រុមយុវវ័យ ក្រុមសិទ្ធិមនុស្ស ក្រុមការពារព្រៃសហគមន៍ ក្រុមថែទាំសុខភាព ក្រុមអប់រំ ក្រុមការពារកុមារ ក្រុមតស៊ូមតិ ក្រុមសន្តិសុខភូមិ ក្រុមអភិវឌ្ឍន៍ភូមិ ក្រុមធនាគារស្រូវ (សហគមន៍) ត្រូវបានបង្កើតឡើង ដោយមានជំនួយឧបត្ថម្ភ ពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការក្នុងតំបន់នេះ ដើម្បីជួយសហគមន៍ក្នុងការធ្វើសកម្មភាពមួយចំនួនទាក់ទងនឹងការពង្រឹងការស្រុះស្រួលផ្នែកសង្គម និងការចិញ្ចឹមជីវិត ក៏ដូចជាកិច្ចការពារបរិស្ថានផងដែរ។ សកម្មភាពទាំងនេះរួម

មានការសន្សំប្រាក់ និងធនាគារស្រូវ ការផ្តល់អំណាចដល់ស្ត្រី ការអប់រំអំពីសុខភាព និងសុខភាពបន្តពូជ សុវត្ថិភាពដីធ្លី ចំណេះដឹងអំពីសិទ្ធិមនុស្សជាដើម។ អ្នកភូមិបានសង្កេតឃើញក្រុមខ្លះដែលសកម្មជាងគេគឺមាន ក្រុមជួយខ្លួនឯង ក្រុមបញ្ហាដីធ្លី ក្រុមស្ត្រី ក្រុមយុវវ័យ និងក្រុមការពារព្រៃសហគមន៍។ ទោះជាយ៉ាងនេះក្តី អ្នកភូមិចំនួនពាក់កណ្តាល (៥០%) គិតថា ក្រុមទាំងនេះមានសមត្ថភាពមធ្យម ចំណែកឯ៤២%ទៀតគិតថា ក្រុមមានសមត្ថភាពទាប។ វាមានសារសំខាន់នឹងកត់សម្គាល់ថា ៤០.៦% មិនដឹងថា មានក្រុមរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍របស់ខ្លួននោះផង។

តើមេភូមិមានការឆ្លើយតបយ៉ាងដូចម្តេច ចំពោះការដោះស្រាយបណ្តឹងរបស់អ្នកភូមិ? ៥៧.១% នៃអ្នកផ្តល់ចម្លើយបានប្រាប់ថា មេភូមិចាត់វិធានការជួយសហគមន៍នៅក្នុងការដោះស្រាយវិវាទដីធ្លី មុនពេលដែលសំណុំរឿងវិវាទត្រូវបានបញ្ជូនទៅបន្ត ហើយអ្នកផ្តល់ចម្លើយភាគច្រើន (៨៧.៦%) មានអារម្មណ៍វិជ្ជមានថា ពួកគាត់ ទុកចិត្តមេភូមិចំពោះអ្វីមួយដែលមេភូមិបានជួយ។ ទោះជាយ៉ាងនេះក្តី មានតែ ៦១.៥% នៃអ្នកភូមិទេដែលមានអារម្មណ៍ថា មេភូមិ និងប្រជាពលរដ្ឋក្នុងសហគមន៍មានសម្លេងដូចគ្នាពាក់ព័ន្ធនឹងការដោះស្រាយករណីវិវាទដីធ្លី។ ភស្តុតាងបានបង្ហាញឲ្យឃើញថា នៅស្រុកឱរ៉ាល់ អាជ្ញាធរមូលដ្ឋាន ក្នុងនោះមានបុគ្គលដែលបម្រើការក្នុងក្រុមប្រឹក្សាឃុំបានបញ្ចុះបញ្ចូលអ្នកភូមិឲ្យទទួលយកសំណងរបស់ក្រុមហ៊ុន។

## ៩.៣ កិច្ចចរចា

ក្នុងគ្រប់ករណីវិវាទដែលបានសិក្សាទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ច កិច្ចចរចាដែលមិនមានសមធម៌តែងតែ កើតមានឡើងជានិច្ចរវាងភាគីវិវាទជាជាងការប្រើអំពើហិង្សា។ ក្នុងគ្រប់ករណីពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច ក្រោយពីបានទទួលបណ្តឹងពីអ្នកភូមិ សាលាឃុំដែលជាអ្នកសម្រុះសម្រួលបានស្នើសុំឲ្យភាគីទាំងសងខាងធ្វើការចរចា។ ក្រៅពីសាលាឃុំ ចំពោះករណីវិវាទខ្លះ តំណាងក្រុមហ៊ុនបានប្រាប់ប្រជាពលរដ្ឋឲ្យទៅសាលាឃុំដើម្បីចរចាគ្នា។ ករណីវិវាទនៅខេត្តពោធិ៍សាត់ កិច្ចចរចាដែលត្រូវបានរៀបចំធ្វើដោយគណៈកម្មការចម្រុះ បានប្រព្រឹត្តទៅនៅក្នុងអំឡុងពេលអនុវត្តគោលនយោបាយចាស់-សកម្មភាពថ្មី តាមរយៈយុទ្ធនាការរបស់ក្រុមយុវជនស្ម័គ្រចិត្ត ដែលបានចុះវាស់វែងដី និងផ្តល់ប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ។

ចំពោះករណីវិវាទពាក់ព័ន្ធនឹងសម្បទានដីសង្គមកិច្ចនៅខេត្តកំពង់ឆ្នាំងនិងបាត់ដំបង ក៏ដូចជានៅខេត្តពោធិ៍សាត់ (វិវាទទី២២) គឺមិនមានកិច្ចចរចាទេ។ អាជ្ញាធរមូលដ្ឋានបានធ្វើអត្តសញ្ញាណកម្មដីធ្លី និងបិទផ្សាយសេចក្តីជូនដំណឹងពាក់ព័ន្ធនឹងទិន្នន័យដីធ្លីរបស់អ្នកភូមិនៅសាលាឃុំ ដើម្បីឲ្យអ្នកភូមិអាចធ្វើការទាមទារនៅពេលដែលពួកគាត់មើលឃើញព័ត៌មានអំពីដីធ្លីរបស់ខ្លួនមិនត្រឹមត្រូវ។

ក្នុងដំណើរការនៃកិច្ចចរចា ក្រុមហ៊ុនបានទទួលផលប្រយោជន៍ ពីព្រោះគេបានទទួលឯកសារដ៏រឹងមាំពីរាជរដ្ឋាភិបាល តែអ្នកភូមិវិញមិនឯកសារដូចនេះទេ។ បណ្តឹងសារទុក្ខដែលពួកគាត់អាចធ្វើបាន គឺមានតែធ្វើការតវ៉ារួមគ្នាជំទាស់នឹងការដកហូតដីធ្លីរបស់ពួកគាត់។ ភាពទន់ខ្សោយបែបនេះ បានធ្វើឲ្យក្រុមហ៊ុនទទួលបានដីធ្លីពីអ្នកភូមិដោយជោគជ័យ។ ជម្រើសតែមួយគត់ដែលអ្នកភូមិត្រូវធ្វើ គឺត្រូវតែទទួលយកសំណងជាប្រាក់បន្តិចបន្តួចពីក្រុមហ៊ុន ពីព្រោះពួកគាត់ខ្លាចក្រែងក្រុមហ៊ុនយកដីពីពួកគាត់ទទេ បើសូម្បីពួកគាត់ទទួលយកប្រាក់សំណងនេះ ឬមិនទទួលយកក្តី៖ *«ស្រេចតែអ្នកឯងទេ រឿងយកលុយឬមិនយកលុយ តែយ៉ាងម៉េចក៏ក្រុមហ៊ុនយកដីដែរ ពីព្រោះអ្នក ឯងធ្វើលើដីរដ្ឋ ហើយក្រុមហ៊ុនធ្វើតាមតែច្បាប់ទេ។»*

ការមិនចរចាគ្នាដូចជាករណីវិវាទនៅបឹងប្រាំជាដើម បាននាំឲ្យកើតជាអំពើហិង្សារវាងអ្នកភូមិនិងអ្នកភូមិ ក៏ដូចជារវាងអ្នកភូមិ និងកងប្រដាប់អាវុធផងដែរ គឺមានដូចជាការចាប់មនុស្សមួយចំនួនដើម្បីជាថ្នូរនឹងការមិនបំផ្លិចបំផ្លាញដំណាំ ឬក៏ដកហូតដីពីពួកគាត់។ លទ្ធផលនៃការប្រើអំពើហិង្សានេះ បានធ្វើឲ្យស្ត្រីម្នាក់បាត់បង់ជីវិត និង បុរសម្នាក់រងរបួសជាទម្ងន់ ហើយសម្ភារៈ ឬគ្រឿងចក្រមួយចំនួនត្រូវបានបំផ្លាញចោល ប៉ុន្តែវិវាទនៅតែដោះស្រាយមិនចេញរហូតមកដល់សព្វថ្ងៃនេះ (គណៈកម្មការចម្រុះស្រុកបវេល ឆ្នាំ២០១៤) ។

## ៩.៤ កិច្ចសម្រុះសម្រួល

ដូចដែលបានបញ្ជាក់ខាងលើ អ្នកភូមិដែលមានដីវិវាទទំនងជាចង់ឲ្យបណ្តឹងរបស់ខ្លួនដោះស្រាយនៅអាជ្ញាធរមូលដ្ឋានថ្នាក់ក្រោមនៅដំណាក់កាលដំបូង។ ក្នុងករណីដែលភាគីវិវាទទាំងសងខាងមិនសម្រេចកិច្ចព្រមព្រៀងណាមួយ ទើបពួកគាត់យកបណ្តឹងនេះទៅឲ្យថ្នាក់បន្ទាប់ៗនៅខាងលើដោះស្រាយ។ ៥៦.២% នៃអ្នកផ្តល់ចម្លើយបានប្រាប់ថាពួកគាត់មានអ្នកណាម្នាក់ ដូចជាអ្នកនៅអង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សដែលជួយគាត់នៅក្នុងដំណើរការសម្រុះសម្រួល។ ជាឧទាហរណ៍គ្រប់ករណីវិវាទដែលបណ្តាលមកពីសម្បទានដីសេដ្ឋកិច្ច មានការពិបាកដោះស្រាយណាស់។ អ្វីដែលមេភូមិ និងក្រុមប្រឹក្សាឃុំអាចធ្វើបានគឺ*«ការសម្រុះសម្រួល»*រវាងភាគីវិវាទទាំងសងខាង ដោយអនុលោមតាមតួនាទីភារកិច្ចរបស់ខ្លួន។ ចំពោះករណីវិវាទពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច មានករណីខ្លះ ដែលអ្នកសម្រុះសម្រួលស្នើសុំអ្នកភូមិឲ្យទទួលយកសំណងបន្តិចបន្តួចជាជាងមិនទទួលបានអ្វីសោះ ឬក៏ឲ្យដោះដូរនឹងក្បាលដីមួយកន្លែងទៀត បើសិនជាមាន។ ទោះជាយ៉ាងនេះក្តី ករណីដោះដូរដីកម្រកើតមានណាស់។ មេឃុំក៏ដូចជាក្រុមប្រឹក្សាឃុំដទៃទៀតជាពិសេសជំទប់ទីមួយតែងតែចូលរួមជានិច្ចក្នុងដំណើរការសម្រុះសម្រួល។ វាមានការពិបាកយល់ដឹងនូវមូលហេតុដែលអ្នកសម្រុះសម្រួល បានស្នើសុំឲ្យអ្នកភូមិទទួលយកសំណងដ៏តិចតួច

នេះ។ ប្រហែលមកពីពួកគាត់ស្ថិតនៅក្នុងស្ថានភាពរវាងញញួរនិងដែកទ្រនាប់ ឬមួយពួកគាត់មានការអាណិតអាសូរចំពោះប្រជាពលរដ្ឋ (នៅក្នុងមណ្ឌលបោះឆ្នោត) របស់ខ្លួន។

អ្នកសម្រុះសម្រួលជាក់ស្តែងអាចមានជំនួយពីអ្នកគួរជេរ (ជាបុគ្គល ឬជាក្រុមមនុស្ស ដែលសម្រុះសម្រួលការ ទិញ/លក់ដីរវាងក្រុមហ៊ុននិងអ្នកភូមិ តាមរយៈគណៈកម្មការមួយនៅពេលចុះអនុវត្តកិច្ចការនេះ) និង អ្នករៀបដី (អ្នកដឹកនាំមិនផ្លូវការនៅក្នុងភូមិ ដែលតំណាងឲ្យអ្នកភូមិនៅក្នុងការចរចាជាមួយក្រុមហ៊ុន)។ អ្នករៀបដីអាចទទួលបានថ្លៃទឹកតែពីក្រុមហ៊ុនផងដែរ ប៉ុន្តែមិនមែនជាប្រាក់ចំណេញដូចដែលអ្នកគួរជេរបានទទួលនោះទេ។

លទ្ធផលនៃកិច្ចសម្រុះសម្រួលវិវាទនៅភូមិតាម៉ិញនៅជំណាក់កាលដំបូងបង្ហាញថា ក្រុមហ៊ុនបានផ្តល់ដីព្រៃមួយផ្នែកទៅឲ្យអ្នកភូមិចំនួនប្រមាណជាង ៧០គ្រួសារ។ ការបែងចែកក្នុងមួយគ្រួសារៗទទួលបានក្បាលដីទំហំស្មើៗគឺ៥០ម x ១០០ម។ ទោះជាយ៉ាងណាក៏ដោយ ក្រុមហ៊ុននៅតែចង់បានដីព្រៃដែលបានបែងចែករួចទៅហើយទៀត។ អ្នកគួរជេរនៅក្នុងភូមិមានគ្នាបីនាក់បានចេញមកគំរាមប្រជាពលរដ្ឋឲ្យលក់ដីឲ្យក្រុមហ៊ុន។ ពួកគេគឺជាមន្រ្តីរាជការនៅក្នុងភូមិ និងមកពីភូមិក្បែរខាង។ យុទ្ធសាស្រ្តតែមួយដែលអ្នកគួរជេរប្រើ គឺទាញយកប្រយោជន៍ពីកិច្ចសន្យាដែលក្រុមហ៊ុនបានទទួលសម្បទានដីសេដ្ឋកិច្ច ដើម្បីគំរាមនិងបញ្ចុះបញ្ចូលអ្នកភូមិឲ្យលក់ដីនៅចុងបញ្ចប់ក្នុងតម្លៃថោក។

ស្រ្តីមួយរូបជាជំនួយការភូមិបានមានប្រសាសន៍៖
«*បើនិយាយជារួមទៅ យើងដូចជាចាញ់បោកក្រុមហ៊ុនហើយ។ គេបានបញ្ចុះបញ្ចូលនិងគំរាមប្រជាពលរដ្ឋ អញ្ចឹងក៏នាំគ្នាលក់ដីទៅ។ បើយើងទុកដី ក៏មិនមានអ្នកណាបង្ខំយើងឲ្យលក់ដែរ។*»

ករណីវិវាទនៅភូមិត្រពាំងគងក្នុងស្រុកឱរ៉ាល់ ក៏មានដំណើរការទៅដូចគ្នានេះដែរ។ ខុសគ្នាគឺនៅត្រង់ដែលថាមានអ្នកភូមិខ្លះមិនបានទទួលសំណងអ្វីសោះពីក្រុមហ៊ុន គឺមកតែពីអ្នកគួរជេរហ្នឹងមិនមានភាពស្មោះត្រង់។

**ករណីវិវាទទី១ៈ វិវាទដីធ្លីនៅឃុំបឹងប្រាំ ក្នុងស្រុកបវេល ខេត្តបាត់ដំបង**

កាលដើមឡើយតំបន់បឹងប្រាំគ្រាន់តែជាផ្នែកនៃឃុំចំនួនបីក្នុងស្រុកបវេល គឺជាព្រៃស្រោងដែលត្រូវបានកាន់កាប់ដោយភាគី ខ្មែរក្រហមរហូតមកទល់នឹងការអនុវត្តគោលនយោបាយឈ្នះ-ឈ្នះរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលគេស្គាល់ថាជាសមាហរណកម្មក្រុមខ្មែរក្រហមជាមួយរាជរដ្ឋាភិបាលនៅក្នុងឆ្នាំ១៩៩៧។ ដោយមកពីគោលនយោបាយនេះមិនមានភាពច្បាស់លាស់ (ពីព្រោះមិនមានទម្រង់ជាលាយលក្ខណ៍អក្សរ) នាយទាហានជាន់ខ្ពស់ខ្មែរក្រហមខ្លះ ដែលបានគ្រប់គ្រងតំបន់ នេះបានលក់ ដីព្រៃនេះទៅឲ្យក្រុមឈ្មួញក្នុងស្រុក។ គឺប្រការនេះហើយដែលធ្វើឲ្យអ្នកដទៃទៀត ដែលគិតថាពួកខ្លួនមានចំណែកក្នុងនោះដែរ បានបាត់បង់ផលប្រយោជន៍។

ម្ល៉ោះហើយនៅពាក់កណ្តាលខែកក្កដាឆ្នាំ២០០៥ អតីតនាយទាហានខ្មែរក្រហមមួយរូបដែលបានចូលធ្វើសមាហរណកម្មនៅ ក្នុងកងពលតូចលេខ៥៣ ដែលទើបបង្កើតថ្មីក្នុងឋានៈជាអនុសេនីយឯក បានប្រមែប្រមូលមនុស្សប្រហែល៥០នាក់ក្នុងសម្លៀកបំពាក់ស៊ីវិលពីអង្គភាពយោធារបស់ខ្លួនចូលមកពិនិត្យតំបន់បឹងប្រាំនេះ ហើយបានមើលឃើញថា មេបញ្ជាការរបស់ពួកគេ បានលក់ដីដែលជាចំណែករបស់ខ្លួនទៅឲ្យក្រុមឈ្មួញ។ ដូច្នោះព័ត៌មានដែលថាគ្រួសារនីមួយៗអាចទទួលបានក្បាលដី សម្រាប់លំនៅដ្ឋាន និងសម្រាប់កសិកម្មបានផ្សព្វផ្សាយចេញយ៉ាងឆាប់រហ័សចេញពីតំបន់នេះ។ ព័ត៌មាននេះបានទាក់ទាញមនុស្សជាច្រើននាក់ ភាគច្រើនជាអ្នកក្រីក្រមកពីខេត្តផ្សេងៗមកតាំងទីលំនៅនៅកន្លែងនេះ ដែលចំនួនបានកើនឡើងរហូតដល់ជាង ៣០០០គ្រួសារនៅក្នុងឆ្នាំ២០០៦ ។ បុរសរូបនេះក្នុងឋានៈជាអ្នកដឹកនាំសហគមន៍តាមរូបភាពនេះ បានចាប់ផ្តើមប្រែក្លាយក្រុមមនុស្សដែលចូលមករស់នៅក្នុងជំរំទាំងអស់តាំងពីលើកដំបូង ឲ្យទៅជាសង្គមមួយដែលមានយន្តការគ្រប់គ្រង ដូចជាមានមេភូមិ និងកងសន្តិសុខស្វ័យការពារជាដើម។ ទោះជាយ៉ាងនេះក្តី អ្នកដែលទើបនឹងចូលមករស់នៅត្រូវចំណាយប្រាក់ទៅឲ្យរដ្ឋអំណាចនេះសម្រាប់ការតាំងទីលំនៅក្នុងតំបន់នេះ ហើយតម្លៃដែលត្រូវចំណាយលើដីធ្លីកាន់តែថ្លៃឡើងៗ ចំពោះអ្នកដែលចូលមករស់នៅក្រោយៗទៀត។ នៅដើមដំបូងនៃការតាំងទីលំនៅ ប្រជាពលរដ្ឋដែលគ្មានដីធ្លីទាំងនេះ ត្រូវរានដីព្រៃសម្រាប់សង់ផ្ទះសម្បែង និងការដាំដុះដំណាំ ដែលបង្កឲ្យមានការប្រឈមមុខជាមួយនឹងកងកម្លាំងសន្តិសុខរបស់ក្រុមឈ្មួញដែលឈរជើងនៅតំបន់នេះ និងកសិករមកពីឃុំទាំងបីដែលនៅជិតខាង។

បើទោះបីជាអ្នកដឹកនាំសហគមន៍បានប៉ុនប៉ងជាច្រើនលើកក្នុងការបញ្ចុះបញ្ចូលអាជ្ញាធរកម្រិតផ្សេងៗឲ្យមានការទទួលស្គាល់ការគ្រប់គ្រងរបស់ខ្លួននៅតំបន់បឹងប្រាំ ប៉ុន្តែការប៉ុនប៉ងនេះមិនបានសម្រេចជោគជ័យទេ។ បញ្ហានៅត្រង់ថាបឹងប្រាំត្រូវបាន មន្ត្រីមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលពេលនោះចាត់ទុកថាជាតំបន់គ្រោះថ្នាក់។ ដូច្នោះហើយអ្នកដឹកនាំរូបនេះបាន

សង្កត់ធ្ងន់ថា៖

*«ពេលដែលប្រជាពលរដ្ឋឈឺចាប់ ពេលនោះកំហឹងរបស់ខ្ញុំមិនបានគិតដល់បញ្ហាខ្លួនឯងប្រឈមនឹងរដ្ឋាភិបាលទេ។ ពេលខ្ញុំមើលឃើញភាពអយុត្តិធម៌សម្រាប់កងកម្លាំងប្រដាប់អាវុធ និងប្រជាជនស្លូតត្រង់ដែលគ្មានជម្រកនៅ និងគ្មានដីកសិកម្ម ហ្នឹងហើយបានជាគាត់សុខចិត្តរួមសុខ រួមទុក្ខ ជាមួយខ្ញុំ។ ប៉ុន្តែអាជ្ញាធរនិងរដ្ឋាភិបាលកាលនោះគាត់មិនទទួលស្គាល់ទេ គេថាយើងមករស់នៅបែបអនាធិបតេយ្យ។ មែនមុននឹងបែបអនាធិបតេយ្យ មកពីពួកគាត់លក់ដីឲ្យពួកអនាធិបតេយ្យធ្វើឲ្យយើងមានកំហឹងឈឺចាប់។»*

នៅថ្ងៃទី១ខែសីហាឆ្នាំ២០០៦ ក្រុមនគរបាល ប៉េអឹម និងទាហានប្រមាណជាង ១០០នាក់បានចូលមកចាប់ខ្លួនអ្នកដឹកនាំតំបន់ បឹងប្រាំ នៅផ្ទះរបស់គាត់នៅក្បែរសាលាឃុំ ពាក់ព័ន្ធនឹងវិវាទដីធ្លីអស់រយៈពេលយ៉ាងយូរជាមួយនឹងមន្ត្រីមូលដ្ឋាន និងក្រុម ឈ្មួញ។ ទោះបីជាអ្នកភូមិជាង ១០០នាក់បានធ្វើរបាំងរាំងមិនឲ្យចាប់ខ្លួនអ្នកដឹកនាំរូបនេះក៏ដោយ នៅទីបញ្ចប់គាត់ក៏ត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅខេត្តបាត់ដំបង។ គាត់បានបញ្ជាក់ថា គាត់ត្រូវបានចោទប្រកាន់ពីបទល្មើសប្រាំពីរករណីខុសៗគ្នា ជាសំខាន់បទរំលោភកម្មសិទ្ធិឯកជន។ ទោះជាយ៉ាងនេះក្តី បើយោងតាមមន្ត្រីមូលដ្ឋានមួយរូប គាត់ត្រូវបានចោទប្រកាន់ពីបទអបគមន៍ និងបទទន្ទ្រានដីព្រៃដែលជាកម្មសិទ្ធិរបស់រដ្ឋ។ ក្នុងពេលជាមួយគ្នានេះដែរ មិនមានតែអ្នកដឹកនាំតំបន់បឹងប្រាំ ម្នាក់ទេដែលត្រូវចាប់ខ្លួន ប៉ុន្តែមានអ្នកដែលធ្វើការជាមួយគាត់មួយចំនួនទៀតក៏ត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ផងដែរ និងត្រូវបានកាត់ទោសជាសំខាន់ពាក់ព័ន្ធនឹងបទរំលោភកម្មសិទ្ធិឯកជន។ មានប្រជាពលរដ្ឋជាច្រើននាក់មកពីតំបន់បឹងប្រាំបានស្នើសុំ ជាច្រើនលើកឲ្យមានការដោះលែងអ្នកដែលជាប់ឃុំឃាំងនៅពន្ធនាគារខេត្តបាត់ដំបង ជាពិសេសអ្នកដឹកនាំមួយរូបរបស់ខ្លួន។ ដោយហេតុថា ការទាមទារតវ៉ារបស់អ្នកភូមិដូចជាមិនអាចបញ្ឈប់បាន អ្នកដឹកនាំតំបន់បឹងប្រាំក៏ត្រូវបានបញ្ជូនទៅពន្ធនាគារ នៅឯភ្នំពេញ។

បើទោះបីជាអ្នកដឹកនាំរូបនេះត្រូវបានឃុំឃាំងនៅភ្នំពេញក៏ដោយ អ្នកតវ៉ាជំទាស់មកពីតំបន់បឹងប្រាំបានប្រមូលផ្តុំគ្នានៅ រាជធានី ដើម្បីសំដែងនូវការគាំទ្ររបស់ខ្លួនឲ្យមានការដោះលែងអ្នកដឹកនាំរូបនេះ។ អ្នក*ដឹកនាំ*នេះក៏បានទទួលស្គាល់ដែរថា ពីមុនភរិយារបស់គាត់ដូចជាមិនមានទំនាក់ទំនងជាមួយអ្នកក្រៅទេ ប៉ុន្តែព្រឹត្តិការណ៍នេះបានតម្រូវឲ្យភរិយាគាត់ស្វែងយល់ពីការរៀបចំ និងដឹកនាំការទាមទារតវ៉ាជាសាធារណៈជាមួយតំណាងប្រជាពលរដ្ឋដទៃៗទៀត។ នៅក្នុងពេលនោះ មានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការអន្តរជាតិជាច្រើន ជាពិសេសក្រុមអង្គការសិទ្ធិមនុស្សបានបង្ហាញនូវការគាំទ្រយ៉ាងមុតមាំ ឲ្យមានការដោះលែងអ្នកដឹកនាំរូបនេះ។ នៅទីបញ្ចប់ អ្នកដឹកនាំតំបន់បឹងប្រាំត្រូវបានដោះលែងនៅខែវិច្ឆិកា ឆ្នាំ២០០៧ បន្ទាប់ពីបានឃុំឃាំងក្នុងពន្ធនាគារអស់រយៈពេល១៤ខែមក។ គាត់បានបង្ហាញខ្លួននៅសាលាឧទ្ធរណ៍ពាក់ព័ន្ធនឹងវិវាទជាមួយក្រុមឈ្មួញ។ ឈ្មួញទាំងនេះត្រូវបានសម្រេចឲ្យចាកចេញពី

តំបន់បឹងប្រាំ ដោយអនុលោមតាមកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាល។ អាស្រ័យដោយប្រជាប្រិយភាព និងការគាំទ្រពីសំណាក់រដ្ឋាភិបាល អ្នកដឹកនាំតំបន់បឹងប្រាំរូបនេះបានក្លាយជាមេឃុំបឹងប្រាំចាប់តាំងពីពេលបោះឆ្នោតឃុំឆ្នាំ២០១២កន្លងមក។

វិវាទនៅក្នុងឃុំបឹងប្រាំមិនទាន់បានបញ្ចប់នៅឡើយទេ។ ក្នុងឆ្នាំ២០០៧-២០០៨ ការប្រឈមមុខដាក់គ្នាធំៗចំនួនពីរលើកបានកើតឡើងរវាងប្រជាពលរដ្ឋក្នុងឃុំបឹងប្រាំ ជាមួយនឹងអ្នកនៅភូមិជិតខាង (ក្រោយមកគេស្គាល់ថា ក្រុម១៩២គ្រួសារ) បង្កឲ្យមាន អ្នកស្លាប់ម្នាក់ និងអ្នករងរបួសមួយចំនួនទៀត។ ម្យ៉ាងវិញទៀត សម្បទានដីសង្គមកិច្ចត្រូវបានអនុម័តដោយអនុក្រឹត្យលេខ២០២ ចេញនៅឆ្នាំ២០១១ និងបទបញ្ជា០០១ដែលបានចេញក្នុងឆ្នាំ២០១២ ដើម្បីធានាសុវត្ថិភាពដល់ការកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋនៅឃុំបឹងប្រាំ និងគ្រួសារអតីតយុទ្ធជន។ ទោះជាយ៉ាងនេះក្តី បញ្ហានេះបានធ្វើឲ្យមានផលប៉ះពាល់មកលើក្រុម១៩២គ្រួសារ ដែលរស់នៅឬដាំដំណាំនៅលើផ្ទៃដីទំហំ ៨០០ហិកតា ដែលជាផ្នែកមួយនៃឃុំបឹងប្រាំ។ ក្រុម ១៩២ គ្រួសារភាគច្រើនមកពីឃុំ/ស្រុកជិតខាង ម្ល៉ោះហើយតំណាងរបស់ពួកគេបានប៉ុនប៉ងទាមទារកម្មសិទ្ធិលើដីវិវាទនៅស្ថាប័នពាក់ព័ន្ធនានានៅភ្នំពេញ។

គួរកត់សម្គាល់ថា ក្នុងខែធ្នូ ឆ្នាំ២០១១ ការប្រយុទ្ធមួយបានកើតឡើង នៅពេលដែលអាជ្ញាធរឃុំដោយមានការគាំទ្រពីសំណាក់ នគរបាល កងរាជអាវុធហត្ថ និងយោធាបានរៀបចំដីសម្រាប់គ្រួសារអតីតយុទ្ធជន ក្នុងអំឡុងពេលច្រូតកាត់ស្រូវរបស់អ្នកភូមិ (ក្រុម១៩២គ្រួសារ)។ ការប្រឈមមុខដាក់គ្នានេះ បានធ្វើឲ្យមានការរងគ្រោះដល់ភាគីទាំងសងខាង៖ អ្នករងរបួស និងការខូច ខាតរថយន្ត និងសម្ភារៈ ហើយមនុស្សមួយចំនួនត្រូវបានចាប់ខ្លួន និងអ្នកដទៃទៀតត្រូវបានចោទប្រកាន់។ មានអ្នកភូមិជាង ៣០០នាក់ប្រដាប់ដោយកាំបិតនិងពូថៅបានចេញមកធ្វើការតវ៉ាជំទាស់។ ពួកគេបានដណ្តើមអាវុធពីកងប្រដាប់អាវុធរបស់រដ្ឋាភិបាល ម្ល៉ោះហើយមានអ្នកតវ៉ាជំទាស់ជាច្រើននាក់ត្រូវបានចោទប្រកាន់ពី «បទប្លន់» និង «បទបំផ្លាញទ្រព្យសម្បត្តិរដ្ឋ» ហើយក៏ត្រូវបានតម្រូវឲ្យពួកគេប្រគល់អាវុធនោះទាំងអស់មកវិញ។ ទើបតែនៅក្នុងខែសីហា ឆ្នាំ២០១៤ទេ ដែលពួកគេត្រូវបានដោះលែង ឬ បញ្ឈប់ការចោទប្រកាន់ទៀត ក្រោយពេលដែលអ្នកភូមិបានហែក្បួនមកជួបជុំគ្នានៅខាងមុខសាលាខេត្ត។

ក្នុងអំឡុងឆ្នាំ២០១២-២០១៣ នៅក្នុងក្របខណ្ឌសម្បទានដីសង្គមកិច្ច ក្រុមយុវជនស្ម័គ្រចិត្តរួមនឹងគណៈកម្មការសុរិយោដីបានចុះវាស់វែងក្បាលដី សម្រាប់លំនៅដ្ឋាន(ទំហំ៤០មx៤០ម) និងកសិកម្ម(ទំហំ១ហិកតា) ដែលគ្របដណ្តប់ផ្ទៃដីសរុបចំនួន ៣៦៣៨ហិកតាសម្រាប់ប្រជាពលរដ្ឋចំនួន១៧៣៦គ្រួសារក្នុងឃុំបឹងប្រាំ។ ទោះជាយ៉ាងនេះក្តី ប្រតិកម្មតបក៏បានកើតឡើងចេញពីក្រុម១៩២គ្រួសារដែលបានរស់នៅឬដាំដំណាំលើដីទំហំ៨០០ហិកតា នៅក្នុងខណៈដែលក្រុមការងារបច្ចេកទេសនេះកំពុងបំពេញភារកិច្ចរបស់ខ្លួននៅទីនោះ។ គឺមានតែគ្រួសារអ្នកមានខ្លះ

ទេ ដែលមានដីទំហំធំៗដែលបានឆ្មៀលចេញ ហើយទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី។ ដូច្នោះ ហើយបានជាបុរសម្នាក់បាននិយាយប្រាប់ថា៖

*«ខាងគេអត់ដី ក៏ប៉ុន្តែគេមានប្លង់ ប៉ុន្តែខ្ញុំមិនដឹងអ្នកណាធ្វើឲ្យ។ ប្រជាជនខាងណោះបានយកប្លង់ គេមកបង្ហាញយើងថា នេះប្លង់គេ៣រ៉ៃៗម្នាក់ គេមក រកដីគេថានៅត្រង់ណា។ពេលនិស្សិតចុះវាស់ គេវាស់ដីខ្ញុំដែរ តែគេអត់ចេញប្លង់ឲ្យ តែដីអ្នកធំៗគេវាស់ឲ្យ ហើយចេញប្លង់ឲ្យទៀត។ គេប្រាប់ ថាបងប្អូនមានដីតិចៗមិនបាច់ភ័យទេ ភ័យតែអាដីគេមានច្រើន។»*

ភាពមិនប្រប្រតី និងការប្រឈមខ្លះពាក់ព័ន្ធនឹងសម្បទានដីសង្គមកិច្ចនៅឃុំបឹងប្រាំអាចទាក់ទិននឹងការគ្រប់គ្រងដីធ្លី និងតម្លាភាពនៅក្នុងការអនុវត្តសម្បទានដីសង្គមកិច្ច។ នៅក្នុងខណៈដែលក្រុម១៩២គ្រួសារត្រូវការភាពស្របច្បាប់នៃការកាន់កាប់ ដីរបស់ខ្លួន ដូចដែលពួកគេបានទាមទារអស់រយៈពេលយ៉ាងយូរមកហើយ អាជ្ញាធរឃុំបឹងប្រាំបានបដិសេធការទាមទារនេះ ហើយបាននិយាយថា ពួកគេបានរាន និងកាន់កាប់ដីនេះដោយខុសច្បាប់ ដោយយោងតាមសម្បទានដីសង្គមកិច្ច។ តំណាង របស់ក្រុម១៩២គ្រួសារនៅតែបន្តដាក់បណ្តឹងរបស់ខ្លួននៅស្ថាប័ន និងអង្គការពាក់ព័ន្ធនានានៅភ្នំពេញ ទាំងថ្នាក់ជាតិ និងអន្តរជាតិ។ នៅខែមិនា ឆ្នាំ ២០១៥ ពួកគេបានដាក់បណ្តឹងនៅរដ្ឋសភា ហើយរដ្ឋសភាក៏បានចេញលិខិតមួយច្បាប់ផ្ញើជូនសាលាខេត្ត ដើម្បីជូនដំណឹងដល់ប្រជាពលរដ្ឋដែលរស់នៅឃុំបឹងប្រាំឲ្យផ្អាកសកម្មភាពលើដីវិវាទនេះសិន ពីព្រោះគេកំពុងធ្វើការស៊ើបអង្កេត។ មកទល់ពេលនេះ ក្រុម១៩២គ្រួសារនៅតែមានកង្វល់ពាក់ព័ន្ធនឹងការទាមទារដីរបស់ខ្លួន ចំណែកឯប្រជាពលរដ្ឋក្នុងឃុំបឹងប្រាំក៏មិនរំពឹងថានឹងទទួលបានដីកសិកម្មទេ ដែលជាហេតុនាំឲ្យពួកគាត់នាំគ្នាធ្វើចំណាកស្រុកយ៉ាងច្រើន។

## ១០. មូលហេតុ និងបរាជ័យក្នុងការដោះស្រាយវិវាទ

នៅក្នុងខេត្តគោលដៅទាំងបួន មិនមែនករណីវិវាទទាំងអស់សុទ្ធតែបានដោះស្រាយនោះឡើយ។ ៦៥.២% នៃអ្នកផ្តល់ចម្លើយបង្ហាញថា វិវាទមិនបានដោះស្រាយទេមកទល់នឹងពេលនេះ។ ជាក់ស្តែងដំណោះស្រាយវិវាទ៩ ករណីមិនបានជោគជ័យទេ ហើយករណីវិវាទទាំងនេះកំពុងព្យួរមកទល់នឹងពេលដែលយើងចុះសិក្សាតាមមូលដ្ឋានដោយមិនមានការដោះស្រាយឲ្យបានច្បាស់លាស់។ ក្នុងខណៈដែលករណីវិវាទដទៃៗទៀតមានដំណោះស្រាយ ដែលភាគីវិវាទទាំងពីរអាចទទួលយកបាន។ វិវាទផ្សេងទៀតចំនួន១៨ករណីត្រូវបានដោះស្រាយហើយ ប៉ុន្តែទោះជាយ៉ាងណា ក៏អ្នកភូមិមានអារម្មណ៍ថា ការដោះស្រាយវិវាទមិនមានសមធម៌។ លទ្ធផលនៃការដោះស្រាយវិវាទគឺមាន ៣៣.៨% ត្រូវបានដោះស្រាយបញ្ចប់ដោយការផ្តល់សំណង ៥៥.៥% មិនត្រូវបានដោះស្រាយ និង ៨.៩%មិនដឹងពីការដោះស្រាយនេះទេ។ ៨០.៦% នៃអ្នកផ្តល់ចម្លើយបានបញ្ជាក់ថា

ភាគីទីពីរកំពុងកាន់កាប់ដីវិវាទមកទល់នឹងពេលនេះ។ អ្នកផ្តល់ចម្លើយចំនួន ៨២.៥% បានប្រាប់ថា លទ្ធផលនៃការដោះស្រាយមិនយុត្តិធម៌ទេ។ ចំនួនច្រើនជាងពាក់កណ្តាលនៃអ្នកផ្តល់ចម្លើយ (៥៧.៧%) កំពុងនៅរង់ចាំដំណោះស្រាយក្នុងខណៈដែល ២៥.៨% ចង់ដាក់បណ្តឹងនៅស្ថាប័នផ្សេងៗទៀត។ អ្នកផ្តល់ចម្លើយចំនួន ៩.៧% ដែលអស់សង្ឃឹម បានគិតថា ឈប់បន្តបណ្តឹង ចំណែកអ្នកផ្តល់ចម្លើយខ្លះបានប្រាប់ថា ពួកគាត់នឹងចេញតវ៉ាជំទាស់ ឬក៏វិលត្រឡប់មកកាន់កាប់ដីរបស់ខ្លួនវិញ។

**រូបទី៤: ផែនការដោះស្រាយវិវាទនៅពេលខាងមុខ**




មូលហេតុជាបឋមនៃបរាជ័យក្នុងដំណោះស្រាយវិវាទទាក់ទិននឹងការមិនមានសំណងស្របតាមបទដ្ឋានសម្រាប់ផ្តល់ឲ្យអ្នកភូមិ ដែលដីរបស់ពួកគាត់ត្រូវបានរឹបអូសតាមរយៈសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច។ គ្រួសាររងគ្រោះភាគច្រើនបានទទួលសំណងយ៉ាងតិចតួចណាស់ គឺមានប្រហែលពី ៣៥ ទៅ ៣០០ដុល្លារ ដូច្នេះទឹកប្រាក់នេះ មិនអាចឲ្យគាត់យកទៅទិញដី ឬក៏ចាប់ផ្តើមប្រកបមុខរបរថ្មីសម្រាប់ទ្រទ្រង់ការចិញ្ចឹមជីវិតរបស់ខ្លួនបានទេ ក្នុងខណៈដែលគ្រួសារមួយចំនួនតូចប៉ុណ្ណោះនៅតស៊ូក្រាញនៀល ទើបបានទទួលប្រាក់ពី ៩០០ ទៅ ១០០០ដុល្លារ។ យើងក៏សង្កេតឃើញថា នៅក្នុងករណីវិវាទខ្លះ អ្នកភូមិបានទាមទារសំណងមានទំហំធំពេក ដែលក្រុមហ៊ុនមិនមានលទ្ធភាពផ្តល់ឲ្យបាន។ សំណងត្រូវបានធ្វើជាថ្នូរនឹងការផ្តិតមេដៃ ដែលជាទឡ្ហីករណ៍ដ៏រឹងមាំតាមផ្លូវច្បាប់គឺធ្វើយ៉ាងដូចនេះ ក៏ដើម្បីកុំឲ្យអ្នកភូមិអាចប្តឹងផ្តល់បាននៅពេលក្រោយ។ ទោះជាយ៉ាងនេះក្តី បើតាមទស្សនៈរបស់អ្នកភូមិ ពួកគាត់មានអារម្មណ៍ថា ដំណោះស្រាយវិវាទមិនមានសមធម៌ទេ។ ពួកគាត់សុខចិត្តទទួលយកសំណង ពីព្រោះពួកគាត់មិនមានជម្រើសអ្វីក្រៅពីនេះ គឺទទួលយកសំណងដ៏ស្តួចស្តើងនេះ វាគ្រាន់បើជាងអត់បានទទួលអ្វីសោះ។ អ្នកភូមិក៏បានត្អូញត្អែរផងដែរថា ពួកគាត់បានចំណាយធនធានច្រើនណាស់ ទាំងប្រាក់កាស ក៏ដូចជា

កម្លាំងពលកម្ម ដើម្បីរានដីកសិកម្ម និងដាំដំណាំ តែសំណាងយ៉ាងតិចតួច នេះវាមិនសមល្មមនឹងអ្វីដែលពួកគាត់បានចំណាយកន្លងមក។

តាមទស្សនវិស័យរបស់អ្នកសម្រុះសម្រួល គេមានការសង្ស័យថា អ្នកភូមិមានគណបក្សនយោបាយ ឬសាច់ញាតិរបស់ខ្លួនដែលជាអ្នកមានអំណាចជាខ្នងបង្អែក ដែលនាំឲ្យការសម្រុះសម្រួលបរាជ័យ។ ករណីវិវាទនៅភូមិតាម៉ិញ ក្នុងខេត្តកំពង់ស្ពឺ អ្នកសម្រុះសម្រួលបានបង្ហាញនូវការដោះស្រាយវិវាទដែលមិនអាចដំណើរការទៅមុខបានគឺមកពីអ្នកភូមិតែងតែមានអ្នកគួរជេរនៅពីក្រោយ។ ចំពោះករណីវិវាទនៅភូមិស្រែសា ក្នុងស្រុកសាមគ្គីមានជ័យ ការដោះស្រាយវិវាទមិនអាចដំណើរការទៅបានយ៉ាងរលូន ពីព្រោះអ្នកសម្រុះសម្រួលមានការភ័យព្រួយចំពោះមន្ត្រីជាន់ខ្ពស់ដែលមានដីនៅកន្លែងដីវិវាទផងដែរ។

កត្តាមួយទៀតដែលនាំឲ្យបរាជ័យក្នុងការដោះស្រាយវិវាទគឺ កង្វះការប្តេជ្ញាចិត្តរបស់អាជ្ញាធរមូលដ្ឋាន។ ចំពោះករណីវិវាទដីធ្លីដំណាក់កាលទីមួយនៅឃុំប្រាំបីមុម ក្នុងខេត្តកំពង់ស្ពឺ អ្នកភូមិបានត្អូញត្អែរអំពីក្រុមហ៊ុនស៊ីធីម៉ាតបានសន្យាថាយកដីរបស់អ្នកភូមិជាថ្នូរនឹងសំណង ប៉ុន្តែក្រុមហ៊ុនបែរជានៅស្ងៀមមិនបានផ្តល់សំណងដូចដែលគេបានសន្យានោះឡើយ។ បណ្តឹងរបស់អ្នកភូមិនៅស្ងាត់គ្មានដំណោះស្រាយ។ ករណីវិវាទមួយទៀតដូចគ្នានេះដែរ គឺវិវាទដីធ្លីនៅក្នុងឃុំត្បែងខ្ពស់នៃខេត្តកំពង់ឆ្នាំង ដែលអាជ្ញាធរបានផ្អើបទុកមិនមានដំណោះស្រាយ។ ទោះជាយ៉ាងនេះក្តី អ្នកភូមិបានរងការប៉ះពាល់លើការចិញ្ចឹមជីវិតរបស់ពួកគាត់ ដែលពឹងអាស្រ័យលើផលដំណាំ ក៏ព្រោះតែនៅទន្ទឹងរង់ចាំការដោះស្រាយវិវាទ។ កង្វះការប្តេជ្ញាចិត្តនៅក្នុងការដោះស្រាយវិវាទរបស់អ្នកសម្រុះសម្រួលជាហេតុនាំឲ្យអ្នកភូមិមានការអស់សង្ឃឹម ហើយក៏យកបណ្តឹងរបស់ខ្លួនទៅដាក់នៅអាជ្ញាធរថ្នាក់លើ ដោយរំពឹងថាស្ថាប័នទាំងនេះនឹងឆ្លើយតបដោយការដោះស្រាយបញ្ហានេះជូនពួកគាត់។

អ្នកសម្រុះសម្រួលក្នុងកម្រិតផ្សេងៗ បានបញ្ជាក់អំពីបញ្ហាលំបាកនៅក្នុងការដោះស្រាយវិវាទដោយមកពីអាជ្ញាធរថ្នាក់លើបានធ្វើសេចក្តីសម្រេចផ្តល់សម្បទានដីសេដ្ឋកិច្ច ឬសម្បទានដីសង្គមកិច្ច។ ពួកគាត់បាននិយាយប្រាប់ថា ការដោះស្រាយករណីវិវាទដីធ្លីប្រភេទនេះ គឺហួសពីដែនសមត្ថកិច្ចរបស់គាត់។ ដូចជាករណីវិវាទនៅស្រុកភ្នំស្រួច ក្នុងខេត្តកំពង់ស្ពឺជាឧទាហរណ៍ស្រាប់ អ្នកសម្រុះសម្រួលទំនងជាបញ្ជូនសំណុំរឿងវិវាទទៅអាជ្ញាធរថ្នាក់លើតាមឋានានុក្រម។ ក្រៅពីនេះ ពួកគាត់ដែលជាអ្នកសម្រុះសម្រួលនៅថ្នាក់ក្រោមបានបង្ហាញពីកង្វះសមត្ថភាពទាំងផ្នែកច្បាប់ក៏ដូចជាផ្នែកបច្ចេកទេស ដើម្បីដោះស្រាយវិវាទដីធ្លីនេះ។ ពួកគាត់ត្រូវចេញទៅពិនិត្យដល់

ទីកន្លែងដីដែលមានវិវាទនៅក្នុងដំណើរការសម្រុះសម្រួលវិវាទដីធ្លីនេះ ប៉ុន្តែជាញឹកញាប់ពួកគាត់បានបញ្ជាក់ថា មិនមានថវិកាសម្រាប់បំពេញកិច្ចការនេះទេ។

**ករណីវិវាទទី២៖ វិវាទដីធ្លីនៅភូមិមួយក្នុងឃុំប្រាំបីមុម ស្រុកថ្កូង ខេត្តកំពង់ស្ពឺ**

នៅក្នុងសម័យសង្គ្រាម (១៩៧០-១៩៧៥) និងនៅក្នុងជំនាន់របប ប៉ុល ពត (១៩៧៥-១៩៧៩) តំបន់ដីខ្ពស់គ្របដណ្តប់ដោយព្រៃ ឈើក្នុងទំហំដី ២៩២៥ហិកតានេះ ដែលជាផ្នែកនៃភូមិមួយត្រូវបានកាន់កាប់ដោយក្រុមខ្មែរក្រហម ដែលចាប់យកតំបន់នេះធ្វើជាប្រភពនៃការបង្កបង្កើនផលដំណាំ។ ក្រោយការដួលលំនៃរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ តំបន់នេះហាក់ដូចជាតំបន់ដាច់ស្រយាលមួយ និងជាទីកន្លែងនៃការប្រឈមមុខដាក់គ្នារវាងទាហានខ្មែរក្រហម និងកងកម្លាំងរបស់រដ្ឋាភិបាល។ ទោះជាយ៉ាងនេះក្តី នៅក្នុងដើមទសវត្ស១៩៩០ គ្រួសារមួយចំនួននៅក្នុងភូមិបានចាប់ផ្តើមដាំដំណាំក្នុងតំបន់នេះ ហើយក្រោយការធ្វើសមាហរណកម្មរបស់ភាគីខ្មែរក្រហមជាមួយរាជរដ្ឋាភិបាលក្នុងឆ្នាំ១៩៩៦ ទើបប្រជាពលរដ្ឋជាច្រើនគ្រួសារបានមកធ្វើកសិកម្មនៅលើទឹកដីនេះ។

នៅឆ្នាំ២០០៦ ក្រុមហ៊ុនស៊ីធីម៉ាតបានប្រើគ្រឿងចក្រមកឈូសឆាយដីមួយផ្នែកនៃតំបន់នេះ សម្រាប់ដាំដើមអាកាស្យា។ ទោះជាយ៉ាងនេះក្តី គេមិនបានជូនដំណឹងដល់ប្រជាពលរដ្ឋក្នុងភូមិអំពីសម្បទានដីសេដ្ឋកិច្ចក្នុងតំបន់នេះទេ។ ដូច្នោះហើយបានជាបង្កឲ្យមានជាការប្រឈមមុខជាច្រើនលើករវាងក្រុមសន្តិសុខរបស់ក្រុមហ៊ុន ជាមួយនិងប្រជាពលរដ្ឋកាន់កាប់ដីដែលប្រដាប់ទៅដោយកាំបិតនិងពូថៅ ប៉ុន្តែមិនដែលមានការប៉ះទង្គិចគ្នារវាងភាគីទាំងសងខាងឡើយ។ បើទោះបីជាពួកគាត់បានសុំឲ្យក្រុមហ៊ុនបញ្ឈប់សកម្មភាពរបស់ខ្លួនក៏ដោយ គ្រឿងចក្ររបស់គេនៅតែបន្តឈូសឆាយដីដាំដំណាំដដែល។ ក្រុមហ៊ុនបានយោងសម្បទានដីសេដ្ឋកិច្ចដែលរដ្ឋាភិបាលបានផ្តល់ឲ្យក្នុងខណៈដែលប្រជាពលរដ្ឋក្នុងភូមិបានអះអាងថា ពួកគាត់បានដាំដំណាំលើដីនេះយូរមកហើយ។

នៅឆ្នាំ២០០៦ ជាលើកដំបូងអ្នកភូមិបានចេញទៅជួបមេភូមិដើម្បីសុំការគាំទ្រ ប៉ុន្តែមេភូមិបានប្រាប់ពួកគាត់ឲ្យទៅរកមេឃុំ ដើម្បីសួរគាត់ថា តើយ៉ាងដូចម្តេចបានជាក្រុមហ៊ុនរំលោភដីប្រជាពលរដ្ឋ។ អ្នកភូមិប្រមាណជាង ៩០នាក់បានធ្វើដំណើរតាមរថយន្តមួយទៅជួបមេឃុំ ដែលបានប្រាប់ពួកគាត់ថាឲ្យរង់ចាំមើលគេដោះស្រាយសិន។ ពីរខែក្រោយមក អ្នកភូមិមួយក្រុមជាមួយនឹងតំណាងរបស់ខ្លួនបានចេញទៅជួបអភិបាលស្រុក ដែលបានផ្តល់ចម្លើយដូចដែលមេឃុំបានឆ្លើយដែរ។

ទោះជាយ៉ាងណាក៏ដោយអ្នកភូមិរងគ្រោះមិនបានបញ្ឈប់ការតវ៉ាជំទាស់នឹងក្រុមហ៊ុនឡើយ។ ៣ ខែក្រោយមកតំណាងអ្នកភូមិ ៦រូប បានប្រមូលស្នាមមេដៃពីប្រជាពលរដ្ឋជាង៣០០នាក់ បានចេញដំណើរជាលើកដំបូងទៅកាន់ទីស្នាក់ប្រចាំខេត្តរបស់អង្គការ សិទ្ធិមនុស្សអាដហុក ដែលនៅទីនោះស្ត្រីជាអ្នកគ្រប់គ្រងមួយរូបបានណែនាំពួកគាត់ឲ្យធ្វើបណ្ដឹង។ គាត់ក៏បានណែនាំតំណាងអ្នកភូមិឲ្យយកបណ្ដឹងនេះទៅដាក់នៅសាលាខេត្ត ហើយពួកគាត់បានទៅជួបអភិបាលខេត្ត ប៉ុន្តែមិនមានចេញជាសេចក្ដីសម្រេចអ្វីឡើយ។

កន្លះខែក្រោយមក តំណាងអ្នកភូមិបានត្រឡប់មករកអ្នកគ្រប់គ្រងអង្គការសិទ្ធិមនុស្សនេះម្ដងទៀត ហើយក៏នាំតំណាងអ្នកភូមិទៅជួបតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ស្ពឺ ដែលបានជូនដំណើរពួកគាត់តាមរថយន្តទៅកាន់រដ្ឋសភាដើម្បីដាក់ញត្តិ។ ពីរខែក្រោយមក ពួកគាត់បានទទួលទូរសព្ទពីរដ្ឋសភាប្រាប់ថា ឲ្យទៅយកលិខិតផ្លូវការមួយច្បាប់ដែលបញ្ជាក់ថា អាជ្ញាធរស្រុក និងខេត្ត ត្រូវតែប្រគល់ដីនៅតំបន់នេះឲ្យប្រជាពលរដ្ឋមូលដ្ឋានវិញ។

នៅពេលផ្ដល់ឯកសារនេះដល់តំណាងអ្នកភូមិ ស្ត្រីជាតំណាងរាស្ត្រមួយរូបក្នុងមុខតំណែងជាន់ខ្ពស់នៅរដ្ឋសភាបានប្រាប់ពួកគាត់ថាត្រូវទុកឯកសារនេះជាប់នឹងខ្លួន ក៏ប៉ុន្តែមិនត្រូវសម្ភាសជាមួយវិទ្យុអន្តរជាតិទេ។

វិវាទបានផ្ទុះម្ដងទៀតក្នុងខែកុម្ភៈ ឆ្នាំ២០១២ នៅពេលដែលក្រុមហ៊ុនបានធ្វើការឈូសឆាយម្ដងទៀតលើដីវិវាទ និងដាំដើមអាកាស្យា។ អ្នកភូមិដែលមានកំហឹងប្រដាប់ដោយកាំបិត និងពូថៅបានចូលមកកន្លែងដីវិវាទនេះជាច្រើនលើកក្នុងការប៉ុនប៉ងបញ្ឈប់សកម្មភាពរបស់ក្រុមហ៊ុន ដែលការពារដោយកងសន្តិសុខប្រដាប់អាវុធ។

នៅក្នុងជំហាននេះ តំណាងខ្លះរបស់ប្រជាពលរដ្ឋក្នុងភូមិចំនួន ៥៥៥គ្រួសារ បានយកបណ្ដឹងទៅដាក់ជូនអភិបាលខេត្ត តាមរយៈអាជ្ញាធរភូមិ ឃុំ និងស្រុក។ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ ២០១២ ក្រុមការងារចម្រុះដែលមានសមាសភាពជាមន្ត្រីឃុំ ស្រុក និងខេត្តបានចុះមកពិនិត្យមើលដីវិវាទ។

នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ សាលាខេត្តបានកោះអញ្ជើញគ្រប់ភាគីពាក់ព័ន្ធឲ្យចូលមកចរចា។ នៅថ្ងៃបន្ទាប់តំណាងអ្នកភូមិ ប្រាំមួយរូប តំណាងក្រុមហ៊ុនពីររូប មេឃុំ និង អភិបាលរងស្រុកបានមានវត្តមាននៅទីនោះ ក្នុងកិច្ចប្រជុំមួយដែលរៀបចំឡើងដោយអភិបាលរងខេត្ត។ នៅក្នុងឱកាសនោះ អភិបាលរងខេត្តបានសួរតំណាងក្រុមហ៊ុនថា តើមានឯកសារណាដែលបញ្ជាក់ថាអ្នកភូមិបានលក់ដីទៅឲ្យក្រុមហ៊ុនដែរឬទេ? ប៉ុន្តែក្រុមហ៊ុនមិនមានឯកសារបែបនេះបង្ហាញឡើយ។ កិច្ចប្រជុំក្រោយទៀតបានរៀបចំធ្វើចំនួនពីរលើកនៅសាលាស្រុក ប៉ុន្តែមិនបាន

សម្រេចកិច្ចព្រមព្រៀងណាមួយឡើយ។ នៅពេលនោះ ក្រុមហ៊ុនបានសន្យាផ្តល់ប្រាក់ចំនួន ៦២.៥០ដុល្លារក្នុងមួយហិកតា ប៉ុន្តែតំណាងអ្នកភូមិបានបដិសេធ។

កិច្ចប្រជុំលើកទីពីរនៅសាលាខេត្តបានផ្តោតលើការបែងចែកដីវិវាទសម្រាប់អ្នកភូមិ និងក្រុមហ៊ុន។ នៅក្នុងឱកាសនេះ តំណាងអ្នកភូមិបានស្នើឲ្យក្រុមហ៊ុនយកដីទំហំ១០០០ហិកតា ហើយដីនៅសល់ចំនួន១៩២៥ហិកតាសម្រាប់អ្នកភូមិ ប៉ុន្តែក្រុមហ៊ុនក៏ចង់បានទំហំដីដែលតំណាងស្នើសម្រាប់អ្នកភូមិដែរ។ ម្ល៉ោះហើយក្នុងឋានៈជាអ្នកសម្រុះសម្រួល អភិបាលរងខេត្តបានសម្រេចចិត្តថាឲ្យគ្រប់ភាគីពាក់ព័ន្ធចូលមកប្រជុំនៅលើកក្រោយ ដើម្បីដោះស្រាយវិវាទនេះ។

នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១២ នៅក្នុងកិច្ចប្រជុំចុងក្រោយនេះដែលបានរៀបចំនៅសាលាខេត្ត តំណាងអ្នកភូមិបានសម្រេចចិត្តយកដីទំហំតែ ១៥០០ហិកតាទេសម្រាប់អ្នកភូមិចំនួន ៥៥៥ គ្រួសារ ហើយដីនៅសល់ទំហំ ១៤២៥ ហិកតានឹងជារបស់ក្រុមហ៊ុន។ កិច្ចព្រមព្រៀងមួយត្រូវបានសម្រេច ដើម្បីបញ្ចប់វិវាទយ៉ាងយូរមួយរវាងក្រុមហ៊ុន និងអ្នកភូមិរងគ្រោះ។ តំណាងក្រុមហ៊ុនពីររូបជាភាគី «ក» និងតំណាងអ្នកភូមិប្រាំរូបជាភាគី «ខ» និងមេឃុំជាសាក្សីបានផ្តិតមេដៃលើឯកសារនៃកិច្ចព្រមព្រៀងនេះ។

ប៉ុន្មានថ្ងៃក្រោយមក ក្រុមការងារមកពីអាជ្ញាធរខេត្ត និងភាគីពាក់ព័ន្ធបានចុះមកតំបន់វិវាទ ដើម្បីធ្វើការបែងចែកដីជាពីរចំណែក សម្រាប់ភាគីទាំងសងខាងដូចដែលបានព្រមព្រៀងគ្នា។ ទោះជាយ៉ាងណាក៏ដោយ វាមានការពិបាកនៅក្នុងការបែងចែកដី សម្រាប់គ្រួសារនីមួយៗនៅក្នុងភូមិក៏ដូចជាការគ្រប់គ្រងនិងការពារដីនេះ ដោយហេតុថា ក្រុមហ៊ុនតែងតែគំរាមពួកគាត់យ៉ាងញឹកញាប់ ដូចជាការបំពុលទឹកដោយសារធាតុគីមី ការកម្រិតដីសម្រាប់ពួកគាត់ឃ្វាលគោក្របី ឬក៏ចោទប្រកាន់អ្នកភូមិថាបាន ដុតចំការដំណាំរបស់ក្រុមហ៊ុន។ ដូច្នោះហើយពីរសប្តាហ៍ក្រោយមក នៅក្នុងកិច្ចប្រជុំមួយ ពួកគាត់បានសម្រេចលក់ដីនេះទៅឲ្យក្រុមហ៊ុនមួយទៀត។ ជាគោលការណ៍ គ្រួសារនីមួយៗទទួលបានប្រាក់ចំនួន៣០០ដុល្លារ ប៉ុន្តែជាការពិតអ្នកភូមិខ្លះអាចទទួលបានទឹកប្រាក់តិចជាង ឬក៏ច្រើនជាងនេះ។ ជាឧទាហរណ៍តំណាងអ្នកភូមិមួយរូប ព្រមទាំង សាច់ញាតិជិតស្និទ្ធរបស់គាត់ ដែលមានក្បាលដីសរុបជាង៥០ហិកតា បានឆ្លៀលចេញពីដីសហគមន៍ ហើយបានលក់ក្រោយគេនៅក្នុងតម្លៃខ្ពស់។ ស្ត្រីមួយរូបក្នុងក្រុមពិភាក្សាបាននិយាយប្រាប់ថា៖

*«ម្នាក់ៗបាន ៣០០ដុល្លារមកវិញ មិនស្មើនឹងយកលុយពីហោប៉ៅចំណាយដើម្បីការពារដីយើងទេ។ យើងចាយតែមួយថ្ងៃអស់ហើយ។ ប៉ុន្តែដឹងធ្វើម៉េច បើសង្គមវាអញ្ចឹងទៅហើយ យើងបត់បែនទៅ ទៅតែឯង វាទៅមិនរួច។»*

គ្រួសារខ្លះបានទទួលក្បាលដីនៅជិតខាងជាថ្នូរនឹងដីដែលក្រុមហ៊ុនយក។ ស្ត្រីវ័យក្មេងមួយរូបនៅក្នុងភូមិបាននិយាយថាតំណាងក្រុមហ៊ុនបានមករកគាត់ ហើយបានប្រាប់ថាឲ្យគាត់យកសំណងជាប្រាក់ តែគាត់មិនអាចទទួលយកប្រាក់នេះបានទេ ដោយបានបញ្ជាក់បន្ថែមថា៖

*«មិនដូចគេទេ ខ្ញុំចង់បានតែដី។ ខ្ញុំមានដីតែមួយកន្លែងដែលឪម៉ែខ្ញុំចែកឲ្យធ្វើស្រែ។ អញ្ចឹងខ្ញុំប្រាប់គាត់ថា ចង់បានដីវិញ។ គាត់ បង្ហាញដីមួយកន្លែង ដីព្រៃនៅក្បែរនេះ។ ដីក្រោយនេះមិនល្អទេ ដីស្រែមុនជាដីល្អបានផលច្រើន យើងធ្វើហូបចុកគ្រប់គ្រាន់។ តែខ្ញុំយកដីល្អជាង។ ដីដូចឪនិងម៉ែ ធ្វើឲ្យយើងហូបគ្រប់គ្រាន់។ បើមិនដូរដីឲ្យវាចប់ហើយ អត់បានអីសោះ។»*

## ១១. យេនឌ័រ និង ទិដ្ឋភាពនៃកម្មសិទ្ធិដីធ្លី

ក្រោយការបង្រួបបង្រួមជាតិនៅឆ្នាំ១៩៩១ និងការបោះឆ្នោតបែបប្រជាធិបតេយ្យលើកទីមួយនៅឆ្នាំ១៩៩៣ ការចូលរួមរបស់ស្ត្រីក្នុងមុខតំណែងជាអ្នកធ្វើសេចក្តីសម្រេច មានការកើនឡើងជាលំដាប់នៅក្នុងវិស័យជាច្រើន។ ចំនួនស្ត្រីនៅរដ្ឋសភាបានបន្តកើនឡើងជាប់រហូតនៅក្នុងបួនអាណត្តិកន្លងមក គឺពី ៥% នៅឆ្នាំ១៩៩៣ ទៅ ២០.៣% នៅឆ្នាំ២០១៣ (ក្រសួងផែនការ ឆ្នាំ២០១៣)។ សមាមាត្រនៃចំនួនស្ត្រីជាសមាជិកព្រឹទ្ធសភាមិនមានការប្រែប្រួលទេ គឺមាន ១៤.៧% ចន្លោះឆ្នាំ១៩៩៩ និង២០១២ (ក្រសួងផែនការ ឆ្នាំ២០១៣)។ តែមានកំណើននៃសមាមាត្ររបស់ស្ត្រីក្នុងមុខ តំណែងជាន់ខ្ពស់នៅក្នុងរដ្ឋាភិបាល។ នៅឆ្នាំ២០១៣ បើទោះបីជាក្នុងចំណោមទេសរដ្ឋមន្ត្រីសរុបចំនួន ១៥រូបមិន មានស្ត្រីណាបានទទួលមុខតំណែងនេះយ៉ាងណាក្តី ក៏មានស្ត្រីមួយរូបដែលមានឋានៈជាឧបនាយករដ្ឋមន្ត្រីក្នុង ចំណោមឧបនាយករដ្ឋមន្ត្រីចំនួន៩រូប។ អត្រាស្ត្រីជារដ្ឋមន្ត្រីបានកើនឡើងពី ៧.១៤% (រដ្ឋមន្ត្រីជាស្ត្រីចំនួនពីររូបក្នុង ចំណោមរដ្ឋមន្ត្រីសរុប២៨រូប) ក្នុងឆ្នាំ២០០៨ ទៅ ១១% (ស្ត្រីរដ្ឋមន្ត្រីបីរូបក្នុងចំនួនរដ្ឋមន្ត្រីសរុប ២៧រូប) នៅឆ្នាំ២០១៣ (ក្រសួងកិច្ចការនារី ឆ្នាំ២០១៤) ។

នៅគ្រប់ក្រសួងមានយ៉ាងហោចណាស់ ស្ត្រីមួយរូបជារដ្ឋលេខាធិការ និងមួយរូបទៀតជាអនុរដ្ឋលេខាធិការ។ សមាមាត្រនៃស្ត្រីដែលត្រូវបានតែងតាំងជារដ្ឋលេខាធិការបានកើនឡើងពី១៦រូប (៨%) ក្នុងឆ្នាំ២០០៨ ទៅ ៣៨រូប (២០.៥%)នៅឆ្នាំ២០១៣។ ចំណែកចំនួនស្ត្រីដែលបានទទួលតំណែងជាអនុរដ្ឋលេខាធិការបានកើនពី៣៣រូប(១៥%) នៅឆ្នាំ២០០៨ទៅ ៨៨រូប (១៧.៥៨%) នៅឆ្នាំ២០១៣។ សកម្មភាពជាវិជ្ជមានក្នុងការលើកកំពស់ស្ត្រីនៅ ក្នុងមុខតំណែងរដ្ឋបាលសាធារណៈនេះ បានធ្វើឲ្យមានការប្រែប្រួល។ ជាលទ្ធផលនៃគោលការណ៍ណែនាំរបស់ រដ្ឋលេខាធិការ

ដ្ឋានមុខងារសាធារណៈនៅឆ្នាំ២០០៧ ដែលបានកំណត់ថា នៅក្នុងក្រសួងនីមួយៗត្រូវមាន ស្ត្រីចំនួនពី ២០ ទៅ ៥០% ក្នុងចំណោមស្ត្រីដែលទើបនឹងជ្រើសរើសថ្មី ដូច្នោះសមាមាត្រនៃស្ត្រីជាមន្ត្រីរាជការ បានកើនឡើងពី ៣៤% នៅ ឆ្នាំ២០០៨ ទៅ ៣៧% ក្នុងឆ្នាំ២០១៣។ ដោយឡែកនៅតុលាការក្នុងឆ្នាំ២០១០ ស្ត្រី បានតំណាងឲ្យដល់ទៅ ១៤% នៃចៅក្រម គឺមានកំណើនពី ៧.៧% ក្នុងឆ្នាំ២០០៨ (ក្រសួងផែនការឆ្នាំ២០១៣)។

នៅថ្នាក់ក្រោមជាតិមានការវិវឌ្ឍយ៉ាងខ្លាំង នៅក្នុងភាពជាតំណាងរបស់ស្ត្រីនៅកម្រិតអនុប្រធានដែលមានស្ត្រីចំនួន ១៦.៧៨% នៃអភិបាលរងខេត្ត/រាជធានី(ស្ត្រី២៨រូបនៃចំនួនសរុប១៤៣) និងជិត ២៥%នៃអភិបាលរងក្រុង/ស្រុក/ខណ្ឌ (២៣.៧៩% ឬ១៩៦រូបជាស្ត្រីក្នុងចំនួនសរុប៨២៨) (ក្រសួងកិច្ចការនារី ២០១៤)។ សមាមាត្រនៃស្ត្រី ដែលបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់មានចំនួនលើសពីពីរដងគឺពី ៨% នៅឆ្នាំ២០០២ ទៅ ១៨% នៅឆ្នាំ២០១២ (ក្រសួងកិច្ចការនារី ឆ្នាំ២០១៤)។

ក្នុងគ្រប់ករណីវិវាទស្ត្រី និងបុរសបានចេញទៅធ្វើការតវ៉ាទាមទារសិទ្ធិលើដីធ្លីរបស់ខ្លួន។ ទោះជាយ៉ាងនេះក្តី ស្ត្រីដែលចូលរួមក្នុងការដោះស្រាយវិវាទដីធ្លីហាក់ដូចជាមានចំនួនតិចជាង ដោយមកពីស្ត្រីដែលធ្វើការក្នុងជួររដ្ឋាភិបាលមានចំនួនតិចជាងបុរស ហើយយើងក៏សង្កេតឃើញថា ចំនួនស្ត្រីមានការកើនឡើងតាមរយៈការលើកកំពស់ ឬការបញ្ជ្រាបស្ត្រីនៅក្នុងគ្រប់វិស័យរបស់រដ្ឋាភិបាលផងដែរ។

នៅក្នុងគ្រប់កម្រិតនៃអាជ្ញាធរមូលដ្ឋាន ចាប់ពីថ្នាក់ស្រុករហូតថ្នាក់ភូមិ សមាមាត្រនៃអ្នកដឹកនាំស្ត្រីមានកម្រិតទាបជាង បើប្រៀបធៀបជាមួយនឹងបុរស។ នៅក្នុងស្រុកនីមួយៗនៃខេត្តទាំងបួនដែលយើងបានសិក្សាមានតែស្ត្រីមួយរូបគត់ ដែលបានបម្រើការងារក្នុងគណៈអភិបាលស្រុក និងស្ត្រីមួយរូបទៀត នៅក្នុងក្រុមប្រឹក្សាស្រុក លើកលែងនៅ ស្រុកថ្ពង ដែលសមាជិកក្រុមប្រឹក្សាស្រុកមានចំនួនបីរូប។ នៅថ្នាក់ឃុំ ក៏មានតែស្ត្រីមួយរូបក្នុងក្រុមប្រឹក្សាឃុំនីមួយៗ ដែលទទួលបន្ទុកកិច្ចការនារីនិងកុមារ។ នៅថ្នាក់ភូមិយើងក៏បានឃើញផងដែរថា មានតែស្ត្រីមួយរូបដែលជាអនុប្រធានភូមិ ឬជំនួយការភូមិ លើកលែងនៅភូមិស្រែសាក្នុងខេត្តកំពង់ឆ្នាំង ដែលស្ត្រីជាមេភូមិ។

យើងមិនបានឃើញស្ត្រីណានៅថ្នាក់ស្រុក ដែលបានចូលរួមយ៉ាងសកម្មនៅការដោះស្រាយវិវាទដីធ្លីឡើយ។ យើងសង្កេតឃើញថា មានស្ត្រីមួយរូបជាជំទប់ និងស្ត្រីមួយរូបទៀតជាមេភូមិ ដែលបានជួយអ្នកភូមិយ៉ាងសកម្មក្នុងការដោះស្រាយវិវាទ។

ទោះជាយ៉ាងណាក៏ដោយ មានស្រ្តីជាច្រើនរូបដែលបានចូលរួមយ៉ាងសកម្ម នៅក្នុងការតវ៉ាការពារដីរបស់ខ្លួន។ នៅក្នុងក្រុមពិភាក្សាក្នុងភូមិមួយ(ភូមិត្រពាំងកើញ ឃុំប្រាំបីមុម)នៃស្រុកថ្កូង អ្នកចូលរួមខ្លះបាននិយាយប្រាប់ថា ក្រុមហ៊ុនបានឈូសឆាយក្បាលដីរបស់អ្នកភូមិ ហើយអ្នកភូមិណាដែលបានឃើញហេតុការណ៍នេះមុនគេ បានទៅហៅអ្នកភូមិផ្សេងៗទៀតឲ្យមកកាន់កន្លែងដីវិវាទ គឺក៏ដើម្បីប្រមូលគ្នាតវ៉ាជំទាស់នឹងសកម្មភាពរបស់ក្រុមហ៊ុន។ ក្នុងពេលជាមួយគ្នានេះដែរ ពួកគាត់បានទៅជួបមេភូមិ ដើម្បីឲ្យគាំទ្រពួកគាត់។ មេភូមិបានឆ្លើយប្រាប់ថា ពួកគាត់ត្រូវតែតស៊ូឡើង ការពារដីរបស់ខ្លួន ពីព្រោះជាដីដែលអាជ្ញាធរមូលដ្ឋានបានចែកឲ្យ។ ស្រ្តីមួយរូបក្នុងចំណោមអ្នកចូលរួមក្នុងក្រុមពិភាក្សាបាននិយាយប្រាប់ថា៖

*«ខ្ញុំនិយាយ ខ្ញុំថាអាត្រាក់កុំអាលឈូស ដីហ្នឹងដីតំបន់ប្រាំបីមុមទេ។ តែកុងអាត្រាក់ហ្នឹងណា គាត់ថាមិនបាច់ឃាត់អត់ឲ្យអាត្រាក់ ឈូសទេ អាត្រាក់ត្រូវតែឈូស ព្រោះអាត្រាក់ទាំងអស់នេះស៊ីឈ្នួលគេ។ តែកុងនោះថា គេអត់ដឹងទេ អត់មានឈប់ទេ បើចង់ដោះស្រាយ ដោះស្រាយជាមួយឃុំ ជាមួយស្រុកទៅ។ អញ្ចឹងខ្ញុំឆ្លើយថា ឲ្យឈប់សិនទៅ តែបើអត់ឈប់ ខ្ញុំដុតអាត្រាក់ហ្នឹងចោល។ កាលហ្នឹងមានមនុស្សរាប់រយនាក់មានកាំបិត មានពូថៅ ពេញទឹកពេញដី មកតាមគោយន្ត ដឹកមីដឹកទឹកពីផ្ទះ។ ទាំងថ្ងៃត្រង់ជាក់ ពួកខ្ញុំផុងមីហូបនៅហ្នឹង តែគេឈប់ គេដឹកសម្ភារៈគេអីចេញទៅ។»*

គាត់បានបញ្ជាក់បន្ថែមថា៖
*«ឃាត់គេបានតែមួយរយៈទេ។ អាត្រាក់ចូលមកមួយសាទៀត បើប្រជាពលរដ្ឋអត់ទៅឃាត់ វាចាប់ឈូសទៀត។ អញ្ចឹងនាំគ្នា ទៅមើលដីនោះជាប់។ ដល់ពេលប្រជាពលរដ្ឋតិចមកដប់ម្ភៃម៉ូតូ ឃាត់គេអត់ស្តាប់ទេ ដល់ប្រជាពលរដ្ឋដាក់គោយន្តទៅច្រើននាក់ បានគេដកអាត្រាក់ចេញ។ នៅក្នុងភូមិ យើងក៏បានប្រមូលផ្តុំគ្នា។ មុននឹងចេញទៅឃុំ ទៅស្រុក យើងប្រជុំគ្នា មានតំណាង១៥នាក់ មេភូមិក៏តំណាងដែរ នាំគ្នាផ្តិតមេដៃតាមផ្ទះ តវ៉ាទៅទាំងអស់គ្នា។»*

ភរិយារបស់អ្នកដឹកនាំនៅខេត្តបាត់ដំបងបានចូលរួមយ៉ាងសកម្មនៅក្នុងការតវ៉ាជំទាស់ដោយសន្តិវិធី ជាពិសេសរួមជាមួយនឹងអ្នកភូមិរាប់រយនាក់ គាត់បានបង្កើតជារបាំងការពារកុំឲ្យគេចាប់ស្វាមីរបស់គាត់។ ម្ល៉ោះហើយអ្នកដឹកនាំសហគមន៍នៅបាត់ដំបងបានបង្ហាញហេតុផលថា ភរិយារបស់គាត់បានក្លាយទៅជាតំណាងមួយរូបក្នុងចំណោម តំណាងអ្នកភូមិទាំងឡាយ ក្រោយព្រឹត្តិការណ៍នៃការចាប់ខ្លួនគាត់បានកើតឡើង៖

*«ដោយសារប្រជាពលរដ្ឋមិនចេញពីកន្លែងតវ៉ាជំទាស់សោះ។ គាត់នៅតែហែ ចេះតែប្រជុំគ្នា ដេកនៅនោះតែម្តង ហើយដូរគ្នាទៀត ជួនកាលអ្នកខាងនោះមក អ្នកខាងនេះទៅជួបគ្នាតាមផ្លូវ។ កាលនោះមិនទាន់មានតំណាងអីទេ មានតែអង្គការទេ មានតែលីកាដូ មានតែអាដហុកអីហ្នឹងឯង។*

*គ្រួសារខ្ញុំជាមនុស្សទោលសុទ្ធ។ ពេលមានរឿង បឹងប្រាំមក គាត់ចេះធ្វើការជាមួយអង្គការមានសមាគមអង្គការក្រៅរដ្ឋាភិបាលច្រើនណាស់ មានគេគាំទ្រច្រើន គណៈកម្មាធិការប្រព្រឹត្តិកម្មមាន ២៣អង្គការ។ ក្នុងពេលនោះ គ្រួសារខ្ញុំក៏ចេញទៅដឹកនាំការតវ៉ាជាមួយប្រជាពលរដ្ឋដែរ។»*

យើងបានដកស្រង់ពីក្រុមពិភាក្សានៅភូមិមួយក្នុងខេត្តពោធិ៍សាត់នូវសំដីរបស់ស្ត្រីមួយរូប ដែលបង្ហាញពីការតវ៉ាជំទាស់របស់ខ្លួនទល់នឹងសកម្មភាពរបស់ក្រុមហ៊ុននៅកន្លែងដីវិវាទ៖
*«ក្នុងឆ្នាំ២០១០ ក្រុមហ៊ុនភាពីម៉ិចវាឈូសព្រៃ អត់មានប្រកាសមុនទេ។ វាឈូសដីព្រៃជុំវិញស្រែខ្ញុំបីដង ខ្ញុំដើរទៅរាំង ឃាត់បាន ខ្ញុំទៅពេលថ្ងៃតែម្នាក់ឯង។ ដល់ពេលយប់ ប្ដីខ្ញុំកាន់ពូថៅការពារដីជំនួសខ្ញុំ។»*

ស្ត្រីមួយរូបទៀតនៅក្នុងក្រុមពិភាក្សា បានរៀបរាប់ពីការចូលរួមរបស់ខ្លួននៅក្នុងការតវ៉ាទាមទារដីធ្លី៖
*«នៅឆ្នាំ២០១៤ សន្តិសុខម្នាក់វាយកកាំភ្លើងមកភ្ជង់គំរាមខ្ញុំ មិនឲ្យធ្វើលើដីខ្ញុំ តែខ្ញុំអត់ចុះចាញ់។ វាត្មះតិះដៀលខ្ញុំថាបងឯងក្បាល រឹងម្ល៉េះ។ តែខ្ញុំប្រាប់ថា ដីខ្ញុំពីដូនពីតាខ្ញុំមក ម៉េចបានថាខ្ញុំក្បាលរឹង។ វាបានយកកាំភ្លើងមកគំរាមខ្ញុំសាចុះសាឡើង កូនខ្ញុំឡើង ញ័រសាច់។ តែខ្ញុំអត់ខ្លាចទេ ពីព្រោះបើខ្លាចទាំងអស់គ្នា អត់បានតស៊ូ ម៉េចបានដី ចែកកូនទៅ បើថាខ្ញុំងាប់ទៅ ក៏នៅប្ដីខ្ញុំដែរ។»*

បុរសពោះម៉ាយរងគ្រោះម្នាក់នៅក្នុងភូមិមួយនៃខេត្តកំពង់ឆ្នាំង បានកោតសរសើរភាពក្លាហានរបស់ស្ត្រីចំណាស់មួយរូប ដែលបានតស៊ូទាមទារដីរបស់ខ្លួនរហូតទទួលបានសំណងយ៉ាងសមស្រប៖
*«គាត់អត់ខ្លាចសោះ។ គាត់លីកាំបិតច្រវេងច្រវាង គាត់មិនខ្លាចប៉េអឹម មិនឲ្យគេដកកាំបិតផង។ ពេលគេយកអាត្រាក់មក គាស់កកាយ គាត់អត់ខ្លាច។ គេមកសុទ្ធតែកាំភ្លើង យាយនោះអត់ខ្លាចកាំភ្លើងទេ អត់ខ្លាចរលីង ទាល់តែបានលុយសមរម្យ។ គាត់ចង់បានលុយអត់ខ្លាចទេ ខ្ញុំវិញ ខ្ញុំខ្លាចគេពេក ឃើញប៉េអឹមគេមានកាំភ្លើងអីមក ទាល់ តែអត់បានអីសោះ។»*

**ស្ត្រីដ៏ក្លាហានម្នាក់ក្នុងឃុំមួយនៅខេត្តពោធិ៍សាត់**

អ្នកស្រី «ក» មានអាយុ៥៩ឆ្នាំ សព្វថ្ងៃរស់នៅក្នុងឃុំមួយនៃស្រុកភ្នំក្រវាញ។ គាត់មានគ្រួសារ និងមានកូនចំនួន៦នាក់។ គាត់ បានបម្រើការជាមេឃុំក្នុងអំឡុងឆ្នាំ២០០២-២០០៧។ នៅក្នុងឆ្នាំ២០០៧ គាត់បានទិញដីទំហំ ៣០ហិកតានៅតំបន់ព្រៃមួយ ប៉ុន្តែគាត់បានដាំដំណាំដូចជា ស្រូវ ពោត ដំឡូង បានត្រឹមតែ៨ហិកតាទេ។ គាត់បានចេញមុខយ៉ាងក្លាហាន ក្នុងនាមជាស្ត្រីនៅប្រទេសកម្ពុជា ដើម្បីតស៊ូទាមទារដីរបស់ខ្លួនមកវិញ បើទោះបីជាការតស៊ូនេះប្រឈមនឹងការហាមប្រាមរបស់ស្វាមីគាត់ ដែលមិនឲ្យតវ៉ាជំទាស់នឹងក្រុមហ៊ុនក៏ដោយ ពីព្រោះស្វាមីគាត់មានការព្រួយបារម្ភខ្លាចគេចាប់រូបគាត់ដាក់ពន្ធនាគារ។ នៅក្នុងឆ្នាំ២០១០ ដីរបស់គាត់មួយចំណែកត្រូវបានឈូសឆាយដោយគ្រឿងចក្ររបស់ក្រុមហ៊ុន ។ នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន

នេះ គេកម្រនឹងរកបានស្ត្រីណាដែលមានភាពក្លាហានហ៊ានប្រឈមមុខនឹងវិវាទបែបនេះណាស់។ ចំពោះរូបគាត់វិញ គាត់ហ៊ានចេញមុខតទល់ជាមួយក្រុមហ៊ុននេះ ដោយបានប្រាប់អ្នកបញ្ជាគ្រឿងចក្រឲ្យបញ្ឈប់សកម្មភាពបែបនេះ។

ទោះជាយ៉ាងណាដោយ នេះគ្រាន់តែជាការបញ្ឈប់សកម្មភាពបណ្តោះអាសន្នប៉ុណ្ណោះ នៅឆ្នាំ ២០១២ក្រុមហ៊ុនបានចូលមក ឈូសឆាយដីរបស់គាត់ម្តងទៀត។ ពេលនោះជារដូវស្ទូងដក បុរស៦នាក់ប្រដាប់ដោយកាំភ្លើងវែងមកពីកងសន្តិសុខរបស់ ក្រុមហ៊ុនបានបង្ហាញខ្លួននៅពីមុខរូបគាត់។ បើទោះជាជួបនឹងការប្រឈមមុខដូចយ៉ាងនេះក្តី គាត់មិនមានការភ័យខ្លាចនឹងជំទាស់ជាមួយក្រុមហ៊ុនឡើយ។ គាត់បានគិតថា គាត់បានបញ្ចេញពលកម្ម ដើម្បីរានដីនេះអស់ពេលជាច្រើនឆ្នាំមកហើយ ហើយក៏រំពឹងថា នឹងបានចែកដីនេះទៅឲ្យកូនៗរបស់គាត់។ ភ្លាមនោះ គាត់បានប្រាប់ទៅពួកសន្តិសុខទាំងនោះថា ហេតុអ្វីបានជាពួកគេមកបំផ្លិចបំផ្លាញស្រូវសន្ទូងរបស់គាត់ ហើយគាត់បានដកស្រង់ប្រសាសន៍របស់សម្តេច ហ៊ុន សែន ដែលបានបញ្ជាក់ថា ដីដែលបានដំណាំហើយមិនអាចដកហូតបានទេ។ គ្រានោះ បុរសម្នាក់ក្នុងចំណោមពួកសន្តិសុខនេះបានឆ្លើយប្រាប់ថា គាត់មិនគប្បីជឿសម្តេចដែលគ្រាន់តែនិយាយនោះឡើយ។ យ៉ាងណាក៏ដោយពួកសន្តិសុខមិនបានបញ្ឈប់សកម្មភាពនៅលើដីរបស់គាត់នោះទេ។

ដោយមើលឃើញនូវទិដ្ឋភាពដូចនេះ គាត់ក៏បានចូលទៅជួបមេឃុំ និងបានទាក់ទងតាមទូរស័ព្ទជាមួយអភិបាលស្រុក ដើម្បីស្នើសុំអន្តរាគមន៍ឲ្យក្រុមហ៊ុនបញ្ឈប់សកម្មភាពរបស់ខ្លួន។ តែទោះជាយ៉ាងណាក៏ដោយមិនមានចម្លើយតបអ្វីឡើយ។ ម្ល៉ោះហើយគាត់ក៏សម្រេចចិត្តដាក់បណ្តឹងនៅសាលាខេត្ត។ ជាលទ្ធផល គណៈកម្មការមួយត្រូវបានបញ្ជូនទៅកាន់កន្លែងដីវិវាទ និងបានវាស់វែងដីចំនួន ៨ហិកតាជូនគាត់ ពីដីសរុបចំនួន ៣០ហិកតាដែលគាត់បានទាមទារ។ ដូចដែលមន្ត្រីថ្នាក់ស្រុកមួយរូប បានគូសបញ្ជាក់ គាត់បានអះអាងថាបានកាន់កាប់ដីទាំងអស់ចំនួន៣០ហិកតាមែន ប៉ុន្តែជាការពិតគាត់បានអាស្រ័យផលតែចំណែកណានៃដីនេះទេ។ បើគិតជាលក្ខណៈបច្ចេកទេស គេមិនអាចវាស់វែងដីគាត់ដែលនៅដាច់ឆ្ងាយពីគេនោះបានឡើយ ប៉ុន្តែគេបានវាស់វែងដីនេះឲ្យគាត់ ក៏ដោយសារតែការយោគយល់ពីព្រោះគាត់បានមកប្តឹងទទូចទាមទារដីញឹកញាប់ពេក។

បើទោះបីជាវិវាទដីធ្លីនេះហាក់ដូចបានបញ្ចប់ទៅយ៉ាងណាក្តី គាត់បានដាក់បណ្តឹងម្តងទៀតជូនអាជ្ញាធរខេត្ត ដើម្បីទាមទារយកដីសេសសល់ដែលក្រុមហ៊ុនបានដកហូតប្រគល់មកឲ្យគាត់វិញ។

បើតាមស្ថិតិ ការអប់រំរបស់អ្នកផ្តល់ចម្លើយប្រុស និងអ្នកផ្តល់ចម្លើយស្រី មានការខុសគ្នាច្រើន គឺបុរសមានការអប់រំ ប្រសើរជាងស្ត្រី (p=0.000) ។ គេក៏សង្កេតឃើញស្ថានភាពដូចគ្នានេះដែរ រវាងបុរសនិងស្ត្រីជាមេគ្រួសារ (p=0.010) ។ អ្នកផ្តល់ចម្លើយស្ត្រីដែលជាមេគ្រួសារ ស្គាល់អំពីទំហំដីរបស់ខ្លួនបានច្បាស់ជាងអ្នកផ្តល់ចម្លើយដែលជាភរិយា បើ ទោះបីជាស្ត្រីមិនបានទទួលផល

ប្រយោជន៍ច្រើនដូចបុរសក៏ដោយ។ នៅពេលសួរសំណួរអំពីទំហំដី ភរិយា/ស្ត្រីផ្សេង ដែលមិនមែនជាមេគ្រួសារ ពួកគាត់តែងតែប្រាប់ថាឲ្យទៅសួរប្តី ឪពុក ឬបង/ប្អូនប្រុសជានិច្ច។

ជាទូទៅ គេបានសង្កេតឃើញថា មានវិសមភាពរវាងបុរសនិងស្ត្រីនៅក្នុងលទ្ធភាពទទួលបានដី និងកម្មសិទ្ធិដីធ្លី នៅក្នុងភូមិនានាដែលបានយើងបានសិក្សា។ នៅក្នុងការសិក្សានេះ គេបានមើលឃើញយ៉ាងច្បាស់ថា មានគម្លាតផ្នែក យេនឌ័ររវាងបុរសនិងស្ត្រីដែលជាមេគ្រួសារ។ ការគ្រប់គ្រងរបស់គ្រួសារដែលមានស្ត្រីជាមេគ្រួសារលើក្បាលដីគ្រប់ប្រភេទមានចំនួនតិចជាងគ្រួសារ ដែលមានបុរសជាមេគ្រួសារ។ ម្យ៉ាងវិញទៀត យើងអាចមើលឃើញនូវទំនាក់ទំនង អវិជ្ជមានរវាងទំហំដី និងចំនួនគ្រួសារដែលមានស្ត្រីជាមេគ្រួសារ គឺដរាបណាទំហំដីដែលគ្រួសារបានទទួលកាន់តែធំដរាបនោះគ្រួសារ ដែលមានស្ត្រីជាមេគ្រួសារកាន់តែមានចំនួនតិចជាងគ្រួសារដែលមានបុរសជាមេគ្រួសារ។
ស្ត្រីជាមេគ្រួសារមានតួនាទីពីរ គឺដូចជាបុរសផង និងជាស្ត្រីផង ម្ល៉ោះហើយពួកគាត់មិនអាចទទួលបានដីច្រើនដូចជាបុរសទេ។

### តារាងទី១០: យេនឌ័រនៅក្នុងកម្មសិទ្ធិដីធ្លី ទី១ (ចំនួនក្បាលដី)

| | លំនៅដ្ឋាន | | | | ស្រែ | | | | ចំការ | | | | ដីព្រៃ | | | | ដីព្រៃសហគមន៍ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប្រុស | | ស្រី | | ប្រុស | | ស្រី | | ប្រុស | | ស្រី | | ប្រុស | | ស្រី | | ប្រុស | | ស្រី | |
| គ្មាន | 1 | 25.0% | 3 | 75.0% | 5 | 41.7% | 7 | 58.3% | 102 | 68.5% | 47 | 31.5% | 82 | 71.3% | 33 | 28.7% | 133 | 73.1% | 49 | 26.9% |
| 1->2 ក្បាលដី | 148 | 73.3% | 54 | 26.7% | 104 | 70.3% | 44 | 29.7% | 42 | 80.8% | 10 | 19.2% | 65 | 73.0% | 24 | 27.0% | 16 | 66.7% | 8 | 33.3% |
| 3 -> 5 ក្បាលដី | 0 | 0 | 0 | 0 | 33 | 84.6% | 6 | 15.4% | 5 | 100% | 0 | 0.0% | 1 | 100% | 0 | 0.0% | 0 | 0 | 0 | 0 |
| លើសពី 5 ក្បាលដី | 0 | 0 | 0 | 0 | 7 | 100% | 0 | 0.0% | 0 | 0 | 0 | 0 | 1 | 100% | 0 | 0.0% | 0 | 0 | 0 | 0 |

### តារាងទី១១: យេនឌ័រនៅក្នុងកម្មសិទ្ធិដីធ្លី ទី២ (ទំហំដី)

| | លំនៅដ្ឋាន | | | | ស្រែ | | | | ចំការ | | | | ដីព្រៃ | | | | ដីព្រៃសហគមន៍ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប្រុស | | ស្រី | | ប្រុស | | ស្រី | | ប្រុស | | ប្រុស | | ស្រី | | ប្រុស | | ស្រី | | ប្រុស | |
| គ្មាន | 1 | 25.0% | 3 | 75.0% | 4 | 33.3% | 8 | 66.7% | 102 | 68.5% | 47 | 31.5% | 82 | 71.3% | 33 | 28.7% | 133 | 73.1% | 49 | 26.9% |
| តិចជាង 1 ហិកតា | 140 | 72.2% | 54 | 27.8% | 42 | 66.7% | 21 | 33.3% | 14 | 70.0% | 6 | 30.0% | 6 | 46.2% | 7 | 53.8% | 6 | 60.0% | 4 | 40.0% |
| 1 ទៅ 5 ហិកតា | 8 | 100% | 0 | 0 | 87 | 77.0% | 26 | 23.0% | 33 | 91.7% | 3 | 8.3% | 24 | 72.7% | 9 | 27.3% | 2 | 100% | 0 | 0 |
| លើសពី 5 ហិកតា | 0 | 0 | 0 | 0 | 15 | 88.2% | 2 | 11.8% | 0 | 0 | 1 | 100% | 10 | 76.9% | 3 | 23.1% | 4 | 80.0% | 1 | 20.0% |

ម្យ៉ាងវិញទៀត វិវាទដីធ្លីបានប៉ះពាល់មកលើស្ត្រីដែលបំពេញកិច្ចការនៅក្នុងគ្រួសារក៏ដូចជានៅក្នុងសហគមន៍ផងដែរ។ ៥៦.២%នៃអ្នកផ្តល់ចម្លើយបានបញ្ជាក់ថា ស្ត្រីមានភាពតឹងតែងផ្លូវចិត្តបណ្តាលមកពីការបាត់បង់ដីធ្លី។ ការបាត់បង់ដីនេះបានជំរុញឲ្យស្ត្រីក្លាយជាអ្នកងាយរងគ្រោះពីព្រោះពួកគាត់មិនអាចផលិតស្រូវ និងដំណាំដទៃទៀត សម្រាប់ប្រើប្រាស់ក្នុងគ្រួសារបាន ក៏ដូចជាមិនអាចមានចំណូលបានមកពីការលក់ផលដំណាំ។ ពួកគាត់ត្រូវការធ្វើការឲ្យក្រុមហ៊ុន និងទទួលបានប្រាក់ឈ្នួលទាប ដែលមិនអាចផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃក្នុងគ្រួសារបាន។ ស្ត្រីមួយរូបដែលបានចូលរួមក្នុងក្រុមពិភាក្សានៅភូមិមួយ (ស្រែពពាយ) ក្នុងខេត្តពោធិ៍សាត់បានសំដែងនូវទោមនុស្សចំពោះការបាត់បង់ដី៖

*«វាប៉ះពាល់ជីវភាពយើង អត់មានដីធ្វើ អត់មានដីដាំដំណាំ ហើយមានអារម្មណ៍គិតថា អញ ស្អើយបើគេយកដីអញហើយ អត់បាយស៊ីហើយ ព្រោះដីយើងកំពុងតែធ្វើដល់ពេលគេយកទៅវិញ វាសោកស្តាយមានអារម្មណ៍អស់កម្លាំង ទាំងផ្លូវចិត្ត និងកម្លាំងធ្វើ។»*

ស្ត្រីមួយរូបក្នុងក្រុមពិភាក្សានៅភូមិមួយ(ស្រែសា)ក្នុងខេត្តកំពង់ឆ្នាំង បាននិយាយប្រាប់ថា៖

*«ខ្ញុំបាត់បង់ដីធ្លី អញ្ចឹងមានអារម្មណ៍មិននឹងនរ ព្រោះខ្លាចវាមិនបានដីមកវិញផង និងជីវភាពកាន់តែអត់ទៅផង ព្រោះរាល់ឆ្នាំទិញអង្ករចិនដាក់ខែ និងដើររកស៊ីឈ្នួលគេ ដើម្បីទិញអង្ករហូប ធ្វើឲ្យសុខភាពទ្រុឌទ្រោម និងជំពាក់លុយគេ។*

**តារាងទី១២: ផលប៉ះពាល់នៃវិវាទដីធ្លីមកលើកិច្ចការរបស់ស្ត្រីនៅក្នុងគ្រួសារនិងសហគមន៍**

| | ចំនួន | %ករណី |
|---|---|---|
| កើនភាពតានតឹងផ្លូវចិត្ត | 123 | 56.2% |
| ស្ត្រីមិនមានលទ្ធភាពទទួលបានដីដាំដំណាំ | 82 | 37.4% |
| បាត់បង់មុខរបរ | 48 | 21.9% |
| ស្ត្រីមិនមានលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ | 19 | 8.7% |
| ប្រឈមនឹងបញ្ហាសុខភាព | 19 | 8.7% |
| មិនដឹង/គ្មានចម្លើយ | 9 | 4.1% |
| បាត់បង់ឱកាសចូលរួមក្នុងការអភិវឌ្ឍសហគមន៍ | 4 | 1.8% |
| រងការប្រើអំពើហិង្សាពីស្វាមី | 1 | .5% |
| សរុប | 305 | 139.3% |

**ករណីសិក្សាទី៣: ស្ត្រីកំសត់មួយរូបនៅភូមិមួយនៃឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ**

ក្នុងវ័យ៤០ឆ្នាំប្លាយ អ្នកស្រី«ខ» មានស្វាមី និងមានកូនចំនួន៧នាក់ សព្វថ្ងៃរស់នៅជាមួយគ្រួសារគាត់ក្នុងភូមិមួយនៃស្រុកឱរ៉ាល់។ គាត់មានកំណើតនៅភូមិមួយក្នុងឃុំនេះ ហើយបានបន្តរស់នៅកន្លែងនេះដដែល ក្នុងអំឡុងសម័យ ប៉ុល ពត។ នៅ ឆ្នាំ១៩៧៩ គាត់បានប្តូរទីលំនៅទៅនៅភូមិមួយទៀត ប៉ុន្តែការប្រឈមមុខដាក់គ្នាយ៉ាងខ្លាំងក្លារវាងកងទ័ពខ្មែរក្រហម និងកងកម្លាំងរបស់រដ្ឋាភិបាលបានបង្ខំឲ្យគាត់ភៀសខ្លួនទៅរស់នៅឃុំមួយក្នុងស្រុកសំរោងទង ហើយពេលនោះគាត់បានរៀបការ ជាមួយកម្លោះមួយរូបដែលមានស្រុកកំណើតនៅទីនោះ។

គាត់បានវិលត្រឡប់មកស្រុកកំណើតរបស់គាត់វិញនៅឆ្នាំ២០០០ ហើយក៏បានរានព្រៃសម្រាប់យកដីសង់លំនៅដ្ឋាន ដែល មានទំហំ១០០មx១៦០ម។ នៅឆ្នាំ២០០១ ដូចជាប្រជាពលរដ្ឋក្នុងភូមិដែរ គាត់និងគ្រួសារបានសម្រេចចិត្តរានព្រៃ ដែលធ្លាប់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមខ្មែរក្រហម រហូតមកដល់ពេលសមាហរណកម្មក្នុងឆ្នាំ១៩៩៧។ ពេលនោះគាត់បាន ដាំដំណាំចំនួន ៣ហិកតា (ក្នុងទំហំដីដែលគាត់កាន់កាប់ចំនួន៥ហិកតា) ហើយផលដំណាំទាំងនេះជាប្រភពចំណូលយ៉ាងសំខាន់ក្នុងគ្រួសារ។

នៅឆ្នាំ២០១១ ដោយមិនបានផ្តល់ដំណឹងជាមុនដល់ប្រជាពលរដ្ឋមូលដ្ឋាន ក្រុមហ៊ុនបានឈូសឆាយដីតំបន់នេះ សម្រាប់សម្បទានដីសេដ្ឋកិច្ច ដែលបង្កឲ្យមានផលប៉ះពាល់មកលើអ្នកភូមិដែលមានក្បាលដីនៅទីនោះ។ ដូចជាអ្នកកាប់កាប់ដីដំបូងដទៃទៀតដែរ គាត់ និងគ្រួសារបានធ្វើដំណើរមកចំការរបស់គាត់ នៅក្នុងការប៉ុនប៉ងបញ្ឈប់សកម្មភាពរបស់ក្រុមហ៊ុន ប៉ុន្តែជាលទ្ធផលគាត់អាចបញ្ឈប់សកម្មភាពនេះបានត្រឹមតែមួយរយៈប៉ុណ្ណោះ។

នៅខែកុម្ភៈ ឆ្នាំ២០១២ ស្ត្រីមួយរូបបម្រើការក្នុងក្រុមប្រឹក្សាឃុំបានមកកាន់កន្លែងកើតហេតុនោះដើម្បីវាស់វែងដីវិវាទ ហើយបន្ទាប់មកគាត់បានកោះអញ្ជើញគ្រួសារពាក់ព័ន្ធទាំងអស់ឲ្យចូលរួមក្នុងកិច្ចប្រជុំមួយនៅសាលាឃុំ។ នៅក្នុងឱកាសនោះ មានអ្នកភូមិជាច្រើននាក់បានមកប្រជុំ ហើយស្ត្រីជាតំណាងក្រុមហ៊ុនមួយរូបបានប្រាប់អ្នកភូមិថា៖

*«អ្នកឯងទៅលួចដីរដ្ឋធ្វើ ជាដីសម្បទានរបស់រដ្ឋ។ ឥឡូវខ្ញុំឲ្យ១ហិកតា២០០ដុល្លារ ដីមានដំណាំ។ បើយកលុយ ក៏យកទៅ បើមិនយក អត់ហើយ។»*

ជាលទ្ធផល អ្នកភូមិរងគ្រោះស្ទើរតែទាំងអស់បានយល់ព្រមទទួលយកសំណងបែបនេះ លើកលែងតែប្អូនគ្រួសាររួមទាំងគ្រួសារគាត់ផង។ ពួកគាត់បាននាំគ្នាមកសាលាស្រុក ដើម្បីធ្វើការតវ៉ាជំទាស់ ប៉ុន្តែកិច្ចចរចារវាងគ្រួសារគាត់ និងតំណាង ក្រុមហ៊ុនហាក់ដូចជាមិនចេញជាលទ្ធផលអ្វីឡើយ។ គាត់បានបញ្ជាក់ដូច្នេះ៖

*«សម័យប៉ុល ពត គេសម្លាប់មនុស្សស្រស់ៗ តែសម័យសង្គមនេះ មិនសម្លាប់ទាំងរស់ទេ គេធ្វើ*

*ឲ្យងាប់បន្តិចម្តងៗ មកពីបាត់បង់ដី។ ខ្ញុំថា ខ្ញុំមានដីតែប៉ុណ្ណឹង ខ្ញុំមានដីឯណាចិញ្ចឹមកូនចៅរបស់ខ្ញុំ។ ចិត្តខ្ញុំ ខ្ញុំមិនចង់បានអីទេ ចង់តែបានដីមកវិញ។ កាលណាខ្ញុំដើរកាត់ឃើញដីខ្ញុំ ខ្ញុំនឹកឃើញស្តាយដីខ្ញុំ ដំណាំខ្ញុំ។ បើដីខ្ញុំនៅ ខ្ញុំចែកកូនខ្ញុំបាន។»*

រំលងពីរខែមក ស្ត្រីមកពីក្រុមប្រឹក្សាឃុំបានចូលមកផ្ទះគាត់ និងបានយកលុយចំនួន១០០០ ដុល្លារមកដាក់លើគ្រែគាត់ តែមិនមានឯកសារអ្វីសម្រាប់ឲ្យគាត់ផ្តិតមេដៃឡើយ ព្រមទាំងបានប្រាប់គាត់ថា ឲ្យយកទឹកប្រាក់នេះទៅ ពីព្រោះមិនមានអីដោះស្រាយក្រៅពីនេះទៀតទេ បើគាត់មិនយកទេ មានតែអត់ប៉ុណ្ណឹង។

ជាលទ្ធផល ក្រុមគ្រួសារគាត់បានក្លាយជាអ្នកគ្មានដីធ្លី។ ភាពក្រីក្រក្នុងរង្វង់គ្រួសារបានជំរុញឲ្យពួកគាត់ទៅស៊ីឈ្នួលគេ។ ពួកគាត់មានបញ្ហាសុខភាពទ្រុឌទ្រោម ហើយកូនៗរបស់គាត់បានបោះបង់ការសិក្សា។

## ១២. ផលប៉ះពាល់វិវាទដីធ្លី

នៅក្នុងផ្នែកនេះ គេព្យាយាមពិនិត្យលើផលប៉ះពាល់វិវាទដីធ្លីមកលើតំបន់គោលដៅភាគច្រើន ជាការប៉ះពាល់ដែលបណ្តាលមកពីដំណើរការដោះស្រាយវិវាទមកលើអ្នកភូមិ សហគមន៍ និងស្ថាប័នពាក់ព័ន្ធនានា។ បើទោះបីជាមន្ត្រីមូលដ្ឋានបានបញ្ជាក់ថា លទ្ធផលនៃដំណោះស្រាយវិវាទដីធ្លីបង្កនូវផលប៉ះពាល់តិចតួចមកលើការចិញ្ចឹម ជីវិតរបស់ប្រជាពលរដ្ឋ និងសហគមន៍ទាំងមូលយ៉ាងណាក៏ដោយ អ្នកភូមិបានបង្ហាញហេតុផលថា ការដោះស្រាយវិវាទនេះ មានការប៉ះពាល់យ៉ាងខ្លាំងមកលើជីវភាពប្រចាំថ្ងៃ និងអនាគតកូនរបស់ពួកគាត់(សូមមើល តារាងទី១៣)។ ផលប៉ះពាល់មានការប្រែប្រួលទៅតាមទីតាំងភូមិសាស្ត្រ ចរឹកលក្ខណៈនៃវិវាទ ប្រជាពលរដ្ឋពាក់ព័ន្ធ ហើយនឹងលទ្ធផលនៃដំណោះស្រាយវិវាទផងដែរ។

គោលបំណងជាក់លាក់នៃសម្បទានដីសេដ្ឋកិច្ច គឺអភិវឌ្ឍសកម្មភាពផ្នែកកសិកម្មបែបប្រពលវប្បកម្ម និងកសិ-ឧស្សាហកម្ម។ គឺមានទិសដៅបង្កើតថវិកាជាតិ ឬថ្នាក់ខេត្ត តាមរយៈការបង់ពន្ធដី និងការបង្កើនការងារនៅតំបន់ជនបទ ដើម្បីកាត់បន្ថយភាពក្រីក្រ។ ពិតមែនហើយដែលថា ក្រុមហ៊ុនបានផ្តល់ឱកាសឲ្យអ្នកភូមិមានការងារធ្វើ តែទោះជាយ៉ាងនេះក្តី ឱកាសការងារនេះមានតាមរដូវកាល ប៉ុន្តែមិនមែនជាការងារក្នុងរយៈពេលយូរអង្វែង និងមាន កិច្ចសន្យានោះឡើយ។ ប្រាក់ឈ្នួលក្នុង១ថ្ងៃសម្រាប់កម្មករម្នាក់ៗមានចំនួនប្រមាណ ១៤០០០រៀល ឬស្មើនឹង៣.៥០ដុល្លារ។

**រូបទី៥: ចាប់ពីពេលចាប់ផ្តើមមានវិវាទ តើអ្នកគ្មិនអាចដាំដំណាំលើដីវិវាទបានឬទេ?**




ក្នុងខេត្តគោលដៅទាំងបួន ប្រជាពលរដ្ឋមូលដ្ឋានបានដឹង និងបានឃើញយ៉ាងជាក់ស្តែងនូវផលប៉ះពាល់អវិជ្ជមានបណ្តាលមកពីវិវាទដីធ្លី។ ជាលទ្ធផលនៃការបាត់បង់ដីដាំដំណាំ និងដីសម្រាប់ឃ្វាលគោក្របី និងមិនមានលទ្ធភាពប្រើប្រាស់ធនធានព្រៃឈើ ប្រជាពលរដ្ឋរងគ្រោះបានទៅជាស្ថិតក្នុងស្ថានភាពមិននឹងនរ ហើយប្រឈមនឹងអសន្តិសុខស្បៀងទៀតផង។ គ្រួសាររងគ្រោះយ៉ាងច្រើនបានឲ្យកូនឈប់រៀន ដើម្បីធ្វើចំណាកស្រុកទៅរកការងារធ្វើ ហើយក៏មានគ្រួសារជាច្រើនដែលមិនមានជម្រើសអ្វីក្រៅពីធ្វើការឲ្យក្រុមហ៊ុន ហើយមានមនុស្សជាច្រើននាក់បានយកជម្រើសចុងក្រោយនេះសម្រាប់ការចិញ្ចឹមជីវិតរបស់ខ្លួន ចាប់តាំងពីពេលបាត់បង់ធនធានផលិតកម្មនោះមក។

ដូចដែលបានបញ្ជាក់នៅខាងលើ ករណីវិវាទជាច្រើនមិនត្រូវបានដោះស្រាយនៅឡើយ ហើយប្រជាពលរដ្ឋមូលដ្ឋានបានលើកឡើងពីកង្វល់របស់ខ្លួនពាក់ព័ន្ធនឹងដីកសិកម្ម។ នេះមានន័យថាដីរបស់ពួកគាត់ដែលមានវិវាទមិនត្រូវបាន គេធានាថា អាចឲ្យពួកគាត់បន្តប្រើប្រាស់បានសម្រាប់ការដាំដុះដំណាំទៀតឡើយ។ ៨២% នៃអ្នកផ្តល់ចម្លើយបានប្រាប់ថា ចាប់តាំងពីពេលចាប់ផ្តើមវិវាទនោះមក ពួកគាត់មិនអាចធ្វើសកម្មភាពដាំដុះដំណាំបានទៀតទេ ហើយ ៧៣.៣% ប្រាប់ថាមិនអាចមានលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិក្នុងដីវិវាទបាន។

**រូបទី៦: ប្រាក់ចំណូលប្រែប្រួល ក្រោយពេលចាប់ផ្តើមវិវាទ**




មន្ត្រីមូលដ្ឋានមួយរូប (អភិបាលរងស្រុកថ្គង) នៅខេត្តកំពង់ស្ពឺ បានបង្ហាញអំពីផលប៉ះពាល់នៃវិវាទដីធ្លីមកលើប្រជាពលរដ្ឋមូលដ្ឋាន៖

*«ធម្មតាការដោះស្រាយបញ្ហាវិវាទនីមួយៗមិនមែនប្រើពេលតែមួយថ្ងៃពីរថ្ងៃចប់ទេ វាត្រូវការពេលច្រើន។ ត្រូវការស្រាវជ្រាវ ត្រូវការបង្កើតគណៈកម្មការ ត្រូវការអ្វីសព្វបែបយ៉ាង។ អញ្ចឹងគាត់ (ប្រជាពលរដ្ឋ) ខាតពេលរវល់តែរឿងដី អត់សូវបានរកស៊ីទេ។ ជួនកាលពេលដែលគាត់ដោះស្រាយដីហ្នឹងបានហើយ គាត់លក់ដីអីអញ្ចឹង អាហ្នឹងគាត់អាច ខូះដីធ្វើស្រែ ដែលជាចំណូលយ៉ាងសំខាន់។ អាហ្នឹងជាផលប៉ះពាល់ ជាពិសេសអ្នកដែលមានដីតែមួយកន្លែង ហើយមានកូនច្រើន។»*

អតីតមន្ត្រីមូលដ្ឋាននៅក្នុងភូមិមួយ(ត្រពាំងគង)នៃខេត្តកំពង់ស្ពឺបានបញ្ជាក់ប្រាប់ថា គាត់មានការអាក់អន់ចិត្តនឹង ការបាត់បង់ដីដែលប៉ះពាល់ដល់ការចិញ្ចឹមជីវិតរបស់គាត់និងអ្នកភូមិដទៃទៀតនោះ៖

*«នឹកឃើញថា ទោះបីជាយើងមកពីជំរំក៏ដោយ ក៏គ្រាន់បើដែរ ក្នុងមួយជីវិតនេះបើបានដីប៉ុណ្ណឹងក៏អាចចែកកូន ចែកចៅបានហើយ តែឥឡូវនេះមិនមានសង្ឃឹមទេ។ ខ្ញុំនឹកឃើញពេលជួលគេកាប់ព្រៃ យកលុយទៅលើកភ្លឺស្រែ លើកជុំវិញទាំងអស់។ មានគ្រួសារ មួយនោះមិនមានស្រែងណាមានតែចំការចេកផ្គត់ផ្គង់គ្រួសារ ។ ឥឡូវទៅថៃ វេទនាណាស់ព្រោះអត់មានដី។»*

## តារាងទី១៣: ផលប៉ះពាល់មកពីការបាត់បង់ដីធ្លី

| ផលប៉ះពាល់នៃការបាត់បង់ដីធ្លី | ពិតមែន | | ទេ | |
|---|---|---|---|---|
| | ចំនួន | % | ចំនួន | % |
| ក្រោយពេលវិវាទចាប់ផ្ដើម តើអ្នកអាចដាំដំណាំលើដីវិវាទបានឬទេ? | 68 | 17.8 | 314 | 82.2 |
| ក្រោយពេលវិវាទចាប់ផ្ដើម តើអ្នកអាចប្រើប្រាស់ធនធានធម្មជាតិនៅដីវិវាទបានឬទេ? | 102 | 26.7 | 280 | 73.3 |
| ក្រោយពេលវិវាទចាប់ផ្ដើម តើអ្នកមានប្រាក់គ្រប់គ្រាន់សម្រាប់ប្រកបមុខរបរចិញ្ចឹមជីវិតឬទេ? | 97 | 25.4 | 285 | 74.6 |
| ក្រោយពេលវិវាទចាប់ផ្ដើម តើគ្រួសារអ្នកមានចំណូលគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការមូលដ្ឋាននៃការចិញ្ចឹមជីវិតក្នុងពេល១ឆ្នាំឬទេ? | 93 | 24.3 | 289 | 75.7 |
| ក្រោយពេលវិវាទចាប់ផ្ដើម តើអ្នកភូមិ និងគ្រួសារអ្នកអាចប្រើប្រាស់ផ្លូវទីផ្សារ និងសេវា និងមធ្យោបាយដទៃទៀតបានឬទេ? | 208 | 54.5 | 174 | 45.5 |

វិវាទដីធ្លីបានប៉ះពាល់ចំណូលរបស់អ្នកភូមិ។ ៥៥.៨% នៃអ្នកផ្ដល់ចម្លើយបានប្រាប់ថា ចំណូលក្នុងគ្រួសាររបស់គាត់ជួបប្រទះនឹងស្ថានភាពមិនល្អ បើប្រៀបធៀបនឹងពេលមុន។ ៧៥.៧% នៃអ្នកផ្ដល់ចម្លើយបានបញ្ជាក់ថា គ្រួសាររបស់ខ្លួនមិនមានប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការមូលដ្ឋាន នៃការចិញ្ចឹមជីវិតសម្រាប់ រយៈពេលមួយឆ្នាំឡើយ។ ៧៤.៦% បានប្រាប់ថាពួកគាត់ខ្វះប្រាក់សម្រាប់ប្រកបមុខរបរចិញ្ចឹមជីវិត។ អ្នកភូមិដែលមិនមានលទ្ធភាពទទួលបានដីដាំដំណាំ(៦៣.៨%)និងអ្នកដែលមិនមានលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ (៣៣.៨%) ជាមូលហេតុសំខាន់នាំឲ្យចំណូលក្នុងគ្រួសាររបស់អ្នកភូមិធ្លាក់ចុះ។ អ្នកភូមិម្នាក់ (ត្រពាំងគង) នៃឃុំសង្កែសាទប បាននិយាយប្រាប់យើងអំពីផលប៉ះពាល់នៃការបាត់បង់ដីមកលើការចិញ្ចឹមជីវិតរបស់គ្រួសារគាត់៖

*«ផ្ដល់សំណងប៉ុណ្ណឹងអត់សមកម្លាំងញើសឈាមខ្ញុំទេ។ ការដែលគេយកដីខ្ញុំមានផលប៉ះពាល់ហើយ ព្រោះកន្លែងហូបចុករបស់ គ្រួសារខ្ញុំនៅកន្លែងហ្នឹងហើយ ចំការខ្ញុំមានដាំដូចជាស្រូវ ចេក និងស្វាយ។ ខ្ញុំទើបតែមករស់នៅកន្លែងនេះ ពឹងលើដីតែប៉ុណ្ណឹង ដល់ពេលឥឡូវគ្រួសារខ្ញុំវាដុនដាបណាស់ អត់មានអីទេ។ អញ្ចឹងទៅធ្វើការឲ្យក្រុមហ៊ុនបានលុយបន្តិចបន្តួច ពេលណាគេត្រូវការយើង។ បើអត់ហើយចេះតែធ្វើទៅ។»*

៤៥%នៃអ្នកចម្លើយបានប្រាប់ថា ពួកគាត់មិនអាចធ្វើដំណើរឆ្លងកាត់ដីវិវាទបានទេ ពីព្រោះក្រុមហ៊ុនបានធ្វើរបងបិទផ្លូវ។ អ្នកភូមិក៏អាចលែងគោក្របីរបស់គាត់ដោយសេរីបានដូចមុនទៀត

ឡើយ។ អាចារ្យមួយរូបនៅវត្តមួយ (ក្នុងភូមិ ត្រពាំងក្រើញ) នៃឃុំប្រាំបីមុមបានសំអាងថាមានផលប៉ះពាល់បរិស្ថាន៖

*«ពីមុនយើងមិនខ្វល់ពីគោក្របីទេ។ នៅស្រុកហ្នឹង គេលែងគោក្របីចោលជិតមួយឆ្នាំ។ ហើយឥឡូវហ្នឹង វាអស់កន្លែងគោ ក្របីស៊ី ស្មៅហើយ បើគេ(ក្រុមហ៊ុន)សុទ្ធតែធ្វើរបងព័ទ្ធអស់ហើយ។ អស់ដី អស់ព្រៃ ក៏អស់ទីជម្រកសត្វព្រៃ ប៉ះពាល់លើសុខភាពមនុស្ស ទៅជាមានខ្យល់ព្យុះ ហើយអាកាសធាតុកាន់តែក្តៅឡើងៗ។»*

ស្ត្រីមួយរូបមកពីភូមិមួយក្នុងឃុំប្រាំបីមុមបាននិយាយថា គាត់ត្រូវគេបង្ខំឲ្យឈប់តវ៉ា ហើយប្រគល់ដីទៅឲ្យក្រុមហ៊ុន ពីព្រោះដីក្រុមហ៊ុនហ៊ុមព័ទ្ធដីរបស់គាត់អស់ ហើយគេបិទផ្លូវថែមទៀតដែលមិនអាចឲ្យគាត់ធ្វើដំណើរឆ្លងកាត់តាមនេះទៅដីគាត់បាន៖

*«ខ្ញុំត្រូវតែឲ្យដីទៅក្រុមហ៊ុន ហើយយកសំណងមក។ បើមិនអញ្ចឹង ដូចតំណាងក្រុមហ៊ុនប្រាប់ខ្ញុំថា លុះត្រាតែខ្ញុំមានអាកន្ទុំរុយចុះ ទៅបានទៅដល់ដីហ្នឹងបាន។»*

ជាការពិតដែលថា ចាប់ពីពេលដែលវិវាទបានចាប់ផ្តើម ប្រជាពលរដ្ឋមិនមានលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិបាន។ ៧៣.៣% នៃអ្នកផ្តល់ចម្លើយបានប្រាប់ថា ពួកគាត់លែងមានលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិនៅដីដែលកើតមានវិវាទ។ មន្ត្រីមូលដ្ឋានមួយរូប(មេឃុំប្រាំបីមុម)បានបង្ហាញហេតុផលថា សំណងជាប្រាក់មានចំនួនតិចតួច ដោយបានបញ្ជាក់ផលប៉ះពាល់មកលើការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ ដែលអាស្រ័យលើការចិញ្ចឹមសត្វ និងការប្រមូលអនុផលព្រៃឈើ៖

*«បើនិយាយពីកម្រៃឬតម្លៃ (សំណង) វិញ វាតិចតួចណាស់។ វាពិតប្រាកដហើយ ទីមួយប៉ះពាល់ជីវភាពរស់នៅរបស់ ប្រជាពលរដ្ឋ ទីពីរប៉ះពាល់ព្រៃដែលគាត់ត្រូវការរកឧសរកអី និងសត្វគោក្របីពីដើមឃ្វាលសេរី ឥឡូវទាល់តែឃ្វាល តែប៉ះពាល់ដំណាំគេ គេចាប់ យកលុយ។»*

ចាស់ព្រឹទ្ធាចារ្យមួយរូបនៅភូមិគោកបានសំដែងនូវការខកចិត្តនឹងសំណង ដែលគាត់បានទទួលមានចំនួនតិចតួច ហើយបានបញ្ជាក់បន្ថែមថា៖

*«បាត់បង់ដីធ្លីវាប៉ះពាល់ផ្លូវចិត្ត គិតវាមិនលេចថា មិនដឹងគិតអី។ ខ្ញុំសព្វថ្ងៃទៅវត្តអីងណោះ ដូចជាគ្មានសង្ឃឹមការងារដើរអី មិនបាន ធ្វើអីសោះ។ ពីដើមវាមានដីមានធ្លី ចេះតែធ្វើទៅ ហើយឥឡូវវាគ្មានបានអីធ្វើ តែលតោល បើទៅស៊ីឈ្នួលគេ ក៏គេមិនយក ចាស់ប៉ុណ្ណេះហើយ។ ម្យ៉ាងវាខ្វល់ចិត្តព្រោះសង្គមជាតិយើងមានធម្មជាតិហ្នឹង ដើម្បីឲ្យបានទឹក ដើមឈើនៅទប់ទឹកអី មានធ្លាក់ភ្លៀងតែសព្វថ្ងៃវាអស់ហើយ អស់ទាំងវាលស្រូវ វាមិនដឹងមានអីទប់ អស់រលើងហើយ។»*

វិវាទដីធ្លីក៏ប៉ះពាល់ដល់ការអប់រំរបស់កុមារផងដែរ។ ១៩.១%នៃអ្នកភូមិបានបញ្ជាក់ថា កុមារមិនអាចទៅរៀនបាន មកពីពួកគេត្រូវជួយឪពុកម្តាយស្វែងរកចំណូល ឬក៏ត្រូវជួយមើលថែប្អូនៗ។ ស្ត្រីមួយរូបដែលតំណាងអង្គការមិនមែនរដ្ឋាភិបាលមូលដ្ឋាន (អ្នកសម្របសម្រួលសហគមន៍របស់អង្គការជីវិតថ្លៃថ្នូរ ប្រចាំឃុំប្រាំបីមុម) បានប្រាប់ ថា៖
*«នៅពេលបាត់ដី គាត់ត្រូវចំណាកស្រុក អញ្ចឹងប៉ះពាល់ដល់កូនៗ អត់បានរៀនសូត្រទេ គឺត្រូវទៅតាមឪពុកម្តាយ ឬមានកូន កំពុងរៀនយកទៅឲ្យមើលប្អូន។ គឺទាំងនេះហើយដែលនាំឲ្យកូនគាត់មិនបានទៅរៀន ឬក៏លែងមករៀន។ មួយវិញទៀត គាត់ទៅ ឆ្ងាយ គាត់អាចប្រឈមនឹងជម្ងឺនិងបញ្ហាសុខភាពច្រើន។»*

ស្ត្រីមេម៉ាយម្នាក់នៅភូមិមួយ (ត្រពាំងក្រើញ) ក្នុងស្រុកថ្ពង បានរៀបរាប់អំពីផលប៉ះពាល់ដែលបណ្តាលមកពីលទ្ធផលនៃការដោះស្រាយវិវាទដីធ្លី៖
*«មុននេះ ខ្ញុំបានដីមួយកន្លែងនៅដីជម្លោះនេះ គ្រួសារខ្ញុំក៏បានដាំដំណាំ។ ពេលជម្លោះដីចប់ទៅ ខ្ញុំបានទទួលលុយ តែលុយនេះ យកទៅទិញដីស្រែក៏វាមិនគ្រប់ដែរ។ នៅពេលនោះ ខ្ញុំនិងប្តីខ្ញុំបាននាំគ្នាទៅធ្វើការនៅចំការអំពៅ។ គេឲ្យថ្លៃឈ្នួលតិចពេក មិនអាច ចិញ្ចឹមគ្រួសារបានទេ។ ក្រោយមកប្តីខ្ញុំចេញពីផ្ទះទៅជាយដែន ហើយនៅជាមួយស្រី នៅប៉ៃលិនរហូតមក។ កូនស្រីពៅខ្ញុំ ក៏ឈប់ រៀនទៀត មកពីអត់មានកង់ជិះទៅរៀននឹងគេ។ សព្វថ្ងៃ កូនខ្ញុំបួននាក់ ចេញអស់ហើយ បីនាក់ទៅធ្វើការនៅរោងចក្រស្បែកជើង នៅភ្នំពេញ។ ខ្ញុំឥឡូវនៅផ្ទះ មើលតែចៅបួននាក់ហ្នឹង។»*

ចាស់ព្រឹទ្ធាចារ្យពោះម៉ាយមួយរូប នៅភូមិមួយ(ស្រែសា)ក្នុងស្រុកសាមគ្គីមានជ័យបានរៀបរាប់អំពីជីវភាពយ៉ាងលំបាករបស់ខ្លួនដែលជាលទ្ធផលនៃវិវាទដីធ្លី៖
*«បើកាលណាអត់ដីវាវេទនាណាស់ សព្វថ្ងៃហ្នឹងខ្ញុំផ្ទាល់ដាច់បាយហើយ។ ពេលដែលយើងធ្វើ (ស្រែ) គេមកឃាត់យើង ដល់ពេលគេ អត់មកឃាត់ ធ្វើបានស្រូវក្របីមកស៊ីអស់ ព្រោះខ្ញុំរវល់មកវត្ត។ ម្យ៉ាងទៀតវាប៉ះពាល់តាំងពីកូនរៀន ខ្ញុំមានកូន៣នាក់មិនបានរៀន សូត្រទេ ពីព្រោះខ្ញុំនៅនឹងព្រៃ តែសាលារៀននៅឆ្ងាយ វាមានចំងាយប្រហែល១០គីឡូម៉ែត្រ ហើយកូនវាខ្វះទាំងសំលៀកបំពាក់ទៀតផង។ ពេលណាខ្ញុំទៅធ្វើការទាល់តែផ្ញើកូននឹងគេ សព្វថ្ងៃនេះ ជីវភាពខ្ញុំកាន់តែធ្លាក់ចុះមែនទែនហើយ។»*

តំណាងអ្នកភូមិមួយរូបនៅភូមិមួយ (ច្រកកូវ) ក្នុងខេត្តកំពង់ឆ្នាំង បង្ហាញនូវកង្វល់ពាក់ព័ន្ធនឹងការបាត់បង់ដីធ្លី៖

*«មានទាំងផ្លូវចិត្ត និងផ្លូវកាយ យើងខ្វល់ខ្វាយធ្វើការងារហ្នឹងមិននៅមួយកន្លែងទេ ដោយសារបញ្ហាជីវភាពនេះ។ ចំពោះផ្លូវចិត្តគឺ មានការតូចចិត្តត្រង់ថាយើងជាប្រជាពលរដ្ឋនឹងគេដែរត្រូវគេដកដីពីយើងយកទៅឲ្យអ្នកដទៃដែលមិនសក្តិសម។ និន្នាការនយោបាយ អត់ត្រូវទេ ព្រោះសេរីពហុបក្ស។ ប្រពន្ធខ្ញុំតាំងពីរឿងដីហ្នឹង មកគាត់ឈឺដល់សព្វថ្ងៃ ។ បើយើងបាត់បង់ដីធ្លីបាត់បង់អនាគត វាក្លាយ ខ្លួនជាអន្តោប្រវេសន៍នៅលើដីរបស់ខ្លួន ហើយកូនបាត់បង់ការសិក្សា ដោយគ្មានទីកន្លែងពិតប្រាកដ។»*

ស្ត្រីមួយរូបជាតំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក (ថ្នាក់ឃុំ) បានបញ្ជាក់ថា៖
*«មកពីអត់មានដីបង្កបង្កើនផល គាត់ត្រូវលក់កម្លាំង យកលុយទៅទិញអង្ករហូបវិញទៅ។ អ្នកខ្លះទៅជាជំពាក់គេ អស់នេះ អស់នោះ។ តែកន្លងមកខ្ញុំបានឮថា ការបាត់បង់ដីនេះបានប៉ះពាល់ផ្លូវចិត្ត គាត់គិតតែពីផឹក រកអីអត់បានទៅជាអំពើហិង្សាកើតឡើងក៏មានដែរ។»*

មន្ត្រីមូលដ្ឋានមួយរូប (មេភូមិស្រែសា) នៅខេត្តកំពង់ឆ្នាំងបានរៀបរាប់អំពីជីវភាពរបស់អ្នកភូមិរងគ្រោះ៖
*«គាត់មានដី គាត់មានសង្ឃឹមដីថាពីមួយឆ្នាំទៅមួយឆ្នាំជីវភាពគាត់ធូរធារ ។ ដល់ឥឡូវគាត់បាត់បង់ដីទៅ គាត់គ្មានអារម្មណ៍គ្មានទឹក ចិត្តធ្វើអី គាត់អស់សង្ឃឹម អត់មានអីទីពឹង មិនដឹងពឹងអី ពឹងប្តឹងទាមទារចង់បាន បែរជាមិនបាន។ជីវភាពគាត់ចេះតែក្រទៅៗ គាត់ ចាប់ផ្តើមខ្ចីលុយធនាគារ ជំពាក់គេ។ គាត់ធ្វើចំណាកស្រុកទៅរកស៊ីស្រុកឆ្ងាយ រហូតដល់ថៃ ខ្លះទៅម៉ាឡេ ដោយសារតែអត់ដីធ្វើស្រែហ្នឹង។»*

ស្ត្រីបែកស្វាមីមួយរូបដែលបានចូលរួមក្នុងក្រុមពិភាក្សានៅខេត្តបាត់ដំបងបាននិយាយប្រាប់អំពីជីវភាពយ៉ាងលំបាករបស់គាត់បណ្តាលមកពីការគ្មានដីធ្លីធ្វើ៖
*«យើងអត់មានដីធ្វើស្រែ យើងត្រូវចេញទៅចំណាកស្រុក។ ដូចកន្លងមក ប្តីខ្ញុំចេញទៅប្រទេសថៃគេមានស្រី មានញី រហូតដល់ សព្វថ្ងៃ។ កូនខ្ញុំដើរចំណាកស្រុក វាគ្រប់ខែ មណ្ឌលសុខភាពក៏អត់មិនដឹងទៅណារួច កើតតាមធម្មតានឹងឆ្មបបុរាណ រហូតដល់ បាត់បង់ជីវិត។ អារម្មណ៍ខ្ញុំរាល់ថ្ងៃអត់ពេក សព្វថ្ងៃពិបាកណាស់ ចង់កើតសរសៃប្រសាទហើយ ណាគិតទៅប្តី ណាគិតទៅកូនរៀនអត់លុយអី អត់បានរៀនទេ។ មួយទៀតចេះទៅស្រុកគេអញ្ចឹង ម៉ែឪចេញអស់ទៅយកកូនទៅផ្ញើនឹងម្តាយនៅពោធិ៍សាត់។»*

ស្ត្រីមេម៉ាយម្នាក់នៅភូមិមួយ(ក្បេក្រពុរី)ក្នុងខេត្តពោធិ៍សាត់បាននិយាយប្រាប់អំពី ផលប៉ះពាល់នៃការបាត់បង់ដីធ្លីមក លើគ្រួសាររបស់គាត់៖

*« បានអីទៀត បានស្រែពីណាអាស្រ័យផលហូបទៀត អត់ដីចំការ។ ជីវភាពខ្វះខាត ទាំងសព្វទាំងគ្រប់ ទាំងលុយកាក់ អស់ដីអស់ធ្លី ទាំងលុយ។ ប៉ះពាល់អនាគតកូនចៅ អត់បានរៀនបានសូត្រ។ បើម៉ែឪក្រហើយយកកូនមកជួយរកកាប់ដំឡូងចិន។គោក្របីក៏យ៉ាប់ គោក្របីក៏លែងអត់បាន។»*

**ករណីសិក្សាទី៨៖ បុរសពោះម៉ាយម្នាក់នៅភូមិមួយនៃឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង**

លោក«គ»មានអាយុ៤៨ឆ្នាំ សព្វថ្ងៃរស់នៅក្នុងខ្ទមមួយក្នុងបរិវេណដីទំហំ២០មx២០ម។ គាត់មានកំណើតនៅភូមិមួយក្នុងឃុំ នេះដែរ ហើយនៅឆ្នាំ១៩៨៦ ក៏ដូចជាអ្នកភូមិដទៃទៀត គាត់បានប្តូរទីលំនៅមករស់នៅក្នុងភូមិបច្ចុប្បន្ននេះ។ ចន្លោះឆ្នាំ១៩៧៩ និង១៩៨៧ គាត់បានបម្រើការជានគរបាលនៅក្នុងស្រុកមួយ។ ក្រោយពេលសុំលាឈប់ពីនគរបាលមក គាត់បានរៀបការជាមួយជាមួយនារីម្នាក់ដែលរស់នៅឃុំមួយ និងមានកូនចំនួន៥នាក់។

នៅឆ្នាំ១៩៨៧ គាត់និងគ្រួសារគាត់បានមកតាំងទីលំនៅនៅតំបន់ភ្នំមួយ ដែលគ្របដណ្តប់ចំណែកនៃទឹកដីឃុំចំនួនបីនៅក្នុង ស្រុកនេះ។ នៅទីនោះគាត់បានសង់ផ្ទះពីរខ្នង រួមនឹងរោងម៉ាស៊ីនស្រូវមួយនៅលើផ្ទៃដីបីហិកតា។ ក្រោយមកនៅក្នុងឆ្នាំ២០១១ តំបន់នេះបានត្រូវកងរាជអាវុធហត្ថរៀបចំធ្វើជាមូលដ្ឋានហ្វឹកហ្វឺនទ័ព ដែលបានធ្វើឲ្យប៉ះពាល់ដល់ប្រជាពលរដ្ឋជាង ១០គ្រួសារមកពីពីរភូមិ។ នៅថ្ងៃមួយនោះ ប៉េអិមបានប្រាប់គាត់ថា ដីដែលគាត់កំពុងតែកាន់កាប់នេះជាកម្មសិទ្ធិរបស់កងរាជអាវុធហត្ថ ហើយគាត់ក៏ឆ្លើយតបទៅវិញថា គាត់បានកាន់កាប់ដីនេះតាំងពីឆ្នាំ១៩៨៧មកម្ល៉េះ។ ទោះជាយ៉ាងណាក៏ដោយ ប៉េអិម បានបដិសេធការទាមទារដីរបស់គាត់ ហើយក៏បានឲ្យគាត់ផ្តិតមេដៃលើឯកសារមួយ ព្រមទាំងបានបញ្ជាក់បន្ថែមថា បើទោះជា គាត់ផ្តិតមេដៃឬមួយមិនផ្តិត ក៏គេនៅតែយកដីនេះ ហើយបើគាត់មិនយល់ព្រម ក៏គេឈូសដីទាំងអស់ដែរ។

ជាអកុសល គាត់បានទទួលដីមួយកន្លែងជាកម្មសិទ្ធិរបស់អ្នកភូមិម្នាក់នៅក្នុងទឹកដីនៃស្រុកជាប់ព្រំប្រទល់។ ម្ល៉ោះហើយគាត់ ក៏បានត្រឡប់ទៅសង់ខ្ទមមួយលើដីរបស់កងរាជអាវុធហត្ថ។ ប៉ុន្មានខែក្រោយមក ប៉េអិមក៏បានសែងខ្ទមនេះយកទៅដាក់ក្នុង ដែនសម្បទានដីសង្គមកិច្ច។ ទោះបីជាគាត់ខំអង្វរប៉េអិម ដើម្បីប្រាប់នូវរឿងរ៉ាវទាំងប៉ុន្មាន ដែលបានកើតឡើងយ៉ាងណាក្តី ប៉េអិមមិនបានដោះស្រាយបញ្ហារបស់គាត់ឡើយ។

ដូច្នោះហើយទើបគាត់សាកល្បងស្វះស្វែងរកការគាំទ្រពីសំណាក់មេភូមិ ដែលបានរៀបចំពាក្យបណ្តឹងឲ្យគាត់យកទៅដាក់ជូនមេឃុំ។ មេឃុំក៏បានដាក់បណ្តឹងនេះនៅអាជ្ញាធរស្រុកដើម្បីដោះស្រាយ។ ទាំងថ្នាក់ឃុំ ក៏ដូចជាថ្នាក់ស្រុកបានប្រាប់គាត់ថា ឲ្យរង់ចាំគេដោះស្រាយ។ ជាពិសេសនៅពេលគាត់ទៅជួបអភិបាលស្រុកថ្មី ក៏គាត់បានទទួលចម្លើយដូចពីមុនដដែល។ សព្វថ្ងៃជាអ្នក

ដើរស៊ីឈ្នួលគេ គាត់បាននិយាយប្រាប់ ដោយទឹកមុខយ៉ាងក្រៀមក្រំថា:

*«ពីមុន ខ្ញុំរស់នៅយ៉ាងធូរធារជាមួយគ្រួសារ។ តាំងពីប៉េអិមដកយកដីខ្ញុំទៅ អត់បានសងអីមកវិញ ប្រពន្ធខ្ញុំទៅចោលខ្ញុំទៀត។ ទាំងប្រពន្ធ ទាំងកូនទាំងអស់ គេនាំគ្នាចេញទៅធ្វើការនៅថៃបាត់។ សព្វថ្ងៃខ្ញុំរស់នៅតែឯង មកពីដីសម្រាប់ចិញ្ចឹមជីវិតហ្នឹង គេយកអស់ហើយ។ ខ្ញុំអត់មានអីសល់ទេ សឹងតែរកដីកប់ខ្លួនឯងមិនបានផង។»*

## ១៣. សេចក្តីសន្និដ្ឋាន

ជាលទ្ធផលនៃការសិក្សានេះ របកគំហើញក្នុងរបាយការណ៍នេះមិនជាតំណាងទេ។ គឺរបកគំហើញទាំងនេះបាន មកពីការសិក្សាទាំងផ្នែកគុណវិស័យផង និងបរិមាណវិស័យផង ដែលទាក់ទងនឹងវិវាទដីធ្លី យន្តការដោះស្រាយវិវាទ សកម្មភាពរបស់អ្នកភូមិនៅក្នុងការទាមទារសិទ្ធិលើដីធ្លីរបស់ខ្លួន ព្រមទាំងផលប៉ះពាល់នៅក្នុងខេត្តគោលដៅទាំងបួនរបស់អង្គការជីវិតថ្លៃថ្នូរ ក្នុងចំណោម២៥ខេត្ត/រាជធានីនៃប្រទេសកម្ពុជា។ គេក៏បានប្រៀបធៀបរបកគំហើញទាំងនេះផងដែរ ប៉ុន្តែជួនកាលវាខុសពីអ្វីដែលគេបានរកឃើញក្នុងការសិក្សាស្រាវជ្រាវលើកមុននៅក្នុងតំបន់នេះ។ គេបានរកឃើញថា វិវាទទំហំធំៗពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច សម្បទានដីសង្គមកិច្ច និងព្រៃសហគមន៍ ហើយក្នុងចំណោមវិវាទដីធ្លីចំនួន២៨ដែលបានកើតឡើង មានតែ១៨ករណីវិវាទប៉ុណ្ណោះ ដែលត្រូវបានដោះស្រាយ ហើយវិវាទសល់ពីនេះកំពុងព្យួរនៅឡើយ។ ទាំងករណីវិវាទដែលបានដោះស្រាយហើយនិងវិវាទកំពុងព្យួរ ប្រហែលនឹងបង្កបញ្ហានៅពេលអនាគត ដោយហេតុថាសំណងជាប្រាក់ ឬដូរជាដីហាក់ដូចជាមិនសមស្រប និងដូចជាមានការដាក់សម្ពាធមកលើអ្នកភូមិឲ្យទទួលយកសំណងទាំងនេះ។ គេមានការសម្គាល់នូវចំណុចសំខាន់ៗដូចទៅ៖

- ដំណើរការនៃការចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធបានប្រព្រឹត្តទៅយ៉ាងយឺតៗ បើប្រៀបធៀបនឹងការប្រគល់សម្បទានដីសេដ្ឋកិច្ចដោយរាជរដ្ឋាភិបាល។ ដូច្នោះហើយវាមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋមូលដ្ឋាន ដែលត្រូវការប័ណ្ណកម្មសិទ្ធិដីធ្លី ដើម្បីធានានូវសិទ្ធិលើដីធ្លីរបស់ខ្លួន។
- បញ្ហាបានប៉ះពាល់លើប្រជាពលរដ្ឋមូលដ្ឋាន ក្នុងខណៈដែលមិនមានការវាយតម្លៃលើផលប៉ះពាល់បរិស្ថាននៅក្នុងតំបន់គោលដៅរបស់សម្បទានដីសេដ្ឋកិច្ច ក៏ដូចជាយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន ដែលបានប្រើប្រាស់គ្រឿងចក្រមកឈូសឆាយដីវិវាទដែលអ្នកភូមិបានទាមទារជាមុនសិន ទើបចូលមកចរចាជាមួយពួកគាត់ជាក្រោយ បើសិនជាត្រូវការចាំបាច់។

- ដោយហេតុថា ករណីវិវាទហាក់ដូចជាមានភាពស្មុគស្មាញ អាស្រ័យដោយវិវាទមានទំហំធំៗ តាមធម្មតាអ្នកភូមិបានប៉ុនប៉ងចូលទៅរកការដោះស្រាយនៅថ្នាក់ទាបបំផុតសិន គឺទៅជួបមេភូមិមុននឹងទៅរកថ្នាក់លើ ចាប់ពីឃុំដល់ស្រុក។ នៅក្នុងភាពអស់សង្ឃឹម កាលបើមិនមានការឆ្លើយតប ទើបគាត់សាកល្បងដាក់បណ្តឹងនៅអាជ្ញាធរខេត្ត ឬក៏បន្តដាក់បណ្តឹងជូនអ្នកដែលមានអំណាច ទៅរដ្ឋសភា ខុទ្ទកាល័យនាយករដ្ឋមន្ត្រី និងក្រសួងពាក់ព័ន្ធមួយចំនួន ដូចជាក្រសួងមហាផ្ទៃជាដើម។

- យន្តការដោះស្រាយវិវាទថ្នាក់មូលដ្ឋាន ចាប់ពីថ្នាក់ភូមិដល់ថ្នាក់ខេត្ត មិនបង្ហាញនូវសុឆន្ទៈក្នុងការដោះស្រាយវិវាទដីធ្លី ដោយគិតថាវាហួសពីដែនសមត្ថភាពរបស់ពួកគាត់ ម្ល៉ោះហើយត្រូវរង់ចាំសេចក្តីសម្រេចពីថ្នាក់លើ។ នៅក្នុងក្របខណ្ឌនៃភាពលប់លើនៃប្រព័ន្ធអំណាចបែបបខ្សែ-ខ្នងលើអំណាចបែបការិយាធិបតេយ្យ អ្នកភូមិបានខិតខំទាក់ទងជាមួយអ្នកធ្វើសេចក្តីសម្រេចផ្នែករដ្ឋបាល ដែលមានអំណាច ដើម្បីធ្វើ អន្តរាគមន៍ជំនួសពួកគាត់។ ម្យ៉ាងវិញទៀត បទបញ្ជា០០១របស់សម្តេចនាយករដ្ឋមន្ត្រី ដែលជាការប្រគល់ដោយរដ្ឋាភិបាលនូវសម្បទានដីសេដ្ឋកិច្ច ឬសម្បទានដីសង្គមកិច្ចទំនងជាមានភាពលប់លើសេចក្តីសម្រេចរបស់អ្នកថ្នាក់ក្រោម។

- គណៈកម្មការសុរិយោដី ដែលស្ថាប័នដោះស្រាយទាំងពីរកម្រិត ត្រូវបានដាក់បញ្ចូលនៅយន្តការសម្រុះសម្រួលចម្រុះថ្នាក់ស្រុក/ខេត្ត ដើម្បីដោះស្រាយវិវាទរួមពាក់ព័ន្ធនឹងដីធ្លី។ បើសិនជាមានករណីណាត្រូវ បានដាក់ជូនមកយន្តការនេះ ក៏វានឹងត្រូវបញ្ជូនទៅថ្នាក់ស្រុក/ខេត្តដែរ ពីព្រោះពួកគាត់គិតថា វាហួសពី សមត្ថភាពរបស់ខ្លួន។

- មានតែមួយករណីវិវាទប៉ុណ្ណោះនៅក្នុងចំណោមវិវាទដែលយើងបានសិក្សា គឺអ្នកភូមិបានដាក់បណ្តឹងនៅតុលាការខេត្ត។ មូលហេតុមកពីប្រជាពលរដ្ឋមូលដ្ឋានជាអ្នកប្តឹង មិនមានលទ្ធភាពដាក់បណ្តឹងនៅយន្តការនេះ ដែលទាមទារពេលវេលា និងចំណាយប្រាក់កាសច្រើន និងមានការយល់ដឹងផ្នែកច្បាប់ផង ហើយជាពិសេសពួកគាត់រំពឹងថា លទ្ធផលនៃការដោះស្រាយនឹងមិនបានជាប្រយោជន៍ដល់អ្នកបាត់បង់ប្រយោជន៍ដូចពួកគាត់នោះទេ។

- ច្បាប់ភូមិបាលឆ្នាំ២០០១ និងបទបញ្ញត្តិពាក់ព័ន្ធនឹងដីធ្លី នៅក្នុងក្របខណ្ឌច្បាប់របស់រដ្ឋាភិបាលជំទាស់ នឹងទម្លាប់អនុវត្តបែបប្រពៃណីដែលអ្នកភូមិយល់ថាជាដីកេរ/ដីដូនតា។

- ប្រជាពលរដ្ឋមូលដ្ឋានបានចាត់ទុក «ដី» ថាជាជីវិតរបស់ខ្លួន (ឬជាឆ្នាំងបាយ) ម្ល៉ោះហើយពួកគាត់បានប្តេជ្ញា តស៊ូទាមទារដីដែលពួកគាត់កំពុងកាន់កាប់។ ទោះជាយ៉ាងនេះក្តី សកម្មភាពរបស់អ្នកភូមិបង្ហាញថា បានប្រព្រឹត្តទៅដាច់ដោយឡែកពីគ្នាជាមួយនឹងយុទ្ធ

សាស្ត្រទន់ខ្សោយ និងមិនច្បាស់លាស់របស់ខ្លួន ចំណែកឯតំណាងរបស់ពួកគាត់វិញជាទូទៅបានបង្ហាញថា មិនសកម្ម ឬមិនមានសមត្ថភាពក្នុងការប្រមែប្រមូលប្រជាពលរដ្ឋ ឬចូលទៅដាក់បណ្តឹងនៅយន្តការដោះស្រាយវិវាទ។ ម្យ៉ាងវិញទៀត ចំណេះដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋមូលដ្ឋាននៅមានកម្រិត ភាគច្រើនច្បាប់ភូមិបាល ហើយមានអារម្មណ៍ព្រងើយកន្តើយ ចំពោះប័ណ្ណកម្មសិទ្ធិដីធ្លី ដែលជាហេតុនាំឲ្យពួកគាត់ជួបហានិភ័យនៃភាពគ្មានដីធ្លី។

- ស្ត្រីដែលបម្រើការងារក្នុងអាជ្ញាធរមូលដ្ឋានមានភាគរយទាបជាងច្រើន បើប្រៀបធៀបនឹងបុរស។ ម្ល៉ោះហើយការចូលរួមរបស់ស្ត្រីនៅក្នុងដំណើរការដោះស្រាយវិវាទបានបង្ហាញថា នៅតែមានចំនួនតិចតួចនៅឡើយ។ តែនេះមិនមានន័យថា ស្ត្រីមិនសូវសកម្មក្នុងវិវាទដីធ្លីនោះទេ។ យោងតាមករណីវិវាទដែលបានសិក្សា បើទោះបីជាមានចំនួនតិចយ៉ាងណាក្តី នៅពេលខ្លះស្ត្រីបានបង្ហាញថា ធ្វើបានប្រសើរជាងបុរសមួយចំនួនទៅទៀតពាក់ព័ន្ធនឹងការតវ៉ាយ៉ាងចំហ និងការចូលទៅដាក់បណ្តឹងនៅយន្តការដោះស្រាយវិវាទ។
- ទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋមូលដ្ឋានដែលទាមទារដីរបស់ខ្លួន ក៏ត្រូវការនូវការគាំទ្រពីសំណាក់អាជ្ញាធរមូលដ្ឋានផងដែរ ដើម្បីឲ្យការតវ៉ាតាមសន្តិវិធីរបស់ខ្លួននឹងទទួលបានជោគជ័យ ដូចដែលមាននៅក្នុងការសិក្សានេះ។ ផ្ទុយទៅវិញ ការយកចិត្តទុកដាក់ដ៏តិចតួចរបស់អាជ្ញាធរមូលដ្ឋាន ចំពោះការដោះស្រាយវិវាទដីធ្លីរបស់ប្រជាពលរដ្ឋមូលដ្ឋាន អាចនាំឲ្យអ្នកភូមិស្ថិតក្នុងស្ថានភាពអស់សង្ឃឹម និងឈានទៅរកការប្រើប្រាស់អំពើហិង្សា។
- គេបានរកឃើញថា ក្រៅពីថ្នាក់ជាតិ ប្រជាពលរដ្ឋមូលដ្ឋានបានស្វែងរកអ្នកខាងក្រៅដូចជាអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិដែលពាក់ព័ន្ធ ភាគច្រើនក្រុមអង្គការសិទ្ធិមនុស្ស ដែលបានជួយពួកគាត់ក្នុងការធ្វើបណ្តឹង និងការណែនាំអំពីទីកន្លែង និងរបៀបដាក់បណ្តឹងជាបន្ត បើសិនជាបណ្តឹងរបស់ពួកគាត់មិនបានដោះស្រាយនៅថ្នាក់មូលដ្ឋាន។ អង្គការមិនមែនរដ្ឋាភិបាលខ្លះ ក៏បានចូលរួមក្នុងការពន្យល់ប្រជាពលរដ្ឋឲ្យយល់ដឹងអំពីការតស៊ូមតិ ច្បាប់ដែលមានសព្វថ្ងៃ និងសិទ្ធិមនុស្ស ព្រមទាំងជួយបង្កើតក្រុមជួយខ្លួនឯងដល់ពួកគាត់ផងដែរ។ ទោះជាយ៉ាងណាក៏ដោយ និន្នាការនៃការស្វែងរកការគាំទ្រពីសំណាក់ គណបក្សនយោបាយនានាហាក់ដូចជាមានឥទ្ធិពលតិចតួច។
- ផលប៉ះពាល់ដែលបណ្តាលមកពីដំណោះស្រាយវិវាទរួមពាក់ព័ន្ធនឹងដីធ្លី នៅក្នុងការអនុវត្តសម្បទានដី សេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច បានធ្វើឲ្យអ្នកភូមិរងគ្រោះកាន់តែក្រីក្រឡើង។ ហេតុដូច្នេះហើយ ការបាត់បង់ដីធ្លី ដែលជាប្រភពសំខាន់នៃចំណូលរបស់

គាត់ បានបណ្ដោយឲ្យពួកគាត់រស់នៅដោយគ្មាន សន្តិសុខដីធ្លី ពួកគាត់អាចប្ដូរទីកន្លែងធ្វើការនៅខាងក្រៅជាជនចំណាកស្រុក ដែលមានការងារមិនជាប់លាប់។ ម្យ៉ាងវិញទៀត កូនរបស់គាត់ត្រូវបានបោះបង់ការសិក្សា ឬអាចពាក់ព័ន្ធនឹងពលកម្មកុមារ នេះមិនទាន់គិតដល់បញ្ហាសុខភាពរបស់ពួកគេផង។ ភាពក្រីក្រក៏បង្កជាអំពើហិង្សា ឧក្រិដ្ឋកម្មក្នុងសង្គមផងដែរ។ ក្នុងគ្រានេះដែរ បម្រែបម្រួលអាកាសធាតុក៏អាចកើតមាន ដោយសារការបំផ្លិចបំផ្លាញព្រៃឈើ។

## ១៤. ការស្នើសុំឲ្យមានដំណោះស្រាយបានប្រសើរ តាមទស្សនៈសហគមន៍

ភាពស្មុគស្មាញនៃកត្តានានា ដែលចូលពាក់ព័ន្ធនឹងស្ថានភាពបច្ចុប្បន្ន ដូចជាទីតាំងក្រោយវិវាទ ប្រវត្តិនៃកម្មសិទ្ធិ និងស្ថានភាពនយោបាយបច្ចុប្បន្នធ្វើឲ្យមានការពិបាកដោះស្រាយយ៉ាងខ្លាំង។

គ្រប់ករណីវិវាទក្នុងខេត្តទាំងបួន បង្ហាញនូវអតុល្យភាពនៃអំណាចដែលកើតឡើងនៅក្នុងវិវាទដីធ្លី។ ស្ទើរគ្រប់ករណី វិវាទបានលើកឡើងពីភាពមិនបានសម្រេចនៃយន្តការដោះស្រាយវិវាទបច្ចុប្បន្ន នៅក្នុងការជួយដោះស្រាយសហគមន៍ ដែលដីរបស់ខ្លួនត្រូវបានដកហូតតាមរយៈសម្បទានសង្គមកិច្ច ឬសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ឬក៏ដោយបុគ្គលមានអំណាច។ ១៨ ករណីក្នុងចំណោមវិវាទចំនួន ២៨ ជាវិវាទដីធ្លីរវាងសហគមន៍កសិករ និងក្រុមហ៊ុន។ ៣ករណីវិវាទពាក់ព័ន្ធនឹងសម្បទានដីសង្គមកិច្ច ២ករណីវិវាទរវាងអ្នកភូមិ និងឈ្មួញ និង១ករណីវិវាទ ពាក់ព័ន្ធនឹងរដ្ឋាភិបាលបានឆ្លុះបញ្ចាំងនូវភាពមិនស៊ីសង្វាក់គ្នានៃអំណាចរវាងភាគីនានា ហើយនិងអប្រសិទ្ធភាព នៃក្រុមប្រឹក្សាឃុំ គណៈកម្មការសុរិយោដី និងអភិបាលស្រុក ក៏ដូចជាតុលាការនៅក្នុងការដោះស្រាយវិវាទ។ ស្ថានភាពជុំវិញដំណើរការដោះស្រាយវិវាទ ត្រូវបានបង្ហាញឲ្យឃើញតាមរយៈការបំភិតបំភ័យ និងអំពើពុករលួយ។ ក្រៅពីការស្នើសុំរដ្ឋាភិបាល និងស្ថាប័ននីតិបញ្ញត្តិនានាឲ្យជួយការពារដីធ្លីនិងប្រភពនៃ ការចិញ្ចឹមជីវិតរបស់ខ្លួន សហគមន៍ពាក់ព័ន្ធនឹងវិវាទដីធ្លីបានបែរទៅការពារ និងចាត់ចែងសកម្មភាពប្រឈមនឹងក្រុមហ៊ុន និងអាជ្ញាធរមូលដ្ឋាន ដើម្បីទាមទារភាពស្របច្បាប់របស់ខ្លួន។

ប្រជាពលរដ្ឋកម្ពុជាដែលត្រូវបានបាត់បង់ដីធ្លី ឬក៏ជួបហានិភ័យនៃការដកហូតតាមរយៈសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ចមិនបានទទួលផលប្រយោជន៍ពេញលេញពីយន្តការដោះស្រាយវិវាទដីធ្លីឡើយ។ ការខកខានក្នុងការការពារ និងផ្ដល់លទ្ធភាពដោះស្រាយតាមផ្លូវច្បាប់ ជាពិសេសសម្រាប់ជនក្រីក្រ និងសហគមន៍អ្នកបាត់បង់ប្រយោជន៍ ជាសំខាន់ស្ត្រី គឺជាភស្តុតាងនៃការរំលោភរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាដែលធានាថា៖

*«ប្រជាពលរដ្ឋ ខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥត ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។»*

ដោយហេតុថា ការកើតមានវិវាទដីធ្លីមានកម្រិតខ្ពស់ និងកង្វះសុវត្ថិភាពចំពោះកម្មសិទ្ធិដីធ្លីផង យន្តការដោះស្រាយវិវាទដីធ្លីបំពេញមុខងារប្រកបដោយប្រសិទ្ធភាព អ្នកភូមិដែលមានវិវាទដីធ្លី បានចូលរួមបញ្ចេញគំនិត ដើម្បីឲ្យមាន ដំណោះស្រាយវិវាទដីធ្លីបានល្អ ដែលមានដូចតទៅ៖

- ដោយឃើញថា ករណីវិវាទដីធ្លីជាច្រើនកំពុងព្យួរនៅឡើយ អ្នកភូមិរង់ចាំ និងចង់ឲ្យស្ថាប័នពាក់ព័ន្ធនឹង ការដោះស្រាយវិវាទដីធ្លី មានការប្តេជ្ញាយ៉ាងមាំ ចាត់វិធានការ និងពន្លឿនដំណើរការដោះស្រាយ បើពុំដូច្នោះទេ ស្ថាប័នទាំងនេះនឹងលែងជាទំនុកចិត្តរបស់អ្នកភូមិទៀត ហើយប្រជាពលរដ្ឋអាចនឹងចេញធ្វើការតវ៉ាជំទាស់។
- អ្នកភូមិចង់បានគណៈកម្មការសម្រាប់ដោះស្រាយវិវាទដីធ្លី ដែលបំពេញតួនាទីរបស់ខ្លួនប្រកបដោយ តម្លាភាព និងគណនេយ្យភាព។
- អ្នកភូមិចង់បានអ្នកសម្រុះសម្រួលឯករាជ្យ និងមានការបណ្តុះបណ្តាលបានល្អ ដែលមិនលំអៀងរក ឬនៅក្រោមឥទ្ធិពលរបស់អាជ្ញាធរថ្នាក់លើឬភាគីទីពីរ ព្រមទាំងយកចិត្តទុកដាក់ចំពោះជនក្រីក្រឲ្យបានដូចអ្នកមាននិងអ្នកមានអំណាចផងដែរ។
- អ្នកភូមិចង់បានដំណោះស្រាយដែលយុត្តិធម៌ ប៉ុន្តែមិនមែនជាកិច្ចព្រមព្រៀងបែបបង្ខំនោះឡើយ ពីព្រោះអ្នកភូមិជាភាគីទន់ខ្សោយ នៅក្នុងបរិបទនៃក្របខណ្ឌច្បាប់របស់ប្រទេស។ អ្នកភូមិចង់បានអ្នកសម្រុះសម្រួលដែលស៊ើបអង្កេតយ៉ាងប្រយ័ត្នប្រយែងទាក់ទងនឹងប្រវត្តិនៃការកាប់កាប់ដីរបស់ពួកគាត់យ៉ាងដូចម្តេច ពីព្រោះកាលណាពួកគាត់សម្លឹងមើលបរិបទនៃក្របខណ្ឌច្បាប់របស់ប្រទេស ប្រវត្តិនៃកម្មសិទ្ធិដីធ្លី ហើយនឹងដំណើរការបច្ចុប្បន្ននៃការចុះបញ្ជីដីធ្លី ពួកគាត់គិតថា ពួកគាត់មានភាពស្របច្បាប់ក្នុងការទាមទារដីរបស់ខ្លួនមកវិញ ឬការទទួលបាននូវសំណងយ៉ាងសមស្រប។ កិច្ចព្រមព្រៀងបែបបង្ខំឲ្យទទួលយកសំណង ដែលមិនសមស្របអាចនឹងនាំទៅរកការកកើតវិវាទដីធ្លីជាថ្មីឡើងវិញ។
- អ្នកភូមិជាច្រើននាក់បានត្អូញត្អែរថា ដីកសិកម្មរបស់ខ្លួនមិនទាន់មានប័ណ្ណកម្មសិទ្ធិដីនៅឡើយទេ។ ពួកគាត់ចង់ឲ្យរដ្ឋាភិបាលពន្លឿនដំណើរការចុះបញ្ជីដីធ្លី ដើម្បីឲ្យប្រជាពលរដ្ឋមានបណ្ណ័កម្មសិទ្ធិដីធ្លីគ្រប់ៗគ្នា ក៏ដើម្បីការពារកុំឲ្យមាន ឬកាត់បន្ថយវិវាទដីធ្លី។
- ភាពលប់លើនៃប្រព័ន្ធអំណាចបែបខ្សែ-ខ្នងលើអំណាចបែបការិយាធិបតេយ្យ ត្រូវបានគេមើលឃើញនៅក្នុងការចេញ«ស.ជ.ណ.»(បទបញ្ជា) ដើម្បីប្រគល់សម្បទានដីសេដ្ឋកិច្ចពី

ថ្នាក់លើ។ អាជ្ញាធរថ្នាក់ ក្រោមត្រូវការអនុវត្តតាមថ្នាក់លើ។ អ្នកភូមិចង់ឲ្យអាជ្ញាធរថ្នាក់លើធ្វើការវាយតម្លៃផលប៉ះពាល់សង្គម និង/ឬ ពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋានមុននឹងធ្វើសេចក្តីសម្រេចប្រគល់សម្បទានដីសេដ្ឋកិច្ចឬសម្បទានដីសង្គមកិច្ច។ អាជ្ញាធរមូលដ្ឋានដឹងពីទីកន្លែង និងរបៀបដែលអ្នកភូមិរស់នៅនិងធ្វើកសិកម្ម។ មធ្យោបាយរបៀបនេះ ក៏នឹងជួយបញ្ចៀសវិវាទដីធ្លីផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីវិវាទដែលយើងបានសិក្សា «រូបមន្តស្បែកខ្លា» ត្រូវបានចេញតាមរយៈបទបញ្ជា ០០១ ក្រោយពេលអនុវត្តសម្បទានដីសេដ្ឋកិច្ចរួចហើយ។

តាមទស្សនវិស័យរបស់អ្នកស្រាវជ្រាវ អនុសាសន៍មានដូចតទៅ៖

- គួរមានការអប់រំប្រជាពលរដ្ឋនៅទូទាំងប្រទេសឲ្យយល់ដឹងនូវយន្តការដោះស្រាយវិវាទនានា ព្រមទាំងតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់អាជ្ញាធរគ្រប់ថ្នាក់។
- ដោយឃើញថា មានយន្តការដោះស្រាយវិវាទដីធ្លីនៅប្រទេសកម្ពុជាមែន យ៉ាងណាក៏ដោយ ក៏យន្តការទាំងនេះមិនមានដំណើរការបានរលូនទេ ដោយមកពីភាពលប់លើនៃប្រព័ន្ធអំណាចបែបខ្សែ-ខ្នងលើអំណាចបែបការិយាធិបតេយ្យ។ ដូច្នេះយើងស្នើសុំឲ្យផ្តល់អំណាចពេញលេញដល់យន្តការនានា ដោយអនុលោមតាមក្របខណ្ឌច្បាប់។
- គួរមានការអប់រំប្រជាពលរដ្ឋអំពីសារសំខាន់នៃវិញ្ញាបនបត្រស្តីពីអចលនវត្ថុ ជាពិសេសដីធ្លី ពីព្រោះដីជាជីវិត។
- ដោយឃើញថា តាមការអនុវត្តបទបញ្ជា០០១ គឺមានតែដីដែលអាស្រ័យផលដែលត្រូវបានវាស់វែង និងប្រគល់ជូនអ្នកភូមិ ប៉ុន្តែមិនមែនបញ្ចូលចំណែកដីព្រៃដែលគាត់កាន់កាប់នោះទេ។ ដូច្នេះយើងស្នើសុំឲ្យវាស់វែងដីទាំងមូលដែលគាត់មាន ពីព្រោះដើម្បីពួកគាត់អាចរានដីបានបន្តិចម្តងៗសម្រាប់ពង្រីកដីកសិកម្មរបស់ខ្លួន ឬក៏អាចចែកដីនេះទៅឲ្យអ្នកជំនាន់ក្រោយ។

# ឯកសារយោង

ADHOC (2013) `Land Situation in Cambodia 2013´. Phnom Penh: ADHOC, June 2014

ADHOC, A Turning Point? – Land, Housing and Natural Resources Rights in Cambodia in 2012, February 2013)

Adler, Daniel et al. 2006. Towards Institutional Justice? A Review of the Work of Cambodia`s Cadastral Commission in Relation to Land Dispute Resolution. Report prepared by the Center for Advanced Study, World Bank, National Cadastre Commission Secretariat, and the German Development Cooperation (GTZ). http://ssrn.com/abstract =1012490 (accessed 3 January 2011).

Alice Beban and Pou Sovachana (2014) `Human Security and Land Rights in Cambodia´. Phnom Penh: CICP, 2014, online at http://www.cicp.org.kh/userfiles/file/Publications/HSLR-report-Final-3-29-015.pdf

Amakawa, N. 2001a. Kanbojia ni Okeru Kokuminkokka Keisei to Kokka no Ninaite wo Meguru Funsou. In Kanbojia no Fukkou Kaihatsu, ed. N. Amakawa. Kenkyu Sousho No. 518. Chiba, Japan: Institute of Developing Economies, Japan External Trade Organization.

Amnesty International (2008) `Cambodia: A risky business–defending the right to housing. September 2008´, online at https://www.amnesty.org/download/.../52000/ asa230142008en.pdf  APRODEV, 2011. `Stolen land, stolen future: a report on land grabbing in Cambodia,´ http://bit.ly/17Gmg9k.

Ashley, D. (1999) `Summary Report on Land Disputes´

Asian Development Bank. 2004. Cambodia Gender Assessment – A Fair Share for Women. Manila: ADB.

Cambodia Report. The Implementation of the Beijing Declaration and Platform for Action (1995) and the outcomes of the Twenty-third Special Session of the General Assembly (2000) submitted to the Ministry of Women´s Affairs Kingdom of Cambodia. Online at http://www.unwomen.org /~/media /headquarters /attachments/sections/csw/59/national_reviews/cambodia_review_beijing20.pdf

CAS and WB (2006a) 'Justice for the Poor? An exploratory Study of Collective Grievances over Land and Local Governance in Cambodia', Phnom Penh: World Bank.

CAS and WB (2006) 'Towards Institutional Justice? A Review of the Work of the Cambodia's Cadastral Commission in Relation to Land Dispute Resolution', Phnom Penh: GTZ

CAS and WB (2008) 'Cambodia's National Authority for Land Dispute Resolution: An Exploratory Study', Phnom Penh, online at http://www.academia.edu/3758731/CAMBODIA_S_NATIONAL_AUTHORITY_FOR_LAND_DISPUTE_RESOLUTION_A...

CCHR (2013) 'Cambodia: Land in Conflict. An Overview of the Land Situation', online at http:// cchrcambodia.org /admin/media/report/report/english/CCHR%2520Report%2520%2520Cambodia...

CCHR Briefing Note – July 2014: *The Failure of Land Dispute Resolution Mechanisms*

CONSTITUTION OF THE KINGDOM OF CAMBODIA. *This Constitution was adopted by the Constitutional Assembly in Phnom Penh on September 21, 1993 at its 2nd Plenary Session.*

David Pred (2010) 'Bittersweet. A Briefing Paper on Industrial Sugar Plantation, Trade and Human Rights in Cambodia', online at http://babcambodia.org/developmentwatch/cleansugar campaign/bitter sweet .pdf

German Agency for Technical Cooperation. 2009. Foreign Direct Investment (FDI) in Land in Cambodia. Eschborn,

Grimsditch, Mark and Nick Henderson. 2009. Untitled: Tenure Insecurity and Inequality in the Cambodian Land Sector.

http://www.cohre.org/sites/default/files/cambodia_untitled_tenure_insecurity_and_inequality_in_the_ cambodian_land_sector_30_sept_2009.pdf (accessed 11 November 2010).

Human Rights Organization for Transparency and Peace 'HROTP offers legal advice to victims of land grabbing from Battambang province', March 9, 2015, online at http://hrotp.org/2015/03/09/hrotp-offers-legal-advice-to-victims-of-land-grabbing-from-batt...

Lavinia Helen Schwedersky, 2010. Mechanisms of Land Conflict Resolution in Rural Cambodia. Bachelor Thesis

Leak Ratna ‵Joint commission present findings of land dispute survey′, September 6, 2014, online at http://lwd.org.kh/lwd/joint-commission-present-findings-of-land-dispute-survey/

LICADHO **2014 brings a new wave of Cambodian Land Conflicts**. online at www.licadho-cambodia.org /pressrelease.php?perm=342

LICADHO ‵Media Statement: Unfair court verdict in Bavel land case′, February 15, 2007, online at http://www.licadho-cambodia.org/pressrelease.php%3Fperm%3D142

Mark Grimsditch et al (2012) ‵Access to Land Title in Cambodia. A Study of Systematic Land Registration in Three Cambodia Provinces and the Capital′ World Vision and NGOF, November Men Prachvuthy, 2011. LAND ACQUISITION BY NON-LOCAL ACTORS AND CONSEQUENCES FOR LOCAL DEVELOPMENT: Impacts of Economic Land Concessions on the Livelihoods of Indigenous Communities in Northeast Provinces of Cambodia. 2012, online at http://www.academia.edu/3859491 /Access_to_ Land_Title_in_ Cambodia_ A_Study_of_Systematic_Land... Ministry of Planning (MOP), 2013, Cambodian Inter-Censal Population Survey (CICP) 2013, Phnom Penh.

NGOF on Cambodia, 2013. Statistical Analysis of Land Disputes in Cambodia, 2013. Phnom Penh, Cambodia, September 2014.

Pech Sotheary ‵Appeal aired: EU hears out groups from Battambang′, The Phnom Penh Post, January 12, 2015, online at http://sahrika.com/category/provincecity/battambang/

Pel, S., Y. Yonekura, S. So, and K. Saito. 2005. Land issue study in Cambodia: Landlessness, land disputes and project affected people. Phnom Penh: Centre d′Etude et de Developpment Agricole Cambodgien and Japan International Volunteer Center

Phak Seangly ‵Families say land was taken′, Phnom Penh Post, May 24, 2013, online at sahrika.com/tag /**land**-dispute/page/13/

Rendall, M., J. Tremblay, and P. Baars. 2003. Land law of Cambodia: A study and research manual. Phnom Penh: East-West Management Institute. Online at www.environmentalpeacebuilding.org/assets /Documents/LibraryItem.

Roman Herre and Timothé Feodoroff (2014) 'Case Dossier: Cambodia. Sugar cane plantations, human rights violations and EU's "Everything But Arms" Initiative'. FIAN Germany for Hands Off the Land Alliance, online at http://www.fian.org/fileadmin/media/publications/2014_ Casedossier_ Cambodia_en _final_screen....

Royal Government of Cambodia. 1993. Constitution of Cambodia. http://www.constitution.org/cons /cambodia.htm (accessed 20 November 2010).

Royal Government of Cambodia. N°.27 July 1, 2009: Declaration of the Royal Government on Land Policy

Royal Government of Cambodia.2001a. Land Law. http://www.gocambodia.com/Laws/pdf/LAW-01-Land%20Law-E.pdf (accessed 26 February 2009).

Royal Government of Cambodia. 2001b. Law on Mineral Resource Management and Exploitation. No. NS/RKM/0701/09. http://www.gocambodia.com/laws/pdf/LAW-01-Mineral%20Resource%20Mgt-E.pdf (accessed24 March 2011).

Royal Government of Cambodia. 2005b. Sub-decree No. 146 ANK/BK on Economic Land Concessions. http://www.elc.maff.gov.kh/laws/subdecree.html (accessed 21 March 2011).

Royal Government of Cambodia .2005a. Sub-decree No.118 on State Land Management.
Sekiguchi, M, and N. Hatsunako. 2013. Land Conflict and Land Registration In Cambodia.

Supreme National Economic Council, 2007. The Report of Land and Human Development in Cambodia. Online at www.un.org/esa/agenda21/natlinfo/countr/cambodia/land.pdf

So Sovannarith et al (2001), 'Social Assessment of Land in Cambodia. A Field Study' Working Paper no 20, Phnom Penh: CDRI, online at http://www.cdri.org.kh/webdata/download/ wp/ wp20e.pdf

